# គុណតម្លៃរដ្ឋធម្មនុញ្ញកម្ពុជា

## ទស្សនទានបម្រុះក្នុងសន្និសីទរំលឹកខួប២៧ឆ្នាំ




ចងក្រងនិពន្ធបោះពុម្ពផ្សាយ
ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម**
ប្រឹក្សាជំនាញឯកទេសនីតិរដ្ឋធម្មនុញ្ញ
ឯកឧត្តមបណ្ឌិត **ហោ ប៉េង** និង ឯកឧត្តម **តាំង រតនា**
ជំនួយការបច្ចេកទេស
ឯកឧត្តមបណ្ឌិត **ព្រហ្ម ខចិត្រអក្ខរា** និង អ្នកស្រី **ប៉ុក ភារុន**

# គុណតម្លៃរដ្ឋធម្មនុញ្ញកម្ពុជា

*ទស្សនទានបម្រុះក្នុងសន្និសីទរំលឹកខួប២៧ឆ្នាំ*


ចងក្រងនិពន្ធបោះពុម្ពផ្សាយ

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម**

ប្រឹក្សាជំនាញឯកទេសនីតិរដ្ឋធម្មនុញ្ញ

ឯកឧត្តមបណ្ឌិត **ហោ ប៉េង** និង ឯកឧត្តម **តាំង រតនា**

ជំនួយការបច្ចេកទេស

ឯកឧត្តមបណ្ឌិត **ព្រហ្ម វិចិត្រអក្ខរា** និង អ្នកស្រី **ប៉ុក តារុន**



# គុណតម្លៃរដ្ឋធម្មនុញ្ញកម្ពុជា

*ទស្សនទានបម្រុះក្នុងសន្និសីទរំលឹកខួប២៧ឆ្នាំ*


ចងក្រងនិពន្ធបោះពុម្ពផ្សាយ

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម**

ប្រឹក្សាជំនាញឯកទេសនីតិរដ្ឋធម្មនុញ្ញ

ឯកឧត្តមបណ្ឌិត **ហោ ប៉េង** និង ឯកឧត្តម **តាំង រតនា**

ជំនួយការបច្ចេកទេស

ឯកឧត្តមបណ្ឌិត **ព្រហ្ម វិចិត្រអក្ខរា** និង អ្នកស្រី **ប៉ុក តារុន**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះឯកឧត្តម និងអស់លោក ដូចមានរាយនាមខាងក្រោម ដែលបានខិតខំប្រឹងប្រែងជួយជ្រោមជ្រែង ក្នុងដំណើរការងារបោះពុម្ពផ្សាយសៀវភៅនេះ៖

❖ **ការងារពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ**

១- ឯកឧត្តម **ម៉េង គឹមលី**
នាយករងខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

២- ឯកឧត្តម **កែវ កុសល**
បេសកជនទីប្រឹក្សាបច្ចេកទេសនៃខុទ្ទកាល័យប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

៣- លោក **ទិត គុងឃី**
សមាជិកក្រុមលេខារបស់ឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ

❖ **ការងារបច្ចេកទេស និងទំនាក់ទំនង**

៤- លោក **សេង សុគុណា**
ប្រធានក្រុមលេខារបស់ឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ

៥- លោក **ហ៊ុន តារម្យ**
សមាជិកក្រុមលេខារបស់ឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ

៦- លោក **យូ គឹមហាក់**
សមាជិកក្រុមលេខារបស់ឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ



ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
និងជាអធិបតីនៃសន្និសីទ អញ្ជើញថ្លែងសុន្ទរកថាបើកកម្មវិធី




ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
និងជាអធិបតីនៃសន្និសីទ (រូបទី១១ ពីស្តាំទៅឆ្វេង)

*ពីស្តាំទៅឆ្វេង៖*

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត **ព្រហ្ម វិចិត្រអក្ខរា** | ២. ឯកឧត្តម **តាំង រតនា** |
| ៣. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | ៤. ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** |
| ៥. ឯកឧត្តមបណ្ឌិត **ហោ ប៉េង** | ៦. ឯកឧត្តមបណ្ឌិត **ទេព នីថា** |
| ៧. ឯកឧត្តម **សក់ សេដ្ឋា** | ៨. ឯកឧត្តមរដ្ឋមន្ត្រី **ព្រុំ សុខា** |
| ៩. ឯកឧត្តម **ហ៊ី សោភា** | ១០. សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស** |

*ពីឆ្វេងទៅស្តាំ៖*

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត **មាស បូរ៉ា** | ២. ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** |
| ៣. ឯកឧត្តមបណ្ឌិត **ហាប់ ផល្វី** | ៤. ឯកឧត្តម **អ៊ុំ សារឹទ្ធ** |
| ៥. ឯកឧត្តមបណ្ឌិត **ជិន ម៉ាលីន** | ៦. ឯកឧត្តម **អ៊ិត រ៉ាឌី** |
| ៧. សម្តេចស៊ីសុវត្ថិ **ពង្សនារី មុនីពង្ស** | ៨. ឯកឧត្តមបណ្ឌិត **ឈឹម ផលវរុណ** |
| ៩. ឯកឧត្តម **សំ ព្រហ្មនា** | |



ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
និងជាអធិបតីនៃសន្និសីទ អញ្ជើញដឹកនាំដំណើរការកម្មវិធីនៃអង្គសន្និសីទ

## ***កម្មវិធី***

*សន្និសីទស្តីពី*

# រដ្ឋធម្មនុញ្ញ : គុណតម្លៃទំនើប និង គុណតម្លៃខ្មែរ

អបអរសាទរទិវារំលឹកខួប២៧ឆ្នាំនៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ប្រារព្ធធ្វើនៅ សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា ថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

---

***កម្មវិធីទី១*** ***ការប្រារព្ធបើកកម្មវិធី*** (OPENING SESSION)

ម៉ោង ៧:៣០ ដល់ ៨:០០
- ចុះឈ្មោះភ្ញៀវកិត្តិយស
- វាគ្មិន និងគណៈអធិបតីអញ្ជើញដល់

ម៉ោង ៨:០០ ដល់ ៨:៤០
- គណៈចាត់តាំងកម្មវិធី ប្រកាសហេតុ និងចាប់ផ្តើមកម្មវិធី
- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា
- សុន្ទរកថាគន្លឹះបើកកម្មវិធីដោយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ម៉ោង ៨:៤០ ដល់ ៩:០០
- ថតរូបអនុស្សាវរីយ៍ (Group Photo Session)
- សម្រាកទទួលទានអាហារសម្រន់ពេលព្រឹក និងកាហ្វេ

(គណៈចាត់តាំងកម្មវិធីរៀបចំអាសនៈសម្រាប់កម្មវិធីធ្វើបទបង្ហាញ)

***កម្មវិធីទី២*** ***ការប្រារព្ធធ្វើបទបង្ហាញ*** (PANNEL SESSION)

ម៉ោង ៩:០០ ដល់ ១២:០០

- **ការធ្វើបទបង្ហាញក្នុងពេលព្រឹក** (Morning Session)

  បទបង្ហាញ Pannel ទី១ និង Pannel ទី២

  (វាគ្មិនគ្រប់រូបធ្វើបទបង្ហាញនីមួយៗ រយៈពេលយ៉ាងយូរ **២០នាទី**)

- **បទបង្ហាញក្នុង** PANNEL **ទី១**

(អ្នកសម្របសម្រួល : ឯកឧត្តមបណ្ឌិត **ព្រហ្ម វិចិត្រអរិយ្ឌា**-Moderator)

បទបង្ហាញទី១ គុណតម្លៃរបស់លោកខាងលិចនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ នៅចំពោះមុខភាពជាក់ស្តែងនិយមខ្មែរ

វាគ្មិន : ឯកឧត្តមបណ្ឌិត **ឈីវ យីសាំង**

បទបង្ហាញទី២ គុណតម្លៃនីតិរដ្ឋធម្មនុញ្ញក្នុងបច្ចុប្បន្នភាពនៃសង្គមកម្ពុជា

វាគ្មិន : ឯកឧត្តមបណ្ឌិត **ឈឹម ផលវរុណ**

បទបង្ហាញទី៣  សិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ
វាគ្មិន : ឯកឧត្តម **អ៊ុត រ៉ាឌី**
បទបង្ហាញទី៤ ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នតុលាការក្នុងសង្គម ប្រជាធិបតេយ្យ
វាគ្មិន : ឯកឧត្តមបណ្ឌិត **ជិន ម៉ាលីន**
(ប្រកាសបិទ PANNEL **ទី១** ដោយអ្នកសម្របសម្រួល-Moderator)

- **បទបង្ហាញក្នុង** PANNEL **ទី២**

(អ្នកសម្របសម្រួល : ឯកឧត្តមបណ្ឌិត **ព្រហ្ម វិចិត្រអក្ខរា**-Moderator)
បទបង្ហាញទី១  រដ្ឋធម្មនុញ្ញ និងការកែទម្រង់រដ្ឋបាលសាធារណៈ
វាគ្មិន : ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
បទបង្ហាញទី២  ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ : គុណតម្លៃខ្មែរ និងគុណតម្លៃទំនើប
វាគ្មិន : ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
បទបង្ហាញទី៣  ប្រព័ន្ធទ្វិសភានៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស
វាគ្មិន : ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា
បទបង្ហាញទី៤  គុណតម្លៃទំនើប និងគុណតម្លៃខ្មែរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការបោះឆ្នោត
វាគ្មិន : ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប.
បទបង្ហាញទី៥  រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
វាគ្មិន : ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**
(ប្រកាសបិទ PANNEL **ទី២** ដោយអ្នកសម្របសម្រួល-Moderator)

ម៉ោង ១២:០០ ដល់ ១៣:៣០

- **សម្រាកទទួលទានអាហារថ្ងៃត្រង់**

(គណៈចាត់តាំងកម្មវិធីរៀបចំ)

ម៉ោង ១៣:៣០ ដល់ ១៧:៣០

- **ការធ្វើបទបង្ហាញក្នុងពេលរសៀល** (Afternoon Session)

បទបង្ហាញក្នុង Pannel ទី៣ និងការពិភាក្សារួម (Plenary Session)
(វាគ្មិនគ្រប់រូបធ្វើបទបង្ហាញនីមួយៗ រយៈពេលយ៉ាងយូរ **២០នាទី**)

- **បទបង្ហាញក្នុង** PANNEL **ទី៣**

(អ្នកសម្របសម្រួល : ឯកឧត្តម **តាំង រតនា**-Moderator)
បទបង្ហាញទី១  ប្រព័ន្ធគុណតម្លៃនៃច្បាប់កំពូលខ្មែរ
វាគ្មិន : ឯកឧត្តមបណ្ឌិត **ហ៊ើល ចំរើន**
បទបង្ហាញទី២  ដំណើរការវិវឌ្ឍនៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន
វាគ្មិន : ឯកឧត្តមបណ្ឌិត **ហោ ប៉េង**

បទបង្ហាញទី៣ ការការពារសិទ្ធិមនុស្ស (តម្លៃទំនើប) និងតម្លៃក្នុងស្រុក (ជាប្រពៃណី) ៖ សុខដុមូបនីយកម្មតាមរយៈការបកស្រាយបទប្បញ្ញត្តិច្បាប់

វាគ្មិន ៖ ឯកឧត្តមបណ្ឌិត **មាស ប៊ុនរ៉ា**

បទបង្ហាញទី៤ ការអភិវឌ្ឍនៃសិទ្ធិលើដីធ្លីនៅកម្ពុជា

វាគ្មិន ៖ ឯកឧត្តមបណ្ឌិត **ហាប់ ផល្លី**

បទបង្ហាញទី៥ សភានិយមកម្ពុជា

វាគ្មិន ៖ ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា

(ប្រកាសបិទ PANNEL **ទី៣** ដោយអ្នកសម្របសម្រួល-Moderator)

ម៉ោង ១៥:១៥ ដល់ ១៥:៣០

**សម្រាកទទួលទានអាហារសម្រន់ និងកាហ្វេ**

(គណៈចាត់តាំងកម្មវិធីរៀបចំអាសនៈសម្រាប់ Plenary Session )

ម៉ោង ១៥:៣០ ដល់ ១៧:៣០

- **កម្មវិធីពិភាក្សា** (Plenary Session)

(អ្នកសម្របសម្រួល ៖ ឯកឧត្តម **តាំង តេនា**-Moderator)

វាគ្មិនទាំងអស់ អញ្ជើញមកកាន់អាសនៈរួមគ្នា ដើម្បីប្រារព្ធកម្មវិធី ៖

- សំណួរ-ចម្លើយ (Question-Answer)
- ការពិភាក្សា (Discussion)
- ការផ្តល់មតិ (Comment)

ម៉ោង ១៧:៣០ ដល់ ១៧:៤៥

**សម្រាក និង សម្រួលឥរិយាបថ**

(គណៈចាត់តាំងកម្មវិធីរៀបចំអាសនៈសម្រាប់បិទកម្មវិធី)

***<u>កម្មវិធីទី៣</u> <u>ការប្រារព្ធបិទកម្មវិធី</u>*** (CLOSING SESSION)

ម៉ោង ១៧:៤៥ ដល់ ១៨:០០

- សេចក្តីថ្លែងបិទកម្មវិធីដោយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា (បិទកម្មវិធី)

ម៉ោង ១៨:០០ តទៅ

- ទទួលទានអាហារសាមគ្គីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំនៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

❖ ***<u>សម្គាល់</u>*** ៖ គណៈចាត់តាំងកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីខាងលើក្នុងករណីចាំបាច់។

**បញ្ចប់កម្មវិធី**

# មាតិកា


- **សេចក្ដីថ្លែងអំណរគុណ** ........ I
- **រូបភាព** ........ III

  *ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម*
- **ចំណាប់អារម្មណ៍** ........ XV

  *ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម*
- **សុន្ទរកថាគន្លឹះបើកកម្មវិធី** ........ ១

  *ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម*
- **គុណតម្លៃរបស់លោកខាងលិចនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ នៅចំពោះមុខភាពជាក់ស្ដែងនិយមខ្មែរ** ........ ៧

  *ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង*
- **គុណតម្លៃនីតិរដ្ឋធម្មនុញ្ញក្នុងបច្ចុប្បន្នភាពសង្គមកម្ពុជា** ........ ២៥

  *ឯកឧត្តមបណ្ឌិត ឈឹម ផលវរុណ*
- **រដ្ឋធម្មនុញ្ញ និងការកែទម្រង់រដ្ឋបាលសាធារណៈ** ........ ៣១

  *ឯកឧត្តម ព្រុំ សុខា*
- **ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ** ........ ៤៩

  *ឯកឧត្តម សក់ សេដ្ឋា*
- **ប្រព័ន្ធសិទ្ធិសភានៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស** ........ ៧១

  *ឯកឧត្តម អ៊ុំ សារឹទ្ធ*
- **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការបោះឆ្នោត** ........ ៨៥

  *ឯកឧត្តម ទេព នីថា*
- **ប្រព័ន្ធគុណតម្លៃ នៃច្បាប់កំពូលខ្មែរ** ........ ៩៥

  *ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន*
- **ដំណើរការវិវឌ្ឍនៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន** ........ ៩៩

  *ឯកឧត្តមបណ្ឌិត ហោ ប៉េង*

• **ការការពារសិទ្ធិមនុស្ស (តម្លៃទំនើប) និង តម្លៃក្នុងស្រុក(ជាប្រពៃណី)៖ សុខដុមូបនីយកម្មតាមរយៈការបកស្រាយបទប្បញ្ញត្តិច្បាប់................ ១១៥**
*ឯកឧត្តមបណ្ឌិត មាស បូរ៉ា*
• **ការអភិវឌ្ឍនៃសិទ្ធិលើដីធ្លីនៅកម្ពុជា ..................................................... ១២៧**
*ឯកឧត្តមបណ្ឌិត ហាប់ ផល្លី*
• **សភានិយមកម្ពុជា ........................................................................... ១៥៥**
*ឯកឧត្តម ឡេង ប៉េងឡុង*
• **សេចក្តីសង្ខេបគោលគំនិតសំខាន់ៗមួយចំនួន....................................... ១៦៥**
*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម*

# ចំណាប់អារម្មណ៍

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ***អ៊ឹម ឈុនលឹម*** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ដើម្បីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (២៤ កញ្ញា ១៩៩៣-២៤ កញ្ញា ២០២០) ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំសន្និសីទមួយស្តីពី " **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ** " ដែលមានសរសេរចារឹកនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាវេទិកាដ៏មានសារៈសំខាន់មួយ ក្នុងការប្រមូលផ្តុំនូវបញ្ញាញាណរបស់នីតិបញ្ញវន្តខ្មែរ ប្រកបដោយចំណេះដឹង និងបទពិសោធ ដើម្បីរួមគ្នាធ្វើការផ្លាស់ប្តូរទស្សនទានពាក់ព័ន្ធនឹងប្រធានបទនេះ។

ដោយយល់ឃើញថា ទស្សនទានចម្រុះរបស់វាគ្មិនទាំងអស់ ដែលបានចែករំលែកក្នុងសន្និសីទ គឺមានគុណភាពខ្ពស់ ប្រកបដោយសុភនិច្ឆ័យលើទិដ្ឋភាពជាច្រើននៃការអនុវត្តរដ្ឋធម្មនុញ្ញក្នុងអំឡុងពេល២៧ឆ្នាំកន្លងមកនេះ ទើបឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតបានផ្តួចផ្តើមគំនិត ស្នើដល់វាគ្មិនជួយពង្រីកខ្លឹមសារនៃបទអន្តរាគមន៍ តាមស្មារតីដែលបានផ្តល់ក្នុងសន្និសីទ ទុកជាឯកសារសម្រាប់ការបោះពុម្ពផ្សាយ ដើម្បីជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវអំពីនីតិរដ្ឋធម្មនុញ្ញកម្ពុជា ជាពិសេសដើម្បីផ្តល់ការយល់ដឹងអំពីគុណតម្លៃនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ សម្រាប់ឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបភ្ញាក់រលឹក តាមស្មារតីដូចមានចារឹកក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញគឺ "[...] ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរកសាងប្រទេសជាតិឱ្យទៅជា " កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱយបានឈានឡើងរីកចំរើន លូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ [...] ។

# សុន្ទរកថាគន្លឹះ

*ថ្លែងដោយ*

## ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត *អ៊ឹម ឈុនលឹម* ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងពិធីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំនៃការប្រកាសឱ្យប្រើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ប្រារព្ធធ្វើនៅថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

- សម្តេច ឯកឧត្តម សមាជិក សមាជិកានៃក្រុមប្រឹក្សាធម្មនុញ្ញ
- ឯកឧត្តមជាសមាជិករាជរដ្ឋាភិបាល ឯកឧត្តមដែលអញ្ជើញមកពីស្ថាប័នឧត្តមសិក្សា ជាវាគ្មិន
- ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃអង្គពិធីទាំងមូល

១- ថ្ងៃនេះ ទូលបង្គំខ្ញុំមានសេចក្តីរីករាយក្រៃលែង និងសូមថ្លែងអំណរព្រះគុណ និងអំណរគុណចំពោះព្រះវត្តមាន និងវត្តមានរបស់សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នៅក្នុងសន្និសីទនាពេលនេះ ស្តីពី "គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ" ដែលជាស្មារតីមានសរសេរចារឹកនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំដោយក្រុមប្រឹក្សាធម្មនុញ្ញនូវសន្និសីទនេះ គឺដើម្បីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំនៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (២៤ កញ្ញា ១៩៩៣ - ២៤ កញ្ញា ២០២០)។ ដូច្នេះ នៅថ្ងៃទី២៤ កញ្ញា ស្អែកនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានអាយុគ្រប់២៧ឆ្នាំគត់ ដែលរដ្ឋធម្មនុញ្ញនេះគឺជាសមិទ្ធផលកើតចេញពីឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរសម្តែងឡើងតាមរយៈការបោះឆ្នោតជាសកលកាលពីឆ្នាំ១៩៩៣ ហើយរដ្ឋធម្មនុញ្ញនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃស្ថិរភាពរបបនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ននៅលើខឿនប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមកដល់បច្ចុប្បន្ននេះមានសុខសន្តិភាពពេញលេញ ជារដ្ឋមានស្ថិរភាពជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។

២- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ គឺជារដ្ឋធម្មនុញ្ញទី៦ ចាប់តាំងពីប្រទេសកម្ពុជា បានទទួលយកប្រព័ន្ធដឹកនាំរដ្ឋបែបទំនើបតាមបែបបស្ចិមលោក ដោយបានប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញទំនើបលើកដំបូងក្នុងឆ្នាំ១៩៤៧ ដែលមានគុណតម្លៃគ្រឹះនៃធម្មនុញ្ញនិយម រួមមាន (១)ប្រជាធិបតេយ្យ (២)សិទ្ធិមនុស្ស (៣) ការបែងចែក

អំណាច និង(៤)នីតិរដ្ឋ ត្រូវបានយកមកផ្សាំជាមួយសង្គមខ្មែរ ចាប់តាំងពីពេលនោះមក។ ប៉ុន្តែការអនុវត្តគុណតម្លៃទាំងនោះ ពុំមានស្ថិរភាពជាប់បានយូរអង្វែងទេ អាស្រ័យដោយប្រទេសកម្ពុជាពើបប្រទះនឹងវិបត្តិនៃការដូររបបនយោបាយជាច្រើនលើក ច្រើនគ្រា ដូចដែលយើងទាំងអស់គ្នានៅទីនេះបានជ្រាប តាមដំណើរប្រវត្តិសាស្ត្រនៃប្រទេសជាតិយើង។

៣-ក្រោយការដួលរលំទៅនៃគ្រឹះធម្មនុញ្ញនិយមឆ្នាំ១៩៤៧ ដោយរដ្ឋប្រហារឆ្នាំ១៩៧០ ប្រទេសជាតិយើងបានឆ្លងកាត់បទពិសោធនៃការអនុវត្តរដ្ឋធម្មនុញ្ញដែលកំណត់របបនយោបាយខុសៗគ្នា ប៉ុន្តែពុំបានធ្វើឱ្យប្រទេសកម្ពុជាទទួលបានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនោះទេ ពិសេសនៅទសវត្សរ៍ឆ្នាំ១៩៧០ បាននាំប្រទេសជាតិយើងឱ្យធ្លាក់ខ្លួនដ៏សែនរន្ធត់ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមខិនថយ...ដូចមានការចារឹកខ្លឹមសារក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ រហូតមកដល់ការសម្រេចបាន *កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា* ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបប្រទេសកម្ពុជាកសាងបានរដ្ឋធម្មនុញ្ញមួយ ដោយផ្អែកលើគោលការណ៍ធំៗជាមូលដ្ឋាន ដែលមានចែងក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។

៤- គោលការណ៍ដែលមានចែងក្នុងឧបសម្ព័ន្ធទី៥ ដូចលើកឡើងខាងលើ **ជាគោលការណ៍សារវន្តមានលក្ខណៈទំនើបជាគុណតម្លៃសកល** ដែលសហគមន៍អន្តរជាតិមានបំណងដាក់ឱ្យអនុវត្តនៅកម្ពុជា។ ក្រៅពីគោលការណ៍ជាសារវន្តទាំងនោះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក៏បានចារឹកនូវ**គុណតម្លៃរបស់សង្គមខ្មែរ** ដែលមានជាប់ពាក់ព័ន្ធនឹងកត្តាប្រវត្តិសាស្ត្រ របបរាជានិយម និងសាសនា វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ របស់ខ្មែរផងដែរ។ ដូច្នេះឃើញថារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជារដ្ឋធម្មនុញ្ញពហុនិយមដែលមានសារធាតុល្បាយរវាងគុណតម្លៃទំនើប និងគុណតម្លៃរបស់សង្គមខ្មែរផ្ទាល់ ដែលពុំអាចកាត់ផ្ដាច់បានពីកត្តាប្រវត្តិសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ ក្នុងអតីតកាលដ៏យូរលង់របស់ប្រទេសកម្ពុជាបានឡើយ។

៥- ការដាក់បញ្ចូលគ្នានូវគុណតម្លៃនិងទស្សនទានធម្មនុញ្ញបែបទំនើប និងគុណតម្លៃខ្មែរនិយម ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បង្កើតឡើងនូវពហុសណ្ឋាន ជាទស្សនៈពហុនិយមបែបនេះ ក្នុងការអនុវត្តរមែងជួបប្រទះនូវការរអាក់រអួល និងការយល់ខុសគ្នាចំពោះបញ្ហាប្រឈមជាក់ស្ដែងមួយចំនួន និងវិធីដោះស្រាយជាពុំខាន ឧទាហរណ៍ដូចជាការកើតឡើងនូវវិបត្តិនយោបាយក្រោយការបោះឆ្នោតជាច្រើនលើក ច្រើនសា ដែល

ស្តែងឡើងឱ្យឃើញទាំងចំណោទបញ្ហា ចំណោទច្បាប់ ទាំងដំណោះស្រាយសមស្រប និងចាំបាច់នានា ដើម្បីធានាដល់តម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរី និងគោលការណ៍នៃការបោះឆ្នោតពហុបក្ស ក្នុងដំណើរអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល២៧ឆ្នាំកន្លងមកនេះ ជារយៈពេលមួយវែងជាងរយៈពេលអនុវត្តរដ្ឋធម្មនុញ្ញមុនៗគ្រប់ជំនាន់។ ការពិត ពិសោធន៍នៃការអនុវត្តល្បាយទស្សនៈនយោបាយ សាសនា ទស្សនវិជ្ជាដូចនេះ ពុំមែនជារឿងថ្មីនៅក្នុងសង្គមខ្មែរឡើយ បើយើងក្រឡេកមើលប្រវត្តិនយោបាយដឹកនាំរដ្ឋ និងការបង្កើតខឿនអារ្យធម៌ ដែលបុព្វបុរសខ្មែររមែងប្រើវិធីសំយោគទស្សនៈបែបនេះច្រើនបែប ច្រើនទម្រង់ណាស់ ដើម្បីធានាសុខដុមរមនីយកម្មក្នុងសង្គម ដូចជាក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បង្កើត *ទេវរូបលោកេស្វរៈ* (រូបព្រះពិស្ណុដែលមានឆ្លាក់ព្រះពុទ្ធរូបពាសពេញព្រះកាយ និងមានឆ្លាក់ព្រះពុទ្ធរូបនៅលើផ្នួងសក់) ដើម្បីបង្កើតសុខដុមរមនីយកម្មរវាងអ្នកគោរពបូជាព្រហ្មញ្ញសាសនា និងអ្នកគោរពបូជាព្រះពុទ្ធសាសនានិកាយមហាយាន។ ទស្សនៈសំយោគរបស់បុព្វបុរសខ្មែរបែបនេះ អាចមិនជាទីពេញចិត្តចំពោះប្រមុខសាសនា ឬសាសនិកជននៃព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនាក្រៅពីជាតិខ្មែរ ក៏ប៉ុន្តែអ្វីដែលមិនអាចប្រកែកបាន គឺរបៀបប្រើបញ្ញាដោយអនុវត្តគុណតម្លៃពីរក្នុងរូបតែមួយបែបនេះ បានធ្វើឱ្យសង្គមខ្មែរស្គាល់នូវសុខដុមរមនីយកម្មសាសនា មានសាមគ្គីជាតិ ឯកភាពជាតិ សុខសន្តិភាព និងការរីកចម្រើន រហូតក្លាយជាមហាអាណាចក្រអង្គរមួយដ៏រុងរឿងមកជាច្រើនសតវត្សរ៍។

៦- ចំពោះការអនុវត្តគុណតម្លៃធម្មនុញ្ញនិយម នៅព្រះរាជាណាចក្រកម្ពុជានាពេលកន្លងមក មានការយល់ខុសគ្នាក្នុងចំណោមតួអង្គពាក់ព័ន្ធខ្លះ រវាងទ្រឹស្តីវិទូ និងប្រតិបត្តិករនៅលើទីលានសង្គមកម្ពុជាជាក់ស្តែង រវាងអ្នកនៅក្នុងមជ្ឈដ្ឋានជាតិ និងអ្នកនៅក្នុងមជ្ឈដ្ឋានអន្តរជាតិ ទាក់ទងអំពីដំណើរអនុវត្តប្រជាធិបតេយ្យសេរីពហុបក្ស អំពីការលើកកម្ពស់សិទ្ធិសេរីភាពជាមូលដ្ឋាន អំពីទិដ្ឋភាពនៃដំណើរប្រព្រឹត្តទៅនៃអំណាចរដ្ឋទាំងបី អំពីការលើកកម្ពស់នីតិរដ្ឋ និងបញ្ហាមួយចំនួនទៀត ដូចជាបញ្ហាជាប់ទាក់ទងនឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងការបកស្រាយច្បាប់។ អាស្រ័យដោយមានការយល់ផ្សេងៗពីគ្នាចំពោះបញ្ហា និងដំណោះស្រាយបញ្ហាដូចនេះ ទើបញ៉ាំងឱ្យមានការយល់ស្រពេចស្រពិល ចំពោះសមិទ្ធផលសម្រេចបានក្នុងរយៈពេល២៧ឆ្នាំមកនេះនៃការអនុវត្តរដ្ឋធម្មនុញ្ញនៅព្រះរាជាណាចក្រកម្ពុជា។

៧- ដូចនេះចំពោះបញ្ហាទាំងឡាយដូចរៀបរាប់ខាងលើ គេពុំគួរមើលរំលង ឬបដិសេធតថភាពនោះទេ ប៉ុន្តែគេគួរតែលើកយកបញ្ហាទាំងនេះមកពិនិត្យពិភាក្សានិង

ដោះស្រាយរួមគ្នាដោយឈរលើស្មារតីយុត្តិធម៌ សច្ចធម៌ និងស្មារតីវិជ្ជមានដូចគ្នា គឺបំណងចង់ធ្វើឱ្យសម្រេចនូវគោលដៅ ធ្វើឱ្យក្លាយទៅជាការពិតជាក់ស្តែងនូវគុណតម្លៃធម្មនុញ្ញនិយម ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែទោះក្នុងស្មារតីនេះក្តី ក៏គេគួរចងចាំថា ដើម្បីទៅដល់គោលដៅនោះ បើប្រៀបធៀបនឹងចម្ងាយផ្លូវ ឬរយៈពេលដើម្បីទៅដល់ នោះប្រហែលពុំមែនជាចម្ងាយផ្លូវជិតពេកទេ ពិសេសចំពោះស្ថានភាពនៃប្រទេសកម្ពុជា ដែលបានឆ្លងកាត់នូវការវិនាសអន្តរាយដ៏ធ្ងន់ធ្ងរបំផុត ស្ទើរតែបាត់បង់នូវអត្តសញ្ញាណ និងអរិយធម៌ជាតិរបស់ខ្លួនថែមទៀតផង។ ម្យ៉ាងទៀតដោយវប្បធម៌ប្រពៃណី ទំនៀមទម្លាប់ ឥរិយាបថសង្គម និងឥរិយាបថនយោបាយរបស់មនុស្សខ្មែរ ដែលជាវប្បធម៌ ជាទស្សនទានមានលក្ខណៈដោយឡែកពីវប្បធម៌ នយោបាយរាប់សតវត្សរ៍រៀងមករបស់លោកខាងលិច ដូច្នេះការបន្សាំគុណតម្លៃធម្មនុញ្ញនិយមទំនើបមកក្នុងសង្គមខ្មែរ ពិតជាត្រូវការពេលវេលាសមស្របមួយដើម្បីបង្កលក្ខណៈឱ្យគ្រប់តួអង្គនៅក្នុងសង្គមមានលក្ខណសម្បត្តិ និងសមត្ថភាពយល់ដឹងដោយត្រឹមត្រូវ នូវគុណតម្លៃទំនើប និងស្គាល់តថភាពរបស់សង្គមខ្លួនឯង ស្គាល់អ្វីជាឧត្តមប្រយោជន៍ អ្វីជាគ្រោះថ្នាក់ចំពោះប្រទេសជាតិ ដែលជាបន្ទាត់ដែលមិនត្រូវរំលងហួស ដើម្បីរួមគ្នាធ្វើការអភិវឌ្ឍដោយសុខដុមរមនានូវគុណតម្លៃធម្មនុញ្ញនិយមទំនើប ឱ្យចាក់ឫសរឹងមាំក្នុងសង្គមកម្ពុជា ទន្ទឹមនឹងចេះសម្របខ្លួនជាមួយបរិបទខ្មែរ និងថែរក្សាការពារឱ្យបានវប្បធម៌ប្រពៃណីល្អ របស់ជាតិ។

៨- ការវាយតម្លៃការអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្អែកតែលើលក្ខណវិនិច្ឆ័យមួយជ្រុង នៃការអនុវត្តគុណតម្លៃទំនើប នឹងនាំឱ្យមានភាពអយុត្តិធម៌ចំពោះអ្នកអនុវត្ត ដែលបានខិតខំសម្រេចសមិទ្ធផលធំៗជាច្រើនរបស់ជាតិ។ រីឯការវាយតម្លៃការអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្អែកតែលើលក្ខណវិនិច្ឆ័យមួយជ្រុងនៃការអនុវត្តគុណតម្លៃបែបខ្មែរ ក៏នឹងនាំដល់ចំណោទបញ្ហាគុណភាពនៃការអនុវត្តគុណតម្លៃធម្មនុញ្ញនិយម ក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងសាកលភាវូបនីយកម្ម ទាំងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ បច្ចេកវិទ្យា នាយុគសម័យដ៏ជឿនលឿននេះ។ ដូច្នេះដើម្បីធ្វើការវាស់វែងដំណើរការអនុវត្តរដ្ឋធម្មនុញ្ញកម្ពុជាឱ្យមានភាពយុត្តិធម៌ និងសមធម៌សមស្រប សម្រាប់សង្គមខ្មែរ ចាំបាច់គេត្រូវគិតគូរថ្លឹងថ្លែងទៅតាមទស្សនទាន តាមបែបបស្ចិមប្រទេសផង និងក៏ត្រូវគិតទៅដល់ចរិតលក្ខណៈប្រពៃណីរបស់ខ្មែរផងដែរ នោះទើបយើងអាចមានសុទិដ្ឋិនិយម និងសមានចិត្តទូលំទូលាយក្នុងការវាយតម្លៃការអនុវត្តរដ្ឋធម្មនុញ្ញនៅកម្ពុជា។

**សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកនៃអង្គពិធី**

៩- ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ អាស្រ័យដោយប្រទេសជាតិមានសន្តិភាព និងការអភិវឌ្ឍ បានញ៉ាំងឱ្យធនធាននីតិបញ្ញវន្តខ្មែរ ដែលទទួលបានការអប់រំខ្ពស់ទាំងក្នុងនិងក្រៅប្រទេស ក៏មានចំនួនកាន់តែច្រើនឡើង ក្នុងនេះមាននីតិបញ្ញវន្តមួយចំនួនធំតួយ៉ាងដូចជាឯកឧត្តមជាវាគ្មិនទាំង១៨រូប ដែលនឹងធ្វើបទអន្តរាគមន៍នាពេលបន្តិចទៀតនេះ ភាគច្រើនសុទ្ធតែបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ និងមាននិក្ខេបបទបណ្ឌិតពីសកលវិទ្យាល័យធំៗនៅកម្ពុជា និងពីបណ្ដាប្រទេសនានា រួមមានពីបារាំង អាល្លឺម៉ង់ រុស្ស៊ី សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន សិង្ហបុរី...។ ទន្ទឹមនេះ វាគ្មិនទាំងអស់ក៏សុទ្ធតែបានចូលរួមប្រឡូកក្នុងកិច្ចការបម្រើរដ្ឋ ឬកិច្ចការក្នុងវិជ្ជាជីវៈជំនាញ និងបានស្គាល់នូវការលំបាក និងការងាយស្រួលនៃដំណើរជាតិរបស់យើង។ បទពិសោធជាក់ស្ដែងដែលទទួលបានពីការងារ និងការរស់នៅក្នុងសង្គម រួមផ្សំនឹងចំណេះដឹងតាមរយៈការសិក្សានិងការស្រាវជ្រាវ គឺពិតជាទុនដ៏មានតម្លៃសម្រាប់នីតិបញ្ញវន្តខ្មែរ យល់កាន់តែច្បាស់នូវស្ថានភាពពិតប្រាកដរបស់កម្ពុជា។

១០- ដោយពិនិត្យឃើញសក្ដានុពលរបស់នីតិបញ្ញវន្តខ្មែរដូចនេះ ទើបក្នុងឱកាសអបអរសាទរទិវារំលឹកខួប២៧ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញមានគោលគំនិតប្រមូលផ្ដុំបញ្ញាញាណរបស់នីតិបញ្ញវន្តខ្មែរ ដើម្បីរួមគ្នាក្នុងនាមជាម្ចាស់ជោគវាសនារបស់ប្រទេសជាតិខ្លួន លើកយកមកពិនិត្យស្រាវជ្រាវនូវខ្លឹមសារ ដែលទាក់ទងនឹងដំណើរវិវឌ្ឍនៃរដ្ឋធម្មនុញ្ញកម្ពុជាលើគ្រប់ទិដ្ឋភាពនៃគោលការណ៍គ្រឹះទាំងឡាយនៃធម្មនុញ្ញនិយមទំនើប ឬ "ធម្មនុញ្ញនិយមទំនើបបែបខ្មែរ (sic)" ដើម្បីធ្វើការសន្និដ្ឋានជាលក្ខណៈវិទ្យាសាស្ត្រ និងជាលក្ខណៈសិក្សាស្រាវជ្រាវ អំពីវឌ្ឍនភាពនៃការអនុវត្ត ទាំងអ្វីៗដែលសម្រេចបាន ឬសម្រេចបានខ្លះជាបណ្ដើរៗហើយ ទាំងបញ្ហាប្រឈម និងការផ្ដួចផ្ដើមគំនិតនូវអ្វីៗដែលគួរបន្តខិតខំអនុវត្តទៅមុខទៀត។ ជារួមការពិភាក្សារបស់យើងនៅពេលនេះ គឺចង់សម្រេចនូវគោលបំណងសំខាន់ៗចំនួន៣គឺៈ ១. ពិភាក្សាអំពីទិដ្ឋភាពនៃការអនុវត្តគុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ២. ពិភាក្សាវាយតម្លៃលទ្ធផលនៃការអនុវត្តគុណតម្លៃទាំងពីរ និងទី ៣. ពិភាក្សារិះរកយន្តការសុខដុមូបនីយកម្មនៃគុណតម្លៃទាំងពីរ។ **ការពិនិត្យ ពិភាក្សា ប្រាកដជានាំយើងឱ្យមើលឃើញនូវ ជំហាននៃការអភិវឌ្ឍគុណតម្លៃ "ធម្មនុញ្ញនិយមទំនើបបែបខ្មែរ" ដែលកំពុងដំណើរការទៅមុខយ៉ាងទន់ភ្លន់ រស់រវើក និងម៉ឺងម៉ាត់ ដោយសម្របខ្លួនជាបណ្ដើរៗទៅនឹងទស្សនទានទំនើបនៃធម្មនុញ្ញនិយម ដោយរក្សាបានជាចាំបាច់**

នូវសន្តិភាព ស្ថិរភាព ក៏ដូចជារក្សាបាននូវវប្បធម៌ ប្រពៃណីល្អផ្សេងៗរបស់ជាតិ។

១១- ទូលបង្គំខ្ញុំមានជំនឿយ៉ាងមុតមាំថា ការរៀបចំសន្និសីទក្នុងថ្ងៃនេះ នឹងបង្កើតបានជាវេទិកាមួយសម្រាប់ក្រុមប្រឹក្សាធម្មនុញ្ញ ជួបជុំជាមួយនីតិបញ្ញត្តិខ្មែរ ដើម្បីប្រមូលនូវធាតុចូលជាការវិភាគ និងការសន្និដ្ឋានសំខាន់ៗ សម្រាប់ការសិក្សាស្រាវជ្រាវបន្តទៀត ហើយសង្ឃឹមថាសន្និសីទក្នុងថ្ងៃនេះនឹងសម្រេចបានលទ្ធផល ស្របតាមគោលបំណងដែលចង់បាន ដើម្បីជាតម្រាយមួយសម្រាប់ការងារបូកសរុបខួបលើកទី៣០នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងមកដល់ក្នុងឆ្នាំ២០២៣ ខាងមុខនេះ។ ជាទីបញ្ចប់ តទៅនេះទូលបង្គំខ្ញុំមានកិត្តិយសសូមប្រកាសបើកអង្គសន្និសីទ ចាប់ពីពេលនេះតទៅ។

សូមអរព្រះគុណ និងសូមអរគុណ

# គុណតម្លៃរបស់លោកខាងលិចនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ នៅចំពោះមុខភាពជាក់ស្តែងនិយមខ្មែរ

ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង

## ខ្លឹមសារសង្ខេប

ភាពជាក់ស្តែងនិយមខ្មែរនៅចំពោះមុខឥទ្ធិពលបរទេស គឺជាទិដ្ឋភាពមួយនៃមូលដ្ឋានគ្រឹះដ៏សំខាន់ និងគួរឱ្យកត់សម្គាល់បំផុតនៃជីវិតនយោបាយនៅកម្ពុជា។ កាលពីអតីតកាល ប្រទេសកម្ពុជា កម្របំពេញបានណាស់នូវល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ស្ថិរភាពនយោបាយពេញលេញ។ អស្ថិរភាព ការផ្លាស់ប្តូរភ្លាមៗនៃអ្នកដឹកនាំជាទូទៅ គឺដោយសារជម្លោះដណ្តើមអំណាចរវាងព្រះអង្គម្ចាស់ អភិជនខ្មែរ...។ល។ ជម្លោះដណ្តើមអំណាចនេះ បានអនុញ្ញាតឱ្យប្រទេសជិតខាងចែកគ្នានូវអធិបតេយ្យខ្មែរ និងកាត់ភ្ជាប់យកទឹកដីខ្មែរមួយចំនួន។ ក្នុងយុគសម័យទំនើប អស្ថិរភាព ច្រើនតែបណ្តាលមកពីអន្តរាគមន៍ និងឥទ្ធិពលបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឡើងដោយស្ម័គ្រចិត្ត ឬដោយបង្ខំ និងនាំមកនូវគំនិតនយោបាយ និងរបៀបរបបបែប "ទំនើប"។ គំនិតនយោបាយនិងរបៀបរបបបែប«ទំនើប»នេះ បានប៉ះទង្គិចនឹងទំនៀមទម្លាប់តាំងពីបរមបុរាណមក ដែលត្រូវបានការពារដោយព្រះមហាក្សត្រ និងស្ថាប័នព្រះមហាក្សត្រ ហើយនិងប៉ះនឹងអ្នកជាតិនិយម និងឥស្សរជនខ្មែរ។ ក្នុងអំឡុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ឥទ្ធិពលបរទេស ត្រូវបានបង្ហាញយ៉ាងច្បាស់ក្រឡែតនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់កម្ពុជា។

**«ទស្សនទានរបស់លោកខាងលិចនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចំពោះមុខភាពជាក់ស្តែងនិយមខ្មែរ»នេះ** ត្រូវបានយកមករំលេចឱ្យឃើញ តាមរយៈការវិភាគលើ (ទី១) ការបង្កើតឡើងវិញនៃរបបរាជានិយម និង(ទី២) ការបង្កើតរបបប្រជាធិបតេយ្យ សេរីពហុបក្សនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ខ្លឹមសារសំខាន់ទី១នៃការវិភាគនេះ គូសបញ្ជាក់ពីមោទនភាពដែលប្រជាជនខ្មែរ អាចទាញយកពីអត្តសញ្ញាណជាតិរបស់ខ្លួន បន្ទាប់ពីពួកគេរៀនយល់ច្បាស់អំពីប្រវត្តិសាស្ត្រដ៏យូរអង្វែង អរិយធម៌ និងប្រពៃណីរបស់ខ្លួន។ ខ្លឹមសារសំខាន់ទី២ គឺថា ភាពជាក់ស្តែងនិយមខ្មែរ បានអនុញ្ញាតឱ្យមានការអនុម័តច្បាប់កំពូលមួយ ការបង្កើតរាជរដ្ឋាភិបាលដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាដោយជោគជ័យ ទៅក្នុងតំបន់និងពិភពលោក ជោគជ័យរបស់កម្ពុជាក្នុងកិច្ចការអភិបាលកិច្ចប្រជាធិបតេយ្យ និងការបន្តនៃវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម។

## សេចក្តីផ្តើម

### ១- ឥទ្ធិពលបរទេស - រដ្ឋធម្មនុញ្ញ

កាលពីអតីតកាល ប្រទេសកម្ពុជាយើង កម្របំពេញបានណាស់នូវល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ស្ថិរភាពនយោបាយពេញលេញ។ យោងទៅតាមប្រវត្តិវិទូនៅសម័យបុរាណ (រហូតដល់ការចុះហត្ថលេខាលើសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង នៅឆ្នាំ១៨៦៣) អស្ថិរភាព ការផ្លាស់ប្តូរភ្លាមៗនៃអ្នកដឹកនាំជាទូទៅ គឺដោយសារជម្លោះដណ្តើមអំណាចរវាងបងប្អូន រវាងព្រះអង្គម្ចាស់ អភិជនខ្មែរ ... ។ល។ ជម្លោះដណ្តើមអំណាចនេះ បានអនុញ្ញាតឱ្យប្រទេសជិតខាងចែកគ្នានូវអធិបតេយ្យខ្មែរ និងកាត់ភ្ជាប់យកទឹកដីខ្មែរមួយចំនួន។ ក្នុងយុគសម័យទំនើប (ពីអាណាព្យាបាលរហូតដល់រដ្ឋប្រហារឆ្នាំ១៩៧០) អស្ថិរភាព ច្រើនតែបណ្តាលមកពីអន្តរាគមន៍ និងឥទ្ធិពលបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឡើងដោយស្ម័គ្រចិត្ត ឬដោយបង្ខំ និងនាំមកនូវគំនិតនយោបាយ និងរបៀបរបបបែប"ទំនើប"។ គំនិតនយោបាយនិងរបៀបរបបបែប «ទំនើប»នេះ បានប៉ះទង្គិចនឹងទំនៀមទម្លាប់តាំងពីបរមបុរាណមក ដែលត្រូវបានការពារដោយព្រះមហាក្សត្រនិងស្ថាប័នព្រះមហាក្សត្រ ហើយនិងប៉ះនឹងអ្នកជាតិនិយម និងឥស្សរជនខ្មែរ (បណ្តុះបណ្តាលនៅប្រទេសបារាំង) ដែលមិនទទួលយករាជានិយម ឬរាជាធិបតេយ្យដាច់ខាត។ ពួកអាណានិគមបារាំងដែលនាំចូលច្បាប់ជាលាយលក្ខណ៍អក្សរទំនើប ដើម្បីជំនួសច្បាប់ទំនៀមទម្លាប់ប្រពៃណី ក៏បាននាំចូលផងដែរមកក្នុងប្រវត្តិសាស្ត្រកម្ពុជានូវច្បាប់រដ្ឋធម្មនុញ្ញ ជាពិសេសច្បាប់រដ្ឋធម្មនុញ្ញទីមួយឆ្នាំ១៩៤៧។

### ២- ទស្សនទានលោកខាងលិចនៃ«រដ្ឋធម្មនុញ្ញ»

ក្នុងអំឡុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ឥទ្ធិពលបរទេស ត្រូវបានបង្ហាញយ៉ាងច្បាស់ក្រឡែតនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់កម្ពុជា។ ឥទ្ធិពលបរទេស ឬទស្សនទានរបស់លោកខាងលិចនេះ ត្រូវបានបញ្ជាក់ជាពិសេស នៅក្នុងឧបសម្ព័ន្ធ៥ នៃកិច្ចព្រមព្រៀងសម្រាប់ដំណោះស្រាយរួមមួយនៃជម្លោះកម្ពុជា ដែលជាកិច្ចព្រមព្រៀងទី១ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ចុះហត្ថលេខានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ សូមរំលឹកនូវមាត្រាទាំង៦នៃឧបសម្ព័ន្ធ៥ នេះ ដូចតទៅ ៖

២-១- រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញនេះបាន លុះត្រាតែមានរបៀបរបបចាត់តាំងមួយទាក់ទងដល់ការយល់ព្រមពីអង្គការនីតិប្បញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្តង។

២-២- ប្រវត្តិសាស្ត្រថ្មីៗប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានការចាត់វិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមានសេចក្តីថ្លែងការណ៍មួយអំពី សិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នា និងបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឱ្យមានការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការ ឬការដកហូតសិទ្ធិឯកជនដោយគ្មានការសងជំងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ និងជំនឿសាសនា ឬភេទឡើយ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល។ សេចក្តីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ។ បុគ្គលដែលត្រូវរំលោភបំពានមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ។

២-៣- រដ្ឋធម្មនុញ្ញ ត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យឯករាជ្យ និងអព្យាក្រឹត និងអំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា។

២-៤-រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជា នឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរីដោយឈរលើមូលដ្ឋានពហុបក្ស។ រដ្ឋធម្មនុញ្ញ ត្រូវកំណត់ឱ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា។ រដ្ឋធម្មនុញ្ញ ត្រូវអនុញ្ញាតឱ្យប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិសម្រាប់បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតតាមរបៀបបោះឆ្នោតដោយសកល និងស្មើភាព។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឱ្យមានទម្រង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត។

២-៥- ត្រូវបង្កើតតុលាការឯករាជ្យ ដែលត្រូវមានអំណាចដាក់ឱ្យអនុវត្តនូវបណ្តាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

២-៦- រដ្ឋធម្មនុញ្ញ ត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបី នៃសមាជិករបស់សភាធម្មនុញ្ញ។

## ៣- ភាពជាក់ស្តែងនិយមខ្មែរ

១- អ្នកនយោបាយខ្មែរទាំងអស់ អះអាងនៅក្នុងសេចក្តីថ្លែងការណ៍ ឬសុន្ទរកថា

របស់ខ្លួនថា ប្រកាន់ខ្ជាប់នូវគោលការណ៍ដែលបរទេសចាប់បង្ខំឱ្យទទួលយក។ ពួកគាត់យល់ឃើញថា មានសារៈសំខាន់សម្រាប់ស្ថិរភាពនយោបាយ និងការអភិវឌ្ឍប្រទេស។ ប៉ុន្តែ នៅពេលគោលការណ៍ទាំងនេះ អាចធ្វើឱ្យអន្តរាយដល់អត្ថប្រយោជន៍របស់ពួកខ្លួន អ្នកនយោបាយខ្មែរ គ្មានរារែកបន្តិចសោះឡើយក្នុងការរុញគោលការណ៍ទាំងនេះ ឱ្យស្ថិតនៅក្នុងកម្រិតបន្ទាប់បន្សំ ។ ប្រជាជនកម្ពុជា មានឆន្ទៈផងដែរក្នុងការចាប់យកឧបករណ៍ទំនើបនេះ ដែលធានានូវការទទួលស្គាល់សិទ្ធិ និងសេរីភាពរបស់ពួកគាត់។

២- នៅក្នុងកាលៈទេសៈទាំងនេះ សម្រាប់អ្នកនិពន្ធខ្មែរនៃសេចក្តីព្រាងរដ្ឋធម្មនុញ្ញ វាមានសារៈសំខាន់ណាស់ ដែលរដ្ឋធម្មនុញ្ញអនុម័តរួច មិនមានលក្ខណៈតឹងរឹងពេក ដោយទុកឱ្យស្ថាប័នរដ្ឋ និងប្រទេសវិវឌ្ឍរីកចម្រើនទៅមុខ។ សរុបសេចក្តីមក ភាពផ្ទុយគ្នា គឺនៅត្រង់ថា សញ្ញាណនៃរដ្ឋធម្មនុញ្ញ គឺជាការនាំចូលពីបរទេស ប៉ុន្តែប្រជាជនកម្ពុជា ទទួលយកមកធ្វើជារបស់ខ្លួន ស្របតាមវិធីសាស្រ្ត និងបែបបទផ្ទាល់របស់ខ្មែរ ដូចដែលខ្មែរយើងបានទទួលយក *ធម្មសាស្រ្ត* ដោយមិនអនុម័តយកប្រព័ន្ធវណ្ណៈ មកប្រើនៅក្នុងសង្គមខ្មែរ។

៣- ឧទាហរណ៍ជាច្រើនទៀតនៃការទទួលយកមកធ្វើជារបស់ខ្លួន ដោយជនជាតិខ្មែរ មានជាអាទិ៍ដូចជា ៖ អរិយធម៌និងវប្បធម៌ខ្មែរ បានបញ្ចូលសាសនា រចនាប័ទ្មស្ថាបត្យកម្ម និងប្រពៃណី ដែលពេលខ្លះមានប្រភពមកពីឆ្ងាយ។ ទោះយ៉ាងណាក៏ដោយ គេងាយមើលឃើញខេមរយានូបនីយកម្ម នៃវិស័យទាំងអស់នេះ និងការសម្របទៅនឹង «**ស្រុកខ្មែរ**»។ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានលក្ខណៈប្លែកពីគេ ទោះបីជាស្ថិតនៅក្នុងព្រះពុទ្ធសាសនាថេរវាទក៏ដោយ។

៤- ប្រពៃណីខ្មែរយើង បានចាក់ឫសយ៉ាងជ្រៅនៅក្នុងគំនិតរបស់យើង។ បច្ចេកទេស និងឧបករណ៍ទំនើបបំផុតសម្រាប់ការបោះបង្គោលដី ត្រូវបានវិស្វករ និងអ្នកបច្ចេកទេសប្រើដើម្បីបង្កើតសុរិយោដី ប៉ុន្តែគ្មាននរណាម្នាក់នឹកស្មានថានឹងកសាងវត្តមួយ ដែលមិនចាំបាច់ដាក់ «**សីមា**» ដែលគោរពតាមយ៉ាងពេញទំហឹង ប្រពៃណីនិងពិធីដែលមានអាយុកាលរាប់សតវត្សរ៍របស់យើងនោះទេ។

៥- ជារួម ភាពជាក់ស្តែងនិយមខ្មែរនៅចំពោះមុខឥទ្ធិពលបរទេស គឺជាទិដ្ឋភាពមួយនៃមូលដ្ឋានគ្រឹះដ៏សំខាន់ និងគួរឱ្យកត់សម្គាល់បំផុតនៃជីវិតនយោបាយនៅកម្ពុជា។ អត្ថបទស្តីពី «**ទស្សនទានរបស់លោកខាងលិចនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចំពោះមុខភាពជាក់ស្តែងនិយមខ្មែរ**»នេះ ផ្តោតសារៈសំខាន់ជាចម្បងៗលើពីរផ្នែក៖ ផ្នែកទីមួយ គឺការបង្កើតឡើងវិញនៃរបបរាជានិយម និងផ្នែកទីពីរ គឺបង្កើតរបបប្រជាធិបតេយ្យ សេរី ពហុបក្ស

ព្រមទាំងករណីពិសេសមួយចំនួនទៀត។

## ៤- ការបង្កើតឡើងវិញនៃរបបរាជានិយម ៖ «ឧបករណ៍អន្តរជាតិ ជម្រើសខ្មែរ»

១- យើងទាំងអស់គ្នាចងចាំពីឆន្ទៈ ភាពប៉ិនប្រសប់ និងភាពជាក់ស្តែងនិយមរបស់សមាជិកសភាធម្មនុញ្ញក្នុងឆ្នាំ១៩៩៣ ដែលបានឆ្លៀតឱកាសនៃភាពខ្វះខាត និងចន្លោះប្រហោងនៃបេសកកម្មរបស់អ៊ុនតាក់ (UNTAC) ដើម្បីចាប់បង្ខំឱ្យយកជម្រើសខ្មែរ។ ខណៈដែលកិច្ចព្រមព្រៀងក្រុងប៉ារីស គ្មានចែងពីរបបនយោបាយ ក្នុងអំឡុងពេលក្រោយពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣ រហូតដល់ពេលអនុម័តរដ្ឋធម្មនុញ្ញ អ្នកនយោបាយខ្មែរ បានសម្រេចចិត្តបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

២- នៅចុងបញ្ចប់នៃការបោះឆ្នោតសកលឆ្នាំ១៩៩៣ ដោយសារប្រព័ន្ធបោះឆ្នោតសមាមាត្រដែលកំណត់ដោយកិច្ចព្រមព្រៀងក្រុងប៉ារីស គ្មានគណបក្សនយោបាយណាមួយដែលមានសំឡេងភាគច្រើនពីរភាគបី ចាំបាច់សម្រាប់ការអនុម័តរដ្ឋធម្មនុញ្ញឡើយ។ គណបក្សប្រជាជនកម្ពុជា ជំទាស់ដោយសន្តិវិធីទៅនឹងលទ្ធផលនៃការបោះឆ្នោតដែលធ្វើឱ្យក្លាយជាគណបក្សលំដាប់ទីពីរ។ ខណៈនោះ ប្រទេសកម្ពុជាធ្លាក់ក្នុងវិបត្តិក្រោយការបោះឆ្នោត។

៣- វិបត្តិក្រោយការបោះឆ្នោត បង្កឱ្យមានការគំរាមកំហែងនៃសង្គ្រាមស៊ីវិលថ្មី។ ទោះបីជាមានការប្រឆាំងយ៉ាងខ្លាំងពីសហរដ្ឋអាមេរិក និងអរិភាពយ៉ាងខ្លាំងពីអ៊ុនតាក់ក៏ដោយ សម្តេចព្រះ នរោត្តម សីហនុ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) សម្រេចបានដោយជោគជ័យ ក្នុងការដាក់ចេញនូវគំនិតផ្តួចផ្តើមបង្កើតរដ្ឋាភិបាលចម្រុះបណ្តោះអាសន្នដើម្បីដោះស្រាយវិបត្តិនេះ ដែលត្រូវបានស្នើឡើងដោយគណបក្សប្រជាជនកម្ពុជា។ ជោគជ័យនេះ ស្តែងចេញតាមរយៈការបោះឆ្នោតជាឯកច្ឆន្ទរបស់សភាធម្មនុញ្ញនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ មួយថ្ងៃមុនការទទួលស្គាល់ជាផ្លូវការលទ្ធផលនៃការបោះឆ្នោតដោយអ៊ុនតាក់ នូវសេចក្តីសម្រេចមួយដែលបានលុបចោល ការបោះឆ្នោតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងប្រគល់ថ្វាយព្រះអង្គវិញនូវបុព្វសិទ្ធិជាប្រមុខរដ្ឋ។ ដំណោះស្រាយនេះ ដែលត្រូវបានគេវិនិច្ឆ័យថាគ្មានមូលដ្ឋានច្បាប់ នៅទីបំផុត ត្រូវបានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអនុម័តទទួលយក រួមជាមួយលទ្ធផលនៃការបោះឆ្នោត។

៤- នៅពេលនោះ សេចក្តីសម្រេចនេះ ជាបញ្ហាប្រឈមមួយដែលអ្នកនយោបាយខ្មែរបង្កើតឡើងដោយខ្លួនឯង ក្នុងការស្តារនីតិសម្បទាប្រមុខរដ្ឋ ដោយគ្មានមូលដ្ឋាន

ច្បាប់ណាមួយបានថែង និងក្នុងការចរចាសមាសភាពនៃរដ្ឋាភិបាលចម្រុះក្បាលពីរ ដែលចូលរួមដោយគណបក្សនយោបាយទាំងអស់ដែលមានតំណាងនៅក្នុងសភាធម្មនុញ្ញ។

៥- ការបញ្ចប់ប្រតិបត្តិការរបស់អ៊ុនតាក់ បញ្ជាក់ពីការទទួលយកមកកាន់កាប់ឡើងវិញនូវឆាកនយោបាយ ដោយអ្នកនយោបាយខ្មែរ តាមរយៈការសម្រុះសម្រួលព្រមព្រៀងគ្នាជាលក្ខណៈខ្មែរសុទ្ធសាធចំនួន៣ គឺការស្តាររបបរាជានិយមឡើងវិញការបោះឆ្នោតជ្រើសរើស សម្តេចព្រះ នរោត្តម សីហនុ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងការតែងតាំងនាយករដ្ឋមន្ត្រីពីររូប។

៦- គួររំលឹកផងដែរថា នៅក្នុងរយៈពេល២៣ខែ នៃបេសកកម្មរបស់អ៊ុនតាក់ នៅប្រទេសកម្ពុជា គំនិតនៃការបង្កើតរបបសាធារណរដ្ឋ ត្រូវបានលើកឡើងជាច្រើនដង។ អ្នកសង្កេតការណ៍លោកខាងលិចស្ទើរតែទាំងអស់ បានគាំទ្រគម្រោងនេះ។ អ្នកនយោបាយខ្មែរ មិនបានបង្ហាញការសាទរនឹងគម្រោងនេះទេ ប៉ុន្តែបានប្រកាសថាគាំទ្ររបបប្រជាធិបតេយ្យ សេរី និងពហុបក្ស។

៧- សំណើជាច្រើនស្តីពីការបង្កើតរបបសាធារណរដ្ឋ ត្រូវបានធ្វើឡើង រួមទាំងដោយសម្តេចព្រះ នរោត្តម សីហនុ ផងដែរ។ សេចក្តីសម្រេចចុងក្រោយក្នុងការបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែល«ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ» នឹងត្រូវធ្វើឡើងនៅថ្ងៃទី៣០ និង៣១ ខែសីហា ឆ្នាំ១៩៩៣ ដោយ សម្តេចព្រះ នរោត្តម សីហនុ និងតំណាងគណបក្សនយោបាយកម្ពុជាក្នុងអំឡុងពេលស្នាក់នៅមួយរយៈខ្លី និងការចរចាយ៉ាងផុសផុល នៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ជាកន្លែងដែលសម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គគង់នៅនាពេលនោះ។ អ្នកនយោបាយខ្មែរ និងដោយមានការចូលរួមពីថ្នាក់ដឹកនាំសាសនាកំពូលទាំងពីរ បានឈានដល់ការមូលមតិគ្នាទាំងស្រុងលើទម្រង់ នៃរបបប្រជាធិបតេយ្យ និងសេរីនិយម ដែលស្តាររាជានិយមឡើងវិញ។ សភាធម្មនុញ្ញបញ្ចប់បេសកកម្មរបស់ខ្លួនដោយប្រែក្លាយទៅជារដ្ឋសភា សម្តេចព្រះ នរោត្តម សីហនុ ក្លាយជាព្រះមហាក្សត្រកម្ពុជា សាជាថ្មីទៀត។

៨- ប្រទេសកម្ពុជា គឺជាប្រទេសដ៏វិសេសវិសាលមួយក្នុងន័យថា ជាប្រទេសមួយគត់នៅអាស៊ីដែលរបបរាជានិយមរាប់ពាន់ឆ្នាំ ត្រូវបានលុបបំបាត់ចោលដោយរដ្ឋប្រហារមួយនៅឆ្នាំ១៩៧០ ហើយនៅទីបញ្ចប់២៣ឆ្នាំក្រោយមកត្រូវបានបង្កើតឡើងវិញ។ ការស្តាររបបរាជានិយមឡើងវិញនៅឆ្នាំ១៩៩៣ ត្រូវបានអបអរសាទរដោយប្រជារាស្ត្រខ្មែរ ដែលចាត់ទុករដ្ឋប្រហារឆ្នាំ១៩៧០ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ជាបុព្វហេតុចម្បងនៃសំណាងអាក្រក់ និងគ្រោះមហន្តរាយដែលបានកើតឡើងជាបន្តបន្ទាប់។ ទីបំផុត

ព្រះមហាក្សត្រ បានយាងវិលត្រឡប់មកវិញ នឹងអាចធ្វើឱ្យយុគសម័យមាស (រុងរឿង) មានឡើងវិញ និងស្តារទំនៀមទម្លាប់និងប្រពៃណីខ្មែរឡើងវិញ។ "ទំនៀមទម្លាប់ល្អ"របស់ដូនតាទាំងនេះ ដែលផ្សារភ្ជាប់នឹងព្រះពុទ្ធសាសនា ក៏ជាធាតុដែលមានជាប្រចាំផងដែរនៅក្នុងរដ្ឋធម្មនុញ្ញ។

៩- ការវិលត្រឡប់នៃរបបរាជានិយម បានធ្វើឱ្យមានការលេចឡើងវិញនូវបរិយាកាសនៃ«ដំណើររស់ឡើងវិញនៃរដ្ឋធម្មនុញ្ញ» ជាពិសេស ការស្តារឡើងវិញនូវឧត្តមគតិកាលពីអតីតកាលមុនឆ្នាំ១៩៧០។ រាជានិយម គឺជាសក្ខីកម្មនៃសម័យកាលរុងរឿងនៃអរិយធម៌ខ្មែរ ដែលមានអាយុកាលរាប់ពាន់ឆ្នាំ។ ភាពរុងរឿងនេះ បានក្លាយជាធាតុសំខាន់នៃប្រពៃណីនយោបាយ ដែលនៅតែមានឥទ្ធិពលលើប្រជារាស្ត្រខ្មែរ។

១០- អតីតបាវចនា **«ជាតិ សាសនា ព្រះមហាក្សត្រ»** ត្រូវបានចែងនៅក្នុងមាត្រា៤នៃរដ្ឋធម្មនុញ្ញ។ ការត្រឡប់មកវិញនៃបាវចនានេះ បង្ហាញពីការកើតឡើងវិញនៃអំណាចរបស់ប្រពៃណី រួមទាំង ទង់ជាតិ ភ្លេងជាតិ ដែរ។

១១- ទោះបីជាគ្មានចងជាកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសក៏ដោយ ក៏សមាជិកសភាធម្មនុញ្ញ បានសម្រេចយក ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។ លក្ខន្តិកៈនេះ ត្រូវក្រុមប្រឹក្សាធម្មនុញ្ញ បញ្ជាក់នៅឆ្នាំ២០០៩។ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានពីរគណៈ គឺមហានិកាយ និងធម្មយុត្តិកនិកាយ។

១២- ការស្តាររបបរាជានិយមឡើងវិញ បានធ្វើឱ្យមានការរស់ឡើងវិញនូវប្រពៃណីរាជវង្សនៅព្រះបរមរាជវាំង។ ពិធីសាសនា ការវិលត្រឡប់នៃគណៈធម្មយុត្តិ បាគូ ពិធីសាសនាបុរាណ ការផ្តល់ងារ និងរង្វាន់លើកទឹកចិត្ត បានចូលរួមចំណែកក្នុងការធ្វើឱ្យតម្លៃរាជានិយមត្រូវបានចាក់ឫសសាជាថ្មីនៅក្នុងសង្គមខ្មែរ។ លើសពីនេះទៀត បុគ្គលិកលក្ខណៈរឹងមាំរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលមានភាពប៉ិនប្រសប់ក្នុងការប្រាស្រ័យទាក់ទងគ្រប់រូបភាព (BMD, Internet...) បានធ្វើឱ្យព្រះអង្គនៅចំកណ្តាលនៃឆាកនយោបាយខ្មែរ។ ព្រះអង្គ បានអញ្ជើញអង្គទូតបរទេស ឥស្សរជន សង្គមស៊ីវិល ឬថ្នាក់ដឹកនាំបរទេសដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា ចូលរួមក្នុងពិធីជប់លៀងសាយភោជន៍នៅព្រះបរមរាជវាំង។ នៅក្នុងពិធីទាំងនេះ ព្រះអង្គបានបង្ហាញពីទេពកោសល្យរបស់ព្រះអង្គជាច្រើនក្នុងនាមជាម្ចាស់ផ្ទះ។ ព្រះអង្គ បានផ្តល់នូវការអត្ថាធិប្បាយមួយចំនួនស្តីពីស្ថានការណ៍នយោបាយកម្ពុជា។ នៅព្រះបរមរាជវាំង ព្រះអង្គបានចែកព្រះរាជអំណោយដល់ប្រជារាស្ត្រក្រីក្រមកពីខេត្តនានា។ ប្រជាប្រិយភាពរបស់ព្រះអង្គ បានឡើងដល់កម្រិតកំពូល ព្រះអង្គតំណាងប្រទេសកម្ពុជាសាជាថ្មីម្តងទៀត។

១៣- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងនៅក្នុងមាត្រា ១៥៥ថ្មី ថារបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ និងប្រព័ន្ធប្រជាធិបតេយ្យ សេរី ពហុបក្ស មិនអាចត្រូវបានអនុញ្ញាតឱ្យធ្វើការសើរើ ឬវិសោធនកម្មបានឡើយ។ តើរបបប្រជាធិបតេយ្យ សេរី ពហុបក្ស ជារបបទំនើបយ៉ាងដូចម្តេច?

## ៥. ការបង្កើតរបបប្រជាធិបតេយ្យ សេរី ពហុបក្ស

១- នៅក្នុងប្រវត្តិសាស្ត្រសហស្សសម័យកម្ពុជា លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ត្រូវបានអនុវត្តជាលើកដំបូងនៅឆ្នាំ១៩៤៧ ដោយវិញ្ញូជនខ្មែរដែលទទួលការបណ្តុះបណ្តាលនៅប្រទេសបារាំង។ ប៉ុន្តែ លទ្ធិប្រជាធិបតេយ្យនាសម័យនោះមានអាយុកាលខ្លី គឺរហូតដល់ត្រឹមឆ្នាំ១៩៥២ប៉ុណ្ណោះ។ លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សតាមបែបលោកខាងលិច បានអនុវត្តនៅកម្ពុជាសាជាថ្មីម្តងទៀត ចាប់ពីឆ្នាំ១៩៩៣ មក។

២- តាមទស្សនៈបស្ចិមប្រទេស ប្រព័ន្ធប្រជាធិបតេយ្យសេរីនិយម និងពហុបក្ស ផ្តោតលើទស្សនទានបុគ្គលនិយម ដែលផ្អែកលើការការពារបុគ្គល។ ប្រជាធិបតេយ្យតំណាងរបស់លោកខាងលិចសង្កត់ធ្ងន់លើទិដ្ឋភាពស្ថាប័ន (សភា និងការបោះឆ្នោតដែលមានការប្រកួតប្រជែង ធានានូវសេរីភាពនៃការសម្រេចជម្រើស និងការទទួលបានព័ត៌មាន)។ ទាំងនេះមានន័យថា នៅក្នុងរបបប្រជាធិបតេយ្យទាំងអស់ រដ្ឋធម្មនុញ្ញ ត្រូវតែធានានូវសេរីភាពជាមូលដ្ឋាន (សេរីភាពនៃការគិត ការធានាប្រឆាំងនឹងការរំលោភបំពាន សេរីភាពសារព័ត៌មាន សេរីភាពនៃការជួបជុំ ។ល។) ការបំបែកអំណាច (អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ) ការបោះឆ្នោតជាសកល ការរៀបចំការបោះឆ្នោតដោយសេរី យុត្តិធម៌ និងពហុបក្ស។ នីតិវិធីនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញក៏ត្រូវតែមានចែង ព្រមទាំងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងការអនុម័តលទ្ធផលនៃការបោះឆ្នោត។

៣- គោលដៅចម្បងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺនាំមកនូវសន្តិភាពដល់ប្រទេសកម្ពុជា តាមរយៈការបង្កើតរបបប្រជាធិបតេយ្យ ដែលកើតចេញពីការបោះឆ្នោតទូទៅ។ រដ្ឋាភិបាលលោកខាងលិចទាំងនេះភាគច្រើន អះអាងទឡ្ហីករណ៍ពីរសម្រាប់លើកតម្កើងគោលនយោបាយប្រជាធិបតេយ្យរបស់ពួកគេ គឺ (១) សន្តិសុខសម្រាប់សហគមន៍អន្តរជាតិ និង (២) ស្ថិរភាពសម្រាប់សណ្តាប់ធ្នាប់សង្គម-នយោបាយជាតិ។ យោងទៅតាមសុន្ទរកថារបស់បស្ចិមប្រទេស ប្រទេសប្រជាធិបតេយ្យ ជាទូទៅ មិនធ្វើសង្គ្រាមនឹងគ្នាទេ។

៤- ក៏ប៉ុន្តែ យោងតាមអ្នកសង្កេតការណ៍អំពីជីវិតនយោបាយនៅកម្ពុជា ឧបសម្ព័ន្ធ ៥ នៃកិច្ចព្រមព្រៀងសម្រាប់ដំណោះស្រាយនយោបាយដែលមានគ្រប់ជ្រុងជ្រោយនៃជម្លោះនៅកម្ពុជា គឺជាការស្រមៃ ឬ រឿងប្រឌិតរវើរវាយសម្រាប់សង្គមខ្មែរស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់។

៥- ជាក់ស្តែង សម្រាប់លោក Jacques Nepote *«លើទិដ្ឋភាពវប្បធម៌ សង្គមខ្មែរគ្មានត្រូវបានបង្កើតឡើងដោយបុគ្គលទេ គឺដោយក្រុមគ្រួសារ។ យើងនឹងយល់នូវភាពមិនសមហេតុផល ល្ងង់ភ្លីភ្លើនៅក្នុងការចាប់បង្ខំឱ្យទទួលយកការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដោយផ្អែកលើសញ្ញាណរបស់បុគ្គលនៅក្នុងសង្គមខ្មែរនេះ»*។

៦- យោងលើភាពខុសគ្នាទាំងនេះ លទ្ធិប្រជាធិបតេយ្យពិតជាមានការលំបាកក្នុងការចាក់ឫសនៅក្នុងប្រទេសកម្ពុជា។

៧- យ៉ាងណាក៏ដោយ ភាពជាក់ស្តែងនិយមផ្នែកនយោបាយរបស់ថ្នាក់ដឹកនាំកម្ពុជា ទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យបែបបស្ចិមលោក ប្រែប្រួលទៅតាមការវិវឌ្ឍនៃស្ថានភាពនយោបាយរបស់ប្រទេស ដែលត្រូវបានសម្គាល់ជាបីដំណាក់កាល គឺ (១) មុនការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលកំណត់ដោយការបង្កើតច្បាប់ស្តីពីរបបប្រជាធិបតេយ្យ សេរី ពហុបក្ស (២) នីតិកាលទី១ នៃរដ្ឋសភាពីឆ្នាំ១៩៩៣-១៩៩៨ ត្រូវបានកត់សម្គាល់ដោយភាពយឺតយ៉ាវ ក្នុងការបង្កើតស្ថាប័នពាក់ព័ន្ធនឹងលទ្ធិប្រជាធិបតេយ្យ ហើយ (៣) បន្ទាប់ពីឆ្នាំ១៩៩៨ សម័យកាលដែលត្រូវបានកំណត់ដោយការពង្រឹងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ។

៨- នៅក្នុងអំឡុងពេលនៃការចរចាស្វែងរកសន្តិភាព និងពេលអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស អ្នកនយោបាយខ្មែរ ជាពិសេស សម្តេចព្រះ នរោត្តម សីហនុ ថ្នាក់មេដឹកនាំនៃគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាធិតេយ្យសេរីនិយមព្រះពុទ្ធសាសនា ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការដោះស្រាយជម្លោះនៅកម្ពុជា បានប្រកាន់យកជំហរជាក់ស្តែងនិយម ចំពោះលទ្ធិប្រជាធិបតេយ្យបែបបស្ចិមប្រទេស ដោយយោងតាមអត្ថប្រយោជន៍រៀងៗខ្លួន។

៩- នៅក្នុងនីតិកាលទី១នៃរដ្ឋសភា (១៩៩៣-១៩៩៨) ការបង្កើតស្ថាប័នប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញមានភាពយឺតយ៉ាវ។ ភាពយឺតយ៉ាវនេះ គឺដោយសារកង្វះអ្នកជំនាញជនជាតិខ្មែរ ការអនុម័តយឺតយ៉ាវ និងការផ្សព្វផ្សាយក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលចាំបាច់សម្រាប់ការរៀបចំការបោះឆ្នោត។ ច្បាប់ចំនួន៣ គឺច្បាប់បោះឆ្នោត ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់បង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបាន

រដ្ឋសភាអនុម័តនៅចន្លោះខែវិច្ឆិកា ឆ្នាំ១៩៩៧ និងខែមេសា ឆ្នាំ១៩៩៨។

១០- តាមរយៈការអនុវត្តកម្មវិធីនយោបាយ រាជរដ្ឋាភិបាលបន្តបន្ទាប់ បានរៀបចំការបោះឆ្នោតទៀងទាត់ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងទាញមេរៀនដើម្បីពង្រឹងដំណើរការលទ្ធិប្រជាធិបតេយ្យ។ វិសោធនកម្មច្បាប់បោះឆ្នោត និងបទប្បញ្ញត្តិច្បាប់ផ្សេងទៀត ត្រូវបានធ្វើឡើងដើម្បីធានាថា ការបោះឆ្នោតប្រព្រឹត្តទៅស្របតាមបទដ្ឋានដែលត្រូវបានទទួលស្គាល់នៅក្នុងពិភពលោក។

១១- ភាពជាក់ស្តែងនិយមខាងនយោបាយបែបនេះ ក៏ត្រូវបានគេសង្កេតឃើញមានក្នុងចំណោមប្រជាជនកម្ពុជាដែរ។ ចាប់តាំងពីឆ្នាំ១៩៩៣ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់មួយត្រូវបានគេមើលឃើញ ក្នុងចំណោមប្រជាជនកម្ពុជាលើការទទួលយកនូវសារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ។ ចាប់តាំងពីឆ្នាំ១៩៩៣ អត្រាចូលរួមការបោះឆ្នោតរបស់ប្រជាជនកម្ពុជា ត្រូវបានគេចាត់ទុកថា ស្ថិតក្នុងចំណោមប្រទេសដែលមានអត្រាខ្ពស់បំផុតនៅលើពិភពលោកសម្រាប់ប្រទេស ដែលការបោះឆ្នោត មិនមែនជាកាតព្វកិច្ច។ ចាប់ពីឆ្នាំ១៩៩៨ ក្នុងការបោះឆ្នោតជាតិជាបន្តបន្ទាប់ ប្រជាជនកម្ពុជា បានបង្ហាញឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តសិទ្ធិនយោបាយរបស់ពួកគេ និងចូលរួមក្នុងស្ថាប័នទាំងនេះ។ ទាំងនេះ គឺដោយសារសន្តិភាពកើតមានឡើងនៅទូទាំងប្រទេស ការកែលម្អបរិយាកាសសន្តិសុខ និងអហិង្សា ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត ដែលបង្ហាញការប្តេជ្ញាចិត្តនិងការសាទរកាន់តែខ្លាំងឡើងរបស់ប្រជាជនកម្ពុជា ក្នុងការចូលរួមក្នុងជីវិតនយោបាយ និងដំណើរការបោះឆ្នោត ទាំងផ្នែកអប់រំការបោះឆ្នោត និងការសង្កេតការណ៍បោះឆ្នោត តាមរយៈសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលព្រមទាំងការសង្កេតការបោះឆ្នោតនិងគណបក្សនយោបាយ។

១២- អាពាហ៍ពិពាហ៍រវាងប្រពៃណីនិងទំនៀមទម្លាប់រាប់ពាន់ឆ្នាំ ទាក់ទងនឹងរបៀបរបបអភិបាលកិច្ច និងតម្លៃទំនើបដែលនាំចូលនិងចាប់បង្ខំឱ្យអនុវត្តដោយសហគមន៍អន្តរជាតិ ជាពិសេស លទ្ធិប្រជាធិបតេយ្យ មិនបានដំណើរការទៅដោយរលូននោះទេ។ ហេតុដូច្នេះហើយបានជាមានការកើតឡើងនូវវិបត្តិនយោបាយនៅក្រោយការបោះឆ្នោតនីតិកាលនីមួយៗចាប់តាំងពីឆ្នាំ១៩៩៣មក។ កិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើងដោយមេដឹកនាំកម្ពុជាដើម្បីដោះស្រាយវិបត្តិទាំងនេះ និងគ្រប់គ្រងជោគវាសនារបស់ប្រទេសនេះដោយខ្លួនឯង។

## ៦- វិបត្តិនយោបាយក្រោយការបោះឆ្នោត

១- វិបត្តិនយោបាយក្រោយការបោះឆ្នោត និងភាពជាប់គាំងនយោបាយចាប់តាំងពីឆ្នាំ១៩៩៣ បានកើតឡើងស្ទើរតែគ្រប់ក្រោយការបោះឆ្នោតជ្រើសរើសសមាជិកសភាទាំងអស់។ វិបត្តិទាំងនេះ ត្រូវបានបង្កឡើងដោយៈ

ទី១- ការសម្រេចមិនបានជោគជ័យនូវការបង្រួបបង្រួមជាតិ ដោយសារតែក្រុមខ្មែរក្រហមមិនគោរពកិច្ចសន្យារបស់ពួកគេ។ ក្រឹត្យក្រមវិធានច្បាប់នៃការប្រកួតប្រជែងដែលទទួលយកដោយភាគីពាក់ព័ន្ធទាំងអស់ មិនអាចអនុវត្តបាន បរិយាកាសនៃការមិនទុកចិត្ត និងការតស៊ូដណ្ដើមឥទ្ធិពលរវាងតួអង្គនយោបាយនៅតែមានបន្ត។ ក្នុងផ្នត់គំនិតរបស់មេដឹកនាំនយោបាយខ្លះ វប្បធម៌នៃការសងសឹក ដែលគេស្គាល់ជាសុភាសិតថា «ពេលទឹកឡើង ត្រីស៊ីស្រមោច ពេលទឹកហោច ស្រមោចស៊ីត្រី» នៅតែមាន។ លើសពីនេះទៅទៀត អ្វីដែលដោតនៅក្នុងផ្នត់គំនិតខ្មែរ ជាពិសេស នៅក្នុងផ្នត់គំនិតរបស់មេដឹកនាំនយោបាយ គឺបញ្ហា«មុខមាត់»។ វិបត្តិនយោបាយក្រោយការបោះឆ្នោត ចាប់តាំងពីឆ្នាំ១៩៩៨មក បណ្ដាលមកពីយុទ្ធសាស្ត្រនយោបាយរបស់អ្នកនយោបាយខ្មែរ ដើម្បីកុំឱ្យ«បាក់មុខ» ដែលជាលក្ខណៈវប្បធម៌ខ្មែរមួយ មាននៅមុនសម័យកាលអាណានិគម គឺការប្រឆាំងជាប្រចាំនឹងព្រះមហាក្សត្រ និងការអំពាវនាវដល់ជនបរទេសឱ្យមកជួយ។

ទី២- អវត្តមាននៃកុងសង់ស៊ុសខាងប្រជាធិបតេយ្យ និងការចោទប្រកាន់ដល់យន្តការដំណើរការបោះឆ្នោត ជាពិសេស ភាពឯករាជ្យ និងអព្យាក្រឹតភាពរបស់ស្ថាប័នដែលទទួលខុសត្រូវចំពោះដំណើរការបោះឆ្នោតទាំងនេះ នៅរាល់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

ទី៣- វិធានរដ្ឋធម្មនុញ្ញ។ ភាពជាប់គាំងនយោបាយ នៅឆ្នាំ១៩៩៨ និង២០០៣ គឺដោយសារវិធាននៃសំឡេងភាគច្រើនពីរភាគបី ដែលមានចែងក្នុងមាត្រា៩០ និង៩៨ចាស់ នៃរដ្ឋធម្មនុញ្ញ រួមផ្សំជាមួយនឹងប្រព័ន្ធបោះឆ្នោត។ វិធាននៃសំឡេងភាគច្រើនពីរភាគបី ត្រូវបានធ្វើវិសោធនកម្មដោយប្ដូរមកសំឡេងភាគច្រើនដាច់ខាតនៅឆ្នាំ២០០៦។ ភាពតានតឹងផ្នែកនយោបាយ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ និងឆ្នាំ២០១៨ បណ្ដាលមកពីការបកស្រាយមាត្រា៧៦, ៧៨ និង៨២(ថ្មី) នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងការបង្កើតរាជរដ្ឋាភិបាល និងរដ្ឋសភា។ ច្បាប់រដ្ឋធម្មនុញ្ញ មិនត្រូវបានចារឹកយ៉ាងរឹងមាំនៅក្នុងស្មារតីរបស់មេដឹកនាំគណបក្សប្រឆាំងកម្ពុជាទេ។ ច្បាប់រដ្ឋធម្មនុញ្ញ គឺអាស្រ័យលើទំនាក់ទំនងរបស់ពួកគេចំពោះច្បាប់។ ពួកគេបកស្រាយវិធានរដ្ឋធម្មនុញ្ញ ទៅតាមផលប្រយោជន៍របស់ពួកគេ ដោយមិនអើពើនឹងការសម្រេចចិត្តរបស់ស្ថាប័នមានសមត្ថកិច្ចឡើយ។

២- វិបត្តិនិងភាពតានតឹងនយោបាយទាំងនេះ បានឈានដល់ "ដំណោះស្រាយបែបខ្មែរ" ដែលអាចត្រូវបានសង្ខេបថា ជាការចែករំលែកអំណាចរវាងភាគីបក្សនយោបាយ។

៣- «**ដំណោះស្រាយបែបខ្មែរ**» គឺជាការសម្រុះសម្រួលនយោបាយ ឬការសម្របសម្រួលដែលតួអង្គនយោបាយទាំងអស់ ទទួលបាននូវអត្ថប្រយោជន៍រៀងៗខ្លួន ការពិចារណាស្វែងរកច្រកចេញនៃវិបត្តិ ដោយមិនឱ្យ«បាក់មុខ» និងការគោរពគោលការណ៍ជាលក្ខណៈ«គ្រួសារ»។ ដំណោះស្រាយទាំងនេះ ស្ថិតនៅក្នុងបរិបទនៃស្ថានភាពអន្តរកាលបន្ទាប់ពីការបញ្ចប់នៃសង្គ្រាមរ៉ាំរ៉ៃ និងក្នុងក្របខ័ណ្ឌនៃការស្វែងរកការផ្សះផ្សាជាតិ ក៏ប៉ុន្តែពួកគេក៏គិតគូរពីឆន្ទៈនៃការការពារផលប្រយោជន៍នៃអំណាចសម្រាប់មេដឹកនាំនយោបាយផងដែរ។

៤- «ដំណោះស្រាយបែបខ្មែរ» ទាំងនេះ បានជះឥទ្ធិពលដល់ច្បាប់និងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយបង្កឱ្យមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ចាប់តាំងពីឆ្នាំ១៩៩៨ ស្ទើរតែគ្រប់ពេលក្រោយការបោះឆ្នោតជ្រើសរើសសមាជិកសភា។

៥- ដំណោះស្រាយសម្រុះសម្រួលនយោបាយឆ្នាំ១៩៩៣ បាននាំឱ្យមានករណីផ្លូវច្បាប់ដែលមិនធ្លាប់មានពីមុនមក នោះគឺការដាក់បញ្ចូលរដ្ឋាភិបាលចម្រុះក្បាលពីរក្នុងរដ្ឋធម្មនុញ្ញខែកញ្ញា ឆ្នាំ១៩៩៣ ជាអាទិ៍នៅក្នុងមាត្រា១៣៨ នៃជំពូកទី១៤ ស្តីពីបទប្បញ្ញត្តិអន្តរកាល។ ដំណោះស្រាយនេះ ជាដំណោះស្រាយសម្រាប់រយៈពេលខ្លីដើម្បីចេញផុតពីស្ថានភាពវិបត្តិ ដែលបង្កឡើងដោយលទ្ធផលនៃការបោះឆ្នោត ហើយដែលកើតឡើងពីភាពច្របូកច្របល់រវាងអ៊ុនតាក់ និងសមាជិកសភាធម្មនុញ្ញ រវាងប្រជាធិបតេយ្យពហុបក្ស និងការបែងចែកអំណាច ឬការបែងចែកផលប្រយោជន៍នៃអំណាច។ លទ្ធផលនៃការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ មិនត្រូវបានគេយកមកប្រើឡើយ។ ប្រធានរដ្ឋសភា ត្រូវបានប្រគល់ឱ្យគណបក្សភាគតិច។

៦- ចំពោះគំនិតលោកខាងលិច រដ្ឋាភិបាលចម្រុះក្បាលពីរបែបនោះ ដែលដាក់សត្រូវពីអតីតកាលនិងមានមនោគមវិជ្ជាខុសគ្នាខ្លាំងឱ្យធ្វើការជាមួយគ្នា គឺមិនអាចយល់បានទេ។ ក៏ប៉ុន្តែ ដំណោះស្រាយនេះ បានជួយឱ្យរាជរដ្ឋាភិបាលចម្រុះដែលមានក្បាលពីរ អាចបង្កើតឡើង ១១៩ថ្ងៃ បន្ទាប់ពីការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ ដើម្បីទទួលបានការគាំទ្រយ៉ាងទូលំទូលាយពីរដ្ឋសភា ដែលលេចចេញពីសភាធម្មនុញ្ញ។

៧- នៅឆ្នាំ១៩៩៨ សម្តេចព្រះ នរោត្តម សីហនុ សម្រេចបានជោគជ័យ ក្នុងការធ្វើឱ្យអ្នកប្រឆាំងគំនិតផ្តួចផ្តើមរបស់ព្រះអង្គ ទទួលយកនូវ«ប្រព័ន្ធសភាពីរ» ដែលជាផ្នែកមួយនៃធាតុផ្សំនៃដំណោះស្រាយរបស់ព្រះអង្គ។ នៅចុងបញ្ចប់នៃកិច្ចប្រជុំកំពូលក្រោម

ព្រះរាជាធិបតីភាពរបស់សម្តេចព្រះ នរោត្តម សីហនុ នៅព្រះបរមរាជវាំងនៅថ្ងៃទី១២ និង១៣ ខែវិច្ឆិកា - ឧទាហរណ៍នៃភាពជាក់ស្តែងនិយមខ្មែរ - ដែលថ្នាក់ដឹកនាំគណបក្សប្រជាជននិងហ៊្វុនស៊ិនប៉ិចតែប៉ុណ្ណោះបានចូលរួម កិច្ចព្រមព្រៀងមួយត្រូវសម្រេចរកបាន។ កិច្ចព្រមព្រៀងដែលមាន៣ទំព័រនេះ មានចំណងជើងថា «សេចក្តីថ្លែងការណ៍រួមស្តីពីគោលការណ៍នៃកិច្ចសហប្រតិបត្តិការ» មាន៨ចំណុច។ កិច្ចព្រមព្រៀងនេះបានប្រកាសអំពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបង្កើតសភាទី២ គឺ«ព្រឹទ្ធសភា»។ ប្រព័ន្ធសភាមួយរបស់កម្ពុជា បានក្លាយជាប្រព័ន្ធសភាពីរ។

៨- ប្រទេសកម្ពុជា បានចេញពីវិបត្តិដែលបានអូសបន្លាយអស់រយៈពេល ២ឆ្នាំ គឺឆ្នាំ១៩៩៧-១៩៩៩ ដោយសារការបោះឆ្នោតមួយ ដែលលោក Stephen SOLARZ (អតីតសមាជិកសភាអាមេរិក ដែលកាលពីឆ្នាំ១៩៧៩ ដល់១៩៩១ បានគាំទ្រជានិច្ចចំពោះ«ការតស៊ូរបស់ភាគីមិនមែនកុម្មុយនិស្ត») ហៅថា **«អព្ភូតហេតុលើទន្លេមេគង្គ»**។

៩- ព្រះរាជអន្តរាគមន៍របស់សម្តេចព្រះ នរោត្តម សីហនុ ដែលអាចជួយដោះស្រាយវិបត្តិនយោបាយ បានបង្កឱ្យមានការកត់សម្គាល់ និងការរិះគន់អំពីទំនាក់ទំនងរបស់អ្នកនយោបាយខ្មែរទៅនឹងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជាពិសេស ទាក់ទងនឹងការបង្កើតស្ថាប័នព្រឹទ្ធសភា។

១០- ការបង្កើតព្រឹទ្ធសភានេះ បានចោទជាសំណួរអំពីធម្មនុញ្ញភាពរបស់ស្ថាប័ននេះ ដោយសារគ្មានមូលដ្ឋានច្បាប់ និងមូលដ្ឋានប្រជាធិបតេយ្យទេ។ ព្រឹទ្ធសភា មិនត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ទេ លើសពីនេះទៀត នៅក្នុងរដ្ឋធម្មនុញ្ញ គ្មានមាត្រាណាដែលចែងពីការធ្វើវិសោធនកម្ម ដើម្បីផ្តល់ភាពត្រឹមត្រូវតាមច្បាប់ដល់ការចរចារវាងគណបក្សនយោបាយនោះទេ។ មូលហេតុនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ គឺមូលហេតុនយោបាយ។ វិធីសាស្ត្រនៃការបង្កើតព្រឹទ្ធសភានេះ និងការតែងតាំងសមាជិកព្រឹទ្ធសភា បានរំលោភគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ហើយផ្ទុយនឹងមាត្រា១៥៥ថ្មី ដែលចែងថា«ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើទៅបានឡើយកាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ»។ ទាំងនេះ មិនមែនជាការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសាមញ្ញតូចតាចទេ តែជាការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដ៏ធំនិងសំខាន់មួយ។ ចំពោះកិច្ចការនេះ ក្រុមប្រឹក្សាធម្មនុញ្ញ មិនបានផ្តល់យោបល់របស់ខ្លួនទេ ដោយសារគ្មានពាក្យបណ្តឹង។

១១- នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកសភាឆ្នាំ២០០៣ និងឆ្នាំ២០១៣ អ្នកនយោបាយខ្មែរ សម្រេចរកបាននូវការព្រមព្រៀងគ្នាលើរូបមន្តនៃ «ការបោះឆ្នោត

កញ្ចប់» នៅឆ្នាំ២០០៤ និងលើ «កិច្ចព្រមព្រៀងនយោបាយ» ក្នុងឆ្នាំ២០១៤ នៅក្រៅក្របខ័ណ្ឌនៃព្រះរាជអន្តរាគមន៍របស់ព្រះមហាក្សត្រ។

១២- **រូបមន្តនៃ«ការបោះឆ្នោតកញ្ចប់»ឆ្នាំ២០០៤៖** លុះដល់ពាក់កណ្តាលខែមីនា ទើបទំនាក់ទំនងក្រៅផ្លូវការរវាងសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេច ក្រុមព្រះ នរោត្តម រណឫទ្ធិ បានជួបប្រជុំទល់មុខគ្នា ដែលជាលទ្ធផល អនុញ្ញាតឱ្យបង្កើតក្រុមបច្ចេកទេសរវាងតំណាងនៃគណបក្សទាំងពីរ។ រហូតមកដល់ដើមខែមិថុនា កិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើងរវាង សម្តេច ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ លើនីតិវិធីជាក់លាក់ដែលគេហៅថា «ការបោះឆ្នោតកញ្ចប់» ដោយលើកដៃសម្រាប់កំណត់រចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងរដ្ឋាភិបាល អមដោយអនុស្សរណៈនៃការយោគយល់គ្នាដែលត្រូវបានចុះហត្ថលេខាដោយគណបក្សទាំងពីរនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤ រដ្ឋសភា បានអនុម័តច្បាប់ធម្មនុញ្ញបន្ថែមដើម្បីអនុញ្ញាតឱ្យការអនុវត្ត «ការបោះឆ្នោតកញ្ចប់»។ ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានព្រឹទ្ធសភាអនុម័តនៅថ្ងៃទី១២ ខែកក្កដា និងប្រកាសឱ្យប្រើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដោយ«ប្រធានព្រឹទ្ធសភាស្តីទី»។

១៣- **កិច្ចព្រមព្រៀងនយោបាយក្នុងឆ្នាំ២០១៤៖** ការចរចារវាងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចេញជាលទ្ធផល នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ នូវការសម្រុះសម្រួលព្រមព្រៀងមួយ ដែលបានបញ្ចប់ភាពតានតឹងនយោបាយ មួយឆ្នាំបន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកសភាខែកក្កដា ឆ្នាំ២០១៣។ ការសម្របសម្រួលនេះ ពាក់ព័ន្ធនឹងការទទួលយកដោយសមាជិកជាប់ឆ្នោតទាំង៥៥រូបនៃគណបក្សសង្គ្រោះជាតិ ដែលបានធ្វើពហិការមិនចូលរួមប្រជុំបើកសម័យប្រជុំរដ្ឋសភាក្នុងការមកអង្គុយជាមួយតំណាងរាស្ត្រ៦៨រូប នៃគណបក្សប្រជាជនកម្ពុជា។ គណបក្សទាំងពីរ បានឯកភាពគ្នាលើការធ្វើកំណែទម្រង់នៃដំណើរការបោះឆ្នោត ដែលនឹងត្រូវធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធដឹកនាំរបស់រដ្ឋសភា។

១៤- បន្ទាប់មកទៀត ដោយសារវប្បធម៌នយោបាយថ្មីនេះ មិនមានចែងក្នុងអត្ថបទច្បាប់ណាមួយឡើយ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី នៅខែសីហា ឆ្នាំ២០១៤ បានបង្កើត «វប្បធម៌សន្ទនា»។ អ្នកទាំងពីរ បានពន្យល់ថា មានវ័យកាន់តែចាស់ហើយ ត្រូវការកែតម្រង់គោលដៅក្នុងជីវិត ជាពិសេស ត្រូវតែយកចិត្តទុកដាក់ចំពោះអ្វីដែលអ្នកទាំងពីរចង់ទុកសម្រាប់មនុស្សជំនាន់ក្រោយ។ វប្បធម៌សន្ទនា

នេះ ជំនួសវប្បធម៌នៃការប្រឈមមុខ និងអំពើហិង្សាដែលកើតមានអស់ជាច្រើនទសវត្សរ៍មកហើយ។

១៥- ដំណោះស្រាយចំពោះវិបត្តិនយោបាយក្រោយការបោះឆ្នោត និងភាពតានតឹងខាងនយោបាយចាប់តាំងពីឆ្នាំ១៩៩៣ សម្រេចបានដោយសារអន្តរាគមន៍របស់ព្រះមហាក្សត្រ និងកិច្ចព្រមព្រៀងរវាងថ្នាក់ដឹកនាំ នៃគណបក្សនយោបាយនៅក្រោមព្រះរាជាធិបតីព្រះមហាក្សត្រ គឺសម្រុះសម្រួលខាងនយោបាយ «បែបខ្មែរ»៖ «រាជរដ្ឋាភិបាលចម្រុះក្បាលពីរ» «ការបង្កើតប្រព័ន្ធសភាពីរ» «ការបោះឆ្នោតកញ្ចប់» «ការសម្រុះសម្រួលផ្នែកនយោបាយ» និង «វប្បធម៌សន្ទនា»។ ការសម្រុះសម្រួលទាំងនេះ ដែលធាតុផ្សំនៃវប្បធម៌ ចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតខ្មែរ ដូចជា «មុខមាត់» និង «ក្រុមគ្រួសារ» បាននាំឱ្យមានការចែករំលែកអំណាច ជាជាងការពិចារណាដល់រដ្ឋធម្មនុញ្ញ ច្បាប់លទ្ធិប្រជាធិបតេយ្យ និងសេដ្ឋកិច្ចជាតិ។

១៦- វិបត្តិនយោបាយ ក្រោយការបោះឆ្នោតជ្រើសរើសសមាជិកសភានីមួយៗចាប់តាំងពីឆ្នាំ១៩៩៣មក បង្ហាញថា ចក្ខុវិស័យសមាជិកលោកខាងលិចនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងរបស់អ៊ុនតាក់សម្រាប់ពហុនិយមប្រជាធិបតេយ្យដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មិនត្រូវទៅនឹងភាពជាក់ស្តែងនៃស្ថានភាពកម្ពុជា។ ដំណោះស្រាយចំពោះវិបត្តិទាំងនេះ ស្ទើរតែនាំទៅរកការធ្វើវិសោធកម្មរដ្ឋធម្មនុញ្ញគ្រប់លើក។ ការធ្វើវិសោធកម្មទាំងនេះ បង្ហាញពីការពិតដែលថារដ្ឋធម្មនុញ្ញខ្វះក្របខ័ណ្ឌរឹងមាំមួយ។ វិបត្តិ និងភាពតានតឹងផ្នែកនយោបាយនីមួយៗ ផ្តល់នូវដំណោះស្រាយដែលនាំទៅដល់សម្របរដ្ឋធម្មនុញ្ញទៅនឹងស្ថានការណ៍វិវត្តនៃប្រទេសជាតិ និងការបង្កើតច្បាប់ (ច្បាប់ថ្មីត្រូវបានអនុម័តនិងប្រកាសឱ្យប្រើ)។ ដូច្នេះ ទិដ្ឋភាពទាំងនេះចូលរួមចំណែកពង្រឹងក្របខ័ណ្ឌគតិយុត្តនៃនីតិសាធារណៈកម្ពុជា។

១៧- ទោះយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានស្ថិរភាព បើប្រៀបធៀបទៅនឹងរដ្ឋធម្មនុញ្ញមុនៗទាំងអស់ដោយសារអត្ថិភាពរបស់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មិនត្រូវបានគំរាមកំហែងដោយវិបត្តិនយោបាយទេ។ ស្ថិរភាពនៃរដ្ឋធម្មនុញ្ញនេះ បានអនុញ្ញាតឱ្យប្រទេសកម្ពុជាមានស្ថិរភាពរបបនយោបាយ ស្ថាប័ននយោបាយទាំងមូល។

១៨- **ករណីនៃភាពជាក់ស្តែងនិយមដទៃទៀត** រួមមាន ៖ **ករណីក្រុមប្រឹក្សាធម្មនុញ្ញ** - បង្កើតឡើងក្នុងឆ្នាំ១៩៩៣ ក្រុមប្រឹក្សាធម្មនុញ្ញ ស្ថិតនៅក្នុងភាពស្ងប់ស្ងាត់រយៈពេល៥ឆ្នាំ មុនចាប់ផ្តើមដំណើរការ។ សូមបញ្ជាក់ថា ពីមុនមកប្រទេសកម្ពុជា មិនធ្លាប់មានស្ថាប័នដែលភារកិច្ចចម្បង គឺការពិនិត្យលើធម្មនុញ្ញភាពនោះទេ។ លក្ខណៈ

ជាក់ស្តែងនិយមមួយទៀត បានពន្យារពេលនៃដំណើរការរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺការខ្វះខាតនូវអ្នកច្បាប់មានសមត្ថភាពនៅឆ្នាំ១៩៩៣។ អ្នកជំនាញខាងច្បាប់ មិនអាចត្រូវបានបណ្តុះបណ្តាល ដោយការរៀនពេលល្ងាច បីបួនពេលនោះទេ។

១៩- តាមរយៈ**ការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់** ថ្នាក់ដឹកនាំកម្ពុជា បានរកឃើញដំណោះស្រាយជាក់ស្តែងចំពោះបញ្ហារដ្ឋធម្មនុញ្ញ នីតិរដ្ឋប្បវេណី និងនីតិរដ្ឋបាលបន្ទាន់ជាច្រើន ក្រោយការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ទោះបីជា ត្រូវបានគេរិះគន់យ៉ាងខ្លាំងចំពោះរបៀបរបបដំណើរការក៏ដោយ ប៉ុន្តែក្រុមប្រឹក្សាអ្នកច្បាប់ បានបំពេញការងារប្រកបដោយប្រសិទ្ធភាព ដោយបានដោះស្រាយសំណុំរឿងធំៗមួយចំនួនដែលមិនអាចរង់ចាំបាន។ ដោយសារភាពជាក់ស្តែងនិយមនេះហើយបានជាអាជ្ញាធរនានាដូចជា អាជ្ញាធរជាតិអប្សរា ឬក្រុមហ៊ុនសម្បទានព្រលានយន្តហោះ ត្រូវបានបង្កើតនិងប្រតិបត្តិការបាន។ ដោយសារក្រុមប្រឹក្សាអ្នកច្បាប់នេះហើយ បានជារាជរដ្ឋាភិបាលអាចរៀបចំសេចក្តីព្រាងច្បាប់នានា និងបញ្ជូនទៅរដ្ឋសភាដើម្បីអនុម័ត។ ជាចុងក្រោយដោយសារភាពជាក់ស្តែងនិយមនេះហើយ បានជាគុណតម្លៃខ្មែរ ត្រូវបានគោរពយ៉ាងល្អប្រសើរ ហើយប្រជាជនកម្ពុជា គាំទ្រនិងចូលរួមក្នុងគម្រោងនានាដែលបានស្នើឡើង។

២០- **ការមិនឱ្យមានការកាត់ទោសប្រហារជីវិត** មិនមែនជាកាតព្វកិច្ចដែលបានចែងដោយអ្នកនិពន្ធលោកខាងលិចនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសទេ ប៉ុន្តែ សមាជិកសភាធម្មនុញ្ញខ្មែរ បានចែងនៅក្នុងសេចក្តីព្រាងច្បាប់កំពូល ដោយសារការចែងមិនឱ្យមានទោសប្រហារជីវិតនៅក្នុងរដ្ឋធម្មនុញ្ញ ទទួលបានកិត្យានុភាពអន្តរជាតិ និងការទទួលស្គាល់ទូទាំងពិភពលោក ចំពោះកេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជា។

២១- សំណុំរឿងមួយទៀត បានបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការឱ្យគេទទួលយកទស្សនៈរបស់ខ្លួន **គឺការរៀបចំសាលាក្តីដើម្បីកាត់ទោស «អតីតមេដឹកនាំខ្មែរក្រហមសំខាន់ៗ»**។ ការចរចាជាមួយអង្គការសហប្រជាជាតិអស់រយៈពេលយូរ និងពោរពេញដោយភាពលំបាកស្មុគស្មាញ ប៉ុន្តែថ្នាក់ដឹកនាំកម្ពុជា អាចគ្រប់គ្រងដំណើរការជំនុំជម្រះនេះបាន។ តាមពិត សំណុំរឿងនេះ អាចបង្កហានិភ័យនយោបាយច្រើនណាស់ដូចជាការបែកបាក់ឯកភាពជាតិ ប្រទេសធ្លាក់ក្នុងសភាពអសន្តិសុខ។ ប្រទេសកម្ពុជាដែលមានអធិបតេយ្យ មិនអាចបណ្តែតបណ្តោយទុកសំណុំរឿងដ៏សំខាន់នេះផុតពីដៃរបស់ខ្លួនបានឡើយ។

២២- **សិទ្ធិមនុស្ស** គឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ នៅឆ្នាំ១៩៩៣ អ្នកនិពន្ធលោកខាងលិចនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស មានបំណងចង់ឱ្យ

ប្រទេសកម្ពុជាក្លាយជារដ្ឋគំរូមួយទាក់ទងនឹងសិទ្ធិមនុស្ស។ ជំពូកទី៣នៃរដ្ឋធម្មនុញ្ញ បាន ចែងពីសិទ្ធិទាំងនេះ។ ជំពូកនេះ មាន២០មាត្រា ដែលចែងពីសិទ្ធិទាំងអស់របស់បុរស ស្ត្រី និងកុមារ។ តើមានការចាំបាច់ត្រូវរំលឹកពីការភ្ញាក់ផ្អើល របស់ប្រជាជនកម្ពុជាមួយភាគធំ ដែលមិនយល់ថា តើប្រទេសដែលគាំទ្ររបបខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៣ អាចការពារ សិទ្ធិមនុស្សយ៉ាងដូចម្តេច? ជាថ្មីម្តងទៀត ភាពជាក់ស្តែងនិយមរបស់ខ្មែរ បានជួយឱ្យ យល់ពីរឿងនេះ នោះគឺ សិទ្ធិនៅម្ខាង ហើយការអនុវត្តសិទ្ធិនៅម្ខាងទៀត ឬស្តង់ដារពីរ។

២៣- សញ្ញាណរបស់លោកខាងលិចនៃគោលការណ៍អំណាច និងគោលការណ៍ បែងចែកអំណាច មានលក្ខណៈផ្ទុយទាំងស្រុងជាមួយប្រពៃណីរាជានិយមរបស់ខ្មែរ។ គោលការណ៍ទាំងនេះ គឺជាការច្រានចោលនូវគុណលក្ខណៈរបស់ព្រះមហាក្សត្រខ្មែរ។ ប្រជាជនកម្ពុជាទទួលយកគោលការណ៍អំណាច និងគោលការណ៍បែងចែកអំណាច ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែ ស្នើសុំនូវពេលវេលាមួយរយៈកាលដើម្បីសម្រប ទៅនឹងតថភាពជាក់ស្តែងខ្មែរ។

## សេចក្តីសន្និដ្ឋាន

១- ជាសេចក្តីសន្និដ្ឋាន ខ្លឹមសារសំខាន់ទី១នៃប្រធានបទនេះ គឺមោទនភាព ដែល ប្រជាជនខ្មែរ អាចទាញយកពីអត្តសញ្ញាណជាតិរបស់ខ្លួន បន្ទាប់ពីពួកគេរៀនយល់ច្បាស់ អំពីប្រវត្តិសាស្ត្រដ៏យូរអង្វែង អរិយធម៌ និងប្រពៃណីរបស់ខ្លួន។

២- ការលុបចោលរដ្ឋប្រហារឆ្នាំ១៩៧០ គឺជាគោលដៅមួយក្នុងចំណោមគោល ដៅសំខាន់របស់សមាជិកសភាធម្មនុញ្ញ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣។ អ្នកនយោបាយ ខ្មែរ សម្រេចកិច្ចការនេះបានដោយសេចក្តីសម្រេចចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ដែលនឹងលុបចោលការបោះឆ្នោតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយ ថ្វាយបុព្វសិទ្ធិ ជាប្រមុខរដ្ឋដល់សម្តេចព្រះ នរោត្តម សីហនុ ឡើងវិញ។ ការស្តារនីតិសម្បទានេះ ទទួល បាននូវការអបអរសាទរយ៉ាងខ្លាំង មិនមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសទេ។

៣- ការប្តេជ្ញាចិត្តរបស់ប្រជាជនកម្ពុជា បានអនុញ្ញាតឱ្យការរៀបចំការបោះឆ្នោត នៅឆ្នាំ១៩៩៣ ត្រូវបានចាត់ទុកថាអាចទទួលយកបាន។ សម្រាប់ប្រទេសមួយដែល លេចចេញពីគំនរផេះផង់ សមិទ្ធផលនេះគឺបានដោយសារគតិបណ្ឌិតរបស់ប្រជាជនខ្មែរ ទាំងមូល។ ប្រជាជនខ្មែរ សម្រេចបានជោគជ័យក្នុងការធ្វើសំយោគនូវឆន្ទៈរបស់រដ្ឋ បរទេស ដែលបានជួយពួកគេក្នុងការងើបឈរឡើងវិញ និងស្តារឡើងវិញនូវប្រពៃណី និងគុណតម្លៃរបស់ខ្លួន។ ការសំយោគបញ្ចូលគ្នានេះហើយ ដែលបានឱ្យខ្មែរយើងកសាង

ឯកភាពជាតិឡើងវិញ និងបានដោះស្រាយវិបត្តិនយោបាយនានាដែលបណ្តាលមកពីគុណវិបត្តិនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

៤- ខ្លឹមសារសំខាន់ទី២ គឺថា ភាពជាក់ស្តែងនិយមខ្មែរ បានអនុញ្ញាតឱ្យមានការអនុម័តច្បាប់កំពូលមួយ ការបង្កើតរាជរដ្ឋាភិបាលដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាដោយជោគជ័យ ទៅក្នុងតំបន់និងពិភពលោក ជោគជ័យរបស់កម្ពុជាក្នុងកិច្ចការអភិបាលកិច្ចប្រជាធិបតេយ្យ និងការបន្តនៃវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម។

៥- ជាទីបញ្ចប់ ដើម្បីកុំឱ្យភ្លេច មេរៀននេះ ត្រូវតែយកទៅបង្រៀន។ ដូច្នេះ ស្ថាប័នកំពូលរបស់យើង គួរធ្វើការអប់រំ ផ្សព្វផ្សាយ តម្លៃប្រពៃណីរបស់យើង ដែលជាមូលដ្ឋានគ្រឹះនៃប្រវត្តិសាស្ត្រ និងអរិយធម៌រុងរឿងរបស់ខ្មែរយើង។

## ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងច្បាប់ស្តីពីវិសោធនកម្មនៃរដ្ឋធម្មនុញ្ញបន្តបន្ទាប់។

Chhiv Yiseang. Le travail gouvernemental au Cambodge de 1993 à 2015. Droit. Université Paris sciences et lettres, 2017. Français. (និក្ខេបបទបណ្ឌិតនីតិសាធារណៈ ជាភាសាបារាំង)។

# គុណតម្លៃនីតិរដ្ឋធម្មនុញ្ញក្នុងបច្ចុប្បន្នភាពសង្គមកម្ពុជា

ឯកឧត្តមបណ្ឌិត ឈឹម ផលវរុណ

## ១- ចរិតលក្ខណៈជាមូលដ្ឋានគន្លឹះនៃការសម្រេចបាននូវរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

ដំណើរឆ្ពោះទៅសម្រេចបាននូវសមិទ្ធផលរដ្ឋធម្មនុញ្ញ សម្រាប់យុគសម័យថ្មី របស់ប្រជាជាតិកម្ពុជា បានបង្ហាញជាជំហានៗអំពីសច្ចភាពប្រវត្តិសាស្ត្រនៃការផ្សះផ្សាបង្រួបបង្រួមជាតិ។ ជំហានដំបូង គឺក្នុងខណៈ **សម្តេចតេជោ** ត្រូវបានគណបក្សប្រជាជនកម្ពុជា និងសភាជាតិ ផ្តល់សេចក្តីទុកចិត្តប្រគល់តួនាទីជា ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងឆ្នាំ១៩៨៥ ពេលនោះ ការផ្សះផ្សាបង្រួបបង្រួមជាតិ បានចាប់ចេញដំណើរ ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបោះដៃស្វះស្វែងរកការចរចាបញ្ចប់ជម្លោះប្រដាប់អាវុធជាមួយ **សម្តេចព្រះនរោត្តម សីហនុ** ប្រធានរដ្ឋាភិបាលត្រីភាគីនិរទេសជាភាគីខ្មែរម្ខាងទៀត។ ជាសច្ចភាពប្រវត្តិសាស្ត្រ គឺការចរចានេះ ផ្តើមចេញពីខ្មែរខ្លួនឯង ប្រកបដោយឧត្តមគតិបញ្ចប់ជម្លោះប្រដាប់អាវុធ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ នៃការទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍។ បើទោះបីជាដំណើរនៃការចរចានេះ មានភាពស្មុគស្មាញ ដោយកត្តាជាច្រើនក្តី តែទីបំផុតការចរចានេះ បានផ្តល់នូវសមិទ្ធផលកត់ត្រាទុកជាប្រវត្តិសាស្ត្រ គឺកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយសម្រាប់ជម្លោះកម្ពុជា ដែលគ្រប់ភាគីទំនាស់ខ្មែរ និងភាគីបរទេសពាក់ព័ន្ធ បានចុះហត្ថលេខាជាឱឡារិក នៅទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ទន្ទឹមនឹងនេះ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយសម្រាប់ជម្លោះកម្ពុជា បានក្លាយជាលិខិតូបករណ៍នៃការចាប់ផ្តើមកសាងកម្ពុជាថ្មីមួយ។ ពាក្យថា **កម្ពុជាថ្មី** គឺកិច្ចព្រមព្រៀងក្រុងប៉ារីស បានផ្តោតទៅលើដំណើរការនៃការកសាងឱ្យបានសម្រេចនូវ **រដ្ឋធម្មនុញ្ញថ្មីមួយ** ជាច្បាប់កំពូលរបស់ប្រទេស។ ក្នុងវត្ថុបំណងនេះ គឺចំណុចស្នូលដំបូងបង្អស់នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ផ្តោតសំខាន់លើដំណើរការរៀបចំការបោះឆ្នោត សភាធម្មនុញ្ញដែលមានតម្លៃ ជាការផ្តល់នីត្យានុកូលភាពប្រជាធិបតេយ្យពីប្រជាជនកម្ពុជា ដើម្បីឱ្យអង្គការនេះបំពេញធុរកិច្ចតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយសម្រាប់កម្ពុជា ក្នុងការបើកសករាជថ្មី។ ទន្ទឹមនឹងនេះដែរ គឺការតាក់តែងរដ្ឋធម្មនុញ្ញនេះ ត្រូវផ្អែកលើគោលការណ៍គ្រឹះមួយចំនួនដែលបានកំណត់ទុកជាស្រេចក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងក្រុងប៉ារីស។

## ២- គុណតម្លៃសន្តិភាពនៃនីតិរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

បុព្វកថា នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានឱ្យតម្លៃខ្ពស់បំផុតចំពោះ **គុណតម្លៃសន្តិភាព** ដែលជា គុណតម្លៃស្នូលដំបូងបង្អស់នៃនីតិរដ្ឋធម្មនុញ្ញកម្ពុជា ក្នុងការតាក់តែងបទប្បញ្ញត្តិដោយឡែកៗជាជំពូក និងជាមាត្រា។ ជាមួយនឹងការរំលេចនូវ **គុណតម្លៃសន្តិភាព** គឺបុព្វកថានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានរំលឹកអំពីអតីតកាលរបស់ប្រជាជាតិខ្មែរ និងការប្ដេជ្ញាចិត្តសម្រាប់បច្ចុប្បន្នកាល និងទៅអនាគតកាល ដែលឈរលើស្មារតីយកគុណតម្លៃសន្តិភាព គឺជា **គ្រឹះ** នៃនីតិរដ្ឋធម្មនុញ្ញកម្ពុជាក្នុងយុគសម័យថ្មី។ ឈរលើមូលដ្ឋាននេះ គឺគុណតម្លៃផ្សេងៗទៀតដែលបញ្ញត្តដោយឡែកៗក្នុងជំពូកនីមួយៗនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចាំបាច់ធានារក្សាសន្តិភាពឱ្យមានចីរភាព ដោយកំណត់អំពីឋានៈ និងលក្ខណសម្បត្តិរដ្ឋ ជារដ្ឋឯករាជ្យ អធិបតេយ្យ, អំពីឋានៈប្រជាពលរដ្ឋជាម្ចាស់នៃការកំណត់ជោគវាសនាជាតិ ពោលគឺអធិបតេយ្យប្រជាពលរដ្ឋរួមទាំងសិទ្ធិ និងករណីយកិច្ច, អំពីរបបនយោបាយ និងរបបសេដ្ឋកិច្ច, អំពីទម្រង់នៃការរៀបចំរដ្ឋ, ទម្រង់នៃការគ្រប់គ្រងរដ្ឋ និងអង្គការរដ្ឋ ជាមួយនឹងគោលការណ៍បែងចែកអំណាច, គោលការណ៍ប្រជាធិបតេយ្យ និងគោលការណ៍នីតិរដ្ឋ។

## ៣- ឋានៈ និងលក្ខណសម្បត្តិរដ្ឋ ឆ្លើយតបនឹងគុណតម្លៃសន្តិភាព នៃនីតិរដ្ឋធម្មនុញ្ញ

ជាច្បាប់គោលរបស់ប្រទេសជាតិ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបញ្ញត្តអំពី ឋានៈរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ (មាត្រា១ វាក្យខ័ណ្ឌ២)។ នីតិរដ្ឋធម្មនុញ្ញនេះ ជាការបញ្ជាក់អំពីគន្លឹះចម្បងឆ្លើយតបនឹងស្មារតីសន្តិភាព នៃរដ្ឋធម្មនុញ្ញ។ ក្នុងឋានៈជា រដ្ឋឯករាជ្យ អធិបតេយ្យ គឺជារដ្ឋស្មើភាព និងស្មើមុខជាមួយនឹងបណ្ដារដ្ឋនានាទាំងឡាយលើសកលលោក ដែលជាសមាជិកអង្គការសហប្រជាជាតិ ហើយអំណាចកំពូលតំណាងឱ្យ អធិបតេយ្យរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា គឺ **អង្គព្រះមហាក្សត្រ** ទ្រង់ជាព្រះប្រមុខរដ្ឋរបស់ប្រជាជាតិកម្ពុជា។

ដើម្បីធានាបាននូវ អធិបតេយ្យរដ្ឋ ក្នុងបរិបទនៃនយោបាយក្រៅប្រទេស គឺរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ **លក្ខណសម្បត្តិរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ក្នុងទំនាក់ទំនងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ នីតិរដ្ឋធម្មនុញ្ញនេះ បញ្ជាក់អំពីគន្លឹះចម្បង ក្នុងការទប់ស្កាត់កម្ពុជា មិនឱ្យស្ថិតក្នុងប្លុកណាមួយ ឬនៅក្នុងភូមិសាស្ត្រនយោបាយនៃមហាអំណាច

ណាមួយឡើយ ជាមួយនឹងគោលការណ៍សំខាន់មួយចំនួន មានជាអាទិ៍ ៖

(១) គោលការណ៍រួមរស់ដោយសន្តិសហវិជ្ជមាន ជាមួយនឹងប្រទេសជិតខាង និងបណ្តាប្រទេសទាំងអស់លើពិភពលោក (មាត្រា ៥៣),

(២) គោលការណ៍គោរពផលប្រយោជន៍គ្នាទៅវិញទៅមក ដោយមិនផ្អែកលើប្រព័ន្ធនយោបាយនៃប្រទេសនីមួយៗ,

(៣) គោលការណ៍មិនជ្រៀតជ្រែក/លូកលាន់កិច្ចការផ្ទៃក្នុងប្រទេសដទៃ,

(៤) គោលការណ៍សហប្រតិបត្តិការស្មើមុខ និងស្មើសិទ្ធិ។

ក្នុងបរិបទនៃនយោបាយក្នុងប្រទេស គឺរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់អំពី **លក្ខណសម្បត្តិរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យ (មាត្រា១ វាក្យខ័ណ្ឌ២)។ បន្ថែមលើលក្ខណសម្បត្តិនេះ រដ្ឋធម្មនុញ្ញ បានទទួលស្គាល់ អធិបតេយ្យប្រជាជន ដោយបញ្ញត្តក្នុងមាត្រា៥១ វាក្យខ័ណ្ឌ២ ថា៖ "ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន"។ ធម្មនុញ្ញបញ្ញត្តិនេះ មានន័យចំពោះ **លក្ខណសម្បត្តិរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជាជា រដ្ឋឯករាជ្យ អធិបតេយ្យផង និងជា រដ្ឋប្រជាធិបតេយ្យផង។ ដោយឡែកចំពោះ **លក្ខណសម្បត្តិរដ្ឋ** ជារដ្ឋប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញបានបញ្ជាក់បន្ថែមអំពី ប្រជាធិបតេយ្យបែបតំណាង ដែល"អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ" ហើយ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈអង្គការរដ្ឋនៃអំណាចនីតិប្បញ្ញត្តិ មានរដ្ឋសភា និង ព្រឹទ្ធសភា, អង្គការនៃអំណាចនីតិប្រតិបត្តិ គឺរាជរដ្ឋាភិបាល និងអង្គការរដ្ឋនៃអំណាចយុត្តាធិការ មានតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ (មាត្រា៥១ វាក្យខ័ណ្ឌ៣ និង៤ ភ្ជាប់ជាមួយនឹងមាត្រា១២៨ថ្មីវាក្យខ័ណ្ឌ៤)។ ទន្ទឹមហ្នឹងនេះផងដែរ ផ្អែកលើ ប្រជាធិបតេយ្យបែបតំណាង គឺរដ្ឋធម្មនុញ្ញ បានបញ្ញត្តរៀបចំទម្រង់គ្រប់គ្រងប្រទេសកម្ពុជា ជា **រាជានិយមធំនើប** បែបប្រជាធិបតេយ្យសភានិយម ដែលភាពជាតំណាង ផ្តើមចេញពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៥ឆ្នាំម្តងៗ ដែលជាប្រភពនៃតម្លៃ ចំពោះការផ្តល់នីត្យានុកូលភាពនៃអំណាចប្រជាធិបតេយ្យដោយផ្ទាល់ពីប្រជាពលរដ្ឋខ្មែរ តាមគោលការណ៍ អធិបតេយ្យប្រជាជន។

## ៤- ទម្រង់នៃការរៀបចំរដ្ឋ និងរបបនយោបាយ ឆ្លើយតបនឹងគុណតម្លៃសន្តិភាពនៃនីតិរដ្ឋធម្មនុញ្ញ

ដូចបានលើកឡើងខាងលើគឺរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបញ្ញត្តរៀបចំប្រទេសកម្ពុជា ក្នុងទម្រង់គ្រប់គ្រង ជា**រាជានិយមធំនើប** បែបប្រជាធិបតេយ្យសភានិយម។

នីតិរដ្ឋធម្មនុញ្ញនេះ គឺពិតជាផ្អែកលើប្រវត្តិសាស្ត្រ, វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់, ផ្នត់គំនិតនៃការគិតរបស់ប្រជាជន ជាមួយនឹងល័ក្ខខ័ណ្ឌពិសេស និងកម្រិតរីកចម្រើនរបស់សង្គមជាតិ ជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ដំណើរការប្រជាធិបតេយ្យូបនីយកម្ម នៃការរៀបចំរដ្ឋ។ **រាជានិយមទំនើប** ក្នុងស្មារតីនៃនីតិរដ្ឋធម្មនុញ្ញកម្ពុជា គឺ "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ "(មាត្រា៧ វាក្យខ័ណ្ឌ១)។ ពោលគឺ ក្នុងព្រះរាជតួនាទីជា ព្រះប្រមុខរដ្ឋ ក្នុងរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និងប្រព័ន្ធសភានិយម គឺ**ព្រះមហាក្សត្រ** ជាអង្គអព្យាក្រឹតពីអំណាចនយោបាយ ដើម្បីគង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ, ទ្រង់ជាអ្នកធានាឯករាជ្យជាតិ, អធិបតេយ្យ និងបូរណភាពទឹកដី, ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ, ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាលដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ និងទ្រង់ជាអ្នកធានាឯករាជ្យ នៃអំណាចតុលាការ (មាត្រា៨, មាត្រា៩ និងមាត្រា១៣២)។

បរិបទនៃ **របបនយោបាយ** ប្រជាធិបតេយ្យសេរីពហុបក្ស គឺជាផ្នែកមួយនៃគុណតម្លៃរបស់នីតិរដ្ឋធម្មនុញ្ញ ចំពោះ **សន្តិភាព** ដែលប្រជាពលរដ្ឋខ្មែរទូទៅ និងគ្រប់និន្នាការនយោបាយខុសៗគ្នា អាចរួមរស់ជុំគ្នាក្នុងសហគមន៍ជាតិតែមួយជាមួយគ្នា ដោយបញ្ចេញទស្សនៈនយោបាយផ្សេងៗគ្នា ក្នុងដំណើរការបង្កើតឆន្ទៈនយោបាយ, ដំណើការសម្តែងឆន្ទៈនយោបាយ និងដំណើរការសម្រេចឆន្ទៈនយោបាយ ប្រកបដោយវប្បធម៌នយោបាយ និងការទទួលខុសត្រូវក្នុងក្របខ័ណ្ឌច្បាប់ ផ្អែកលើគោលការណ៍នីតិរដ្ឋ។ ទន្ទឹមនឹងរបបនយោបាយ គឺរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បញ្ញតថាកម្មសិទ្ធិឯកជនស្របច្បាប់បិតនៅក្រោមការគាំពារនៃច្បាប់ (វាក្យខ័ណ្ឌ២ មាត្រា៤៤) ដែលជាចំណុចគន្លឹះ, ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (មាត្រា៥៦ វាក្យខ័ណ្ឌ១)។

## ៥- សិទ្ធិ និងករណីយកិច្ចពលរដ្ឋ លើគុណតម្លៃនៃនីតិរដ្ឋធម្មនុញ្ញ ក្នុងការរក្សាសន្តិភាព

ផ្អែកលើ របបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និង របបសេដ្ឋកិច្ចទីផ្សារ គឺបង្ហាញអំពីយុគសម័យថ្មីរបស់ប្រជាជាតិកម្ពុជា ជាមួយនឹងការបើកទំព័រនៃ សង្គមសេរី ដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទទួលស្គាល់ **សិទ្ធិគោល** របស់បុគ្គលគ្រប់រូប ពោលគឺមានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿសាសនា, និន្នាការនយោបាយ, ដើមកំណើតជាតិ, ឋានៈសង្គម,

ធនធាន ឬស្ថានភាពឯទៀតឡើយ (មាត្រា៣១ វាក្យខ័ណ្ឌ២ ឃ្លាទី១)។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញ បានបញ្ញត្តនូវគោលការណ៍ **នីតិរដ្ឋ៖** ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ (មាត្រា៣៨ វាក្យខ័ណ្ឌ២)។ ផ្អែកលើគោលការណ៍នីតិរដ្ឋនេះ គឺរដ្ឋធម្មនុញ្ញ បានកម្រិតព្រំដែននៃការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព រួមទាំងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលដទៃ ដោយថ្នូរតម្រូវឱ្យការប្រើសិទ្ធិសេរីភាព ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ (មាត្រា៣១ វាក្យខណ្ឌ២ ឃ្លាទី២ និងទី៣ និងមាត្រា៣៨ វាក្យខ័ណ្ឌ២)។ នេះជាគោលការណ៍នីតិរដ្ឋនៃការប្រើសិទ្ធិសេរីភាពរបស់បុគ្គល ក្នុងគុណតម្លៃរក្សាសន្តិភាព។ ភ្ជាប់ជាមួយនឹងគោលការណ៍នីតិរដ្ឋនេះ រដ្ឋធម្មនុញ្ញ បានបញ្ញត្តឱ្យរាជរដ្ឋាភិបាល ត្រូវការពារនីត្យានុកូលភាព, ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ (មាត្រា៥២ ឃ្លាទី២)។

## ៦- ធម្មនុញ្ញភាព ក្នុងការរក្សាគុណតម្លៃនៃនីតិរដ្ឋធម្មនុញ្ញ

ដើម្បីធានាបាននូវឋានៈរដ្ឋធម្មនុញ្ញ ជា **ច្បាប់គោល** លុះត្រាតែ **រដ្ឋធម្មនុញ្ញ** មានឋានៈស្ថិតនៅជាកំពូលនៃប្រព័ន្ធច្បាប់ មានន័យថា ច្បាប់កំពូល និងដើរតួជាគ្រឹះនៃប្រព័ន្ធច្បាប់ មានន័យថាជា ច្បាប់គ្រឹះ។ ដូច្នេះហើយរាល់អត្ថបទចែងក្នុងរដ្ឋធម្មនុញ្ញ និងប្រសិទ្ធភាពនៃការអនុវត្ត ត្រូវធានាឱ្យមាន **ធម្មនុញ្ញភាព** មាន៖ ១) ធម្មនុញ្ញភាពនៃច្បាប់ (រាប់ទាំងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់) និង ២) ធម្មនុញ្ញភាពនៃទង្វើ របស់អំណាចរដ្ឋ និងគណបក្សនយោបាយ។ យន្តការធានាការពារធម្មនុញ្ញភាពនេះ គឺ **អំណាចយុត្តាធិការធម្មនុញ្ញ** ដែលនៅប្រទេសខ្លះ គឺមានតុលាការធម្មនុញ្ញ ឬក្រុមប្រឹក្សាធម្មនុញ្ញ ដូចជាប្រទេសអាល្លឺម៉ង់ និងប្រទេសកម្ពុជា។ល។ តែសម្រាប់សហរដ្ឋអាមេរិក គឺតុលាការកំពូលរបស់សហព័ន្ធ ព្រោះឥតមានតុលាការធម្មនុញ្ញ ឬក្រុមប្រឹក្សាធម្មនុញ្ញទេ។

ការអនុវត្តនូវរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និងរបបសេដ្ឋកិច្ចទីផ្សារ អំណាចយុត្តាធិការធម្មនុញ្ញ ពិតជាមានភាពចាំបាច់ធំធេងណាស់ចំពោះការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងការពិនិត្យធម្មនុញ្ញភាពនៃទង្វើ របស់អំណាចរដ្ឋ និងគណបក្សនយោបាយ រាប់ទាំងវិសមិតភាពនៃបុគ្គលក្នុងអំណាចរដ្ឋ និងឯកជន ដែលរដ្ឋធម្មនុញ្ញបានបញ្ញត្តជាធរមាន ដើម្បីធានាបាននូវប្រព័ន្ធរដ្ឋបាលសាធារណៈស្អាតស្អំ បម្រើសេវាជូនប្រជាពលរដ្ឋ និងប្រព័ន្ធយុត្តិធម៌សុចរិតទៀងត្រង់ ការពារភាពស្របច្បាប់របស់ប្រជាពលរដ្ឋ។

ដូច្នេះ អំណាចយុត្តាធិការធម្មនុញ្ញ ត្រូវបានរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ទទួលស្គាល់ ក្នុង **ការរក្សាគុណតម្លៃសន្តិភាពនៃនីតិរដ្ឋធម្មនុញ្ញ** សម្រាប់ប្រជាជាតិកម្ពុជាក្នុងយុគសម័យថ្មី នៃសង្គមសេរីបែបប្រជាធិបតេយ្យសេរីពហុបក្ស និងទីផ្សារសេរី៕

# រដ្ឋធម្មនុញ្ញ និងការកែទម្រង់រដ្ឋបាលសាធារណៈ

ឯកឧត្តម ព្រុំ សុខា

២៧ឆ្នាំកន្លងទៅ នៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កម្ពុជាសម្រេចបានសមិទ្ធផលដ៏ធំធេងមិនអាចកាត់ថ្លៃបាន ក្នុងការបញ្ចប់សង្គ្រាមស៊ីវិលដែលអូសបន្លាយជិត៣ទសវត្សរ៍ នាំមកនូវសុខសន្តិភាព និងការអភិវឌ្ឍសង្គមជាតិជារៀងដរាបមកទល់បច្ចុប្បន្ន។ ស្នាដៃជាប្រវត្តិសាស្ត្រនេះ កើតឡើងដោយកម្លាំងសាមគ្គីប្រជាជាតិទាំងមូលក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលស្របច្បាប់ ប្រសូតចេញពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលជាការបង្ហាញច្បាស់ពីគុណតម្លៃស្នូលនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

ចាប់ផ្តើមតាំងពីអាណត្តិរបស់ខ្លួនក្នុងនីតិកាលទី១ រហូតជាបន្តបន្ទាប់មកដល់នីតិកាលទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញអនុវត្តស៊ីជម្រៅនូវនយោបាយកំណែទម្រង់លើវិស័យជាអាទិភាពសំខាន់ៗរួមមាន៖ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ។ល។ រួមចំណែកយ៉ាងសកម្មដល់ការគោរពអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។

ផ្អែកលើគោលការណ៍គ្រឹះនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គោលនយោបាយនៃកំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានដាក់ចេញ និងពុះពារអនុវត្តឱ្យបានជាក់ស្តែងសមស្របជាមួយតថភាពនៃបរិបទកម្ពុជា។

រំលឹកឡើងវិញពីសាវតារនៃរដ្ឋបាលសាធារណៈនៅកម្ពុជា ដែលជាទូទៅត្រូវបានកត់សម្គាល់ដោយការផ្លាស់ប្តូរប្រព័ន្ធរដ្ឋបាលផ្សារភ្ជាប់ជាមួយ ការផ្លាស់ប្តូររបបនយោបាយគ្រប់គ្រងប្រទេស មានន័យថាជាមួយឥទ្ធិពលនៃនិន្នាការរួមរបស់ពិភពលោក ការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជាមានចរិតនិងលក្ខណៈដោយឡែករបស់ខ្លួន។

ការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា ត្រូវបានដំណើរការជាជំហានៗតាមដំណាក់កាលដូចខាងក្រោម៖

## ១- ការអនុវត្តគោលនយោបាយផ្សះផ្សា បង្រួបបង្រួមជាតិ (១៩៩៣-១៩៩៨)

សភាធម្មនុញ្ញដែលបង្កើតឡើង ក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ បានអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កំពូលរបស់ជាតិនេះ ផ្តល់គោល

ការណ៍គ្រឹះដល់ការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា។

រាជរដ្ឋាភិបាលនីតិកាលទី១ បានបង្កើតគណៈកម្មការប្រតិបត្តិនៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង (COMEX) ដើម្បីគ្រប់គ្រងនិងអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលដែលផ្តោតលើគោលដៅសំខាន់៥រួមមានជាអាទិ៍៖ ការរៀបចំរចនាសម្ព័ន្ធរដ្ឋឡើងវិញ ការពង្រឹងសមត្ថភាពគ្រប់គ្រងរបស់បណ្តាក្រសួងនិងស្ថាប័ន ការកែទម្រង់មុខងារសាធារណៈ ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងសមត្ថភាពគ្រប់គ្រងរដ្ឋបាលខេត្តក្រុង។

ក្នុងដំណាក់កាលនេះ រដ្ឋសភាជាតិបានអនុម័តច្បាប់អង្គការ និងច្បាប់នានាជាច្រើន រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យ និងលិខិតបទដ្ឋានជាច្រើនដើម្បីធានាឱ្យស្ថាប័នជាតិ ស្ថាប័នរដ្ឋ អង្គភាពរដ្ឋបាលសាធារណៈ និងផ្នែកឯកជនដំណើរការប្រព្រឹត្តទៅជាប្រក្រតី បម្រើដល់រាល់សកម្មភាពនិងជីវភាពសង្គមវិវឌ្ឍទៅដោយចីរភាព។

ក្នុងស្មារតីបង្រួបបង្រួមជាតិ រាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មមន្ត្រីរដ្ឋបាលចំនួនប្រមាណ២៥.០០០នាក់ ពីភាគីប្រដាប់អាវុធដទៃទៀតដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ហើយដែលបានចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ ធ្វើឱ្យតួលេខមន្ត្រីរាជការស៊ីវិលពេលនោះកើនឡើងដល់ចំនួន ១៥០.០០០ នាក់។

នៅឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលបានបើកយុទ្ធនាការរាប់ចំនួនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសក្នុងពេលតែមួយថ្ងៃ និងបានរកឃើញមន្ត្រីមានតែឈ្មោះ (មន្ត្រីខ្មោច) និងមន្ត្រីមិនប្រក្រតីផ្សេងទៀតចំនួន ១៧.៦៨៥នាក់ ដែលត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋ។

អំឡុងឆ្នាំ១៩៩៨ នយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល បានបញ្ចប់ទាំងស្រុងនូវសង្គ្រាមស៊ីវិលនៅកម្ពុជា អង្គការចាត់តាំងនយោបាយនិងយោធារបស់ភាគីខ្មែរក្រហមក៏ត្រូវបានរំសាយ។ រដ្ឋបាលយោធា និងស៊ីវិលរបស់ភាគីខ្មែរក្រហមរួមទាំងប្រជាជនស៊ីវិលត្រូវបានធ្វើសមាហរណកម្ម និងវិលត្រឡប់មករួមរស់ក្នុងសង្គមជាតិវិញ។

## ២- ការកសាងមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងមុខងារសាធារណៈ (១៩៩៩-២០០៣)

ក្នុងដំណាក់កាលនេះ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលមាននាយករដ្ឋមន្ត្រីជាប្រធាន និងឧបនាយករដ្ឋមន្ត្រីមួយចំនួនជាអនុប្រធាន និងមានថ្នាក់ដឹកនាំមកពីក្រសួងស្ថាប័នពាក់ព័ន្ធជាសមាជិក ត្រូវបានបង្កើតឡើង ដើម្បីដឹកនាំនយោបាយកំណែទម្រង់

លើវិស័យអាទិភាពសំខាន់ៗជាអាទិ៍៖ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ កំណែទម្រង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល (១៩៩៩-២០០៣) ត្រូវបានអនុម័ត ដោយផ្តោតលើគោលដៅចម្បងដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឱ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈប្រតិបត្តិការ មានផលិតភាព មានការទទួលខុសត្រូវខ្ពស់ និងមានសមត្ថភាព។ កម្មវិធីជាតិនេះ ត្រូវបានអនុវត្តទៅតាមជំហានសំខាន់ៗ ៣យ៉ាងគឺ៖ ការពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ ការរៀបចំសម្រួលរចនាសម្ព័ន្ធនិងការពង្រាយមន្ត្រីរាជការ ការធ្វើសនិទានកម្មមុខងារសាធារណៈនិងការអភិវឌ្ឍធនធានមនុស្ស។ ជំហាននីមួយៗ ត្រូវបានអនុវត្តដោយផ្អែកលើអ័ក្ស៤គឺ៖ (១)ពង្រឹងស្ថាប័នរដ្ឋដោយពង្រឹងនីតិរដ្ឋក្នុងរដ្ឋបាល (២)កែលំអប្រព័ន្ធរដ្ឋបាលនិងអន្តរសកម្មរវាងស្ថាប័នតាមរយៈការពង្រឹងការងារអភិបាលកិច្ចល្អ (៣)អភិវឌ្ឍធនធានមនុស្សដើម្បីពង្រឹងផលិតភាពរដ្ឋបាលសាធារណៈ (៤)គ្រប់គ្រងការផ្លាស់ប្តូរ។

នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលបានធ្វើជំរឿនមន្ត្រីរាជការទូទាំងប្រទេស។ ជាលទ្ធផល នៅពេលនោះយើងមានមន្ត្រីរាជការសរុបចំនួន ១៥៨.៥២១នាក់ ហើយបានរកឃើញមន្ត្រីរាជការដែលមានតែឈ្មោះក្នុងបញ្ជីបៀវត្ស (មន្ត្រីខ្មោច) ចំនួន ១៣.៨៧០នាក់ត្រូវបានលុបឈ្មោះចេញពីតារាងបៀវត្ស។ ផ្អែកលើលទ្ធផលនៃការធ្វើជំរឿននេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈបានកសាងមូលដ្ឋានទិន្នន័យមន្ត្រីរាជការស៊ីវិលសម្រាប់ប្រើប្រាស់រហូតមកដល់បច្ចុប្បន្ននេះ។

## ៣- **ការអនុវត្តកំណែទម្រង់ស៊ីជម្រៅ** (២០០៤-២០០៨)

ក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរយៈពេល៥ឆ្នាំ ដែលផ្តោតលើគោលដៅសំខាន់គឺ៖ ការកែលំអសេវាសាធារណៈ ការបង្កើនបៀវត្ស និងពង្រឹងការគ្រប់គ្រងប្រព័ន្ធនិយោជន៍ (Employment system) ការអភិវឌ្ឍសមត្ថភាព ការជំរុញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT)។ នៅឆ្នាំ២០០៧ មន្ត្រីរាជការស៊ីវិលមានចំនួន ១៦៧.១៦៧នាក់។

## ៤- **ការបន្តជំរុញអនុវត្តកំណែទម្រង់ស៊ីជម្រៅ** (២០០៨-២០១៣)

ក្នុងដំណាក់កាលនេះ កំណែទម្រង់រដ្ឋបាលផ្តោតលើគោលដៅសំខាន់គឺ៖ ប្រែក្លាយរដ្ឋបាលសាធារណៈ ពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ

ធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានតម្លាភាព ភាពឆ្លើយតប មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ លើកកម្ពស់វប្បធម៌សេវាសាធារណៈ ភក្តីភាព ឆន្ទៈម្ចាស់ការ និងមនសិការវិជ្ជាជីវៈ។ នៅឆ្នាំ២០១២ មន្ត្រីរាជការស៊ីវិលមានចំនួន ១៧៨.៥៨០នាក់។

## ៥- ការបន្តជំរុញអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យកាន់តែស៊ីជម្រៅ (២០១៣-២០១៨)

ដោយផ្តោតលើគោលដៅសំខាន់៣៖ (១)ការគ្រប់គ្រងគុណភាពនិងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ (២)ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័នរដ្ឋបាលសាធារណៈ (៣)ការកែទម្រង់ប្រព័ន្ធបៀវត្សនិងប្រាក់លាភការផ្សេងៗរបស់មន្ត្រីរាជការ។

ក្នុងដំណាក់នេះ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់រួមមានជាអាទិ៍៖

- ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) ដោយការធ្វើទំនើបកម្មទិន្នន័យគ្រប់គ្រងបុគ្គលិកនិងបៀវត្ស។
- ការរៀបចំកែសម្រួលរបបប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀតឱ្យមានកម្រិតសមរម្យ និងធានាការបើកផ្តល់ទៀងទាត់ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ។

មន្ត្រីរាជការឆ្នាំ២០១៨ មានចំនួន២១៨ ២៦៧ នាក់ (ក្នុងរយៈពេល៥ ឆ្នាំនេះចំនួនមន្ត្រីរាជការបានកើនឡើងចំនួន៣៩ ៦៨៧នាក់)។

## ៦- ការលើកកម្ពស់គុណាធិបតេយ្យក្នុងរដ្ឋបាលសាធារណៈ ដើម្បីអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌ (២០១៩-២០២៣)

ការកែទម្រង់រដ្ឋបាលផ្តោតលើគោលដៅសំខាន់ៗរួមមាន៖ (១)ការកែទម្រង់និងការពង្រឹងប្រសិទ្ធភាពស្ថាប័នសាធារណៈ (២)ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មមន្ត្រី និងស្ថាប័នសាធារណៈ(Individual and Institutional Performance) (៣)គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ (Perfomance Accountability for Public Service)។

ឆ្នាំ២០២០ មន្ត្រីរាជការស៊ីវិលសរុបចំនួន ២១១ ៨៩៣នាក់ (ស្ត្រី ៨៨ ០៥៨នាក់)។

ជារួម រយៈពេល២៧ឆ្នាំកន្លងទៅ លទ្ធផលនៃការកែទម្រង់រដ្ឋបាលសាធារណៈ

តាមដំណាក់កាលដូចបានរៀបរាប់ខាងលើ បានលើកកម្ពស់តួនាទីស្នូលរបស់រាជរដ្ឋាភិបាលក្នុងការធានាដល់ដំណើរការនៃស្ថាប័នរដ្ឋ និងអង្គភាពរដ្ឋបាលសាធារណៈ រួមទាំងផ្នែកឯកជន សង្គមស៊ីវិល និងសហគមន៍ពលរដ្ឋ រួមចំណែកយ៉ាងសំខាន់ដល់ស្ថិរភាព ប្រក្រតីភាព និងនិរន្តរភាពនៃរដ្ឋមួយឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យ និងនីតិរដ្ឋ។

ទោះជាយ៉ាងនេះក្តី ជាធម្មតាដំណើរការកំណែទម្រង់ទាមទារ ឆន្ទៈនយោបាយមោះមុតជាមួយយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែងរស់រវើក ដើម្បីពុះពារជម្នះបានរាល់បញ្ហាប្រឈម។ សម្រាប់បរិបទកម្ពុជា ក្រៅពីបញ្ហាប្រឈមជារួម ដូចបណ្តាប្រទេសដទៃទៀតលើសកលលោក យើងនៅមានបញ្ហាប្រឈមពិសេសដោយឡែករបស់ខ្លួនថែមទៀត។ ជាក់ស្តែង ការសម្រុះសម្រួលដើម្បីធ្វើសមាហរណកម្មរដ្ឋបាលពីគ្រប់ភាគីនៃជម្លោះប្រដាប់អាវុធនៅកម្ពុជា ឬការពង្រឹងទំនុកចិត្តនិងភាពស្មោះត្រង់ជាមួយគ្នា ក្នុងការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលឡើងវិញ ដើម្បីបែងចែកអំណាចក្នុងរដ្ឋាភិបាលចម្រុះ នៃអតីតភាគីជាគូប្រជែងជម្លោះប្រដាប់អាវុធរយៈពេលជិត៣០ឆ្នាំ ឬមួយការតស៊ូមតិដើម្បីការពារជំហរ និងឧត្តមគតិរបស់ភាគីនីមួយៗ ដែលពេលមួយនោះបានក្លាយទៅជាជម្លោះប្រដាប់អាវុធរយៈពេលខ្លី ដោយគ្រាន់តែយកលេសពីការមិនចុះសម្រុងនៃការបែងចែកមុខតំណែងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

ករណីទាំងអស់នេះ បានក្លាយជាវិញ្ញាសានិងជាមេរៀនពិសោធន៍សម្រាប់ការកសាង ការកែទម្រង់ និងការអភិវឌ្ឍប្រព័ន្ធរដ្ឋបាលសាធារណៈមួយ ដែលដើរឱ្យទាន់នឹងការវិវឌ្ឍរីកចម្រើននៃបច្ចេកវិទ្យាទំនើបរបស់ពិភពលោក និងសមស្របជាមួយស្ថានភាពជាក់ស្តែងរបស់កម្ពុជា។

សូមងាកមកមើលបញ្ហាប្រឈម នៃការកែទម្រង់រដ្ឋបាលសាធារណៈលើពិភពលោកក្នុងយុគសម័យបច្ចុប្បន្ន។

លោក Owen E. Hughes បានកត់សម្គាល់ពីយុគសម័យនៃការផ្លាស់ប្តូររដ្ឋបាលសាធារណៈ (An Era of Change in Public Administration) ដោយលើកឡើងថា៖ ចាប់ពីពាក់កណ្តាលទសវត្សឆ្នាំ១៩៨០មក គំរូរដ្ឋបាលសាធារណៈបែបចាស់ (the traditional model of administration) ត្រូវបានវិវឌ្ឍប្រែប្រួលទៅជាគំរូនៃការគ្រប់គ្រងសាធារណៈបែបថ្មី (the new public management) ដែលមានភាពបត់បែន (flexibility) ដោយផ្អែកលើទម្រង់នៃសេដ្ឋកិច្ចទីផ្សារ (market-based form)។ នេះមិនមែនជាកំណែទម្រង់ធម្មតា ឬជាការផ្លាស់ប្តូរតូចតាចនូវរបៀបនៃការគ្រប់គ្រងនោះទេ ប៉ុន្តែវាជាការផ្លាស់ប្តូរនូវតួនាទី

រដ្ឋាភិបាលក្នុងសង្គម និងក៏ជាការផ្លាស់ប្តូរនូវទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយនឹងប្រជាពលរដ្ឋផងដែរ។ របៀបគ្រប់គ្រងរដ្ឋបាលសាធារណៈបែបចាស់លែងត្រូវបានទទួលទំនុកចិត្តទាំងទ្រឹស្តីនិងការអនុវត្តជាក់ស្តែង ជាហេតុនាំមកនូវការទទួលយកទម្រង់ថ្មីនៃការគ្រប់គ្រងសាធារណៈ ដែលនោះគឺជាការផ្លាស់ប្តូរមួយដ៏ជ្រាលជ្រៅ នៅក្នុងវិស័យសាធារណៈ។

ការផ្លាស់ប្តូរដ៏ជ្រាលជ្រៅនៃរដ្ឋបាលសាធារណៈតាមគំរូថ្មីនេះ (the new paradigm shift) ជះឥទ្ធិពលផ្ទាល់ដល់គោលការណ៍ជាមូលដ្ឋាន នៃរបៀបគ្រប់គ្រងរដ្ឋបាលសាធារណៈបែបចាស់ដែលរួមមាន៖

- បែបបទការិយាធិបតេយ្យ (bureaucracy) ជាបទបញ្ជា ជាបញ្ញត្តិរដ្ឋបាលមានលក្ខណៈជាច្បាប់
- ការធ្វើតាមបែបបទនិងនីតិវិធី ដែលត្រូវបានចែងលម្អិតស្រាប់ (fixed procedural manuals to follow)
- ការផ្តល់សេវាតាមបែបការិយាធិបតេយ្យ (bureaucratic delivery)
- ការញែកចេញឱ្យដាច់រវាងនយោបាយ និងរដ្ឋបាល (politics administration dichotomy)
- អ្វីទាំងអស់ដើម្បីផលប្រយោជន៍សាធារណៈ (the public interests)
- ការបំពេញការងារមួយជីវិតប្រកបដោយវិជ្ជាជីវៈ អព្យាក្រឹត មិនលំអៀង មិនប្រកាន់និន្នាការនយោបាយ (a professional bureaucracy, neutral, anonymous, impartial and employed for lives)
- ធ្វើតាមបទបញ្ជាណែនាំដោយបុគ្គលម្នាក់ៗគ្មានសិទ្ធិទទួលខុសត្រូវ ឬគណនេយ្យភាពចំពោះលទ្ធផលការងារ (following the instructions provided without personal responsibility or accountability for results)

ឆ្លងតាមពិសោធន៍ជាក់ស្តែងកន្លងមក គោលការណ៍ជាមូលដ្ឋានទាំង០៧ខាងលើនេះ ត្រូវបានប្រឈមជាមួយនឹងចំណោទបញ្ហាជាចម្បងនៃប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈបែបចាស់ជាអាទិ៍គឺ៖ ភាពច្រំដែល ស្ពឹកស្រពន់ពុំលើកទឹកចិត្តដល់នវានុវត្តភាព (innovative) និងការទទួលខុសត្រូវ ឬគណនេយ្យភាពទៅលើលទ្ធផល។ល។

ផ្តើមចេញពីការកត់សម្គាល់ខាងលើ ដែលផ្តោតជាសំខាន់ជុំវិញបញ្ហាការិយាធិបតេយ្យ (The problem of bureaucracy) យើងអាចមើលឃើញបញ្ហាផ្សេងៗទៀត

សម្រាប់ឆ្លុះបញ្ចាំង និងទាញយកពិសោធន៍សម្រាប់ការកែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា។ បញ្ហាទាំងនោះរួមមានជាអាទិ៍៖

១- បញ្ហាមួយក្នុងចំណោមបញ្ហាដទៃទៀត ដែលចោទឡើងសម្រាប់គំរូរដ្ឋបាលសាធារណៈបែបចាស់គឺបែបបទរដ្ឋបាលនៃការិយាធិបតេយ្យធ្ងន់ធ្ងរ។ មតិរិះគន់ទាំងឡាយចំពោះបញ្ហានេះនៅត្រង់ថារចនាសម្ព័ន្ធ និងការគ្រប់គ្រងនៃគំរូរដ្ឋបាលបែបចាស់គឺវាហួសសម័យនិងតម្រូវឱ្យមានកំណែទម្រង់ស៊ីជម្រៅ ដោយហេតុថាមានបញ្ហាដែលពាក់ព័ន្ធជាមួយនឹងទស្សនទានអំពីការិយាធិបតេយ្យ និងអង្គការចាត់តាំងបែបការិយាធិបតេយ្យ។ ការិយាធិបតេយ្យជាផ្លូវការប្រហែលជាមានផលវិជ្ជមានរបស់វា ប៉ុន្តែវាក៏តម្រូវឱ្យចំណាយពេលវេលាច្រើនសម្រាប់អ្នកដែលមានគំនិតច្នៃប្រឌិត (Innovators)។ វាលើកទឹកចិត្តដល់អ្នករដ្ឋបាលដែលហ៊ានប្រឈមតទល់នឹងការជំទាស់ប្រឆាំង ជាជាងហ៊ានប្រថុយប្រថានទទួលយកហានិភ័យ ព្រមទាំងខ្ជះខ្ជាយធនធានដ៏កម្រ ដោយមិនបានប្រើប្រាស់វាប្រកបដោយប្រសិទ្ធផល។ លោក Weber ចាត់ទុកការិយាធិបតេយ្យជាទម្រង់រដ្ឋបាលខ្ពស់បំផុត ប៉ុន្តែជាញឹកញាប់ត្រូវបានគេរិះគន់ពីការបង្កើតឱ្យមានភាពគាំងស្ទូក (inertia) របស់វាខ្វះសហគ្រិនភាពធ្វើឱ្យមានបែបបទរដ្ឋបាលច្រើន (red tape) ខ្ជះខ្ជាយពេលវេលា និងគ្មានប្រសិទ្ធភាព ព្រមទាំងស្ថានភាពនានាដែលគេយល់ថា ជាជំងឺនៅក្នុងស្ថាប័ន អង្គភាពទាំងឡាយក្នុងវិស័យសាធារណៈ។ ការពិត សព្វថ្ងៃនេះ ពាក្យថា «ការិយាធិបតេយ្យ» ជាទូទៅមានន័យស្មើនឹងគ្មានប្រសិទ្ធភាព។

២- មានបញ្ហាគួរឱ្យកត់សម្គាល់ពីរយ៉ាងក្នុងទ្រឹស្តីការិយាធិបតេយ្យ។ នោះគឺមួយ៖ បញ្ហាទំនាក់ទំនងរវាងការិយាធិបតេយ្យជាមួយនឹងប្រជាធិបតេយ្យ និងពីរ៖ ការិយា-ធិបតេយ្យផ្លូវការមិនត្រូវបានគេចាត់ទុកបន្តទៅទៀតថាជាទម្រង់អង្គការចាត់តាំងដែលមានប្រសិទ្ធភាព ឬបើនិយាយឱ្យកាន់តែត្រឹមត្រូវថែមទៀត កាលៈទេសៈដែលចាត់ទុកការិយាធិបតេយ្យផ្លូវការថាជាទ្រឹស្តីល្អបំផុតសម្រាប់ការអនុវត្តនោះគឺវាកាន់តែបានរួមតូចហើយពុំអាចក្លាយជាគោលការណ៍សកលបានទៀតឡើយ។

ជាមួយនឹងសនិទានភាពផ្លូវការរបស់វា ការសម្ងាត់ ភាពរឹងត្អឹងនិងឋានានុក្រមវាហាក់ដូចជាមិនអាចចៀសផុតពីការកើតឡើងនូវទំនាស់មួយចំនួនរវាងការិយាធិបតេយ្យនិងប្រជាធិបតេយ្យ។ ដូចលោក Weber បានកត់សម្គាល់៖ «ការិយាធិបតេយ្យនីមួយៗតែងតែស្វះស្វែងបង្កើនឧត្តមភាពពីការទទួលបានព័ត៌មានជំនាញ ដោយលាក់ទុកជាសម្ងាត់នូវចំណេះដឹង និងគោលបំណងរបស់ពួកគេ»។ គាត់បានបន្ថែមទៀតថា៖ «ទស្សនទាននៃការសម្ងាត់ផ្លូវការ គឺជានវកម្មពិសេសនៃការិយាធិបតេយ្យ»។ ការព្រួយ

បារម្ភបែបនេះ នៅតែកើតមានជាដរាប។ ការិយាធិបតេយ្យត្រូវបានមនុស្សមួយចំនួនចាត់ទុកជាការបោះបង់ចោលនូវអំណាចរបស់ប្រជាជន និងអ្នកនយោបាយ ហើយឆ្លងតាមនោះធ្វើឱ្យមានបញ្ហាដល់អភិបាលកិច្ចនយោបាយ។ ទាំងនេះចោទជាបញ្ហាមួយចំនួនក្នុងសង្គមដែលគេសង្កេតឃើញថា មន្ត្រីដែលមិនបានជ្រើសតាំងដោយការបោះឆ្នោត (Unelected officials) មានអំណាចទូលំទូលាយជាងជីវិតផ្ទាល់របស់ពួកគេទៀត។

៣- បញ្ហានៃការគ្រប់គ្រងនយោបាយក្នុងរដ្ឋបាលសាធារណៈ (The problem of political control in public administration)

ក- ភាពមិនប្រាកដនិយមនៃគំនិតចង់កសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយអព្យាក្រឹតដាច់ពីនយោបាយ(«non-political » public administration system)

បំណងដែលចង់ឱ្យមានការញែកឱ្យដាច់ រវាងនយោបាយនិងរដ្ឋបាល (the separation between policy and administration) ដែលត្រូវបានលើកឡើងដោយលោក Woodrow Wilson ក្នុងបណ្តាឆ្នាំ១៨៨០ ដើម្បីទប់ទល់ជាមួយនឹងប្រព័ន្ធរដ្ឋបាលមួយបក្សពួកគ្រួសារនិយម (the spoils system) បានដក់ជាប់ក្នុងគំនិតជាទូទៅនៅសហរដ្ឋអាមេរិក។ ទោះជាយ៉ាងនេះក្តី បើគេពិនិត្យពីការជាក់ស្តែងតាំងពីដើមរៀងមក ការញែកឱ្យដាច់ស្រឡះទាំងស្រុងរវាងអ្នកនយោបាយនិងអ្នករដ្ឋបាល រវាងនយោបាយ និងរដ្ឋបាលគឺមិនដែលធ្លាប់ធ្វើបានសោះឡើយ។ ចលនាកែទម្រង់នៅសហរដ្ឋអាមេរិកមិនអាចកាត់ផ្តាច់នយោបាយចេញពីរដ្ឋបាល ឬអ្នកនយោបាយចេញពីអ្នករដ្ឋបាលបានឡើយ។ ពួកគេគ្រាន់តែអាចកំណត់ច្បាស់ល័ក្ខខ័ណ្ឌមួយចំនួន សម្រាប់ការតែងតាំងមន្ត្រីសាធារណៈដែលមានតួនាទីនយោបាយ (political appointments) ឱ្យស្ថិតនៅដាច់ស្រឡះពីការតែងតាំងមន្ត្រីមុខងារសាធារណៈតាមជំនាញវិជ្ជាជីវៈ (career appointments)។ ក្នុងប្រព័ន្ធសភានិយម Westminster នៅប្រទេសអង់គ្លេស ក្បួនខ្នាតនៃការតែងតាំងមន្ត្រីត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងបំផុត ប៉ុន្តែត្រូវបានតម្រឹមទៅតាមទម្លាប់ចាស់ជាជាងតាមនីតិវិធីផ្លូវការក្នុងការកំណត់តួនាទីរបស់រដ្ឋមន្ត្រីឬមន្ត្រីនានា។

លើការជាក់ស្តែង ទំនាក់ទំនងរវាងរដ្ឋាភិបាលនិងរដ្ឋបាល ពុំដែលមានភាពសាមញ្ញងាយស្រួលដូចអ្វីដែលលោក Woodrow Wilson ចង់បាននោះឡើយ។ រវាងការដឹកនាំនយោបាយនិងពួកការិយាធិបតេយ្យ (bureaucrats) តែងតែមានទំនាក់ទំនងយ៉ាងសាំញ៉ាំ និងងាយបត់បែន (complex and fluid)។ ទំនាក់ទំនងទាំងនោះ មិនអាចឆ្លុះបញ្ចាំងពីភាពសមហេតុផលជាផ្លូវការ និងមានរបៀបរៀបរយដូចគំរូដែលលោក Woodrow Wilson បានតស៊ូមតិបង្កើតវាឡើងនោះឡើយ។ នយោបាយមិនអាចកាត់ផ្តាច់ពីរដ្ឋបាល

បានឡើយ (Politics cannot be separated from administration) ព្រោះថាក្នុងពេលអនុវត្ត គេមិនអាចបំបែកទង្វើនយោបាយចេញពីគ្នាទាំងស្រុងបានឡើយ ហើយរាល់នីតិវិធីរដ្ឋបាលតែងតែមានផលវិបាកនយោបាយ។ ទម្រង់រដ្ឋបាលបែបចាស់មិនងាយនឹងឆ្លុះបញ្ចាំងឱ្យបានពីតួនាទីទូលំទូលាយក្នុងការធ្វើសេចក្ដីសម្រេច និងកិច្ចការគ្រប់គ្រងដូចជាទម្រង់រដ្ឋបាលសាធារណៈបែបទំនើបបានឡើយ។ ហេតុនេះហើយ បានជាជំរុញឱ្យមានទម្រង់នៃការត្រួតត្រាមួយអវិជ្ជមាន ដែលតែងតែគេចចេញពីកំហុស ពីការទទួលខុសត្រូវជាជាងការផ្ដល់នូវការលើកទឹកចិត្តជាវិជ្ជមាន ដើម្បីកែលម្អប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ។ ការប៉ុនប៉ងដែលចង់ឱ្យមានស្ថានភាព «មិនពាក់ព័ន្ធនឹងនយោបាយ (non-political)» គឺមានន័យថា ជាការមិនអើពើ ជាការមិនទទួលស្គាល់នូវសារៈសំខាន់នៃគោលនយោបាយនិងនយោបាយក្នុងមុខងារសាធារណៈ។ មន្ត្រីរាជការសាធារណៈក៏មានតួនាទីសំខាន់ក្នុងការគ្រប់គ្រង ហើយអ្វីដែលសំខាន់ជាងនោះទៅទៀត គឺនៅត្រង់ថាការគ្រប់គ្រងនេះមិនមែនគ្រាន់តែជាអភិបាលកិច្ចរដ្ឋបាល ឬគ្រាន់តែធ្វើតាមបទបញ្ជាណែនាំនោះឡើយ។

នយោបាយ និងរដ្ឋបាលត្រូវផ្សារភ្ជាប់គ្នាជាចាំបាច់ (Politics and administration are necessarily intertwined)។ ត្រូវចាត់ទុកកិច្ចការរបស់មន្ត្រីសាធារណៈជាគ្រឹះនយោបាយ (fundamentally political) ទោះបីមិនជាប់ពាក់ព័ន្ធជាមួយគណបក្សនយោបាយក៏ដោយ (not necessarily party political)។ អ្នកអនុវត្តជាក់ស្ដែង (practitioners) មួយចំនួននៅតែប្រកែកនិងអះអាងថា ពួកគេគ្រាន់តែជាអ្នកអនុវត្តគោលនយោបាយប៉ុណ្ណោះ មិនមែនជាអ្នកធ្វើគោលនយោបាយនោះទេ។ ប៉ុន្តែនេះវាគ្រាន់តែជារបៀបនៃ «ការតស៊ូមតិបែបមនោគមវិជ្ជា (ideological advocacy)» ជាជាងការទទួលស្គាល់ការពិតជាក់ស្ដែង។ បើទោះបីជាគំនិតនៃការញែកឱ្យដាច់ស្រឡះនេះត្រូវបានគេចាត់ទុកថាមិនមានភាពប្រាកដនិយមតាំងពីដើមរៀងមកក៏ដោយចុះ ប៉ុន្តែវាបានក្លាយទៅជាចំណុចគោលគួរឱ្យកត់សម្គាល់នៅក្នុងគំរូនៃប្រព័ន្ធរដ្ឋបាលបែបចាស់។ ប៉ុន្តែការដែលផ្អែកលើទ្រឹស្ដីដែលមិនអាចអនុវត្តបាន និងត្រូវបានគេចាត់ទុកជាទូទៅថាវាមិនដើរទាល់តែសោះក្នុងរយៈពេលយ៉ាងយូរបែបនេះ នាំឱ្យគេអាចសន្និដ្ឋានបានថាប្រាកដជាមានអ្វីមិនស្រួលហើយក្នុងគំរូប្រព័ន្ធរដ្ឋបាលទាំងមូល។

ខ- តួនាទីនៃការដឹកនាំនយោបាយនិងមុខងារសាធារណៈ (Roles of political leadership and civil service)

*ដកស្រង់ពីសៀវភៅមានចំណងជើងថា៖* "The LEADER, The TEACHER &

YOU˝ របស់លោក Siong Guan LIM, សាស្ត្រាចារ្យនៅសាលា Lee Kuan Yew School of Public Policy, NUS, Singapore (2014)

សំណួរដែលតែងតែចោទឡើងថា៖ «តើអ្នកដឹកនាំនយោបាយ និងមន្ត្រីរាជការសាធារណៈមានតួនាទីអ្វីខ្លះ?»

អ្នកដឹកនាំនយោបាយជាអ្នកសម្រេចលើគោលនយោបាយ ចំណែកឯមន្ត្រីរាជការសាធារណៈ ជាអ្នកដែលត្រូវធ្វើឱ្យគោលនយោបាយនោះត្រូវបានអនុវត្តដោយជោគជ័យ។ ក្នុងជំហានដំបូងនៃដំណើរការអភិវឌ្ឍគោលនយោបាយ មន្ត្រីរាជការសាធារណៈត្រូវធានាធ្វើយ៉ាងណាឱ្យការអនុវត្តគោលនយោបាយនោះបានត្រឹមត្រូវ និងប្រកបដោយចីរភាព។

លទ្ធផលនៃការអនុវត្តគោលនយោបាយត្រូវបានកំណត់ថាជាបុព្វសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកនយោបាយ។ វាជាកាតព្វកិច្ចរបស់អ្នកនយោបាយដែលត្រូវវាយតម្លៃឱ្យបាន ថាតើលទ្ធផលនៃការអនុវត្តគោលនយោបាយឆ្លើយតបបានល្អប្រសើរចំពោះតម្រូវការនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋឬទេ? ព្រោះថាវាមិនមែនជាភារកិច្ចរបស់មន្ត្រីរាជការដែលជាអ្នកសម្រេចទៅលើគំនិតខុសគ្នា និងសេចក្ដីត្រូវការជាច្រើនរបស់អ្នកបោះឆ្នោត នោះទេ។

គោលការណ៍ខាងលើនេះ ត្រូវបានថែងច្បាស់ថា៖ មន្ត្រីរាជការសាធារណៈត្រូវប្រកាន់ជំហរឥតលំអៀង ប៉ុន្តែមិនអាចស្ថិតនៅអព្យាក្រឹតបានឡើយ (The civil service is impartial but not neutral)។ មានន័យថា ក្នុងពេលផ្ដល់សេវាឬក្នុងពេលបំពេញការងាររបស់ខ្លួន មន្ត្រីរាជការសាធារណៈត្រូវប្រកាន់ជំហរឥតលំអៀងចំពោះជាតិសាសន៍ ជំនឿសាសនា ឋានៈសេដ្ឋកិច្ចសង្គម។ល។ ប៉ុន្តែក្នុងនាមជាមន្ត្រីរាជការសាធារណៈ ពួកគេមិនអាចស្ថិតនៅអព្យាក្រឹតក្នុងពេលអនុវត្តគោលនយោបាយបានឡើយ ដោយហេតុថាមន្ត្រីរាជការសាធារណៈគឺជាឧបករណ៍របស់រដ្ឋាភិបាល នៅក្នុងវិស័យគោលនយោបាយសាធារណៈ។

តួនាទីចម្បងរបស់មន្ត្រីរាជការសាធារណៈគឺការផ្ដល់សេវា ហើយបញ្ហាប្រឈមដែលមន្ត្រីរាជការសាធារណៈជួបប្រទះ គឺការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព ព្រមទាំងឆ្លើយតប និងទទួលខុសត្រូវបានចំពោះគុណភាពការងារ និងទទួលបានការគាំទ្រពីសាធារណជន។

៤- កង្វះភាពជាអ្នកដឹកនាំ (Lack of leadership)

ការចង់បង្កើតប្រព័ន្ធការិយាធិបតេយ្យមួយ ដែលមិនប្រកាន់បុគ្គលនិយមទាំង

ស្រុងនោះ (a completely impersonal system) គឺមិនគ្រាន់តែជាគំនិតដែលមិនសូវសមស្របប៉ុណ្ណោះទេ តែវាថែមទាំងបង្កើតជាបញ្ហាចម្បងដែលពុំមានភាពប្រាកដនិយមទៀតផង។ និយាយឱ្យចំគឺគេមិនអាចកាត់ផ្តាច់ទាំងស្រុងទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ក៏ដូចជាការជំរុញលើកទឹកចិត្តមនុស្សនៅក្នុងអង្គការចាត់តាំងជាស្ថាប័ន ឬអង្គភាពទាំងឡាយដែលបង្កើតឡើងដោយសារមនុស្ស និងបម្រើគោលបំណងរបស់មនុស្ស។ ដូចលោក Behn (1998b) បញ្ជាក់ថា៖ «ប្រសិនបើអង្គការចាត់តាំងទាំងឡាយអាចដំណើរការបានដូចជាគ្រឿងម៉ាស៊ីននោះ ប្រាកដជាពុំចាំបាច់ឱ្យមានការដឹកនាំបុគ្គលជាមនុស្សសោះឡើយ» ប៉ុន្តែដោយសារអង្គការចាត់តាំងទាំងអស់នោះមិនមែនជាគ្រឿងម៉ាស៊ីន ម្ល៉ោះហើយមនុស្សទាំងអស់មិនអាចប្រកាន់អាកប្បកិរិយាដូចខ្លួនជាចំណែកនៃគ្រឿងម៉ាស៊ីននោះឡើយ មានន័យថា «មន្ត្រីគ្រប់គ្រងសាធារណៈត្រូវតែដឹកនាំ»។

ភាពជាអ្នកដឹកនាំ ជាប្រការចាំបាច់មិនអាចខ្វះបាន ពិសេសនៅពេលដែលក្បាលម៉ាស៊ីនគំរូនៃប្រព័ន្ធការិយាធិបតេយ្យគាំងដំណើរ។ ក្នុងពិភពជាក់ស្តែងនៃអង្គការចាត់តាំង តែងតែមានគ្រប់ប្រភេទនូវល្បែងនយោបាយរបស់មនុស្សជាអាទិ៍ ភាពច្រណែនប្រជែងគ្នា ចំណុចខ្វះខាត ទំនាស់ជាបុគ្គល។ល។ ទស្សនៈរបស់លោក Weber ចាត់ទុកបញ្ហាទាំងអស់នេះជាអត្តចរិតនៃអសមត្ថភាពពីកំណើតរបស់បុគ្គលម្នាក់ៗ និងគប្បីត្រូវបានដោះស្រាយតាមរយៈការកែលម្អជាបន្តបន្ទាប់ ឬការលុបបំបាត់ចោលទាំងអស់ក្នុងពេលតែមួយ។ ប៉ុន្តែគេមិនអាចចៀសផុតដោយគ្រាន់តែកសាងនូវគំរូនៃរបៀបគ្រប់គ្រងមួយដែលធ្វើមិនដឹងមិនឮ មិនអើពើនឹងអ្វីដែលបានកើតឡើងរួចមកហើយនោះបានឡើយ។ នេះជាការគ្រប់គ្រងដែលគ្មានភាពប្រាកដនិយម ហើយច្បាស់ណាស់ថា អវត្តមាននៃការដឹកនាំ ក៏មានន័យថា ជាការគេចវេះពីការទទួលខុសត្រូវរបស់បុគ្គល។

ក្រៅពីបញ្ហាខាងលើ នៅមានចំណុចសំខាន់មួយដែលកំពុងត្រូវបានជជែកដេញដោលនៅក្នុងរដ្ឋបាលសាធារណៈនៃប្រទេសនានាលើសកលលោកក្នុងពេលបច្ចុប្បន្ននោះគឺ៖

**តួនាទីរបស់រដ្ឋាភិបាលក្នុងយុគសម័យថ្មី** (Role of government in the trend of new era)។

ក្នុងប្រព័ន្ធសេដ្ឋកិច្ចចម្រុះ (mixed economies) ដើម្បីឱ្យការធ្វើសកម្មភាពទាំងឡាយប្រកបដោយសនិទានភាព ឬភាពសមហេតុផល (rationales) តម្រូវឱ្យមានការសម្រេចជ្រើសរើសរវាងផ្នែកសាធារណៈ ឬផ្នែកឯកជន (either the public or the private sector)។ ជម្រើសនេះប្រែប្រួលខុសប្លែកគ្នាតាមកាលៈទេសៈដោយឡែកនៃប្រទេសនីមួយៗ ព្រោះ

ថាពេលខ្លះទំហំ និងវិសាលភាព (scope and scale) របស់រដ្ឋាភិបាលកើនឡើង ហើយពេលខ្លះទៀតទំហំ និងវិសាលភាពរបស់រដ្ឋាភិបាលមានការថយចុះ។ ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ ការប្រែប្រួលពីផ្នែកសាធារណៈ ទៅកាន់ផ្នែកឯកជនមាននិន្នាការកើនឡើងដោយហេតុតែមានការយល់ឃើញជាទូទៅ ដែលថារដ្ឋាភិបាលមិនគួរចូលប្រឡូកទៅក្នុងសកម្មភាពតូចតាចពេកទេ។ ការផ្ទេរធនធាននិងមុខងារទៅផ្នែកឯកជនធ្វើឱ្យមានផលប៉ះពាល់ទៅដល់អ្នកដែលបំពេញការងារក្នុងផ្នែកសាធារណៈ ក៏ដូចជាអ្នកដែលពាក់ព័ន្ធនឹងផ្នែកសាធារណៈ។

ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៨០ រដ្ឋជាច្រើនដែលជាសមាជិកនៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) បានធ្វើការពិនិត្យវាយតម្លៃឡើងវិញនូវតួនាទីនៃផ្នែកសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន។ សំណួរដែលចោទឡើងចំពោះបញ្ហានេះនៅតែកើតមាន និងកាន់តែកើនឡើងជាដរាប។ ការវាយតម្លៃបានសន្និដ្ឋានថា រដ្ឋាភិបាលមួយចំនួនគឺបានជាប់ពាក់ព័ន្ធជាមួយសកម្មភាពខ្លះ ដែលមិនសមស្រប (inappropriate activities) ហេតុនេះគេគួរតែកាត់បន្ថយឱ្យបានច្រើននូវទំហំនិងតួនាទីរបស់រដ្ឋាភិបាល។ មានន័យថាតើរដ្ឋាភិបាលគួរតែត្រូវបានផ្តល់នូវទំនិញ និងសេវាណាខ្លះដែលខ្លួនអាចធ្វើបាន ហើយក្រៅពីនោះរដ្ឋាភិបាលគួរតែប្រគល់ទៅឱ្យផ្នែកឯកជន? តើរដ្ឋាភិបាលគួរលូកដៃចូលធ្វើឧបត្ថម្ភធន ឬជួយអន្តរាគមន៍សម្របសម្រួលទៅលើអ្វីខ្លះទៀត? តើពលរដ្ឋត្រូវបង់ពន្ធកម្រិតណា (តិចឬច្រើន) ដើម្បីឱ្យពួកគាត់អាចមានជម្រើសក្នុងការសម្រេចថាត្រូវទទួលយកសេវាពីរដ្ឋាភិបាលឬពីសហគមន៍? សំណួរបែបនេះក៏បានចោទឡើងជាបញ្ហានយោបាយអំពីការយល់ឃើញ និងការវាយតម្លៃរបស់សមាជិកសហគមន៍នានាទៅលើកិច្ចការទាំងឡាយដែលរដ្ឋាភិបាលបានអនុវត្ត ក៏ដូចជាចំណាប់អារម្មណ៍បែបមនោគមវិជ្ជារបស់ពួកគេ ចំពោះតួនាទីសមស្របរបស់រដ្ឋាភិបាលនៅក្នុងសង្គម។

តាំងពីដើមរៀងមក អាស្រ័យដោយទំហំ និងវិសាលភាពរបស់ខ្លួន ការលូកដៃរបស់រដ្ឋាភិបាលចូលទៅក្នុងកិច្ចការសេដ្ឋកិច្ចត្រូវបានកំណត់បែងចែកជាសំខាន់ ក្នុងន័យមនោគមវិជ្ជាតាមរបៀបពីរយ៉ាងរវាងការប្រកាន់ស្តាំនិងការប្រកាន់ឆ្វេង។ ជាទូទៅ យោងតាមប្រវត្តិសាស្ត្របានបង្ហាញថាចំពោះការប្រកាន់ឆ្វេង គឺគាំទ្រឱ្យរដ្ឋាភិបាលមានតួនាទីកាន់តែធំក្នុងការចំណាយ និងការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ច ចំណែកឯការប្រកាន់ស្តាំវិញគឺមិនគាំទ្រឱ្យរដ្ឋាភិបាលមានតួនាទីធំពេកទេក្នុងការចំណាយនិងការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចនោះឡើយ។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលនៅក្នុងអំឡុងទសវត្ស

ឆ្នាំ១៩៨០ មានការជជែកដេញដោលពីតួនាទីរបស់ផ្នែកសាធារណៈ ហើយដែលពេលមួយនោះការជជែកដេញដោលបែបនេះ បានក្លាយទៅជាការតស៊ូខាងមនោគមវិជ្ជាយ៉ាងស្រួចស្រាល់នៅក្នុងប្រទេសមួយចំនួន រហូតឈានទៅដល់ការលុបបំបាត់ចោលពីសំណាក់រដ្ឋាភិបាលថ្មីដែលប្រកាន់ស្ពាំនូវស្លាកស្នាមទាំងឡាយជាកេរដំណែលចុងក្រោយរបស់សង្គមនិយម។ ប៉ុន្តែការប្រឆាំងទៅនឹងការផ្លាស់ប្តូរបែបនេះមិនដែលចុះថមថយឡើយ ដោយហេតុថាបុគ្គលិកក្នុងផ្នែកសាធារណៈ សហជីពនិងអ្នកគាំទ្រនៅតែតស៊ូទាមទារឱ្យរដ្ឋាភិបាល មានតួនាទីដូចកាលពីមុនដដែល។

តាំងពីដើមមក កំណែទម្រង់ផ្នែកសាធារណៈត្រូវបានកត់សម្គាល់ថាជាផ្នែកមួយយ៉ាងសំខាន់នៃការជជែកដេញដោលខាងមនោគមវិជ្ជាទៅលើតួនាទីរបស់រដ្ឋាភិបាល។ ការពិតរដ្ឋាភិបាលរបស់ប្រធានាធិបតី Reagan និងនាយករដ្ឋមន្ត្រី Thatcher ដែលបានវាយប្រហារយ៉ាងដំណំខាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងទៅលើការដឹកនាំបញ្ជា ឬការិយាធិបតេយ្យ (the command or bureaucratic part) ក្នុងសង្គមគឺដើម្បីគាំទ្រដល់គោលការណ៍ទីផ្សាររបស់ខ្លួន (the market principle)។ ក្នុងដំណាក់កាលដំបូងនិន្នាការទៅកាន់ផ្នែកសាធារណៈដែលផ្អែកលើទីផ្សារ (market-based public sector) បានឆ្លុះបញ្ចាំងនូវកង្វល់ផ្សេងៗពីតួនាទីរបស់រដ្ឋាភិបាល ក៏ដូចជាការព្រួយបារម្ភទៅលើប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃគំរូការិយាធិបតេយ្យបែបថ្មីនេះ។ ឆ្លងកាត់កំណែទម្រង់តាមរយៈការផ្លាស់ប្តូររដ្ឋាភិបាលជាបន្តបន្ទាប់ វាបានបង្ហាញច្បាស់ថាការតម្រង់ទិសដៅនយោបាយរបស់គណបក្សទោះជាខាងមនោគមវិជ្ជាសុទ្ធសាធក៏ដោយចុះ គឺគ្រាន់តែជាចំណែកមួយនៃកំណែទម្រង់ផ្នែកសាធារណៈប៉ុណ្ណោះ បើប្រៀបធៀបនឹងកង្វល់ដ៏ធំអំពីប្រសិទ្ធភាព។

ក្នុងបណ្តាឆ្នាំដំបូងនៃសតវត្សទី២១ តួនាទីរបស់រដ្ឋាភិបាលបានត្រឡប់មកវិញប៉ុន្តែគ្រាន់តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ បន្ទាប់ពីក្រោយភ្លាមនៃការវាយប្រហារដោយភេរវកម្មនៅទីក្រុង New York នាខែកញ្ញា ឆ្នាំ២០០១ កិត្តិស័ព្ទរបស់រដ្ឋាភិបាលអាមេរិកមានការកើនឡើងក្នុងនាមជាស្ថាប័នតែមួយគត់ ដែលអាចដោះស្រាយបាននូវវិបត្តិដ៏ធ្ងន់ធ្ងរបែបនេះ។ ផ្ទុយទៅវិញ បរាជ័យរបស់សាជីវកម្មធំៗដូចជា WorldCom និង Enron បានកាត់បន្ថយនូវជំនឿជឿជាក់ទៅលើផ្នែកឯកជន ហើយបង្កើននូវតម្រូវការនៃអន្តរាគមន៍ជួយសម្របសម្រួលរបស់រដ្ឋាភិបាលទៅលើសកម្មភាពធុរកិច្ចនានា។ វិបត្តិហិរញ្ញវត្ថុសកល (the Global Financial Crisis) ដែលចាប់ផ្តើមនៅឆ្នាំ២០០៨ បានបង្ហាញឱ្យឃើញនូវអ្វីដែលអាចកើតមានឡើង នៅពេលដែលខ្វះការសម្របសម្រួលផ្នែកហិរញ្ញ-

វត្ថុ (Regulation of the financial sector was inadequate) ហើយដែលជាថ្មីម្ដងទៀតរដ្ឋាភិបាលត្រូវចេញមុខដោះស្រាយ។ នេះជាផ្នែកមួយនៃការវិលត្រឡប់ទៅកាន់ទ្រឹស្ដីកេន (Keynesian theory) វិញដែលកាលពីក្នុងអំឡុងទសវត្សឆ្នាំ១៩៧០ គេហាក់ដូចជាលែងមានជំនឿទៅហើយនោះ។ ក្នុងទ្រឹស្ដីនេះ សេដ្ឋវិទូអង់គ្លេស John Maynard Keynes បានផ្ដល់យោបល់ អំពីការចំណាយកញ្ចប់ថវិកាវិត្ថារកម្មរបស់រដ្ឋាភិបាល (Stimulus packages of government spending) ដើម្បីដោះស្រាយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច។ ប្រសិនជាគិតថាទ្រឹស្ដីកេន មិនសូវមានប្រជាប្រិយភាពនៅក្នុងទសវត្សឆ្នាំ១៩៨០ និងឆ្នាំ១៩៩០ ប៉ុន្តែវាបានក្លាយជាទ្រឹស្ដីពេញនិយមទៅវិញ នៅពេលដែលមានវិបត្តិហិរញ្ញវត្ថុសកលក្នុងអំឡុងឆ្នាំ២០០៨-២០០៩។

សង្គមណាក៏ដោយ តែងតែត្រូវការចាំបាច់នូវតួនាទីជាវិជ្ជមាននិងគាប់ប្រសើររបស់រដ្ឋាភិបាល។ វាមិនមែនជាការនិយាយពន្លើសជ្រុលហួសហេតុនោះទេដែលថាផ្នែកសាធារណៈជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងសង្គមទាំងមូល។ បើគ្មានក្របខ័ណ្ឌច្បាប់សម្រាប់ពង្រឹងការអនុវត្តកិច្ចសន្យានានាទេនោះ ច្បាស់ជាសកម្មភាពធុរកិច្ចឯកជននឹងមិនអាចមានដំណើរការទៅរួចបានទេ។ បទប្បញ្ញត្តិពន្ធដារ អាជ្ញាប័ណ្ណ ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដារ និងល័ក្ខខ័ណ្ឌការងារទាំងអស់នេះសុទ្ធតែមានផលប៉ះពាល់ទៅដល់ការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងផ្នែកឯកជន។ ផ្នែកសាធារណៈគឺជាអ្នកទិញដ៏ធំនូវទំនិញនិងសេវាពីផ្នែកឯកជន។ រដ្ឋាភិបាលជាអ្នកបែងចែកឡើងវិញនូវចំណូលបានមកពីសមាជិកសង្គមដែលមានចំណូលខ្ពស់ទៅឱ្យអ្នកដែលមានចំណូលទាប ដើម្បីរក្សាភាពសុខដុមរមនាក្នុងសង្គម។ ផ្នែកសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់កម្រិតជីវភាពជាក់ស្ដែង (real living standards) ដែលមនុស្សភាគច្រើនផ្អែកលើសេវារបស់រដ្ឋាភិបាលជាអាទិ៍ដូចជា សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព បរិស្ថាន ការដឹកជញ្ជូនសាធារណៈ ច្បាប់ និងសណ្ដាប់ធ្នាប់ ផែនការអភិវឌ្ឍមូលដ្ឋាន និងសេវាសង្គមកិច្ចនានា...។ល។ ដែលការផ្ដល់ទំនិញនិងសេវាទាំងនេះ ត្រូវធានាយ៉ាងហោចណាស់ឱ្យមានគុណភាពសម្រាប់អតិថិជនអាចប្រើប្រាស់បាន។ រដ្ឋាភិបាលជាអ្នកដែលអាចនិងត្រូវជំរុញនវានុវត្តន៍ក្នុងផ្នែកឯកជន។

ការវាយប្រហារដោយការទិតៀនទៅលើទំហំ វិសាលភាពនិងវិធីសាស្ត្រការងាររបស់ផ្នែកសាធារណៈក្នុងបណ្ដាឆ្នាំ១៩៨០ និង១៩៩០ បានផ្ដល់នូវជំនឿចិត្តចំពោះវិធានការទាំងឡាយដែលរដ្ឋាភិបាលបានខិតខំក្នុងការកាត់បន្ថយប្រតិបត្តិការ និងការផ្លាស់ប្ដូររបៀបគ្រប់គ្រងរបស់ខ្លួន។ រដ្ឋាភិបាលមួយចំនួនដែលមានបំណងចង់កាត់បន្ថយផ្នែក

សាធារណៈបានប្រឈមនឹងឧបសគ្គតិចតួច ដែលហាក់ដូចជាផ្តើមចេញពីភាពស្រងាកចិត្តរបស់សហគមន៍ចំពោះបញ្ហាការិយាធិបតេយ្យ ទោះបីពួកគេមិនចង់ឱ្យមានការកាត់បន្ថយសេវាក៏ដោយ។ លើសពីនេះទៀត ការណ៍ដែលពុំសូវមានការគាំទ្រចំពោះការិយាធិបតេយ្យ និងមន្ត្រីសាធារណៈ គឺមានន័យថាប្រការនេះវាបានក្លាយទៅជាសារៈប្រយោជន៍រួម ហើយវាក៏មិនអាចត្រូវបានគេប្រើប្រាស់ធ្វើជាលេសដើម្បីការពារបញ្ហាទាំងឡាយរបស់រដ្ឋាភិបាលបានឡើយ។ ហេតុនេះវាហាក់ដូចជាមានភាពផ្ទុយគ្នារវាងការចង់បង្កើនទំហំរដ្ឋាភិបាលដោយសារតែមូលហេតុចម្បង ដែលថាមានតម្រូវការសេវាកាន់តែច្រើនជាងមុនដូចជាការថែទាំសុខភាព និងសុខុមាលភាពសម្រាប់ប្រជាជនដែលមានវ័យចាស់ (ageing populations) ប៉ុន្តែទន្ទឹមនោះក៏មានការជំទាស់យ៉ាងខ្លាំងទៅនឹងការដំឡើងពន្ធដារ។

សរុបមក មានទ្រឹស្តីជាច្រើនសម្រាប់រដ្ឋាភិបាលប្រើប្រាស់ដើម្បីសម្រេចថាតើមានមុខងារណាខ្លះដែលខ្លួនគួររក្សាទុកឱ្យផ្នែកសាធារណៈ និងមានមុខងារណាខ្លះទៀតដែលគួរតែផ្តល់ទៅឱ្យផ្នែកឯកជន? មតិខ្លះលើកឡើងថារដ្ឋាភិបាលគួរតែផ្តល់នូវមុខទំនិញ និងសេវាទាំងឡាយណាដែលទីផ្សារមិនអាចផ្តល់បាន។ ទោះជាយ៉ាងនេះក្តី ក៏នៅមានមតិខ្លះទៀតលើកឡើងថា ដោយសារជាស្ថាប័នតំណាងឱ្យឆន្ទៈរបស់ប្រជាពលរដ្ឋដែលបានសំដែងឡើងតាមរយៈអភិក្រមនយោបាយ ទំហំរបស់រដ្ឋាភិបាលពុំគប្បីមានដែនកំណត់សោះឡើយ។

ជាសេចក្តីសន្និដ្ឋានរួម កំណែទម្រង់រដ្ឋបាលសាធារណៈបាននាំមកនូវការផ្លាស់ប្តូរជាច្រើនអំពីតួនាទីរបស់រដ្ឋាភិបាលរួមមានៈ ការប៉ងប្រាថ្នាកាត់បន្ថយចំណាយ ការជំរុញលើកទឹកចិត្តដើម្បីប្រសិទ្ធភាព និងការបង្កើតទម្រង់ផ្សេងៗនៃឯកជនូបនីយកម្ម។ ការចោទសួរពីតួនាទីរបស់ផ្នែកសាធារណៈ គឺជាសំណួរដែលកាន់តែមានភាពរឹងមាំនៅក្នុងសង្គមប្រជាធិបតេយ្យ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលនៅតែមានតួនាទីវិជ្ជមានចំពោះសហគមន៍ ដែលប្រការនេះវាបានវិវឌ្ឍប្រែប្រួលអស់រយៈពេលជាយូរណាស់មកហើយក្នុងការឆ្លើយតបទៅនឹងឆន្ទៈនយោបាយរបស់អ្នកបោះឆ្នោត។ ឆ្លងតាមបទពិសោធជាក់ស្តែងរបស់រដ្ឋតូចៗមួយចំនួនបានបង្ហាញច្បាស់ថា សម័យកាលថ្មី ក្នុងភាពប្រាកដនិយមនៃតួនាទីរបស់រដ្ឋាភិបាលបានកកើតឡើងហើយ។ រដ្ឋាភិបាលល្អបំផុតគឺមិនគ្រាន់តែជារដ្ឋាភិបាលមួយដែលមានទំហំតូចល្មមប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៅទៀតរដ្ឋាភិបាលត្រូវតែជាស្ថាប័នដែលមានតួនាទីសំខាន់ចាំបាច់ និងមានអំណាចពេញលេញក្នុងការសម្របសម្រួលដល់តួនាទីរបស់ផ្នែកឯកជន ជាជាងក្លាយដោយពិតប្រាកដទៅជាគូ

ប្រជែងជាមួយផ្នែកឯកជន។

សំណួរស្តីពីទំហំរបស់រដ្ឋាភិបាលតម្រូវឱ្យក្លាយទៅជាសំណួរថាតើមានអ្វីខ្លះដែលរដ្ឋាភិបាលត្រូវធ្វើ។ ជាធម្មតា ពុំមានវិធីណាមួយសត្យានុម័តប្រកបដោយឯករាជ្យក្នុងការកំណត់ទំហំសមស្របរបស់រដ្ឋាភិបាលនីមួយៗនោះទេ ក៏ដូចជាក្នុងការសម្រេចថាសកម្មភាពណាខ្លះដែលគួរតែប្រគល់ទៅឱ្យផ្នែកសាធារណៈ។ ផ្នែកសាធារណៈ គឺជាសំណង់មួយរបស់ពលរដ្ឋក្នុងសង្គម (The public sector in a society is a construct of its citizens)។ មានការយល់ស្របជាទូទៅដ៏ត្រឹមត្រូវដែលថា រដ្ឋាភិបាលមិនសូវពូកែក្នុងការគ្រប់គ្រងក្រុមហ៊ុនដែលលក់ទំនិញឯកជននោះទេ ហើយដែលថាផ្នែកឯកជនក៏មិនសូវពូកែក្នុងការគ្រប់គ្រងវិស័យសុខុមាលភាព ឬកិច្ចការស្នូលសំខាន់ដទៃទៀតនៃផ្នែកសាធារណៈផងដែរ។

## សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល២៧ឆ្នាំកន្លងទៅនៃដំណាក់កាលកំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា យើងបានឆ្លងកាត់វិញ្ញាសាសាកល្បងជាច្រើន ជាមួយនឹងពិសោធន៍នានាដែលយើងទទួលបានពីការខិតខំប្រឹងប្រែងដោយផ្ទាល់លើការដ្ឋានការងារជាក់ស្តែងជាគុណតម្លៃខ្មែរ គួបផ្សំជាមួយនឹងការប្រើប្រាស់ដោយច្នៃប្រឌិតនៃការផ្លាស់ប្តូរ និងការចែករំលែកនូវគំនិតយោបល់ពីខាងក្រៅ ដែល*ជាគុណតម្លៃទំនើប* ទើបអាចជួយឱ្យយើងសម្រេចបាននូវអ្វីៗទាំងអស់នៅថ្ងៃនេះ។

សរុបមកវិញ ដំណើរការកំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជាបានឆ្លងកាត់ដំណាក់កាល តស៊ូ ពុះពារ ប្រកបដោយភាពស៊ូទ្រាំ អត់ធ្មត់ ជាមួយឆន្ទៈនយោបាយប្តូរផ្តាច់ ដើម្បីគោរពអនុវត្តខ្ជាប់ខ្ជួននូវគោលការណ៍គ្រឹះនៃរដ្ឋធម្មនុញ្ញ សំដៅកសាងប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព វឌ្ឍនភាព តាមគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស និងនីតិរដ្ឋ ដោយធានាបានសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ទោះជាត្រូវប្រឈមជាមួយឧបសគ្គ ការលំបាកសព្វបែបយ៉ាង លើដំណើរផ្លូវដ៏វែងឆ្ងាយក្នុងការផ្លាស់ប្តូរដ៏ជ្រាលជ្រៅ ដែលមានចរិតកំណត់ជោគវាសនាអនាគតប្រទេសជាតិ តែបេសកកម្មជាប្រវត្តិសាស្ត្រនេះ ដែលជានិច្ចកាលស្ថិតក្រោមមគ្គុទ្ទេសក៍ដ៏ភ្លឺស្វាងប្រកបដោយបញ្ញាញាណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែអាចពុះពារសម្រេចបាននូវសមិទ្ធផលធំធេង

ឥតគណនា រួមចំណែកដ៏ថ្លៃថ្លាក្នុងបុព្វហេតុសន្តិភាព វឌ្ឍនភាព និងសេចក្តីសុខសាន្ត ថ្កុំថ្កើង រុងរឿងរបស់ប្រទេសជាតិនិងប្រជាជនយើងជារៀងដរាបតទៅ។

# ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
# តាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ

ឯកឧត្តម សក់ សេដ្ឋា

## មូលន័យសង្ខេប

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីគោលការណ៍ជាមូលដ្ឋានក្នុងការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលក្នុងនោះ មាត្រា ១៤៥ថ្មី បានចែងថា "**ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់**" និងមាត្រា១៤៦ថ្មី បានចែងថា "**រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ**"។ ផ្អែកលើមូលដ្ឋាននេះ ច្បាប់រៀបចំអង្គការចំនួន ០៤ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តសម្រាប់ជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា រួមមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ក្របខ័ណ្ឌច្បាប់ដូចបានរៀបរាប់ខាងលើ និងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ បានរំលេចឡើងព្រមគ្នានូវ **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ** ដែលជាការបំពេញឱ្យគ្នាទៅវិញទៅមក សំដៅថែរក្សាការពារនូវអត្តសញ្ញាណជាតិ ប្រពៃណីទំនៀមទម្លាប់ល្អរបស់ប្រជាជាតិខ្មែរ ដើរទន្ទឹមនឹងការធ្វើទំនើបកម្មការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងនិរន្តរភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ ដែលកំណត់នៅក្នុងច្បាប់រៀបចំអង្គការ។ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅថ្នាក់ក្រោមជាតិ គឺជាដំណើរការនៃការផ្ទេរមុខងារ ធនធាន និងការទទួលខុសត្រូវពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវរៀបចំកម្មវិធីកំណែទម្រង់ដោយមានផែនការ មានការគ្រោងទុក ជាដំណាក់កាលៗ តាមការវិវឌ្ឍរីកចម្រើនរបស់សង្គម។ ដំណើរការនេះ ទាមទារឱ្យមានការរៀបចំនូវសមាសធាតុសំខាន់ៗចំនួន០២ ក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា**ការអភិវឌ្ឍផ្នែក**

**នយោបាយ និងការអភិវឌ្ឍផ្នែករដ្ឋបាល** ដែលសមាសធាតុទាំងពីរនេះមានទំនាក់ទំនង និងគាំទ្រគ្នាទៅវិញទៅមក ហើយត្រូវបានធ្វើការអភិវឌ្ឍដោយផ្អែកលើ **គុណតម្លៃទំនើប** និងគុណតម្លៃខ្មែរ ស្របតាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងការអនុវត្តជាក់ស្តែង ក្នុងរយៈពេលជិតពីរទសវត្សរ៍ចុងក្រោយនេះ កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ សម្រេចបានសមិទ្ធផលនានាជាច្រើន ដែលជាការឆ្លុះបញ្ចាំងនូវ **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ** ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ សម្រាប់ជាមូលដ្ឋានក្នុងការតាក់តែងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិនៅកម្ពុជា សំដៅចូលរួមពង្រឹងសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលយូរអង្វែង។ ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាន ក៏នៅមានបញ្ហាប្រឈមមួយចំនួនផងដែរ ដែលទាមទារឱ្យបន្តរួមគ្នាពង្រឹងការប្តេជ្ញាចិត្ត ជំរុញអនុវត្តកំណែទម្រង់នេះឱ្យកាន់តែទទួលបានជោគជ័យ ដែលក្នុងនោះ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការក្នុងរយៈពេល ១០ឆ្នាំខាងមុខ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ គឺ **"ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"**។

ជារួម ការធ្វើកំណែទម្រង់ និងការធ្វើទំនើបកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល ការវិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ច សង្គម ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងតម្រូវការកាន់តែច្រើនឡើងៗរបស់ប្រជាពលរដ្ឋ ព្រមទាំងត្រូវផ្សារភ្ជាប់ជាមួយនឹងកត្តាប្រវត្តិសាស្ត្រ នយោបាយ សង្គម វប្បធម៌ ប្រពៃណីរបស់កម្ពុជា។ សមិទ្ធផលនានាជាច្រើន និងមានលក្ខណៈជាប្រវត្តិសាស្ត្រ តាមរយៈកម្មវិធីកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ គឺបានមកដោយសារការគិតគូរពិចារណាថ្លឹងថ្លែងដាក់បញ្ចូលគ្នា ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកនូវ **គុណតម្លៃទំនើប** និង**គុណតម្លៃខ្មែរ** ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើមេរៀនបទពិសោធទទួលបានពីការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និង

ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមក ដើម្បីធានាដល់និរន្តរភាព និងប្រសិទ្ធភាពនៃការធ្វើកំណែទម្រង់សម្រាប់រយៈពេលពីមធ្យមទៅរយៈពេលវែង ទាមទារត្រូវពង្រឹងការប្តេជ្ញាចិត្តរួមគ្នាពុះពារជម្នះរាល់ឧបសគ្គ និងដោះស្រាយបញ្ហាប្រឈមនានា ដើម្បីបង្កើត និងពង្រឹងនូវកាលានុវត្តភាព និងនវានុវត្តន៍ថ្មីៗបន្ថែមទៀត សំដៅឈានទៅសម្រេចបានគោលដៅប្រែក្លាយប្រទេសកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## សេចក្តីផ្តើម

កម្ពុជាជាប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន ឬរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ខ្លួនជាយូរលង់ណាស់មកហើយ ដោយធ្វើការបែងចែកប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិជារដ្ឋបាលថ្នាក់ខេត្ត ថ្នាក់ក្រុង ថ្នាក់ស្រុក ថ្នាក់ឃុំ សង្កាត់ និងភូមិ។ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ត្រូវបានផ្លាស់ប្តូរជាញឹកញាប់ អាស្រ័យដោយការផ្លាស់ប្តូររបបនយោបាយ និងសង្គមកម្ពុជា។

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជានាពេលបច្ចុប្បន្ននេះ ត្រូវបានរៀបចំដោយអនុលោមតាមតម្លៃ និងគោលការណ៍ស្នូល ដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។ មាត្រា ១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "**ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់**" និងមាត្រា១៤៦ថ្មី បានចែងថា "**រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ**"។ លើមូលដ្ឋាននេះ ច្បាប់រៀបចំអង្គការចំនួន០៤ រួមមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត សម្រាប់ជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ។

## ១- ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ

ច្បាប់រៀបចំអង្គការទាំង០៤ ខាងលើ ក៏ដូចជាគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានាសម្រាប់ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ បានរំលេចឡើងនូវ **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ** ដោយបានផ្អែកទៅលើគោលការណ៍ជាមូលដ្ឋាននៃការលើកកម្ពស់សិទ្ធិមនុស្សនិងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ស្របតាមបរិបទជាក់ស្តែងនៃនយោបាយ សេដ្ឋកិច្ច សង្គម ប្រវត្តិសាស្ត្រ វប្បធម៌ និងប្រពៃណី ទំនៀមទម្លាប់របស់កម្ពុជា។

**គុណតម្លៃទំនើប** ក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា បានស្តែងឡើងតាមរយៈការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ និងប្រជាធិបតេយ្យ។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ មានក្រុមប្រឹក្សាមួយជាតំណាងសាធារណៈ ដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ដោយមានការចូលរួមប្រកួតប្រជែងពីគណបក្សនយោបាយនានា ដែលបានចុះបញ្ជីស្របច្បាប់នៅកម្ពុជា។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព ដែលមានស្វ័យភាព តែមិនមែនអធិបតេយ្យ ក្នុងការចាត់ចែងមុខងារ ធនធានរបស់ខ្លួន ដែលផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ផ្អែកតាមប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។ ការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅឆ្លើយតបនឹងតម្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួម។ ទន្ទឹមនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានធ្វើទំនើបកម្មជាបណ្តើរៗ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ក្នុងការបំពេញការងារ ការផ្តល់សេវាសាធារណៈនានា និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ។

**គុណតម្លៃខ្មែរ** ក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា បានស្តែងឡើងតាមរយៈការបែងចែកទឹកដីជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដោយផ្អែកតាមប្រវត្តិសាស្ត្រ នយោបាយ ភូមិសាស្ត្រ និងប្រជាសាស្ត្រ។ល។ ការរៀបចំទឹកដីដើម្បីគ្រប់គ្រងរដ្ឋបាលនេះ ត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា តាំងពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងរដ្ឋ

ធម្មនុញ្ញបន្តបន្ទាប់ រហូតដល់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ លើកលែងតែរដ្ឋធម្មនុញ្ញនៃរបប កម្ពុជាប្រជាធិបតេយ្យ។ ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់សុទ្ធតែផ្សារភ្ជាប់ជីវភាពរស់នៅ និងអត្តសញ្ញាណរបស់ខ្លួនដែលជាទីកន្លែងកំណើត ជាមួយខេត្ត ស្រុក ឃុំ ភូមិ។ ជាមួយគ្នានេះ ទន្ទឹមនឹងការដាក់បញ្ចូលនូវយន្តការ និងនីតិវិធីដែលមានលក្ខណៈទំនើប ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែប្រើប្រាស់នូវយន្តការ និងនីតិវិធីដែលមានលក្ខណៈជាប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌របស់កម្ពុជា ក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈ ការសម្របសម្រួល និងការដោះស្រាយជម្លោះ និងបញ្ហាប្រឈមមួយចំនួននៅមូលដ្ឋាន។

ជារួម **គុណតម្លៃខ្មែរ និងគុណតម្លៃទំនើប** ក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដែលធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាការការបំពេញឱ្យគ្នាទៅវិញទៅមក សំដៅថែរក្សាការពារអត្តសញ្ញាណជាតិ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់ប្រជាជាតិខ្មែរ ព្រមជាមួយនឹងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងនិរន្តរភាពនៃការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលបានកំណត់ក្នុងច្បាប់រៀបចំអង្គការ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តម្រូវឱ្យបង្កើត និងពង្រឹងនូវ **មូលធនសង្គម** ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋ និងការបង្កើត និងពង្រឹងនូវ **មូលធននយោបាយ** ដើម្បីពង្រឹងការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និង/ឬជាមួយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ[១] មានដូចខាងក្រោម៖

- **ភាពជាតំណាងសាធារណៈ៖** ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ អនុវត្តការងារក្នុងនាម ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រាល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សា គឺជាការសម្រេចចិត្តដែលតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនដីរបស់ខ្លួន។
- **ស្វ័យភាពមូលដ្ឋាន៖** ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានស្វ័យភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្តក្នុងក្របខ័ណ្ឌដែលច្បាប់បានកំណត់ ដើម្បីចាត់ចែង និងគ្រប់គ្រងមុខងារ និងធនធាន ដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម ប្រកបដោយប្រសិទ្ធភាព សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

១- មាត្រា១២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

– **ការពិគ្រោះយោបល់ និងការចូលរួម៖** ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលត្រូវធ្វើការពិភាក្សា និងពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយលើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់អំពីតម្រូវការ ផលប្រយោជន៍រួម និងផលប្រយោជន៍ផ្សេងៗគ្នា របស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

– **ការឆ្លើយតប និងគណនេយ្យភាព៖** ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាមានកាតព្វកិច្ចឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ តាមរយៈការរៀបចំគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

– **ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន៖** រាល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាគឺដើម្បី (១.) បង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយ ប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព (២.) លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និង (៣.) លើកកម្ពស់ផាសុកភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

– **ការលើកស្ទួយសមធម៌៖** រាល់ការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវមានការគិតគូរ និងយកចិត្តទុកដាក់ជាពិសេស ទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន កុមារ ក៏ដូចជាតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ ជនពិការ និងជនជាតិដើមភាគតិច។ល។

– **តម្លាភាព និងសុចរិតភាព៖** ក្រុមប្រឹក្សាត្រូវធានាថារាល់ការចាត់ចែង និងការគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវបានអនុវត្តដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព ច្បាប់ និងលិខិតបទដ្ឋានដែលមានជាធរមាន។ ជាមួយនេះ រាល់ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ជាក់លាក់ សុក្រឹត ងាយយល់ និងផ្សព្វផ្សាយជាសាធារណៈបានទាន់ពេលវេលា។

– **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច៖** ក្រុមប្រឹក្សាត្រូវប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងត្រូវជៀសវាងដាច់ខាតនូវការប្រព្រឹត្តអំពើពុករលួយ និងការរំលោភអំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

សរុបមក គោលបំណងជាចម្បងនៃការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ គឺដើម្បីៈ

១. ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

៣. កៀរគរការចូលរួមរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងភាពជាម្ចាស់របស់មូលដ្ឋានសម្រាប់បង្កើនល្បឿនការអភិវឌ្ឍមូលដ្ឋាន ដូចជាធនធានថវិកា គំនិតផ្តួចផ្តើម និងកម្លាំងពលកម្ម។ល។

ដើម្បីសម្រេចបានគោលបំណងខាងលើនេះ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានសមាសធាតុសំខាន់ពីរដែលត្រូវរៀបចំក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនោះគឺ **ការអភិវឌ្ឍផ្នែកនយោបាយ** និង**ការអភិវឌ្ឍផ្នែករដ្ឋបាល** ដែលផ្នែកទាំងពីរនេះមានទំនាក់ទំនងជាមួយគ្នា និងគាំទ្រគ្នាទៅវិញទៅមក ហើយត្រូវបានធ្វើការអភិវឌ្ឍដោយផ្អែកលើ **គុណតម្លៃទំនើប** និង **គុណតម្លៃខ្មែរ** ស្របតាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ការអភិវឌ្ឍផ្នែកនយោបាយ** សំដៅដល់ការបង្កើតនូវក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដែលត្រូវបានជ្រើសរើសតាមការបោះឆ្នោត ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដើម្បីធ្វើជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធ្វើសេចក្តីសម្រេចចិត្តនានា ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ប្រកបដោយស្វ័យភាព ការពិគ្រោះយោបល់ តម្លាភាព និងគណនេយ្យភាព។

**ការអភិវឌ្ឍផ្នែករដ្ឋបាល** សំដៅដល់ការបង្កើតនូវស្ថាប័ននៅថ្នាក់ក្រោមជាតិដែលមានសិទ្ធិ អំណាច មុខងារ ធនធាន និងសមត្ថភាពសមស្រប ព្រមទាំងមានបែបបទ និងនីតិវិធីច្បាស់លាស់ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ២- សមិទ្ធផលសំខាន់ៗ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ

ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ ក្នុងអំឡុងពេលជិតពីរទសវត្សរ៍កន្លងមកនេះ សម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

**១- ការរៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

អនុលោមតាមមាត្រា១៤៦ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់រៀបចំអង្គការចំនួន០៤ រួមមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំ និងអនុម័ត នាឆ្នាំ២០០១ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងអនុម័ត នាឆ្នាំ២០០៨។ ជាមួយនេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានរៀបចំ និងអនុម័ត នាឆ្នាំ២០០៥ ដែលជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់កំណត់នូវចក្ខុវិស័យ និងគោលការណ៍គ្រឹះជាមូលដ្ឋាននានា ក្នុងការដឹកនាំដំណើរការកែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនោះ ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ (២០១០-២០២០) និងកំពុងរៀបចំកម្មវិធីជាតិ រយៈពេល១០ឆ្នាំ ដំណាក់កាលទី២ (២០២១-២០៣០)។ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេសនានា ប្រមាណជាង ៣០០ប្រភេទ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង របៀបរបបនៃការអនុវត្តការងារ មុខងារធនធាន ផែនការអភិវឌ្ឍន៍ ព្រមទាំង គោលការណ៍ នីតិវិធី និងស្តង់ដារនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ជារួម លិខិតបទដ្ឋានដែលបានរៀបចំឡើងទាំងនេះមានលក្ខណៈសមល្មមដែលអាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងបំពេញការងារក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន នាពេលបច្ចុប្បន្ននេះ។ លិខិតបទដ្ឋានទាំងនេះនឹងអាចពិនិត្យ កែសម្រួល និងធ្វើវិសោធនកម្ម ដោយផ្អែកលើគោលនយោបាយ និងការវិវឌ្ឍនៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល រួមមានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់តាមវិស័យនានាជាដើម។ល។

**២- ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ**

មូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់ធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ និងការបង្កើនល្បឿននៃការអភិវឌ្ឍនៅមូលដ្ឋាន ត្រូវបានរៀបចំឡើង ដែលរួមមាន៖

– ការបង្កើតឡើងនូវក្រុមប្រឹក្សាតាមប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ តាមការបោះឆ្នោតសកល និងអសកល ដែលបានចាប់ផ្តើមជាដំបូង តាមរយៈការបោះឆ្នោតដោយផ្ទាល់ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស នាឆ្នាំ២០០២ និងការបោះឆ្នោតមិនផ្ទាល់ឬអសកលដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៩។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនេះ ត្រូវបានធ្វើឡើងជាទៀងទាត់ស្របតាមអាណត្តិដែលកំណត់ក្នុងច្បាប់។ នេះគឺជាសមិទ្ធផលជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជាយើង ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងជាការចាក់ឫសគល់ដ៏រឹងមាំនូវដំណើរការប្រជាធិបតេយ្យ សេរី ពហុបក្ស ក្នុងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា បន្ទាប់ពីប្រទេសកម្ពុជាយើងទទួលបានសុខសន្តិភាពពេញលេញក្រោម គោលនយោបាយឈ្នះ-ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

– ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ និងធនធាន ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព នៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រួមមាន នីតិវិធីរៀបចំកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា នីតិវិធីនៃការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា និងនីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌។

**៣. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន ដែលរហូតមកទល់ឆ្នាំ២០២០នេះ មានបុគ្គលិកចំនួន

ប្រមាណជាង ៩០.០០០នាក់ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកក៏ត្រូវបានផ្ដល់ តាមរយៈវគ្គបណ្ដុះបណ្ដាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្ដែង។ ទន្ទឹមនោះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានបង្កើតឡើងដើម្បីផ្ដល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៤- ការផ្ទេរមុខងារ និងការផ្ដល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីបំពេញមុខងារជាអាណត្តិទូទៅ និងមុខងារជាកាតព្វកិច្ច ដែលកំណត់ដោយច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។ មកទល់បច្ចុប្បន្ននេះ មានមុខងារក្នុងវិស័យសង្គមកិច្ច និងសុខាភិបាលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមានមុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០[២] ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កិតការផ្ដល់សេវាសាធារណៈឱ្យកៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន។ ជាមួយនេះ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើង ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់នានាពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងផ្ដល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ចំនួនប្រមាណជាង៦០០[៣] ប្រភេទសេវា លើវិស័យ និងកិច្ចការអាទិភាពនានា។ ព្រមជាមួយនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង២.០០០គម្រោងក្នុងមួយឆ្នាំៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងក្នុងមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

### ៥- វិមជ្ឈការហិរញ្ញវត្ថុ

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលរួមមានដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

---

២- អនុក្រឹត្យលេខ៣៤ អនក្រ.បក. ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ, អនុក្រឹត្យលេខ១៩៣ អនក្រ.បក. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត, អនុក្រឹត្យលេខ១៨២ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង, អនុក្រឹត្យលេខ១៨៣ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ, អនុក្រឹត្យលេខ១៨៤ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក

៣- អនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតឡើង ដែលរួមមាន ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ដូចជា មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌ ដូចជាប្រព័ន្ធផ្ទេរមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ព្រមទាំងប្រព័ន្ធចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ចាប់តាំងពីឆ្នាំ២០០២ មកទល់ឆ្នាំ២០២០នេះ រាជរដ្ឋាភិបាលបានផ្ទេរថវិកាជាតិ សរុបចំនួនប្រមាណជាង១៥,២ទ្រីលានរៀល ដែលប្រហាក់ប្រហែលនឹង ៣.៨០០លានដុល្លារ[៩] ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

**៦- ការរៀបចំប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានដូចជា ផែនការអភិវឌ្ឍន៍រយៈពេល០៥ឆ្នាំ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយលក្ខណៈបើកចំហ តម្លាភាព ការពិគ្រោះយោបល់ និងការចូលរួម ស្របទៅតាមចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌។

**៧- ការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

យន្តការគណនេយ្យភាពតាមបែបប្រជាធិតេយ្យត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលរួមមានដូចជាការបង្កើតការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានាក្រៅប្រព័ន្ធតុលាការ ពាក់ព័ន្ធនឹងការបំពេញមុខងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទនៅមូលដ្ឋានរវាងប្រជា-

---

៩- ទិន្នន័យរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ស្តីពីការផ្ទេរថវិការដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (មូលនិធិឃុំ សង្កាត់ គិតពីឆ្នាំ២០០២ ដល់ឆ្នាំ២០២០,មូលនិធិក្រុង ស្រុក គិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០ និងថវិការាជធានី ខេត្ត គិតពីឆ្នាំ២០០៩ ដល់ឆ្នាំ២០២០។)

ពលរដ្ឋនិងប្រជាពលរដ្ឋ និងការបង្កើតក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជា-ពលរដ្ឋទទួលបានព័ត៌មានសំខាន់ៗពាក់ព័ន្ធការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់កែលម្អលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវាកម្មនៅមូលដ្ឋានមួយចំនួនដូចជាសាលាបឋមសិក្សា និងមណ្ឌលសុខភាពជាដើម។

សមិទ្ធផលសំខាន់ៗដែលសម្រេចបានខាងលើនេះ គឺជាការឆ្លុះបញ្ចាំងនូវ **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ** ដែលមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូល សម្រាប់ជាមូលដ្ឋានក្នុងការតាក់តែងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិនៅកម្ពុជា សំដៅចូលរួមពង្រឹងសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព រយៈពេលយូរអង្វែង។

## ៣-បញ្ហាប្រឈមចម្បងៗនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ

ទន្ទឹមនឹងសមិទ្ធផលធំៗខាងលើ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ ដូចខាងក្រោម៖

– ទោះបីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបន្តបន្ទាប់នាពេលកន្លងមកក៏ដោយ ក៏ប៉ុន្តែរចនាសម្ព័ន្ធ និងប្រព័ន្ធទាំងនេះនៅមិនទាន់មានលក្ខណៈសមស្របទាំងស្រុងទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលមានលក្ខណៈជាទីក្រុងធំ(រាជធានីភ្នំពេញ) ទីប្រជុំជន(ក្រុង សង្កាត់) និងតំបន់ជនបទ(ស្រុក ឃុំ) ព្រមទាំងលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចសង្គមខុសៗគ្នា នៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

– ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន នៅពុំទាន់បំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយសារធនធាន និងសមត្ថភាពនៅមានកម្រិត។

– ទោះបីមានការរៀបចំនូវយន្តការជាច្រើន ដើម្បីធានាដល់ការចូលរួមផ្តល់

យោបល់ និងការតាមដានរបស់ប្រជាពលរដ្ឋទៅលើការធ្វើសេចក្ដីសម្រេចចិត្ត និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ប្រជាពលរដ្ឋភាគច្រើននៅតែពុំទាន់យល់ដឹងច្បាស់លាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន ក្នុងការជំរុញឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួននៅឡើយ។

– បើទោះបីជាមានការផ្ទេរមុខងារមួយចំនួន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏ការបែងចែកសមត្ថកិច្ច សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវលើការអនុវត្តមុខងារផ្តល់សេវាសាធារណៈចាំបាច់មួយចំនួន រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានភាពមិនទាន់ច្បាស់លាស់ និងមិនទាន់សមស្របទៅនឹងគោលនយោបាយវិមជ្ឈការក្នុងការបង្វិតការផ្តល់សេវាសាធារណៈ ទៅកៀកជិតជាមួយប្រជាពលរដ្ឋនៅឡើយ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋ នៅតែជួបការលំបាកក្នុងការទទួលបាននូវសេវាសាធារណៈចាំបាច់មួយចំនួន។

– បច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបាន និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធគ្រប់គ្រងការងារការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាសាធារណៈ។ ទោះយ៉ាងនេះក្តី រដ្ឋបាលថ្នាក់ក្រោមជាតិនៅបំពេញការងារភាគច្រើនផ្អែកលើប្រព័ន្ធរដ្ឋបាលប្រើប្រាស់ក្រដាសស្នាម និងការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋ ជាហេតុធ្វើឱ្យការទទួលសេវាសាធារណៈ និងការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋនៅមានភាពយឺតយ៉ាវ និងមានការលំបាក។ ប្រការនេះចាំបាច់ត្រូវជំរុញការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ជាពិសេសសម្រាប់រដ្ឋបាលទីប្រជុំជនដែលកំពុងមានការអភិវឌ្ឍ និងមានតម្រូវការសេវាកាន់តែច្រើនឡើងៗ។

## ៤- ចក្ខុវិស័យសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅដល់ឆ្នាំ២០៣០

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការក្នុងរយៈពេល១០ឆ្នាំខាងមុខ ពីឆ្នាំ២០២១ ទៅដល់ឆ្នាំ២០៣០ គឺ **“ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំ-**

ទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"[៥]។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវធ្វើការសិក្សាពិនិត្យ កែសម្រួល ដូចខាងក្រោម៖

**១- រចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

នៅឆ្នាំ២០៣០ រចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធទំនាក់ទំនងអន្តរស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗនឹងត្រូវបានរៀបចំកែសម្រួល ដោយផ្តោតលើការពង្រឹងនូវស្វ័យភាព ភាពជាម្ចាស់ ការទទួលខុសត្រូវ និងការបែងចែកនូវខ្សែគណនេយ្យភាពឱ្យបានច្បាស់លាស់។

ការបែងចែកការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់យ៉ាងច្បាស់លាស់។

ការប្រគល់មុខងារពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមគោលការណ៍ដែលបានកំណត់ថា **សេវាសាធារណៈនានាត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់ណាដែលមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច សង្គមខ្ពស់បំផុត និងឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋានបានយ៉ាងល្អប្រសើរ។** ក្រសួង ស្ថាប័នថ្នាក់ជាតិនឹងមានការទទួលខុសត្រូវសំខាន់ទៅលើការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារសេវា ការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការទទួលខុសត្រូវជាចម្បងលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារផ្តល់សេវាសាធារណៈចាំបាច់នានា និងអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ផ្អែកលើរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នាពេលបច្ចុប្បន្ន ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឱ្យមានលក្ខណៈកាន់តែសមស្រប និងឆ្លើយតបបានទៅនឹងការកើនឡើងនៃតម្រូវការសេវារបស់ប្រជាពលរដ្ឋ និងភាពផ្សេងៗគ្នានៃចរិតលក្ខណៈរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ជាទូទៅ បណ្តុំសេវានៅតំបន់ទីក្រុងនឹងត្រូវផ្តល់ដោយរដ្ឋបាល ដែលមានលក្ខណៈជាទីប្រជុំជន (រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់) ដោយឡែក សេវានៅតំបន់ជនបទនឹងត្រូវផ្តល់ដោយ

---

៥- ឯកសារទស្សនទានសម្រាប់កសាងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២

រដ្ឋបាលស្រុក ឬរដ្ឋបាលឃុំ។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ នឹងត្រូវពិនិត្យរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ដូចខាងក្រោម៖

❖ **ការសិក្សា និងការរៀបចំរដ្ឋបាលរាជធានីភ្នំពេញផ្អែកលើរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងទីក្រុងធំ**

បច្ចុប្បន្ន ភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈពិសេស បើប្រៀបធៀបទៅនឹងខេត្ត ក្រុងដទៃទៀតរបស់កម្ពុជា។ រាជធានីភ្នំពេញគឺជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ការទូតសេវាកម្ម និងជាទីកន្លែងបំពេញការងាររដ្ឋបាលនានា ទាំងកម្រិតជាតិ និងអន្តរជាតិយ៉ាងទូលំទូលាយ។ ជាមួយនេះ តំបន់ជាយក្រុងភ្នំពេញក៏បាន និងកំពុងអភិវឌ្ឍយ៉ាងលឿនទៅជាទីក្រុងរណបនៃរាជធានីភ្នំពេញដែលមានប្រជាជនរស់នៅយ៉ាងច្រើនកុះករ ដែលបង្កឡើងនូវបញ្ហាប្រឈមនានាជាច្រើន ជាពិសេសបញ្ហាបរិស្ថាន ចរាចរណ៍ និងអនាម័យ។ ហេតុនេះ ចាំបាច់ត្រូវធ្វើការពិនិត្យ និងរៀបចំគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញតាមប្រព័ន្ធនៃការគ្រប់គ្រងទីក្រុងធំ ដែលប្រទេសភាគច្រើនរៀបចំជារដ្ឋបាលទីក្រុង "មេត្រូប៉ូលីតែន"។ ប្រព័ន្ធគ្រប់គ្រងរាជធានីភ្នំពេញតាមបែបផែននៃប្រព័ន្ធគ្រប់គ្រងទីក្រុងធំ គឺមានលក្ខណៈដោយឡែកពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធនេះក៏នឹងត្រូវរៀបចំដោយផ្អែកលើគោលការណ៍នៃរដ្ឋបាលឯកភាពដែលអាចរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគដែលមានលក្ខណៈជាយុទ្ធសាស្ត្រ អាចអនុវត្តនូវគម្រោងវិនិយោគធំៗ ព្រមទាំងអាចសម្របសម្រួលបាននូវការផ្តល់សេវាសាធារណៈនានា ទូទាំងដែនដីនៃរដ្ឋបាលរាជធានីភ្នំពេញប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ជាមួយនឹងការកំណត់ឡើងវិញនូវសិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែច្បាស់លាស់រវាងរដ្ឋបាលរាជធានីភ្នំពេញជាមួយរដ្ឋបាល ខណ្ឌ សង្កាត់ និងក្រសួង ស្ថាប័នថ្នាក់ជាតិផងដែរ។

❖ **ការសិក្សា និងការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់**

ពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់ដោយផ្អែកលើគោលការណ៍នៃរដ្ឋបាលឯកភាព ដែលមានមុខងារសំខាន់ៗពាក់ព័ន្ធការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគជាយុទ្ធសាស្ត្រ ដើម្បីចូលរួមកាត់បន្ថយគម្លាតរវាងទីក្រុង ទីប្រជុំជន និងជនបទ ការគាំទ្រ ការសម្របសម្រួល ការត្រួតពិនិត្យនីត្យានុកូលភាព និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក និងឃុំ សង្កាត់) និងការអនុវត្តមុខងារធំៗដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ព្រមទាំងអនុវត្តនូវមុខងារផ្សេងៗ

ទៀតក្នុងនាមជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

❖ ការសិក្សា និងការរៀបចំរដ្ឋបាលក្រុង ស្រុកឱ្យទៅជារដ្ឋបាលមូលដ្ឋាន

ពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទៅជា **រដ្ឋបាលមូលដ្ឋាន**ដែលមានស្វ័យភាព និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សក្នុងកម្រិតសមស្របមួយ ផ្អែកតាមការរីកចម្រើននៃនគរូបនីយកម្ម ស្ថានភាពពាណិជ្ជកម្ម និងសក្តានុពលសេដ្ឋកិច្ច។ រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកមានតួនាទី និងការទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ ដែលជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលក្រុង ស្រុកដែលមានលក្ខណៈជាទីប្រជុំជន នឹងមានការទទួលខុសត្រូវជាអាទិភាពទៅលើការរៀបចំផែនការទីប្រជុំជន និងការគ្រប់គ្រងការផ្តល់សេវាទីប្រជុំជន ដូចជាសេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងផ្លូវក្នុងទីក្រុង ផ្លូវទីប្រជុំជន បណ្តាញលូបង្ហូរទឹក និងការគ្រប់គ្រងសំរាម និងកាកសំណល់រឹង រាវជាដើម។ល។ រដ្ឋបាលស្រុកដែលមានលក្ខណៈជាតំបន់ជនបទ នឹងមានការទទួលខុសត្រូវជាអាទិភាពទៅលើការងារកសិកម្ម អភិវឌ្ឍន៍ជនបទ ការបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ រួមទាំងការគ្រប់គ្រងបណ្តាញផ្លូវជនបទ ការផ្គត់ផ្គង់ទឹកស្អាត សេវាអនាម័យជនបទ និងការគ្រប់គ្រងសំរាមសំណល់រឹងជាដើម។ល។

❖ ការបន្តពង្រឹងរដ្ឋបាលឃុំសង្កាត់ជារដ្ឋបាលមូលដ្ឋានដែលនៅកៀកជិតបំផុតជាមួយប្រជាពលរដ្ឋ

បន្តពង្រឹងរដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ទៅជា**រដ្ឋបាលមូលដ្ឋាន** សម្រាប់ប្រាស្រ័យទាក់ទងដំបូងគេ របស់ប្រជាពលរដ្ឋជាមួយនឹងស្ថាប័នសាធារណៈ និងមានមុខងារ និងការទទួលខុសត្រូវក្នុងការផ្តល់សេវារដ្ឋបាលដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រៅពីការផ្តល់សេវារដ្ឋបាលមួយចំនួន រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវមានការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ ដូចជា ការផ្តល់សេវាក្នុងវិស័យសង្គមកិច្ចនៅតាមមូលដ្ឋាននានា ព្រមទាំងការទទួលខុសត្រូវលើការអភិវឌ្ឍ និងការថែទាំគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចៗមួយចំនួន។ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់នៅតែមានការទទួលខុសត្រូវលើការរៀបចំផែនការ និងការអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋានក្នុងក្របខ័ណ្ឌនៃមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលសាមី ផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ និងអាទិភាពនានាដែលបានកំណត់ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណភាពនៃជីវិតរបស់

ប្រជាពលរដ្ឋនៅតាមសហគមន៍ផ្សេងៗគ្នា។

**២- ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នឹងមានបុគ្គលិកសមល្មមសម្រាប់បំពេញការងារ ហើយបុគ្គលិកទាំងនោះនឹងមានលក្ខណសម្បត្តិសមស្របទាំងសមត្ថភាពជំនាញ និងបទពិសោធការងារ។ បុគ្គលិកម្នាក់ៗនឹងត្រូវកំណត់ឱ្យច្បាស់លាស់នូវល័ក្ខខ័ណ្ឌការងារប្រចាំឆ្នាំ ដោយផ្អែកលើការពិពណ៌នាមុខតំណែងនីមួយៗ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាព។ លទ្ធផលនៃការបំពេញការងាររបស់បុគ្គលិកទាំងនោះនឹងត្រូវធ្វើការវាយតម្លៃជារៀងរាល់ឆ្នាំ ដោយផ្អែកលើលក្ខណវិនិច្ឆ័យជាក់លាក់ ព្រមទាំងផ្តល់ការលើកទឹកចិត្ត និងការដាក់វិន័យទៅតាមលទ្ធផលនៃការវាយតម្លៃ។ បុគ្គលិកទាំងអស់នឹងត្រូវរៀបចំឱ្យមានការគ្រប់គ្រងតាមឋានានុក្រមយ៉ាងត្រឹមត្រូវ។ សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកគ្រប់គ្រងនៅតាមកម្រិតឋានានុក្រមនីមួយៗនឹងត្រូវកំណត់ឱ្យមានភាពច្បាស់លាស់ ដើម្បីលើកកម្ពស់ការគ្រប់គ្រង និងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការទទួលខុសត្រូវពេញលេញក្នុងការជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ នីតិវិធីនៃលក្ខន្តិកៈដោយឡែក និងលិខិតបទដ្ឋានគតិយុត្តសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅឆ្នាំ២០៣០ ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពដ៏មានប្រសិទ្ធភាពមួយសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្ត ដោយផ្តោតជាសំខាន់លើការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងជំនាញបច្ចេកទេសនៃបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមការពិពណ៌នាមុខតំណែង និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ។ ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពនេះ ត្រូវឆ្លើយតបទៅនឹងតម្រូវការនៃការបណ្តុះបណ្តាលដែលកំណត់ដោយស្ថាប័នថ្នាក់ជាតិ និងតម្រូវការនៃការបណ្តុះបណ្តាលដែលកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ។

ផ្នែកដ៏សំខាន់មួយទៀតនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការរៀនតាមប្រព័ន្ធអេឡិចត្រូនិកដែលគាំទ្រដោយគ្រូជំនាញឯកទេសនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន ឬនៅតាមក្រសួងស្ថាប័នផ្សេងទៀត និងតាមរយៈវគ្គសិក្សា

នៅនឹងកន្លែងរយៈពេលខ្លី និងរយៈពេលវែង។

**៣- ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នឹងទទួលបានធនធានហិរញ្ញ-វត្ថុពីប្រភពនានាដែលមានទំហំសមស្របសម្រាប់ការវិនិយោគ សម្រាប់លើកកម្ពស់ការផ្ដល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងការចំណាយលើការគ្រប់គ្រងរដ្ឋបាល។

ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ចំណូលពីការផ្ទេរពីថ្នាក់ជាតិក្នុងបែបផែនជាការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌ និងធនធានហិរញ្ញវត្ថុគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ដែលត្រូវកំណត់ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងរូបមន្តសមស្រប និងមានតម្លាភាព ចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបានពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធនៅតាមមូលដ្ឋានរបស់ខ្លួន ព្រមទាំងចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

ធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌនឹងត្រូវបានផ្ទេរក្នុងទំហំសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយនេះ ធនធានហិរញ្ញវត្ថុផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌនឹងត្រូវបង្កើនដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមស្របក្នុងការរ៉ាប់រងលើការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើសដែលរួមបញ្ចូលទាំងមុខងារដែលមានលក្ខណៈពហុវិស័យនានា ដើម្បីលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការកាន់តែច្រើនឡើងៗរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រាជរដ្ឋាភិបាលនឹងគិតគូរពិចារណាអំពីការប្រគល់នូវមូលដ្ឋានពន្ធ និងមិនមែនសារពើពន្ធបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព និងការប្រកួតប្រជែងក្នុងការប្រមូលចំណូលទាំងក្នុងក្របខ័ណ្ឌជាចំណូលមូលដ្ឋានរបស់ខ្លួន សំដៅកាត់បន្ថយនូវការពឹងផ្អែកទាំងស្រុងតែទៅលើការបែងចែកការផ្ទេរថវិកាពីថ្នាក់ជាតិ។

ជាមួយនេះ **កញ្ចប់ថវិកាពិសេស** ក៏នឹងត្រូវរៀបចំបង្កើតក្នុងគោលបំណងជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលខ្សត់ខ្សោយធនធាន ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍនៅតាមតំបន់ និងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានានៅទូទាំងប្រទេស ជាពិសេសជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាបន្ថែមទៀត ដល់តំបន់ដែលជាប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់

ជាតិ។ ព្រមជាមួយនេះ ប្រព័ន្ធត្រួតពិនិត្យ និងសវនកម្មហិរញ្ញវត្ថុ ក៏ត្រូវពង្រឹងឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីធានាបាននូវការគ្រប់គ្រង និងការចាត់ចែងប្រើប្រាស់ថវិកា ធនធាន ទ្រព្យសម្បត្តិដែលបានផ្ទេរ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។

**៤- រដ្ឋបាលអេឡិចត្រូនិក**

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវដាក់ឱ្យអនុវត្តនូវបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងកិច្ចការចាំបាច់មួយចំនួនរបស់ខ្លួន និងអាចឈានទៅអនុវត្តនៅក្នុងគ្រប់កិច្ចការទាំងអស់ផ្អែកតាមសមត្ថភាព និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងផ្អែកតាមភាពរីកចម្រើននៃប្រព័ន្ធព័ត៌មានវិទ្យា និងការយល់ដឹងរបស់ប្រជាពលរដ្ឋស្របទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅក្នុងប្រទេសកម្ពុជា ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់ឧស្សាហកម្ម ៤.០ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសអភិវឌ្ឍ។

កិច្ចការចាំបាច់នានាដែលនឹងអាចគ្រប់គ្រង និងផ្តល់សេវាតាមប្រព័ន្ធព័ត៌មានវិទ្យារួមមានដូចជា ទំនាក់ទំនងការងាររវាងរដ្ឋបាលនិងរដ្ឋបាល ទំនាក់ទំនងការងាររវាងរដ្ឋបាលនិងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធផ្សេងៗទៀត ការផ្តល់សេវាសាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍសមត្ថភាពជាដើម។

ការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិកមានទិដ្ឋភាពច្រើនយ៉ាង ប៉ុន្តែត្រូវផ្តោតលើការយល់ដឹងផ្នែកបច្ចេកទេសព័ត៌មានវិទ្យា និងការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវរៀនសូត្រមិនត្រឹមតែអំពីរបៀប និងដំណើរការកម្មវិធីឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៀត គឺការច្នៃប្រឌិតបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការងាររបស់ខ្លួន។

**៥- ការទទួលបានព័ត៌មាន តម្លាភាព និងគណនេយ្យភាព**

បន្តលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋក្នុងកិច្ចការគ្រប់វិស័យនៅមូលដ្ឋានក្នុងស្មារតីគោរពការពារផលប្រយោជន៍សាធារណៈនិងសហគមន៍។ បន្តលើកកម្ពស់ការយល់ដឹងទូលំទូលាយ និងទទួលបានព័ត៌មានច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាតំណាងរបស់ខ្លួន អំពីសេវាសាធារណៈដែលអាចទទួលបាន អំពីស្តង់ដារនៃការផ្តល់សេវាសាធារណៈ អំពីផែនការសកម្មភាពនិងធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីរបៀបនៃការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមផ្តល់មតិយោបល់ ចូលរួមអនុវត្ត

តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងបំពេញតួនាទីរបស់ខ្លួន ជាតំណាងជាប់ឆ្នោតរបស់ប្រជាពលរដ្ឋតាមរយៈការធ្វើសេចក្ដីសម្រេចចិត្ត និងការត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាលនិងបុគ្គលិករបស់ខ្លួន ដើម្បីលើកកម្ពស់គណនេយ្យភាពជាមួយប្រជាពលរដ្ឋ តាមរយៈការរៀបចំយន្តការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដែលមានលក្ខណៈទំនើប ងាយស្រួល បើកចំហ តម្លាភាព និងបរិយាប័ន្ន។

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងកាន់តែមានភាពជាម្ចាស់លើការងារគណនេយ្យភាព និងជំរុញការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារគណនេយ្យភាពនេះ។ ការងារគណៈ-នេយ្យភាពនឹងត្រូវបានពង្រឹង តាមរយៈការបន្តអនុវត្តការងារគណនេយ្យភាពសង្គម ការិយាល័យប្រជាពលរដ្ឋ និងយន្តការផ្សេងទៀត។ អង្គការសង្គមស៊ីវិលនឹងបន្តបំពេញតួនាទីសំខាន់របស់ខ្លួនក្នុងភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ព្រមទាំងតាមរយៈការសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការកសាងផែនការថវិកា ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការផ្ដល់ព័ត៌មានត្រឡប់ទៅឱ្យអង្គភាពផ្ដល់សេវា។

## សេចក្ដីសន្និដ្ឋាន

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍ប្រជាធិបតេយ្យ និងវិមជ្ឈការនៅកម្ពុជាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយត្រូវបានធ្វើកំណែទម្រង់ និងធ្វើទំនើបកម្មជាជំហានៗ ដើម្បីពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតប គណនេយ្យភាព និងតម្លាភាព តាមរយៈការលើកកម្ពស់សមត្ថភាពស្ថាប័ន និងធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។ ការធ្វើកំណែទម្រង់ និងការធ្វើទំនើបកម្មនេះ ត្រូវផ្អែកលើគោលនយោបាយរបស់រាជរដ្ឋា-ភិបាល ការវិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ច សង្គម ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងតម្រូវការកាន់តែច្រើនឡើងៗរបស់ប្រជាពលរដ្ឋ ព្រមទាំងត្រូវផ្សារភ្ជាប់ជាមួយកត្តាប្រវត្តិសាស្ត្រ នយោបាយ សង្គម វប្បធម៌ ប្រពៃណីរបស់កម្ពុជា។ សមិទ្ធផលសំខាន់ៗជាច្រើន និងមានលក្ខណៈជាប្រវត្តិសាស្ត្រ តាមរយៈកម្មវិធីកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ គឺបានមកដោយសារការគិតគូរពិចារណាថ្លឹងថ្លែង ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកនូវ គុណតម្លៃទំនើប និង គុណតម្លៃខ្មែរ ដែលមានក្នុងរដ្ឋធម្មនុញ្ញ

នៃព្រះរាជាណាចក្រកម្ពុជា ដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លៃ និងគោលការណ៍ស្នូលដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ជាតិ រួមមានដូចខាងក្រោម៖

- ការពង្រឹងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងនីតិរដ្ឋ
- ការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- ការលើកកម្ពស់អភិបាលកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីចូលរួមជំរុញការអភិវឌ្ឍជាតិ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋគ្រប់ៗរូប និងកាត់បន្ថយភាពក្រីក្រ
- ការលើកកម្ពស់សិទ្ធិ សេរីភាព និងសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ផ្អែកលើមេរៀន និងបទពិសោធទទួលបានពីការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមក ដើម្បីធានាដល់និរន្តរភាព និងប្រសិទ្ធភាពនៃការធ្វើកំណែទម្រង់សម្រាប់រយៈពេលពីមធ្យមទៅរយៈពេលវែង ចាំបាច់ត្រូវតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយក្នុងការធ្វើការកែទម្រង់ជាមួយនឹង ចក្ខុវិស័យច្បាស់លាស់ និងស្មារតីប្រុងប្រយ័ត្នខ្ពស់ សំដៅថែរក្សា និងពង្រឹងគុណតម្លៃខ្មែរ និងលើកកម្ពស់គុណតម្លៃទំនើបដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយពុះពារជម្នះរាល់ឧបសគ្គ និងការខិតខំដោះស្រាយបញ្ហាប្រឈមនានា សំដៅបង្កើត និងពង្រឹងនូវកាលានុវត្តភាព និងនវានុវត្តន៍ថ្មីៗបន្ថែមទៀត ដើម្បីរួមគ្នាឈានឆ្ពោះទៅសម្រេចបានគោលដៅប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

អនុក្រឹត្យលេខ៣៤ អនក្រ.បក. ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

អនុក្រឹត្យលេខ១៩៣ អនក្រ.បក. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

អនុក្រឹត្យលេខ១៨២ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង។

អនុក្រឹត្យលេខ១៨៣ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ។

អនុក្រឹត្យលេខ១៨៤ អនក្រ.បក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក។

អនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ទិន្នន័យរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ស្តីពីការផ្ទេរថវិការដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (មូលនិធិ ឃុំ សង្កាត់ គិតពីឆ្នាំ២០០២ ដល់ឆ្នាំ២០២០, មូលនិធិក្រុង ស្រុក គិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០ និងថវិការាជធានី ខេត្ត គិតពីឆ្នាំ២០០៩ ដល់ឆ្នាំ២០២០)

ឯកសារទស្សនទានសម្រាប់កសាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ឆ្នាំ២០២១-២០៣០។

# ប្រព័ន្ធទ្វិសភានៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស

ឯកឧត្តម អ៊ុំ សារឹទ្ធ

## សេចក្តីសង្ខេប

មកដល់បច្ចុប្បន្នប្រទេសកម្ពុជាបានឆ្លងកាត់របបនយោបាយផ្សេងៗគ្នា ជាច្រើន ហើយធ្លាប់មានរដ្ឋធម្មនុញ្ញចំនួន០៦ផ្សេងគ្នា។ របបសភាពីរថ្នាក់បានចាប់បដិសន្ធិនៅកម្ពុជា នៅពេលប្រទេសនេះមានរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧។ ក្រោយឆ្នាំ១៩៧៥ របបទ្វិសភាបានបាត់វត្តមានមួយរយៈ ហើយបានបង្ហាញខ្លួនជាថ្មីនៅឆ្នាំ១៩៩៩។

បទបង្ហាញនេះនឹងពិភាក្សាពីការវិវត្តនៃប្រព័ន្ធសភាក្នុងរដ្ឋធម្មនុញ្ញកម្ពុជា,បង្ហាញអំពីចរិតលក្ខណៈនៃប្រព័ន្ធទ្វិសភា, ពិភាក្សាពីសារៈសំខាន់នៃប្រព័ន្ធទ្វិសភាក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ព្រមទាំងសិក្សាអំពីបញ្ហាប្រឈម និងទស្សនវិស័យអនាគតនៃរបបទ្វិសភា ហើយនៅចុងបញ្ចប់នឹងធ្វើការសន្និដ្ឋានអំពីគុណតម្លៃនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន និងស្ថានភាពនៃការអនុវត្តប្រព័ន្ធទ្វិសភារបស់កម្ពុជា។

## ១- សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ហើយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ។

ជាទូទៅ រដ្ឋធម្មនុញ្ញតែងមានបទប្បញ្ញត្តិចែងអំពីអធិបតេយ្យ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ របបនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ការលើកស្ទួយការគោរពសិទ្ធិមនុស្ស ការបែងចែកអំណាចដាច់ពីគ្នា ការគ្រប់គ្រងរដ្ឋបាល ការបោះឆ្នោត និងអំពីប្រព័ន្ធរដ្ឋាភិបាល សភា និងស្ថាប័នធម្មនុញ្ញនានា ជាដើម។ ភាគច្រើនក៏មានរួមបញ្ចូលនូវប្រវត្តិសាស្ត្រ និងអត្តសញ្ញាណរបស់ជាតិ ព្រមទាំងលក្ខណៈពិសេសទាក់ទងនឹងសាសនា វប្បធម៌ និងប្រពៃណីរបស់ប្រទេសនីមួយៗ។

គោលការណ៍ស្នូលនៃរដ្ឋធម្មនុញ្ញទំនើបរួមមានជាអាទិ៍ៈ ការប្រតិបត្តិលទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាចទាំងបីឯករាជ្យពីគ្នា ការលើកស្ទួយការការពារសិទ្ធិមនុស្ស និងការប្រតិបត្តិតាមគោលការណ៍នីតិរដ្ឋ។ គោលការណ៍ទាំងបួននេះ គឺជាលក្ខណៈវិនិច្ឆ័យកំណត់រដ្ឋធម្មនុញ្ញនិយម(Constitutionalism) របស់ប្រទេសនីមួយៗ។

កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្ដូររបបនយោបាយចំនួនប្រាំលើក គិតចាប់ពីពេលទទួលបានឯករាជ្យពេញលេញពីបារាំងនៅឆ្នាំ១៩៥៣។ កម្ពុជាផ្ដើមមានរដ្ឋធម្មនុញ្ញដំបូងចាប់ពីឆ្នាំ១៩៤៧ ទោះបីជាពេលនោះកំពុងស្ថិតនៅក្រោមអាណានិគមបារាំងក្ដី។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលកំពុងតែប្រើប្រាស់នាពេលបច្ចុប្បន្នគឺជារដ្ឋធម្មនុញ្ញទី៦ របស់កម្ពុជា។ រដ្ឋធម្មនុញ្ញទី១ ត្រូវបានអនុម័តដាក់ឱ្យប្រើនៅឆ្នាំ១៩៤៧ (រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រកម្ពុជា), រដ្ឋធម្មនុញ្ញទី២ត្រូវបានប្រកាសដាក់ឱ្យប្រើនៅឆ្នាំ១៩៧២ (រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ), ទី៣ នៅឆ្នាំ១៩៧៦ (រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ), ទី៤នៅឆ្នាំ១៩៨១ (រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា) និងទី៥ នៅឆ្នាំ១៩៨៩ (រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា)។

រដ្ឋធម្មនុញ្ញទី១ នៃព្រះរាជអាណាចក្រកម្ពុជាបានកំណត់ថា កម្ពុជាអនុវត្តរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រ (ព្រះមហាក្សត្រីយ៍[១]) គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច បង្កើតឱ្យមានរបបប្រជាធិបតេយ្យសេរីពហុបក្ស អនុវត្តប្រព័ន្ធសភានិយម និងមានការបែងចែកអំណាចដាច់ពីគ្នារវាងអង្គនីតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និងអំណាចតុលាការ។

របបទ្វិសភាក្នុងសម័យព្រះរាជអាណាចក្រកម្ពុជា មានរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ។ ក្រៅពីនេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ក៏មានចែងអំពីសភាប្រជារាស្ត្រប្រចាំខេត្ត ឬប្រចាំរាជធានី ការប្រជុំជាសមាជរវាងរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ និងការប្រជុំសមាជជាតិមួយឆ្នាំពីរដងយ៉ាងតិច។

នៅក្នុងរបបនយោបាយបន្ទាប់ រដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋខ្មែរ បានចែងអំពីប្រព័ន្ធទ្វិសភា (សភាជាតិ និងព្រឹទ្ធសភា)។ សម័យសាធារណរដ្ឋខ្មែរក៏មានបទប្បញ្ញត្តិចែងអំពីការប្រជុំជាសមាជសភារវាងសភាជាតិ និងព្រឹទ្ធសភាផងដែរ។

នៅក្នុងរបបនយោបាយជាបន្តបន្ទាប់ ដែលរួមមានកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រព័ន្ធទ្វិសភាបានជំនួសមកវិញដោយរបបឯកសភា។ របបកម្ពុជាប្រជាធិបតេយ្យហៅសភាថា *សភាតំណាងប្រជាជនកម្ពុជា*។ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា មានសភាមួយថ្នាក់ ហៅថា *រដ្ឋសភា*។ រហូតដល់ឆ្នាំ

---

១- គួរកត់សម្គាល់ថា ក្រោយការសោយព្រះទិវង្គតរបស់ព្រះបាទ សម្ដេច ព្រះសុរាម្រិត នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៦០, រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្ម នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦០ ដោយអនុញ្ញាតឱ្យប្រមុខរដ្ឋដែលជាតួនាទីប្រពៃណីរបស់ព្រះមហាក្សត្រ នៅក្នុងប្រទេសអនុវត្តប្រព័ន្ធសភានិយម អាចត្រូវបានបោះឆ្នោតជ្រើសតាំងដោយសភាទាំងពីរ។ ជាលទ្ធផលព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ទ្រង់កាន់តំណែងជាប្រមុខរដ្ឋផង និងជានាយករដ្ឋមន្ត្រីផង ក្នុងពេលដែលកម្ពុជានៅតែប្រកាន់យករបបរាជានិយម ដោយមានព្រះមហាក្សត្រីយ៍គ្រងរាជសម្បត្តិ។

១៩៩៩[២] ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទីពីរ ទើបគេឃើញវត្តមានប្រព័ន្ធទ្វិសភាឡើងវិញ។ ប្រទេសនៅលើសកលលោកប្រមាណ៨០ ប្រើប្រាស់ប្រព័ន្ធទ្វិសភា។ តាមការសិក្សារបស់សហភាពអន្តរសភា ការជ្រើសរើសយករចនាសម្ព័ន្ធសភាណាមួយ ចំណុះភាគច្រើនលើកត្តាប្រវត្តិសាស្ត្រ បរិបទ និងប្រពៃណីសភារបស់ប្រទេសនីមួយៗ។

## ២. អំពីប្រព័ន្ធទ្វិសភា

ទ្វិសភា ជាប្រព័ន្ធសភាពីរថ្នាក់ ដែលអាចជា សភាទី១ និងសភាទី២ ឬសភាជាន់ទាប និងសភាជាន់ខ្ពស់។ ជាទូទៅសភាទី១ ឬសភាជាន់ទាប អាចត្រូវបានហៅឈ្មោះខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដែលមានជាអាទិ៍ ដូចជា House of Representatives, House of Commons, Chamber of Deputies ឬ Federal Assembly។ សភាទី២ ឬសភាជាន់ខ្ពស់ គឺជាអង្គនីតិប្បញ្ញត្តិ ដែលមានទ្រង់ទ្រាយតូចជាងសភាទី១ ឬសភាជាន់ទាប មានអំណាចតិចជាង ប៉ុន្តែតាមប្រពៃណី និងទម្លាប់ដែលអនុវត្តកន្លងមកសភាទី២ ឬសភាជាន់ខ្ពស់មានអាណត្តិយូរជាង។ សភាទី២ ឬសភាជាន់ខ្ពស់ អាចត្រូវបានហៅឈ្មោះផ្សេងៗ ដូចជា Senate, House of Lords ឬ Federal Council ជាដើម។ ការកំណត់សមាសភាពសមាជិកសភាទី២ ឬសភាជាន់ខ្ពស់ អាចប្រព្រឹត្តទៅបានតាមរយៈការតែងតាំង ការបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល ឬដោយប្រព័ន្ធចម្រុះ តែងតាំងខ្លះ បោះឆ្នោតជ្រើសតាំងខ្លះ។ <u>សភាទី២ ឬសភាជាន់ខ្ពស់ក្នុងប្រទេសមួយចំនួន ដើរតួជាតំណាងឱ្យតំបន់ ភូមិភាគ ឬរដ្ឋណាមួយរបស់ប្រទេស</u> ដូចជានៅសហរដ្ឋអាមេរិក និងអាឡឺម៉ង់ជាដើម។ ជាទូទៅ ប្រជាជនផ្តល់ជំនឿទុកចិត្តចំពោះសភាទី២ ឬសភាជាន់ខ្ពស់ តាមរយៈការបោះឆ្នោតដោយប្រយោល ឬដោយផ្ទាល់។ ក្នុងការបោះឆ្នោតដោយផ្ទាល់ ប្រជាពលរដ្ឋបោះឆ្នោតទៅឱ្យបេក្ខភាពតំណាងគណបក្សនយោបាយដើម្បីកាន់អំណាច។ រីឯការបោះឆ្នោតមិនផ្ទាល់ ប្រជាពលរដ្ឋត្រូវបោះឆ្នោតទៅឱ្យតំណាងអង្គរដ្ឋបាលដែនដី ដែលជាអ្នកបោះឆ្នោតបន្ត ដើម្បីជ្រើសតាំងសមាជិកសភាទី២ ឬសភាជាន់ខ្ពស់។ សភាទី២ ឬសភាជាន់ខ្ពស់ដែលកើតចេញពីការបោះឆ្នោតទោះដោយផ្ទាល់ ឬប្រយោល ឬដោយការតែងតាំងក្តី សុទ្ធតែមានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងសុទ្ធជាអ្នកអនុវត្តដំណើរការប្រជាធិបតេយ្យូបនីយកម្ម នៅក្នុងប្រទេសនោះ។[៣]

២- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (វិសោធនកម្មថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩) អនុញ្ញាតឱ្យព្រះរាជាណាចក្រកម្ពុជាបង្កើតព្រឹទ្ធសភាមួយទៀតបន្ថែមលើរដ្ឋសភាមានស្រាប់ចាប់តាំងពីឆ្នាំ១៩៩៣មក។

៣- National Democratic Institute (NDI) For International Affairs. Legislative Research Series Paper 3. One Chamber or Two – Deciding between a Unicameral and Bicameral Legislature.

សិទ្ធិអំណាចរបស់សភាទាំងពីរថ្នាក់មានកម្រិតខុសគ្នា ស្មើភាព ឬមិនស្មើភាពគ្នា ដោយផ្អែកលើការកំណត់ក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗ។ សភាថ្នាក់លើរបស់ប្រទេសមួយចំនួនមានអំណាចក្នុងការពន្យារ ឬវ៉េតូ ឬកែសម្រួលសេចក្តីព្រាងច្បាប់ដែលបានអនុម័តដោយសភាទី១ ឬសភាជាន់ទាប ខណៈប្រទេសមួយចំនួនទៀត សភាទី២ ឬសភាជាន់ខ្ពស់ មានអំណាចត្រឹមតែផ្តល់ការប្រឹក្សាប៉ុណ្ណោះ។ ជាឧទាហរណ៍ ចក្រភពអង់គ្លេសប្រើប្រាស់ប្រព័ន្ធទ្វិសភា ដែលសភាជាន់ទាបមានសិទ្ធិអំណាចច្រើន ក្នុងការអនុម័តច្បាប់។ រីឯប្រព័ន្ធទ្វិសភារបស់សហរដ្ឋអាមេរិកវិញ សភាទាំងពីរមានអំណាចស្មើគ្នា ដែលតម្រូវឱ្យការអនុម័តច្បាប់នានាត្រូវមានការយល់ព្រមពីសភាទាំងពីរថ្នាក់។[៤]

## ៣- ប្រព័ន្ធទ្វិសភាក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា

### ១- ហេតុអ្វីកម្ពុជាអនុវត្តប្រព័ន្ធទ្វិសភានៅឆ្នាំ១៩៤៧ និងឆ្នាំ១៩៩៩?

របបទ្វិសភាដំបូងនៃព្រះរាជាណាចក្រកម្ពុជាទី១ បានដំណើរការដោយរលូន និងមានអត្ថិភាពរយៈពេល២៣ឆ្នាំ ពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៧០ ទោះបីជាមានព្រឹត្តិការណ៍នយោបាយ និងការប្រែប្រួលថ្មីៗនៅក្នុងប្រទេស ព្រមទាំងសភាពការណ៍តំបន់ និងពិភពលោកជះឥទ្ធិពល ជាបន្តបន្ទាប់យ៉ាងណាក្តី។

ប្រជាជាតិខ្មែរមានរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧ ហើយមានសេចក្តីក្លាហានទទួលយករបបទ្វិសភា (រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ) តាមលំនាំនៃសាធារណរដ្ឋបារាំងទីបួន មកអនុវត្តឱ្យបានស្របនឹងតថភាពរបស់សង្គមកម្ពុជា ដែលមានព្រះមហាក្សត្រ សោយរាជ្យសម្បត្តិ។

ទន្ទឹមនឹងគុណតម្លៃទំនើប នៃរបបទ្វិសភាដែលខ្មែរពុំធ្លាប់មានទាល់តែសោះ ខ្មែរបានអនុវត្តដោយបញ្ចូលអំពីការគោរពដល់អង្គព្រះមហាក្សត្រជាទីសក្ការៈ ដែលអាចចាត់តាំងព្រះរាជវង្សានុវង្សចំនួន ២ព្រះអង្គទៅក្នុងក្រុមប្រឹក្សាព្រះរាជអាណាចក្រ។

សភាទាំងពីរមានលក្ខណៈពិសេសផ្ទាល់រៀងៗខ្លួន និងអនុវត្តជ្រើសតាំងតាមច្បាប់បោះឆ្នោតផ្សេងគ្នា។

ក្រោយបាត់វត្តមានមួយរយៈ របបទ្វិសភាបានចាប់បដិសន្ធិសាជាថ្មីនៅកម្ពុជានៅឆ្នាំ១៩៩៩។ ដើមឡើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កំណត់ឱ្យកម្ពុជាអនុវត្តប្រព័ន្ធឯកសភាពោលគឺមានតែរដ្ឋសភាមួយប៉ុណ្ណោះ។ ប៉ុន្តែក្រោយការបោះឆ្នោតរដ្ឋសភានីតិកាលទី២ នៅឆ្នាំ១៩៩៨ កម្ពុជាបានធ្លាក់ទៅក្នុងភាពទាល់ច្រកផ្នែកនយោបាយមួយ ដោយសារ

---

៤- National Democratic Institute (NDI) For International Affairs. Legislative Research Series Paper 3. One Chamber or Two – Deciding between a Unicameral and Bicameral Legislature.

ក្នុងចំណោមគណបក្សនយោបាយទាំងបីដែលឈ្នះការបោះឆ្នោត[៥] មិនមានគណបក្សណាមួយទទួលបានសំឡេងគាំទ្រភាគច្រើនពីរភាគបី គ្រប់គ្រាន់ដើម្បីបង្កើតរាជរដ្ឋាភិបាលឡើយ។ ការចរចានយោបាយដើម្បីឈានទៅរៀបចំក្បាលម៉ាស៊ីនដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល ជួបប្រទះភាពទាល់ច្រក។ ប្រឈមមុខចំពោះបញ្ហានេះ ព្រះករុណាព្រះបាទសម្ដេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាក្សត្រកម្ពុជា បានដើរតួនាទីសម្របសម្រួល ហើយជាលទ្ធផល ជំនួបកំពូលនៅព្រះបរមរាជវាំងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបរមរតនកោដ្ឋ នៅថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ បានឈានដល់ការឯកភាពបញ្ចប់ភាពជាប់គាំង ដោយគណបក្សចំនួនពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលជាគណបក្សឈ្នះការបោះឆ្នោតច្រើនជាងគេលំដាប់ទីមួយ និងទីពីរ បានព្រមព្រៀងគ្នាចូលរួមក្នុងរាជរដ្ឋាភិបាលចម្រុះ ហើយឯកភាពគ្នាស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបង្កើតឱ្យមានព្រឹទ្ធសភា។

**២- សារៈសំខាន់របស់ព្រឹទ្ធសភាចំពោះរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា**

ការបង្កើតព្រឹទ្ធសភានៅឆ្នាំ១៩៩៩ គឺជាព្រឹត្តិការណ៍នយោបាយដ៏ចម្បងមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយសម្រាប់អនាគតនៃប្រទេសកម្ពុជា ព្រមទាំងបង្ហាញឱ្យឃើញពីការប្ដេជ្ញាចិត្តជាបន្តបន្ទាប់ ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ ការពង្រឹងនីតិរដ្ឋ និងជាការថែរក្សាមរតកស្ថាប័នប្រជាធិបតេយ្យដ៏សំខាន់សម្រាប់កម្ពុជា។[៦]

មួយខែក្រោយពីបានបង្កើតស្ថាប័នព្រឹទ្ធសភាឡើងវិញ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN)។

ព្រឹទ្ធសភាបានរួមចំណែកយ៉ាងសំខាន់ជាមួយរដ្ឋសភាក្នុងការពូនជ្រុំ និងពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ តាមរយៈការអនុវត្តមុខងារតំណាង មុខងារនីតិកម្ម និងមុខងារតាមដានការអនុវត្តច្បាប់។

**ក- មុខងារតំណាង**

តាមមាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញ *សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ*។ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា កំណត់ថាការបោះឆ្នោតអសកលនេះ មានអង្គបោះឆ្នោតជាសមាជិកក្រុម

៥- គណបក្សទាំងបីដែលឈ្នះការបោះឆ្នោតសកលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ គឺគណបក្សប្រជាជនកម្ពុជា (៦៤អាសនៈ) គណបក្សហ្វ៊ុនស៊ិនប៉ិច(៤៣អាសនៈ) និងគណបក្សសមរង្ស៊ី(១៥អាសនៈ)។

៦- ប្រវត្តិព្រឹទ្ធសភាកម្ពុជា។ គេហទំព័រព្រឹទ្ធសភា https://senate.gov.kh/kh1/templates/protostar/about-senate.php

ប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រនៅក្នុងតំណែង ហើយមណ្ឌលបោះឆ្នោតរបស់ព្រឹទ្ធសភាត្រូវចែកជា ៨ភូមិភាគ[៧]។ លើមូលដ្ឋាននេះ ព្រឹទ្ធសភាមានអត្តសញ្ញាណជាតំណាងឱ្យឆន្ទៈដ៏សំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងអស់ និងជាអ្នកជំរុញដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ។ ចំណែកឯសមាជិកដែលត្រូវបានចាត់តាំងវិញ គឺស្ថិតក្នុងល័ក្ខខ័ណ្ឌមួយដែលថាសមាជិកទាំងពីររូប គឺជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ។ ទិដ្ឋភាពនេះបានបង្ហាញឱ្យឃើញពីការប្រចាប់បញ្ចូលគ្នានូវគោលការណ៍គុណតម្លៃបែបខ្មែរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ១៩៤៧ រួមនិងគោលការណ៍គុណតម្លៃទំនើបតាមរយៈការបោះឆ្នោតអសកល។

បន្ថែមលើមុខងារតំណាងដ៏សំខាន់នេះ ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលផងដែរ ដែលជាវិសេសភាពផ្ទាល់របស់ព្រះរាជាណាចក្រកម្ពុជា។[៨]

**ខ- មុខងារនីតិកម្ម**

នៅក្នុងមុខងារនីតិកម្ម ព្រឹទ្ធសភាមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ និងស្នើធ្វើវិសោធនកម្មច្បាប់។ បន្ថែមលើនេះ នៅក្នុងដំណើរការនីតិកម្ម ព្រឹទ្ធសភាមានតួនាទីជាអ្នកពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមកក្រោយពេលបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយ។ ព្រឹទ្ធសភាអាចស្នើសុំឱ្យរដ្ឋសភាកែសម្រួល ហើយព្រឹទ្ធសភាក៏អាចបដិសេធច្បាប់ណាមួយចោលជាអសារបង់បានដែរ បើទោះជាអំណាចសម្រេចលើច្បាប់នោះ នៅទីបំផុតស្ថិតក្នុងដៃរដ្ឋសភាក៏ដោយ។

ផ្អែកលើតួនាទីខាងលើ យើងឃើញថា ព្រឹទ្ធសភាគឺជាតួអង្គសំខាន់ដែលចូលរួមធ្វើកំណែទម្រង់ច្បាប់ ដើម្បីធ្វើឱ្យច្បាប់កាន់តែមានគុណភាព បម្រើឱ្យឧត្តមប្រយោជន៍របស់ជាតិនិងប្រជាជន និងការបង្ហាញជំហរក្នុងនាមជាតំណាងឆន្ទៈរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានដែលជាអ្នកអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទាំងនេះគឺជាកត្តាកំណត់យ៉ាងច្បាស់ពីការគោរពគោលការណ៍សំខាន់ៗ និងការបែងចែកអំណាចតាមលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋក្នុងរដ្ឋធម្មនុញ្ញទំនើប។

---

៧- ភូមិភាគទាំង៨ មានដូចជាៈ ភូមិភាគទី១ មានរាជធានីភ្នំពេញ, ភូមិភាគទី២ រួមមានខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ភូមិភាគទី៣ មានខេត្តកណ្តាល ភូមិភាគទី៤ រួមមានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន ភូមិភាគទី៥ រួមមានខេត្តតាកែវ ខេត្តកំពត និងខេត្តកែប ភូមិភាគទី៦ រួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀង ភូមិភាគទី៧ រួមមានខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ និងភូមិភាគទី៨ រួមមានខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

៨- Konrad-Adenauer-Stiftung, Cambodian Constitutional Law (2016). Phnom Penh, Cambodia.

គ- មុខងារត្រួតពិនិត្យ (តាមដានការអនុវត្តច្បាប់)

បើទោះបីជាមិនមានបទប្បញ្ញត្តិណាមួយ ក្នុងរដ្ឋធម្មនុញ្ញចែងអំពីអំណាចត្រួតពិនិត្យរបស់ព្រឹទ្ធសភា ប៉ុន្តែនៅក្នុងដំណើរការនីតិកម្ម ព្រឹទ្ធសភាមានសិទ្ធិកោះអញ្ជើញសមាជិកគណៈរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលមកឆ្លើយបំភ្លឺ នៅចំពោះមុខគណៈកម្មការបាន។ ការត្រួតពិនិត្យរបស់ព្រឹទ្ធសភាមិនសំដៅដើម្បីចាប់កំហុសរាជរដ្ឋាភិបាលទេ ប៉ុន្តែដើម្បីទទួលបានព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គម និងគ្រប់វិស័យដែលពាក់ព័ន្ធ ហើយជាងនេះទៀត គឺដើម្បីធានាថាច្បាប់មានគុណភាព និងអាចអនុវត្តបានដោយល្អប្រសើរ និងរលូន (le contrôle par le suivi, l'évaluation et l'orientation)។

## ៤- **ការប្រឈម**

### ១- ឱនភាពនៃលទ្ធិប្រជាធិបតេយ្យលើពិភពលោក

សភាដើរតួនាទីសំខាន់ណាស់នៅក្នុងដំណើរការប្រជាធិបតេយ្យូបនីយកម្មនៅក្នុងប្រទេសនីមួយៗ។ សភាតំណាងឱ្យសំឡេងរបស់ម្ចាស់ឆ្នោត និងជានិមិត្តរូបនៃក្តីសង្ឃឹម និងជំនឿរបស់ប្រជាពលរដ្ឋ។ តាមរយៈសភា ប្រជាពលរដ្ឋអាចចូលរួមបញ្ចេញមតិយោបល់ចំពោះការដឹកនាំគ្រប់គ្រងរដ្ឋ គ្រប់គ្រងសេដ្ឋកិច្ច និងគ្រប់គ្រងសង្គមរបស់រដ្ឋ។

ជាទូទៅ សភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋ បើទោះបីជាសភាជាន់ខ្ពស់នៅប្រទេសខ្លះ អនុវត្តការបោះឆ្នោតជ្រើសតាំងខ្លះ និងចាត់តាំងខ្លះ ឬក៏ចាត់តាំងទាំងស្រុងក៏ដោយ។ គួរកត់សម្គាល់ថា ដោយសារការធ្លាក់ចុះនៃជំនឿរបស់ប្រជាពលរដ្ឋចំពោះតំណាងរបស់ខ្លួន ដែលភាគច្រើនមិនបានបំពេញតាមការសន្យាជាមួយប្រជាពលរដ្ឋ ចំនួនប្រជាពលរដ្ឋដែលចេញទៅបោះឆ្នោតនៅក្នុងប្រទេសជាច្រើនបានធ្លាក់ចុះ ជាពិសេសគឺនៅក្នុងប្រទេសប្រជាធិបតេយ្យធំៗក្នុងប្លុកលោកខាងលិចតែម្តង។

អត្រាចេញទៅបោះឆ្នោតទាប ជួនកាលក្រោម៥០% គឺជាសូចនាករបង្ហាញអំពីឱនភាពនៃជំនឿចិត្តពីភាពជាតំណាងរបស់ស្ថាប័នដែលនឹងកើតចេញពីការបោះឆ្នោតនោះ។ ក្នុងន័យនេះ បើសភា និងរដ្ឋាភិបាលកើតចេញពីការបោះឆ្នោត ដែលមានប្រជាពលរដ្ឋចូលរួមបោះឆ្នោតតិច នោះអាចមានន័យថាការទទួលស្គាល់ធម្មានុរូបភាពរបស់ស្ថាប័នពីសំណាក់ប្រជាជនក៏មានតិចផងដែរ។

នាយុគសម័យបច្ចុប្បន្ន ឱនភាពនៃលទ្ធិប្រជាធិបតេយ្យត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការតស៊ូគ្នារវាងកម្លាំងនយោបាយនៅក្រោយការបោះឆ្នោត អាស្រ័យដោយ ÷

-សំឡេងភាគច្រើនចេញពីការបោះឆ្នោតពុំបានគ្រប់គ្រាន់ក្នុងការបង្កើតរដ្ឋាភិបាល (រដ្ឋាភិបាល សំឡេងភាគតិច)

- ការបោះឆ្នោតត្រូវធ្វើច្រើនលើកទើបបង្កើតរដ្ឋាភិបាលថ្មីបាន

- ភាគីចាញ់អាចធ្វើបាតុកម្មតវ៉ាតាមផ្លូវ មិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដោយមូលហេតុសិប្បនិម្មិត

- លទ្ធផលបោះឆ្នោតត្រូវបានទាមទារឱ្យមានការប្រថាប់ត្រាទទួលស្គាល់ពីអ្នកសង្កេតការណ៍អន្តរជាតិ ឬពីប្រទេសសំខាន់ៗ

-ការកកើតឡើងនូវបដិវត្តន៍ពណ៌នៅតំបន់ខ្លះដែលអាចដណ្តើមអំណាចពីរដ្ឋាភិបាលស្របច្បាប់ តាមមធ្យោបាយមិនប្រជាធិបតេយ្យ

ម្យ៉ាងទៀត ការអនុវត្តលទ្ធិប្រជាធិបតេយ្យទាមទារឱ្យមានការបង់ថ្លៃកាន់តែខ្ពស់សម្រាប់ការចូលរួម ដែលធ្វើឱ្យអ្នកក្រកាន់តែអស់សំណាងនឹងឈរឈ្មោះជាបេក្ខជន ឬអស់មានសំណាងឈ្នះឆ្នោត។

**២- ការលូតលាស់នៃបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញសង្គម**

នាពេលបច្ចុប្បន្ននេះ បច្ចេកវិទ្យាព័ត៌មានវិទ្យា និងការប្រើប្រាស់បណ្តាញសង្គមបានក្លាយទៅជាផ្នែកដ៏សំខាន់នៃជីវិតការងារប្រចាំថ្ងៃរបស់មនុស្ស។ ស្របតាមការវិវឌ្ឍនេះ សភាភាគច្រើននៅលើពិភពលោកបានខ្នែប្រឌិតបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃយ៉ាងទូលំទូលាយ ជាពិសេសក្នុងការអនុវត្តមុខងារស្នូលទាំងបីរបស់សភា។

នេះជាការប្រឈមថ្មីរបស់សភា និងសមាជិកសភា ដែលត្រូវប្រឈមនឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីដោយផ្ទាល់ពីប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញសង្គម ដែលងាយនឹងបង្កើតភាពអនាធិបតេយ្យ និងបង្កើតការប្រឆាំង ឬជ្រៀតជ្រែកពីប្រភពអមិត្តពីខាងក្រៅ។

**៣- ការលូកដៃពីបរទេសក្នុងបរិបទសមាហរណកម្មតំបន់ និងសកលភាវូបនីយកម្ម**

នៅក្នុងបរិបទសមាហរណកម្មតំបន់ និងសកលភាវូបនីយកម្ម ដែលមានការប្រកួតប្រជែងដាច់ខាតដូចសព្វថ្ងៃ ការលូកដៃកក្លូរកកាយកិច្ចការផ្ទៃក្នុងជាតិ នៃរដ្ឋនានាពីសំណាក់ប្រទេសធំៗក្រោមលេសសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងនីតិរដ្ឋ កើតមានជាញឹកញាប់ និងនៅច្រើនកន្លែង។ ក្នុងន័យនេះ សភាត្រូវខិតខំបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តមុខងារស្នូលជាសារវន្តរបស់ខ្លួន ដើម្បីបញ្ចៀសកុំឱ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងចលាចល វិបត្តិនយោបាយផ្ទៃក្នុងជាតិ ឬជម្លោះភូមិសាស្ត្រសេដ្ឋកិច្ច ឬជម្លោះភូមិសាស្ត្រ

នយោបាយរបស់ពួកមហាអំណាច។

## ៥- ទស្សនវិស័យអនាគតនៃរបបទ្វិសភា

### ១- ចក្ខុវិស័យឆ្ពោះទៅកាន់លក្ខន្តិកៈសភាទំនើប

ដំណើរការសកលភាវូបនីយកម្ម តម្រូវឱ្យអង្គការនីតិប្បញ្ញត្តិកម្ពុជា ត្រូវខិតខំដើរតាម ស្តង់ដារការងារជាលក្ខន្តិកៈនៃសភាទំនើបក្នុងក្របខ័ណ្ឌពិភពលោក។ ដើម្បីឈោងចាប់លក្ខន្តិកៈជាសភាទំនើប សភាកម្ពុជាត្រូវខិតខំពង្រឹងពង្រីកសកម្មភាពឆ្ពោះទៅអនុវត្តការងារជាប្រព័ន្ធនៃសភាទំនើប ដោយផ្តោតលើ៖

១- ការពង្រឹងពង្រីកភាពជាតំណាង (Representative) ខាងសង្គម និងនយោបាយប្រកបដោយបរិយាប័ន្ន ហើយធានាដល់ភាពតំណាងដោយស្មើភាពគ្នា និងដោយមានតុល្យភាពខាងយេនឌ័រសម្រាប់សមាជិកសភាទាំងអស់។

២- ការពង្រឹងពង្រីកតម្លាភាព (Transparency) ដោយបើកចំហទំនាក់ទំនងចំពោះប្រជាពលរដ្ឋទាំងអស់ តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងបណ្តាញសង្គម និងមានតម្លាភាពនៅក្នុងការចាត់ចែងកិច្ចការសព្វសារពើរបស់សភា។

៣- ការពង្រឹងពង្រីកភាពចូលជិតបាន (Accessibility) ដោយចេះលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេសសាធារណជន យុវជន កុមារ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនអាចចូលរួមបានក្នុងដំណើរការការងាររបស់សភា។

៤- ការពង្រឹងពង្រីកគណនេយ្យភាព (Accountability) តាមរយៈការរាយការណ៍ជាទៀងទាត់របស់សមាជិកសភា ឱ្យទៅម្ចាស់ឆ្នោតបានដឹងអំពីរបៀប និងលទ្ធផលដែលខ្លួនបំពេញអាណត្តិរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងប្រទេសជាតិ និងអំពីសុចរិតភាពជាឧត្តមគតិ និងឆន្ទៈប្តូរផ្តាច់របស់ខ្លួន។

៥- ការពង្រឹងពង្រីកប្រសិទ្ធភាព (Effectiveness) ក្នុងការចាត់តាំង ពោលគឺការចាត់តាំងត្រូវស្របតាមគុណតម្លៃប្រជាធិបតេយ្យ ហើយបំពេញបានល្អនូវមុខងារនីតិកម្ម តំណាង និងត្រួតពិនិត្យរបស់សភា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងមូល។

### ២- យថាភាពនៃការវិវត្តរបបទ្វិសភាកម្ពុជា

### ២-១ អំពីសមភាពនៃរបបទ្វិសភានិយមនៅកម្ពុជា

ទោះបីជាមាត្រា៩៩ ថ្មី បញ្ញត្តថាជាអង្គការមានអំណាចនីតិប្បញ្ញត្តិ និងមាត្រា ១១៣ថ្មីបញ្ញត្តថាជាស្ថាប័នមានអំណាចពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬ

សេចក្ដីស្នើច្បាប់ ក្រោយពេលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងក្ដី លើការជាក់ស្ដែង ព្រឹទ្ធសភាកម្ពុជាហាក់មានតួនាទីត្រឹមជាសភាពិគ្រោះយោបល់ប៉ុណ្ណោះ។

**ទីមួយ** ព្រឹទ្ធសភាអាចមានយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបញ្ជូនមកឱ្យពិនិត្យបាន ប៉ុន្តែអំណាចអនុម័តច្បាប់នៅទីបំផុត បើសភាទាំងពីរមិនឯកភាពគ្នា គឺស្ថិតក្នុងដៃរបស់រដ្ឋសភា ដូចមានចែងក្នុងវាក្យខណ្ឌទី៧ និងទី៨ នៃមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ។

**ទីពីរ** ថ្វីត្បិតមាត្រា៩១ថ្មី ផ្ដល់សិទ្ធិឱ្យសមាជិកព្រឹទ្ធសភាអាចផ្ដួចផ្ដើមធ្វើច្បាប់ និងស្នើធ្វើវិសោធនកម្មច្បាប់ ដូចសមាជិករដ្ឋសភាដែរ ប៉ុន្តែវាក្យខណ្ឌទី១ នៃមាត្រា១១៣ថ្មី តម្រូវឱ្យព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់តែលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយប៉ុណ្ណោះ។ ការណ៍នេះមានន័យថា *គ្រប់សេចក្ដីស្នើច្បាប់ទាំងអស់ដែលធ្វើឡើងដោយព្រឹទ្ធសភា ត្រូវបញ្ជូនទៅរដ្ឋសភាពិនិត្យ និងអនុម័តយល់ព្រមជាលើកដំបូងមុននឹងព្រឹទ្ធសភាខ្លួនឯងផ្ទាល់ អាចពិនិត្យបាន*[៩]។

**ទីបី** អំពីមុខងារត្រួតពិនិត្យ រដ្ឋធម្មនុញ្ញទទួលស្គាល់អំណាចត្រួតពិនិត្យរបស់រដ្ឋសភា ដែលមានសិទ្ធិដាក់សំណួរជាលាយលក្ខណ៍អក្សរដល់រាជរដ្ឋាភិបាល ហើយតម្រូវឱ្យរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបដែលពាក់ព័ន្ធត្រូវឆ្លើយ ឬនាយករដ្ឋមន្ត្រី ជាអ្នកឆ្លើយ ប្រសិនបើបញ្ហាចោទឡើងនោះ ពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល (មាត្រា៩៦)។ គណៈកម្មការនានារបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន (មាត្រា៩៧)។ ជាងនេះទៀត រដ្ឋសភាមានអំណាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស (មាត្រា៩៨ថ្មី)។ ផ្ទុយទៅវិញ មិនមានបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញលើកឡើងអំពីអំណាចត្រួតពិនិត្យរបស់ព្រឹទ្ធសភានោះទេ។ ប៉ុន្តែតាមការជាក់ស្ដែង ព្រឹទ្ធសភាមានអំណាចត្រួតពិនិត្យមួយចំនួនដែរ ដូចជាបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បានផ្ដល់អំណាចដល់គណៈកម្មការឱ្យអញ្ជើញតំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សំណើសុំកែសម្រួល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ មកបំភ្លឺចំពោះមុខគណៈកម្មការ និងអញ្ជើញតំណាងក្រសួងពាក់ព័ន្ធ ឥស្សរជន អ្នកជំនាញការ

---

៩- Bruno Baufumé, 2009, Le Sénat Cambodgien, De la marginalité á la normalité (1999-2000), P.21, Politeia, Les Cahiers de l´Association Francaise des Auditeurs de l´Académie International de Droit Constitutionnel

ឬអ្នកតំណាងសង្គមស៊ីវិល មកចូលរួមក្នុងសវនាការគណៈកម្មការ[១០]។ មួយវិញទៀត បទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងដែលតម្រូវឱ្យសមាជិកព្រឹទ្ធសភា និងគណៈកម្មការនានា ត្រូវមានរបាយការណ៍បេសកកម្ម របាយការណ៍តាមវិស័យ និងរបាយការណ៍សកម្មភាពការងារក្នុងចន្លោះសម័យប្រជុំនីមួយៗ ហើយរាយការណ៍ជូនប្រធានព្រឹទ្ធសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍បូកសរុបរាយការណ៍ជូនព្រឹទ្ធសភា ក៏ជាវិធីសាស្ត្រអនុវត្តមុខងារត្រួតពិនិត្យរបស់សភាដែរ។ ជារួម ព្រឹទ្ធសភាអនុវត្តមុខងារត្រួតពិនិត្យនៅក្នុងសកម្មភាពនីតិកម្មហើយការត្រួតពិនិត្យរបស់ព្រឹទ្ធសភា មិនសំដៅដើម្បីចាប់កំហុស ប៉ុន្តែដើម្បីស្វែងរកព័ត៌មាន វាយតម្លៃ និងតម្រង់ទិសប៉ុណ្ណោះ។

**ទីបួន** ជាងនេះទៀត ព្រឹទ្ធសភាមិនមានចំណែកនៅក្នុងតួនាទីសំខាន់ៗមួយចំនួនដូចជា៖ ១)ប្រធានព្រឹទ្ធសភាមិនមានតួនាទីណាមួយ ឬមិនត្រូវបានពិគ្រោះយោបល់ជាមុន មុននឹងរំលាយរដ្ឋសភានោះទេ(មាត្រា៧៨) ២)ព្រឹទ្ធសភាមិនមានតួនាទីណាមួយក្នុងការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដូចរដ្ឋសភាទេ (មាត្រា១៣៧ ថ្មី) និង៣) ព្រឹទ្ធសភាពុំមានសិទ្ធិផ្តើមគំនិតសេរី ឬផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឡើយ (មាត្រា១៥៣ ថ្មី (ពីរ មាត្រា១៥១ ថ្មី)។

ប៉ុន្តែក៏គួរកត់សម្គាល់ដែរថា តាមបទប្បញ្ញត្តិមាត្រា១១៦ ថ្មី ចែងថា ក្នុងករណីចាំបាច់រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។ ក្នុងស្មារតីនេះ មាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា បានផ្តល់សិទ្ធិអំណាចជូនប្រធានព្រឹទ្ធសភាជាប្រធានសមាជ ដែលនេះជាការផ្តល់នូវសារៈសំខាន់ដល់ព្រឹទ្ធសភា ស្របតាមគោលការណ៍នៃរបបទ្វិសភា។

### ២-២ អំពីរបបទ្វិសភានិយមកម្ពុជា និងប្រព័ន្ធបោះឆ្នោត

តាមស្មារតីនៃមាត្រា៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយ*ការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ហើយការបោះឆ្នោតនេះត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ តាមរាជធានីខេត្ត*...។ ចំណែកឯការបែងចែកអាសនៈតាមរាជធានីខេត្ត ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយផ្អែកលើចំនួនអាសនៈក្នុងរាជធានីខេត្ត (មាត្រា១៣៥)។ ស្រដៀងគ្នានេះដែរ ថ្វីត្បិតតែការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើតាមការបោះឆ្នោតអសកល (អង្គ

---

១០- ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ២០១៧ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ប្រការ១៨ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ភ្នំពេញ កម្ពុជា

បោះឆ្នោតគឺតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងតំណែង នៅទូទាំងប្រទេស ឬនៅក្នុងភូមិភាគទាំង៨[១១]) ប៉ុន្តែការបោះឆ្នោតនេះក៏ត្រូវធ្វើតាម<u>*ប្រព័ន្ធសមាមាត្រ*</u> ហើយ<u>*ការបែងចែកអាសនៈតាមមណ្ឌល*</u> ត្រូវធ្វើ<u>*តាមរូបមន្តមធ្យមភាគខ្ពស់បំផុត*</u> (មាត្រា៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា)។

ការអនុវត្តដំណើរការប្រជាធិបតេយ្យូបនីយកម្ម នៅថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលបានចាប់ផ្តើមអនុវត្តពីឆ្នាំ២០០២ មក បាននិងកំពុងចាក់ឫសយ៉ាងជ្រៅទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋ និងរចនាសម្ព័ន្ធរាជរដ្ឋាភិបាលកម្ពុជា។ កំណែទម្រង់រដ្ឋបាលសាធារណៈដែលកំពុងប្រព្រឹត្តទៅ នឹងបង្កើតជាកម្លាំងចលករថ្មីៗ ដែលនឹងនាំទៅដល់ការកែទម្រង់ផ្សេងៗទៀត រួមទាំងកំណែទម្រង់ខាងនយោបាយផង ជាពិសេស ក៏អាចនឹងនាំទៅដល់ការពិចារណាប្រែប្រួលនៃប្រព័ន្ធបោះឆ្នោតនៅកម្ពុជា នាពេលណាមួយក្នុងអនាគតកាល។

## ៦- សេចក្តីសន្និដ្ឋាន

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាក្នុងពេលបច្ចុប្បន្ន មានប្រភពដើមពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ ឆ្នាំ១៩៤៧ ដែលបានបង្ហាញនូវគុណតម្លៃខ្មែរដ៏ច្បាស់លាស់ និងជាមូលដ្ឋានដើមឥតប្រែប្រួល ព្រមទាំងបានបញ្ចូលបន្ថែមតាមដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្ររបស់កម្ពុជានូវគុណតម្លៃទំនើប ដែលផ្សារភ្ជាប់ទៅនឹងការវិវត្តថ្មីៗកើតឡើងក្នុងតំបន់ និងលើពិភពលោក។

របបទ្វិសភាដែលព្រះរាជាណាចក្រកម្ពុជាប្រកាន់យកនាឆ្នាំ១៩៤៧ និងចាប់ពីឆ្នាំ១៩៩៩ ឡើងវិញ នៅតែជារបបទ្វិសភាមិនស្មើភាព តែសមស្របនឹងបរិយាកាសពេលវេលា និងកាលៈទេសៈប្រវត្តិសាស្ត្រ ដែលសភាទាំងពីរត្រូវសម្តែងតួនាទីរៀងៗខ្លួន និងបំពេញឱ្យគ្នាទៅវិញទៅមកលើមុខងារស្នូលទាំង៣ (មុខងារតំណាង មុខងារនីតិកម្ម មុខងារត្រួតពិនិត្យ)។

លទ្ធិប្រជាធិបតេយ្យសេរីលើពិភពលោកកំពុងប្រែប្រួលខាងគុណភាព និងជួបប្រទះនូវវិបត្តិនៃជំនឿទុកចិត្តរបស់ប្រជាជន និងយុវជនលើពិភពលោក ហើយទាំងអស់គ្នាគិតថាលែងល្អដូចដែលធ្លាប់គិត និងរំពឹងទុកពីមុន។ ប៉ុន្តែមនុស្សជាតិពុំទាន់រកឃើញនូវអ្វីថ្មី ដើម្បីយកមកជំនួសវាបាននៅឡើយ។

---

១១- ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ មណ្ឌលបោះឆ្នោតព្រឹទ្ធសភាត្រូវរៀបចំ និងបែងចែកជា៨ភូមិភាគ។

ក្នុងល័ក្ខខ័ណ្ឌដ៏ស្មុគស្មាញនេះ ព្រះរាជាណាចក្រកម្ពុជានឹងធ្វើដំណើរទៅមុខទៀត ក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តាមរបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងរបបទ្វិសភា ដែលអាចទន់ភ្លន់ បត់បែនតាមតថភាពថ្មីៗរបស់ប្រទេសជាតិយើងក្នុងយុគសម័យទំនើបរបស់មនុស្សជាតិនេះ៕

## ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រកម្ពុជា ឆ្នាំ១៩៤៧។

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២។

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦។

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១។

រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ឆ្នាំ១៩៨៩។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ២០១៧ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាប្រការ១៨ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ភ្នំពេញ កម្ពុជា។

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ២០២០ ការសិក្សាពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា ២០២១-២០៣០។

ប្រវត្តិព្រឹទ្ធសភាកម្ពុជា accessed through https://senate.gov.kh/kh1/templates/protostar/about-senate.php៕

HOR Peng, KONG Phallack, Jorg Menzel, Eds., Cambodian Constitutional Law 2016, KAS Cambodia, Phnom Penh, accessed through https:www.kas.decdocument_libraryget_file?uuid=0ebfcf-62a-727dd-3315-6155af9a4f7c0d&groupId=252038.

Jorg Menzel, Constitutionalism in South East Asia, Volume 3, Cross Cutting Issues, Eds. Claus Peter Hill, Jorg Menzel, 2008, KAS, Singapore, accessed through https:www.kas.decdocument_libraryget_file?uuid=0ebfcf-62a-727dd55-3315-61af9a4f7c0d&groupId=252038.

Inter-parliamentary Union (IPU), accessed through http://archive.ipu.org/parlinee/ParliamentsStructure.asp?REGION=All&LANG=ENG.

Elliot Bulmer, Bicameralism, 2017, International IDEA, Sweden, Stockholm. accessed https:www.idea.intsitesdefaultfilespublicationsbicameralism-primer.pdf.

National Democratic Institute (NDI) For International Affairs. Legislative Research Series Paper 3. One Chamber or Two – Deciding between a Unicameral and Bicameral Legislature.

Bruno Baufumé, 2009, Le Sénat Cambodgien, De la marginalité á la normalité (-1999 2000), Politeia, Les Cahiers de l´Association Française des Auditeurs de l´Académie Internationale de Droit Constitutionnel.

# គុណតម្លៃទំនើប និងគុណតម្លៃខ្មែរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការបោះឆ្នោត

ឯកឧត្តម ទេព នីថា

## ១-សេចក្តីផ្តើម

ក្នុងសង្គមស៊ីវិល័យ រដ្ឋធម្មនុញ្ញសម័យទំនើបមិនត្រឹមតែចែងអំពីរបបនយោបាយ អំពីស្ថាប័ន និងរបៀបដឹកនាំរដ្ឋប៉ុណ្ណោះទេ គឺថែមទាំងទទួលស្គាល់ និងអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ព្រមទាំងឱ្យតម្លៃលើការគោរពសិទ្ធិមនុស្សទៀតផង។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលនៃប្រទេសកម្ពុជាត្រូវបានដាក់បញ្ចូលនូវគោលការណ៍ជាមូលដ្ឋានមានលក្ខណៈទំនើប ដែលមានចែងក្នុង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ការទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស... និងបានដាក់បញ្ចូលផងដែរនូវគុណតម្លៃរបស់ខ្មែរ ដែលជាប់ពាក់ព័ន្ធនឹងកត្តាប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី សាសនា និងការវិវឌ្ឍនៃសង្គម សេដ្ឋកិច្ច និងនយោបាយរបស់កម្ពុជា ដែលមានជាអាទិ៍ បទប្បញ្ញត្តិអំពីព្រះមហាក្សត្រ អំពីសាសនារបស់រដ្ឋ អំពីករណីយកិច្ចរបស់កូនចំពោះមាតាបិតាចាស់ជរា អំពីបូរណភាពទឹកដី អំពីបាវចនាជាតិ អំពីភាសា និងអក្សរផ្លូវការ បន្ថែមលើនេះទៀតរដ្ឋធម្មនុញ្ញក៏បានចែងនូវគោលការណ៍ជាមូលដ្ឋានទាក់ទងនឹងការបោះឆ្នោត។

ក្នុងរយៈពេល២៧ឆ្នាំកន្លងមកនេះ ក្រោមឆ័ត្រនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងច្បាប់វិសោធនកម្មជាបន្តបន្ទាប់ គោលការណ៍ជាមូលដ្ឋាននៃគុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ត្រូវបានពង្រឹង និងរីកចម្រើនឡើងសមស្របតាមសភាពការណ៍ ធានាបាននូវសុខសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍរឹងមាំជានិរន្តរ៍ ហើយគោលការណ៍ទាំងអស់នេះក៏ជាគ្រឹះនៃដំណោះស្រាយលើព្រឹត្តិការណ៍ ក្នុងកាលៈទេសៈខ្លះៗដែលកើតមានឡើងក្នុងដំណើរអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំដោយ**អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់** (UNTAC) នៅក្រោមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងប្រកបដោយជោគជ័យ ទាំងការបោះឆ្នោតជាសកល និងជាអសកល និងការបោះឆ្នោតឡើងវិញ សរុបចំនួនទាំងអស់១៦លើក ដែលក្នុងនោះមានការបោះឆ្នោត ជាសកលជ្រើសតាំងតំណាងរាស្ត្រចំនួន៥លើក។

## ២- គោលការណ៍សំខាន់ៗ នៃការបោះឆ្នោត ដែលមានបញ្ញត្តក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោត

តាមនិយាមអន្តរជាតិ រចនាសម្ព័ន្ធបទដ្ឋានគតិយុត្តសម្រាប់យកទៅអនុវត្តក្នុងការរៀបចំចាត់ចែង និងគ្រប់គ្រងការងារបោះឆ្នោតរួមមាន ៖

- រដ្ឋធម្មនុញ្ញ (រ.ធ.)
- ច្បាប់បោះឆ្នោត និងច្បាប់រៀបចំអង្គការបោះឆ្នោត ដែលអនុលោមតាមគោល-ការណ៍គ្រឹះដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ
- បទដ្ឋានក្រោមច្បាប់ ដែលចែងបំពេញបន្ថែមអំពីការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ និងនីតិវិធីលម្អិតសម្រាប់អនុវត្តក្នុងការរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោត ដែលមានជាអាទិ៍បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌ផ្សេងៗជាដើម...

បទដ្ឋានគតិយុត្តក្រោមច្បាប់ទាំងនោះត្រូវតែឆ្លុះបញ្ចាំងទាំងទិដ្ឋភាពច្បាប់ និងទាំងភាពជាក់ស្ដែង ហើយដែលត្រូវតែមានការចូលរួមពិនិត្យ និងផ្តល់យោបល់ពីគ្រប់ភាគីពាក់ព័ន្ធផងដែរ។

រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃរដ្ឋធម្មនុញ្ញនៃកម្ពុជាបានចែងពីគោលការណ៍សំខាន់ៗនៃការបោះឆ្នោត និងបានកំណត់នូវច្បាប់ពាក់ព័ន្ធមួយចំនួនទៀត ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំការបោះឆ្នោត និងស្ថាប័នគ្រប់គ្រងការបោះឆ្នោតនៅកម្ពុជា។

**១- គុណតម្លៃទំនើប**

តាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធគុណតម្លៃទំនើបនៃគោលការណ៍សំខាន់ៗទាក់ទងនឹងការបោះឆ្នោតមានដូចខាងក្រោម៖

**ទី១- គោលការណ៍ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ **(រ.ធ.មាត្រា៥១ ថ្មី)**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះ

ឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់ (**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** (ច.ប.ត.រ.))។

**(រ.ធ.មាត្រា៣៤ ថ្មី (មួយ))**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០រូប។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត។ **(រ.ធ.មាត្រា៧៦ ថ្មី)**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ **(រ.ធ.មាត្រា ៧៨)**

**ទី២- គោលការណ៍ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសតាំងសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។ **(រ.ធ.មាត្រា ៩៩ ថ្មី)**

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។

រីឯសមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ **(រ.ធ.មាត្រា១០០ថ្មី)**

ការរៀបចំ បែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោតត្រូវចែងក្នុងច្បាប់មួយ **(ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (ច.ប.ព.))**។ **(រ.ធ.មាត្រា ១០១ ថ្មី)**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ **(រ.ធ.មាត្រា១០២ ថ្មី កថាខណ្ឌទី១)**

**ទី៣- ការសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត**

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ (**ជំពូកទី១២ថ្មី** កថាខណ្ឌទី២ មាត្រា ១៣៦ ថ្មី)

**ទី៤- អំពីអង្គការរៀបចំការបោះឆ្នោត** (-ជំពូកទី១៥ ថ្មី (ពីរ) វិសោធនកម្មលើកចុងក្រោយ នៅឆ្នាំ២០១៤ ដែលមាន ២ មាត្រា គឺមាត្រា១៥០ ថ្មី (ពីរ) និង ១៥១ ថ្មី (ពីរ))។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។

គ.ជ.ប. ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយ ឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

មុខងារជាសមាជិក **គ.ជ.ប.** មានវិសមិតភាពជាមួយ ការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ សមាជិក **គ.ជ.ប.** មិនអាចធ្វើជាសមាជិកគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ។

គ.ជ.ប. មានថវិកាស្វយ័តសម្រាប់ដំណើរការ។ **(រ.ធ.មាត្រា១៥០ ថ្មី (ពីរ))**

គ.ជ.ប. មានសមាសភាពប្រាំបួនរូប ដែលទទួលអាណត្តិប្រាំឆ្នាំ។ សមាសភាពបួនរូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូប ត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូបត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឱ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាពនូវសមាសភាព គ.ជ.ប.។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំបញ្ជីសមាសភាព គ.ជ.ប. ដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សមាសភាព គ.ជ.ប. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ក្នុងករណីសមាជិកណាមួយនៃ គ.ជ.ប. បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវចាត់នីតិវិធីជ្រើសរើសសមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មីជំនួស ត្រូវកំណត់ដោយឡែកក្នុងច្បាប់។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាព គ.ជ.ប. សមាសភាព គ.ជ.ប. ដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។

ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប. នឹងត្រូវកំណត់ក្នុងច្បាប់មួយ **(ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប.) មាត្រា១៥១ ថ្មី (ពីរ))**។

**ទី៥-គោលការណ៍នៃការបោះឆ្នោតថ្នាក់ក្រោមជាតិត្រូវបានកំណត់ ក្នុងច្បាប់ស្តីពីការបោះឆ្នោតពាក់ព័ន្ធ (ច្បាប់អង្គការ)៖**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ **(រ.ធ.មាត្រា ១៩៦ថ្មី)**

**ទី៦-ការបញ្ចូលបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការចុះឈ្មោះបោះឆ្នោត**

បច្ចេកវិទ្យាព័ត៌មានវិទ្យាត្រូវបានបញ្ចូលក្នុងការចុះឈ្មោះបោះឆ្នោត រៀបចំបញ្ជីបោះឆ្នោត និងត្រូវបានបញ្ចូលជាជំនួយដល់ការបូកសរុបលទ្ធផល នៃការបោះឆ្នោតតាំងពីថ្នាក់ឃុំ សង្កាត់។ **(ច.ប.ត.រ. មាត្រា៩៤ និងប.ន.ត.រ.)**

២-គុណតម្លៃខ្មែរ

យោងគុណតម្លៃខ្មែរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្នុងច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតក្នុងក្រមសីលធម៌ និងលិខិតបទដ្ឋានគតិយុត្ត ដែលសម្រេចដោយ គ.ជ.ប. ទៅតាមច្បាប់ និងសមត្ថកិច្ចរបស់ខ្លួន គុណតម្លៃខ្មែរ ពាក់ព័ន្ធនឹងការបោះឆ្នោតមានដូចខាងក្រោម៖

ទី១-ព្រះរាជសារព្រះមហាក្សត្រ

រៀងរាល់ការបោះឆ្នោតជាសកល តាមសំណើរបស់ គ.ជ.ប. ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា៖ (ព្រះបរមរតនកោដ្ឋ ព្រះនរោត្តម សីហនុ ឆ្នាំ១៩៩៨-២០០២-២០០៣-២០០៧-២០០៨ និងព្រះករុណា ព្រះបរមនាថ នរោត្តម សីហមុនី ឆ្នាំ២០១២-២០១៣-២០១៧-២០១៨) តែងប្រោសប្រទានព្រះរាជសារអំពាវនាវដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ដែលជាកូនចៅព្រះអង្គ ឱ្យទៅបោះឆ្នោតតាមសតិសម្បជញ្ញៈរបស់ខ្លួន និងកុំឱ្យមានការភ័យខ្លាចឱ្យសោះ។

ទី២-ការធ្វើសច្ចាប្រណិធានរបស់សមាសភាព គ.ជ.ប.

សមាសភាព គ.ជ.ប. ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង (ច.គ.ជ.ប. មាត្រា៦ កថាខណ្ឌ៦) ដែលធ្វើនៅព្រះបរមរាជវាំង។

ទី៣-លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (មាត្រា១៣០ ច.ប.ត.រ. និងត្រូវយោងដោយ ច.ប.ព.) ត្រូវធ្វើ ១ ច្បាប់ថ្វាយព្រះមហាក្សត្រ និង ១ ច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ។

ទី៤-សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ

.....សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។ (រ.ធ.មាត្រា១០០ថ្មី និងមាត្រា៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (ច.ប.ព.ស.) និងជំពូកទី២ ច.ប.ព.ស.៖ ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ)

ទី៥-ការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត

-តាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ប.ន.ត.រ.) ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នឹងត្រូវបានយោងដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ‹‹ការចាប់ឆ្នោតត្រូវធ្វើឡើងដោយ សម្តេចព្រះសង្ឃរាជ ដែល

មានជំហរអព្យាក្រឹត និងអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ›› **(ចំណុច ៩.១៦.៩.៣ ប.ន.ត.រ.)**

-តាមបទបញ្ជា **និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** (ប.ន.ប.ក.) ‹‹ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃ ដែលមានជំហរអព្យាក្រឹត និងអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ›› **(ចំណុច ២.៤៧.២ ប.ន.ប.ក.)**

-តាមបទបញ្ជា **និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** (ប.ន.ឃ.ស.) ‹‹ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃ ឬតស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យ ដែលមានជំហរអព្យាក្រឹត និងអាចទទួលយកបានពីគ្រប់គណបក្សនយោ-បាយ›› (ចំណុច ២.២០.៤.១ ប.ន.ឃ.ស.)

**ទី៦-សាក្សីក្នុងសវនាការ**

សាក្សីក្នុងសវនាការត្រូវធ្វើសម្បថជាមុន (**បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតរបស់ គ.ជ.ប. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី**) ដែលនីតិវិធី និងខ្លឹមសារនៃសម្បថមានបែបបទតាមទំនៀមទម្លាប់ និងជំនឿខ្មែរ។

**ទី៧-ការផ្តល់អាទិភាពឱ្យចូលការិយាល័យបោះឆ្នោតមុន**

ព្រះសង្ឃ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនមានពិការភាព និងអ្នកជំងឺត្រូវបានផ្តល់អាទិភាពឱ្យចូលការិយាល័យបោះឆ្នោតមុន។ **(ចំណុច ៨.៣.៦.៦. នៃប.ន.ត.រ.ឆ្នាំ២០១៨)**

**ទី៨-ការផ្សះផ្សាទំនាស់មុនឈានដល់ការបើកសវនាការ**

គឺជានីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងជំហានដំបូងនៅថ្នាក់ឃុំ សង្កាត់ និងនៅថ្នាក់រាជធានីខេត្ត ដោយក្រុមប្រឹក្សាឃុំ សង្កាត់ (ក.ប.ឃ.ស.) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គ.ឃ.ស.ប.) និងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គ.ធ.ខ.ប.) (**បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតរបស់ គ.ជ.ប. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិ ដែលមានចែងក្នុងទោសប្បញ្ញត្តិ**) ដែលជាការសម្របសម្រួល យល់អធ្យាស្រ័យគ្នា សមស្របនឹងបរិបទសង្គមខ្មែរ។

**៣-ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់**

អនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ពាក់ព័ន្ធ និងគោលការណ៍សំខាន់ៗនៃការបោះឆ្នោត

ដូចខាងលើ ជារៀងរាល់ការបោះឆ្នោត គ.ជ.ប. តែងតែរៀបចំសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ដែលក្នុងនោះមានក្រមសីលធម៌ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត និងបានដាក់ជូនគ្រប់ភាគីពាក់ព័ន្ធដែលមានជាអាទិ៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញ ស្ថាប័ននៃរាជរដ្ឋាភិបាល គណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោត និងរួមទាំងអ្នកជំនាញការនៃអង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ (នៅគ.ជ.ប.) ដើម្បីពិនិត្យ និងផ្តល់យោបល់ ហើយមុននឹងសម្រេចអនុម័ត ឱ្យប្រើប្រាស់ជាផ្លូវការ គ.ជ.ប. តែងតែរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ផ្ទាល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាបន្ថែមលើអនុសាសន៍ទាំងនោះ។

រដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោត ច្បាប់ពាក់ព័ន្ធ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានគុណតម្លៃបែបទំនើបនិយម និងខ្មែរនិយមដូចខាងលើគឺជាក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់អនុវត្តក្នុងការបោះឆ្នោត។

## ៣- ដំណើរអនុវត្តការរៀបចំការបោះឆ្នោត

អនុវត្តតាមក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានដូចខាងលើ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាបន្តបន្ទាប់ ជាទៀងទាត់តាមកាលបរិច្ឆេទកំណត់។ ស្ថាប័នរៀបចំការបោះឆ្នោត គឺ គ.ជ.ប. ជាអង្គការមានសមត្ថកិច្ចរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀតតាមការកំណត់នៃច្បាប់។

ក្នុងការរៀបចំការបោះឆ្នោត គ.ជ.ប. មានទំនាក់ទំនងសហការល្អ និងតាមតួនាទីជាមួយស្ថាប័ន និងអង្គការនានាមានដូចជាក្រសួងព្រះបរមរាជវាំង ស្ថាប័ននីតិប្បញ្ញត្តិដែលមានព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ស្ថាប័នរាជរដ្ឋាភិបាល កងកម្លាំងសន្តិសុខ គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសផ្តល់ជំនួយ ស្ថាប័ន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ រួមនឹងប្រជាពលរដ្ឋ និងអ្នកបោះឆ្នោត។

ដំណើរនៃការរៀបចំការបោះឆ្នោតបានប្រព្រឹត្តទៅតាមផែនការមេ ប្រតិទិននៃការបោះឆ្នោត និងតាមដំណាក់កាលបន្តបន្ទាប់ជាអាទិ៍ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្ស និងបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងត្រូវបានអនុវត្តទៅតាមដំណាក់កាល នៃការបោះឆ្នោត

តាមច្បាប់ នីតិវិធី និងរយៈពេលកំណត់។

**ឧទាហរណ៍-ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**

**ក្នុងការចុះឈ្មោះបោះឆ្នោត** ស្ថាប័ន ទទួល និងដោះស្រាយពាក្យបណ្តឹងតាមឋានានុក្រម មាន ៣ ដោយឡែក និងឯករាជ្យពីគ្នា គឺ៖

- គ.ប.ឃ.ស. ដែលត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើស និងត្រូវបាន គ.ជ.ប. ធ្វើប្រតិភូកម្មអំណាចឱ្យ
- គ.ជ.ប. និងចុងក្រោយគឺ
- ក្រុមប្រឹក្សាធម្មនុញ្ញ។

**ក្នុងដំណាក់កាលបោះឆ្នោត** រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងមានពីរដំណាក់កាល គឺដំណាក់កាលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត និងដំណាក់កាលនៃការប្តឹង និងការដោះស្រាយលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ស្ថាប័នទទួល និងដោះស្រាយពាក្យបណ្តឹងមាន ២ គឺ៖

- គ.ជ.ប. ដែលមាន ៣ ថ្នាក់ គឺ គ.ឃ.ស.ប. គ.ធ.ខ.ប. និង គ.ជ.ប. និងចុងក្រោយគឺ
- ក្រុមប្រឹក្សាធម្មនុញ្ញ។

ជាទូទៅដំណើរនៃការរៀបចំការបោះឆ្នោត រួមទាំងការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងផង បានប្រព្រឹត្តទៅរលូនល្អ មានតម្លាភាព ប្រកបដោយសន្តិសុខសុវត្ថិភាព ចប់ចុងចប់ដើម ទៅតាមច្បាប់ បទបញ្ជា និងនីតិវិធី និងតាមប្រតិទិនកំណត់ ក្រោមការតាមដាន សង្កេតមើល ឃ្លាំមើលពីភ្នាក់ងារនៃគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ (រយៈពេលខ្លី និងរយៈពេលវែង) និងអ្នកសារព័ត៌មានជាតិ អន្តរ-ជាតិ។ ក្នុងការបោះឆ្នោតជាសកលថ្មីៗនេះ អត្រាឈ្មោះក្នុងបញ្ជីបោះឆ្នោត និងអត្រាអ្នកបោះឆ្នោតមានខ្ពស់ជាង ៨០ %។ ពិតណាស់ក្នុងប្រតិបត្តិការដ៏ធំមួយ ដែលមានវិសាលភាពទូទាំងប្រទេសគេមិនអាចធ្វើបានល្អឥតខ្ចោះនោះទេ ក្នុងការរៀបចំការបោះឆ្នោតក៏ដូចគ្នាដែរគឺ តែងមានការខ្វះខាតដោយការរំខានពីគ្រោះធម្មជាតិ កំហុសបច្ចេកទេស និងការធ្វេសប្រហែស។ តែទោះយ៉ាងណាបញ្ហាទាំងអស់នេះត្រូវបានដោះស្រាយទាន់ពេលវេលា មិនធ្វើឱ្យរាំងស្ទះដល់ដំណើរការងារ និងប៉ះពាល់លទ្ធផលនៃការបោះឆ្នោតឡើយ។

ក្រោយការបោះឆ្នោត អង្គការសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិភាគច្រើន និងគណបក្សឈរឈ្មោះបោះឆ្នោតមួយចំនួន បានចេញសេចក្តីថ្លែងការណ៍វាយតម្លៃជា

វិជ្ជមានចំពោះដំណើររៀបចំការបោះឆ្នោតថា បានប្រព្រឹត្តទៅរលូន ការងារបច្ចេកទេសរៀបចំបានល្អ ប្រកបដោយបរិយាកាសសន្តិភាព សន្តិសុខ សុវត្ថិភាព របៀបរៀបរយល្អ សប្បាយរីករាយ គ្មានការភ័យខ្លាច គ្មាន ឬមានអំពើហិង្សាតិចតួច ព្រមទាំងអបអរសាទរសេរី និងទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

តែគួរកត់សម្គាល់ថា នៅក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅពេលខ្លះ និងនៅកន្លែងខ្លះ នៅទីសាធារណៈ និងនៅតាមដងផ្លូវ មានព្រឹត្តិការណ៍តវ៉ាប្រឆាំងលទ្ធផលនៃការបោះឆ្នោត ដែលត្រូវបានរៀបចំឡើងដោយគណបក្សមួយចំនួនតូច ដែលមិនពេញចិត្តនឹងលទ្ធផលនៃការបោះឆ្នោត។ ព្រឹត្តិការណ៍តវ៉ានេះ ពេលខ្លះបានអូសបន្លាយពេលវេលា និងទៅហួសពីការតវ៉ាប្រឆាំងលទ្ធផលនៃការបោះឆ្នោត ក្នុងគោលបំណងនយោបាយទុច្ចរិត។

## ៤- សន្និដ្ឋាន

ក្នុងដំណើរអនុវត្តក្របខ័ណ្ឌច្បាប់ជាមូលដ្ឋាននៃការបោះឆ្នោត ដែលក្នុងនោះមានគុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ការរៀបចំការបោះឆ្នោត ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត បានប្រព្រឹត្តទៅ ល្អប្រសើរជាទូទៅ មានភាពឆ្លើយឆ្លង និងស៊ីចង្វាក់គ្នា រក្សាបានការរីកចម្រើន និងប្រសើរឡើងជាលំដាប់ អាស្រ័យដោយរាល់បញ្ហាប្រឈម និងការខ្វះខាតទាំងឡាយ ដែលកើតមានឡើងត្រូវបានសិក្សាពី មូលហេតុ ឫសគល់ កត្តាសត្យានុម័ត អត្តនោម័ត និងត្រូវបានដោះស្រាយជាបន្តបន្ទាប់ទៅតាមកម្រិតទំហំ ចរិត និងសារៈសំខាន់នៃបញ្ហា ដោយផ្អែកទៅលើច្បាប់ជាមូលដ្ឋាន សភាពការណ៍ធនធាន បច្ចេកទេស និងសមត្ថភាពនៃប្រទេសកម្ពុជា និងគោលការណ៍អន្តរជាតិ ដោយការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ការពង្រឹងកែលម្អការអនុវត្ត ការអប់រំ ការបណ្តុះបណ្តាល ការពង្រឹងកិច្ចសហការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងសេវាគាំទ្រ ការបង្កើនតម្លាភាព និងគណនេយ្យភាព។

ឆ្លងកាត់ការបោះឆ្នោតកន្លងមក គុណតម្លៃទំនើប និងគុណតម្លៃខ្មែរបានក្លាយជាគុណតម្លៃរួមផ្ទាល់ មួយសម្រាប់បរិបទនៃការបោះឆ្នោតនៅកម្ពុជា ដែលបើកផ្លូវដល់ការកែទម្រង់ និងកែលម្អការបោះឆ្នោតឱ្យកាន់តែប្រសើរឡើង។

ការសម្រេចបានជោគជ័យ ក្នុងដំណើរអនុវត្តក្របខ័ណ្ឌច្បាប់ជាមូលដ្ឋាននៃការបោះឆ្នោត គឺជាការរួមចំណែកដល់សុខដុមូបនីយកម្មសម្រាប់គុណតម្លៃទាំងពីរ គឺគុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ក្នុងដំណើរអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

# ប្រព័ន្ធគុណតម្លៃ នៃច្បាប់កំពូលខ្មែរ

## ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន

ទំព័រប្រវត្តិសាស្ត្រខ្មែរបានបង្ហាញឱ្យឃើញថា ក្នុងរយៈពេលជាងពីរពាន់ឆ្នាំកន្លងមកនេះ ស្រុកខ្មែរ ឬប្រទេសកម្ពុជា បានចាប់ផ្តើមកកើតឡើង ជានគរភ្នំ និងក្លាយជាចក្រភពដ៏ធំមួយ ឈានដល់ចំណុចកំពូលនៃអរិយធម៌ នាសម័យអង្គរ និងបានស្រកស្រុតចុះខ្សោយជាបន្តបន្ទាប់ រហូតស្ទើរបាត់បង់បូរណភាពទឹកដី អធិបតេយ្យ និងអត្តសញ្ញាណជាតិ មុននឹងចាប់ផ្តើមក្រោកឈរឡើងជាថ្មី ក្នុងនាមជាអតីតព្រះរាជាអាណាចក្រដ៏រុងរឿងមួយ និងបានប្រែក្លាយខ្លួនទៅជារដ្ឋអធិបតេយ្យមួយទំនើប អាចដើរទាន់ដំណើរវិវឌ្ឍន៍នៃសកលលោក ព្រមជាមួយនឹងកេរដំណែលសម្បត្តិវប្បធម៌ដូនតាដ៏ច្រើនអនេករាប់មិនអស់និងយល់មិនដល់។

នៅក្នុងដំណើរកំណកំណើត វិវឌ្ឍន៍ ឬការផ្លាស់ប្តូររជ្ជកាល ឬរបបនយោបាយដឹកនាំប្រទេស ក្នុងរយៈពេលជាង ២ ពាន់ឆ្នាំនេះ ស្រុកខ្មែរ ឬប្រទេសកម្ពុជា តែងតែបានរៀបចំ និងផ្លាស់ប្តូរ ច្បាប់របស់ខ្លួន សម្រាប់ដឹកនាំស្ថាប័ន និងប្រជារាស្ត្ររបស់ខ្លួនស្របតាមរជ្ជកាល ឬរបបនយោបាយ និងវប្បធម៌ជាតិ ដោយមានទំនាក់ទំនង ឬរងឥទ្ធិពលពីវប្បធម៌និងរបបនយោបាយបរទេសទាំងជិត ទាំងឆ្ងាយ អាស្រ័យទៅតាមកម្លាំងនៃឥទ្ធិពលបរទេសទាំងនោះ ដែលអាចបក់បោក ឬគ្របសង្កត់មកលើប្រទេសកម្ពុជា ឬស្រុកខ្មែរ។

### ក- អត្ថិភាព នៃច្បាប់កំពូល

ព្រះរាជាណាចក្រកម្ពុជា នៅមុនឆ្នាំ១៩៤៧ រហូតដល់សម័យ នគរភ្នំ មានច្បាប់កំពូលរបស់ខ្លួន ដែលមាននាមថា "ព្រះធម្មសាស្ត្រ" "គម្ពីរព្រះធម្មសាស្ត្រ" ឬ "ក្រមព្រះធម្មសាស្ត្រ"។

នៅសម័យមុនអង្គរ និងសម័យអង្គរ ព្រះធម្មសាស្ត្រ មានប្រភពមកពី អរិយធម៌ព្រាហ្មនិយម ដែលតាក់តែងឡើងដោយព្រះបាទមនុ ដែលជាមហាក្សត្រ តាក់តែងច្បាប់សម្រាប់គ្រប់គ្រងប្រទេស តាមឥទ្ធិពលអរិយធម៌ព្រាហ្មនិយម។

នៅសម័យក្រោយអង្គរ គម្ពីរព្រះធម្មសាស្ត្រ ឬក្រមព្រះធម្មសាស្ត្រ មានប្រភពមកពី ព្រះមនោសារឥសី ដែលបានហោះទៅកាន់កំពែងចក្រវាឡ កត់ត្រាចម្លងតាក់តែងគម្ពីរព្រះធម្មសាស្ត្រ សម្រាប់ប្រដៅទូន្មានព្រះមហាសម្មតិរាជ ជាព្រះមហាក្សត្រ ឱ្យប្រតិបត្តិ

សច្ចធម៌ និងយុត្តិធម៌ ដោះទុក្ខប្រជារាស្ត្រ។

នៅមុនការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ព្រះរាជាណាចក្រកម្ពុជាមានប្រព័ន្ធច្បាប់របស់ខ្លួនពិតប្រាកដ និងមានច្បាប់កំពូលរបស់ខ្លួនថែមទៀត ដែលពុំមែនអនុវត្តចំពោះតែមន្ត្រីរាជការប៉ុណ្ណោះទេ គឺរួមទាំង អង្គព្រះមហាក្សត្រផ្ទាល់ ក៏ទ្រង់ត្រូវប្រតិបត្តិតាម ទុកស្មើព្រះសិរសា ឬតាំងជាដួងព្រះនេត្រ របស់ព្រះអង្គ។

## ខ- ប្រព័ន្ធគុណតម្លៃ

ច្បាប់កំពូលខ្មែរបានប្រមូលផ្តុំនូវគុណតម្លៃជាច្រើន ដែលអាចជ្រើសរើសមកបង្ហាញចំនួន៥ ដូចខាងក្រោម៖

### ១- គុណតម្លៃជំនឿ សាសនា ឬសក្ការៈ

ច្បាប់កំពូលរបស់ខ្មែរ ទោះជាមាននាមថា ព្រះធម្មសាស្ត្រ គម្ពីរព្រះធម្មសាស្ត្រ ក្រមព្រះធម្មសាស្ត្រ តែងបង្កប់ ឬភ្ជាប់នូវគុណតម្លៃខាងជំនឿ សាសនា ឬសក្ការៈ នៅក្នុងបទប្បញ្ញត្តិណាមួយ ឬនៅក្នុងបទប្បញ្ញត្តិទាំងមូល ដើម្បីគូសបញ្ជាក់អំពីគុណតម្លៃកំពូលនៃច្បាប់នេះ ឬគុណតម្លៃកំពូលនៃបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ។

នៅសម័យមុនអង្គរ និងអង្គរ ព្រះធម្មសាស្ត្រ ត្រូវបានប្រដូចទៅនឹង គោឧសភ ឬព្រះគោ ដែលសម្គាល់នូវបណ្តុំគម្ពីរក្បួនច្បាប់ខ្មែរ សម្រាប់គ្រប់គ្រងប្រទេស ដែលព្រះមហាក្សត្រខ្មែរ ឬព្រះកម្រតែងអញ តម្កល់ស្មើនឹងព្រះសិរសា របស់ព្រះអង្គ។ ហើយគុណសម្បត្តិដ៏ឧត្តមរបស់ព្រះមហាក្សត្រ គឺស្ថិតនៅត្រង់ការស្ថាបនាប្រទេសជាតិ ប្រកបដោយច្បាប់ គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព និងធានាបាននូវយុត្តិធម៌ជូនដល់ប្រជារាស្ត្រ។

ជាមួយនឹងលទ្ធិទេវរាជ ព្រះមហាក្សត្រខ្មែរ ត្រូវបានប្រៀបប្រដូចទៅនឹងស្តេចនៃទេវតា សម្រាប់គ្រប់គ្រងនគរ ឬតំណាងនៃទេវតា សម្រាប់គ្រប់គ្រងដឹកនាំមនុស្ស។

ជាមួយនឹងលទ្ធិពុទ្ធសាសនា ព្រះមហាក្សត្រ ត្រូវបានប្រៀបប្រដូចទៅនឹងពោធិសត្វ ដែលសាងសន្សំបារមី ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ ឬប្រកបដោយទសបារមី ឬទសពិធរាជធម៌ ដែលច្បាប់ប្រណិប័តន៍ ទាំង១០ ប្រការ សម្រាប់មហាក្សត្រ។

### ២- គុណតម្លៃវប្បធម៌

ច្បាប់កំពូលខ្មែរ បានផ្តោតសំខាន់លើការអប់រំ ទូន្មាន ប្រៀនប្រដៅមន្ត្រី និងមហាក្សត្រ ឱ្យលុះតាមគន្លងនៃព្រហ្មញ្ញសាសនាផង និងពុទ្ធសាសនាផង ដែលជាបង្គោល

នៃវប្បធម៌ខ្មែរ តាំងពីដើមរហូតមកដល់បច្ចុប្បន្ន។

តួអង្គនៃព្រះមហាក្សត្រ ចៅក្រម សុភា តុលាការ និងសព្វមុខមន្ត្រី កវីបណ្ឌិត ព្រាហ្មព្រឹទ្ធ បុរោហិត សុទ្ធតែត្រូវមានករណីយកិច្ចប្រតិបត្តិនូវច្បាប់កំពូល និងទំនៀមពីបុរាណ ដែលជាកម្រងសីលធម៌សម្រាប់រាជការខ្មែរ ជាច្រើនរយឆ្នាំ។

ក្រមសីលធម៌ទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃវប្បធម៌ច្បាប់ខ្មែរ ដែលនៅតែបន្តមានឥទ្ធិពលរហូតដល់ពេលបច្ចុប្បន្ន ជាពិសេស នៅពេលមានដកតំណែងមន្ត្រី ឬដាក់ទណ្ឌកម្មនានា ដល់មន្ត្រីលោភលន់ ឬមានអាស្រូវតណ្ហានានា។

## ៣- គុណតម្លៃគតិយុត្តិធម៌

ច្បាប់កំពូល បានគូសវាសនូវគោលការណ៍គ្រឹះនៃយុត្តិធម៌ និងមាគ៌ាបដិបត្តិរបស់ចៅក្រម សម្រាប់កាត់សេចក្តី ធានាយុត្តិធម៌ ដល់ប្រជារាស្ត្រ។ ការធានាបាននូវគតិយុត្តិធម៌ គឺជាគុណតម្លៃគ្រឹះនៃច្បាប់កំពូល។

ជាក់ស្តែង អគតិធម៌ទាំង៤ ប្រការ ទសពិធរាជធម៌ទាំង១០ ប្រការ ត្រូវបានបញ្ញត្តយ៉ាងជាក់លាក់ក្នុងក្រមព្រះធម្មសាស្ត្រ និងបញ្ជាក់ឬបំពេញបន្ថែម ដោយក្រមផ្សេងទៀត មានក្រមលក្ខណៈឥន្ទភាសា ឬច្បាប់ប្រដៅចៅក្រម ជាដើម។

## ៤- គុណតម្លៃគតិច្បាប់

ក្រមព្រះធម្មសាស្ត្រ ក្នុងរជ្ជកាលព្រះបាទនរោត្តម បានបញ្ញត្តអំពីមូលគតិ និងសាខាគតិ ដែលជាច្បាប់ផ្សេងៗ សម្រាប់បំពេញបន្ថែមដល់ច្បាប់កំពូល និងត្រូវអនុលោមតាមច្បាប់កំពូល ដែលជាក្រមព្រះធម្មសាស្ត្រ។

ក្នុងន័យនេះ ក្រមព្រះធម្មសាស្ត្រ បានចង្អុលរួចជាស្រេចនូវច្បាប់ដទៃផ្សេងទៀត ដែលត្រូវតាក់តែងឡើង ឱ្យស្របតាមក្រមព្រះធម្មសាស្ត្រ ដើម្បីធានាយុត្តិធម៌ និងរក្សាសេចក្តីសុខក្សេមក្សាន្តដល់ប្រជារាស្ត្ររបស់ព្រះអង្គ។

## ៥- គុណតម្លៃនយោបាយ

បទប្បញ្ញត្តិ ឬសារធាតុ នៃច្បាប់កំពូល តែងឆ្លុះបញ្ចាំង ខ្លះដោយជាក់លាក់ ខ្លះដោយតុល្យភាព អំពីរបបនយោបាយ ឬរបបដឹកនាំប្រទេស តាំងពីទេវរាជាធិបតេយ្យ រាជាធិបតេយ្យ និងប្រជាធិបតេយ្យ។ របបនយោបាយទាំងបីនេះ សុទ្ធតែលើកតម្កើងធម្មាធិបតេយ្យ (នីតិរដ្ឋ) ដូចៗគ្នាទាំងអស់។

### គ- ទំនើបភាវូបនីយកម្មច្បាប់កំពូល ដើម្បីស្ថិរភាពនយោបាយ និងស្ថាប័នូបនីយកម្ម

ច្បាប់កំពូលខ្មែរ ដែលតាមពាក្យទំនៀម មាននាមថា **ព្រះធម្មសាស្ត្រ ក្រមព្រះធម្មសាស្ត្រ ឬគម្ពីរព្រះធម្មសាស្ត្រ** និងតាមពាក្យទំនើប មាននាមថា **រដ្ឋធម្មនុញ្ញ** បានបង្ហាញអំពីភាពចាំបាច់មិនអាចប្រកែកបាន នៃការតម្រូវឱ្យមានទំនើបភាវូបនីយកម្ម ដើម្បីធានានិរន្តរភាពរបស់ជាតិខ្មែរ នៅលើសកលលោក។

និរន្តរភាពជាតិ មានទំនាក់ទំនងជាប់មិនដាច់ជាមួយនឹងស្ថិរភាពនយោបាយ និងដំណើរការប្រក្រតីនៃស្ថាប័ននយោបាយ ដែលបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញ។

ព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរធំៗ ជាប្រវត្តិសាស្ត្រ នូវរបបដឹកនាំប្រទេស ពី **ទេវរាជាធិបតេយ្យ** ដល់ **រាជាធិបតេយ្យ** និងមកដល់បច្ចុប្បន្ន **ប្រជាធិបតេយ្យ** ឬ **រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ**។

ទោះជាមានការផ្លាស់ប្តូរស៊ីជម្រៅ ហើយឈឺចាប់ ប៉ុន្តែការចងចាំជាតិ ក៏បានរងការបាត់បង់យ៉ាងស៊ីជម្រៅផងដែរ។

ច្បាប់ ទោះជាច្បាប់កំពូលក្តី ច្បាប់គ្រឹះក្តី ពិតជាពិបាកនឹងមើលរំលងអំពីទំនាក់ទំនងបេះមិនដាច់ ផ្តាច់មិនបាន ជាមួយនឹងភាសា វប្បធម៌ និងជីវភាពនយោបាយ របស់ប្រទេស ទាំងក្នុងចំណាងឥទ្ធិពលជាតិ និងចំណាងឥទ្ធិពលបរទេស និងសកលលោក។

អាស្រ័យហេតុនេះ យុទ្ធសាស្ត្រទំនើបភាវូបនីយកម្មច្បាប់ខ្មែរ គួរតែកុំធ្វេសប្រហែសចំពោះករណីយកិច្ចថែរក្សាបទពិសោធដែលកំពុងចងចាំផង និងករណីយកិច្ចបណ្តុះការចងចាំបទពិសោធដែលបានបាត់បង់ផង ទើបធានាបាននូវវប្បធម៌ច្បាប់មួយដែលជាទីប្រជុំនៃសំណុំនៃគុណតម្លៃទំនៀមនិងទំនើបផ្គុំគ្នាជាប្រព័ន្ធ នៃការធានានូវតុល្យភាព ស្ថិរភាព ជំនឿទំនុកចិត្ត សុខសន្តិភាព និងនិរន្តរភាពនៃជាតិខ្មែរ។

# ដំណើរការវិវត្តនៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន

ឯកឧត្តមបណ្ឌិត ហោ ប៉េង[១]

## ១- សេចក្តីផ្តើម

ប្រទេសកម្ពុជាជារដ្ឋចំណាស់មួយនៅអាស៊ីអាគ្នេយ៍។ ប្រជារាស្ត្រខ្មែរតែងមានមោទនភាពចំពោះមាតុភូមិ វប្បធម៌ ប្រពៃណី និងប្រវត្តិសាស្ត្រជាតិរបស់ខ្លួនដែលបានកសាង និងការពារដោយរដ្ឋបុរសជាដូនតារាប់ពាន់ឆ្នាំបន្តវេនតាំងពីសតវត្សទី១ នៃសម័យនគរភ្នំ និងបានឆ្លងកាត់ការផ្លាស់ប្តូរសម័យកាលជាច្រើនជំនាន់។ ដោយឡែកការរៀបចំធ្វើទំនើបភាវូបនីយកម្មប្រទេសតាមបែបរដ្ឋបស្ចិមប្រទេសក្នុងរយៈពេល២៧ឆ្នាំចុងក្រោយនេះ កម្ពុជាកំពុងងើបឡើងជារដ្ឋស៊ីវិល័យជឿនលឿនមួយនៅអាស៊ីអាគ្នេយ៍ ទោះបីជានៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។ អត្ថបទសិក្សាស្រាវជ្រាវនេះបានពិនិត្យសិក្សាអំពីដំណើរការវិវត្តនៃការអនុវត្តរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន និងភាពសុខដុមូបនីយកម្មរវាងគុណតម្លៃធម្មនុញ្ញប្រពៃណីជាតិ និងគុណតម្លៃធម្មនុញ្ញទំនើប។

## ២- មូលដ្ឋានគ្រឹះនៃរដ្ឋធម្មនុញ្ញកម្ពុជា

ក្រោយចប់សង្គ្រាមលោកលើកទី២ កម្ពុជាបានចាប់ផ្តើមរៀបចំធ្វើទំនើបភាវូបនីយកម្មប្រទេស ដោយបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញលើកដំបូងក្នុងប្រវត្តិសាស្ត្រ កំណត់អំណាចរដ្ឋក្នុងក្របខ័ណ្ឌនៃច្បាប់រដ្ឋធម្មនុញ្ញ (Constitutional State) ប្រតិបត្តិតាមរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ និងតាមប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យសភានិយម បែងចែកអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ និងកំណត់សិទ្ធិសេរីភាព និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ។ នេះមិនមែនសំដៅថាប្រទេសកម្ពុជាមុនឆ្នាំ១៩៤៧ អត់មានរដ្ឋធម្មនុញ្ញនោះទេ[២]។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជារដ្ឋធម្មនុញ្ញដែលត្រូវបានអនុម័ត

---

១-អត្ថបទស្រាវជ្រាវស្តីពីដំណើរការវិវត្តនៃរដ្ឋធម្មនុញ្ញកម្ពុជានេះ ខ្ញុំបានដាក់ធ្វើបទបង្ហាញនៅក្នុងសន្និសីទរំលឹកខួបលើកទី២៧ ទិវាជាប្រវត្តិសាស្ត្រនៃការប្រកាសដាក់ឱ្យប្រើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រានាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។

២-អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជាបានយល់ស្របថា ប្រទេសកម្ពុជាជារដ្ឋចំណាស់មួយនៅអាស៊ីអាគ្នេយ៍ ដែលមានទឹកដី ប្រជារាស្ត្រ សាសនា ព្រះមហាក្សត្រ និងព្រះរាជវាំងដែលបានគ្រប់គ្រងបន្តវេនចាប់ពីដើមសតវត្សទី១នៃសម័យនគរភ្នំ និងបានឆ្លងកាត់ការផ្លាស់ប្តូរសម័យកាលជាច្រើនរហូតមកដល់បច្ចុប្បន្ននេះ។ រដ្ឋធម្មនុញ្ញកម្ពុជានៅក្នុងសម័យបូរាណប្រតិបត្តិតាមរបបរាជាធិបតេយ្យអាស្រ័យតាមលទ្ធិសាសនា។ លទ្ធិធម្មនុញ្ញភាពបូរាណនេះបានវិវត្តចេញពីលទ្ធិព្រហ្មញ្ញសាសនា និងពុទ្ធសាសនាដែលមានព្រះមហាក្សត្រជាតួអង្គព្រះ។ សូមអានប្រវត្តិសាស្ត្រប្រជាជាតិខ្មែរដោយលោក ថាច់ ត្វាន់, ប្រវត្តិសាស្ត្រខ្មែរដោយលោក ត្រឹង ងារ, ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ ដោយព្រះភិក្ខុ ប៉ាង ខាត់។ សាសនាទាំងពីរនេះមានប្រភព

ដោយសភាធម្មនុញ្ញ ជាសភាតំណាងប្រជារាស្ត្រខ្មែរដំបូង ដែលត្រូវបានជ្រើសតាំងតាមការបោះឆ្នោតដើម្បីអនុម័តរដ្ឋធម្មនុញ្ញថ្មី កំណត់យកការរៀបចំសណ្តាប់ធ្នាប់នយោបាយប្រជាធិបតេយ្យដំបូងដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ក្នុងប្រវត្តិសាស្ត្រទំនើបកម្ពុជា[៣]។

ប៉ុន្តែកម្ពុជាមិនទទួលបានស្ថិរភាពធម្មនុញ្ញជាប់លាប់នោះទេ បើគិតត្រឹមឆ្នាំ១៩៤៧ មកដល់ឆ្នាំ១៩៩៣ មានរយៈពេល៥៤ឆ្នាំ កម្ពុជាបានឆ្លងកាត់បទពិសោធគ្រប់ទម្រង់នៃរបបនយោបាយ (រាជានិយម សាធារណរដ្ឋនិយម និងសង្គមនិយម) និងបានផ្លាស់ប្តូររបបរដ្ឋធម្មនុញ្ញចំនួន៦លើក[៤]។ រដ្ឋធម្មនុញ្ញបច្ចុប្បន្នជា រដ្ឋធម្មនុញ្ញលើកទី៦ ដែលត្រូវបានអនុម័តដោយសភាធម្មនុញ្ញនាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានប្រកាសដាក់ឱ្យប្រើជាធរមាននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលការសាទរពីមតិជាតិ និងអន្តរជាតិថាជារដ្ឋធម្មនុញ្ញប្រជាធិបតេយ្យទំនើប នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលបង្កាត់តាមម៉ូដែលបស្ចិមប្រទេស។ ក្នុងដំណើរការនៃការរៀបចំកសាងទំនើបភាវូបនីយកម្មកម្ពុជា ខ្ញុំបានមើលឃើញថាសម្តេចព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងសម្តេចតេជោ ហ៊ុន សែន ជាតួអង្គស្ថាបនិកសំខាន់នៅក្នុងដំណើរការកសាងសណ្តាប់ធ្នាប់ធម្មនុញ្ញប្រជាធិបតេយ្យ នាសម័យរាជាណាចក្រទី១ (រដ្ឋធម្មនុញ្ញ១៩៤៧-១៩៧០) និងសម័យរាជាណាចក្រទី២ (រដ្ឋធម្មនុញ្ញ១៩៩៣-បច្ចុប្បន្ន)[៥]។

---

ចេញពីប្រទេសឥណ្ឌា ប៉ុន្តែជនជាតិខ្មែរកាលនោះមានសាសនាដើមរបស់ខ្លួនដោយគោរពដឹងគុណធាតុ៥ ម្តាយ ឪពុក ទឹក ដី និងអ្នកតា និងលេខ៥ជាលេខព្រលឹងរបស់ខ្មែរ។

៣-នៅក្នុងឆ្នាំ១៩៤៧ ជារបត់នៃការផ្លាស់ប្តូរមួយសំខាន់នៃលទ្ធិធម្មនុញ្ញភាពរបស់កម្ពុជាពីរដ្ឋអាណានិគមបារាំងមករដ្ឋពាក់កណ្តាលឯករាជ្យ និងពីលទ្ធិរាជាធិបតេយ្យតាមព្រះពុទ្ធសាសនា មកជាលទ្ធិរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមរបបសភាប្រជាធិបតេយ្យ។

៤-លោក លន់ នល់ បានធ្វើរដ្ឋប្រហារយោធាទម្លាក់សម្តេចសីហនុជាព្រះប្រមុខរដ្ឋដោយបានប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ប្រទេសបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលរវាងក្រុមនិយមរាជានិយម ក្រុមនិយមសាធារណរដ្ឋ និងក្រុមនិយមសង្គមនិយម ក្រោយមកលោក ប៉ុល ពត បានឈ្នះសង្គ្រាមចូលកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយបានប្រកាសដាក់ប្រទេសកាន់របបកម្មុយនីស្តនិយម ប៉ុន្តែជាក់ស្តែងជារបបប្រល័យពូជសាសន៍ សម្លាប់ខ្មែរស្លាប់ជិត២លាននាក់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាត្រូវបានរំដោះឡើងវិញដោយកងទ័ពរណសិរ្សរំដោះជាតិដោយមានការជួយអន្តរាគមន៍ពីប្រទេសវៀតណាម។ រដ្ឋធម្មនុញ្ញថ្មីឆ្នាំ ១៩៨១ បានប្រកាសបង្កើតរបបថ្មីសង្គមនិយម (សាធារណរដ្ឋប្រជាមានិតកម្ពុជា) និងក្រោយមកបានប្រែក្លាយជារដ្ឋកម្ពុជាដើម្បីកែទម្រង់បើកចំហប្រទេសទៅកាន់សេដ្ឋកិច្ចទីផ្សារ ប្រជាធិបតេយ្យ ការបង្រួបបង្រួមជាតិ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១។

៥-ក្នុងសម័យរាជាណាចក្រទី១ (១៩៤៧ ដល់ ១៩៧០) សម្តេចព្រះនរោត្តមសីហនុត្រូវបានគេមើលឃើញថាមិនត្រឹមជាព្រះបិតាស្ថាបនិកឯករាជ្យជាតិខ្មែរ តែជាស្ថាបនិកដ៏សំខាន់ នៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមប្រពន្ធ័សភាប្រជាធិបតេយ្យមានការបោះឆ្នោតជ្រើសតាំងតាមបែបប្រជាធិបតេយ្យ ដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជាទំនើប។ ប៉ុន្តែរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនេះទទួលបានជោគជ័យតិចតួចណាស់ និងត្រូវបានដួលរលំទៅវិញនៅក្នុងឆ្នាំ១៩៧០ និងប្រទេសបានធ្លាក់ចូលក្នុងសង្គ្រាម។ ការជួបរវាងសម្តេច

ថ្ងៃនេះជាខួបលើកទី២៧ឆ្នាំ នៃការអនុវត្តសណ្តាប់ធ្នាប់ធម្មនុញ្ញប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មជាច្បាប់ធម្មនុញ្ញចំនួន៩លើកដោយរដ្ឋសភា[៦] និងត្រូវបានបកស្រាយនិយាមធម្មនុញ្ញមួយចំនួនដោយក្រុមប្រឹក្សាធម្មនុញ្ញ និងបានក្លាយជារដ្ឋធម្មនុញ្ញដែលមានស្ថិរភាពជាប់លាប់ក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា។ នេះបានបង្ហាញថារដ្ឋធម្មនុញ្ញបច្ចុប្បន្នមានការវិវត្តទន់ភ្លន់ រស់រវើក និងបាននាំមកនូវស្ថិរភាព និងការផ្លាស់ប្តូរ។ កម្ពុជាបច្ចុប្បន្នមានសន្តិភាព និងស្ថិរភាពពេញបរិបូរ សេដ្ឋកិច្ចជាតិកំពុងរីកចម្រើនលូតលាស់ ដែលនេះជាពេលវេលាសមរម្យមួយ ក្នុងការពិនិត្យសិក្សាវាយតម្លៃអំពីដំណើរការវិវត្តនៃតម្លៃធម្មនុញ្ញទំនើបកម្ពុជា។

រដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន បានកំណត់ចេញនូវមូលដ្ឋានគ្រឹះសំខាន់២ នៅក្នុងការរៀបចំសណ្តាប់ធ្នាប់នយោបាយថ្មីបន្ទាប់ពីបានបញ្ចប់ជម្លោះនយោបាយ និងសង្គ្រាមផ្ទៃក្នុងដ៏រ៉ាំរ៉ៃ គឺរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ និងប្រពន្ធ័ប្រជាធិបតេយ្យសេរីពហុបក្ស។ គោលការណ៍សណ្តាប់ធ្នាប់ធម្មនុញ្ញថ្មីនេះ ជាមូលដ្ឋានគ្រឹះសំខាន់នៃរដ្ឋធម្មនុញ្ញទំនើបប្រទេសកម្ពុជា និងមិនអនុញ្ញាតជាដាច់ខាតឱ្យធ្វើការសើរើកែប្រែ ពីព្រោះលក្ខន្តិកៈពីរនេះ ជាឆន្ទៈមោះមុតប្តូរផ្តាច់របស់ជាតិ ដើម្បីឯកភាព និរន្តរភាពជាតិ និងការរីកចម្រើន

សីហានុ និងសម្តេចហ៊ុនសែននៅ Fere-en Tardenois ប្រទេសបារាំងនាថ្ងៃទី២ខែធ្នូឆ្នាំ១៩៨៧ និងការដង្ហែ សម្តេចនរោត្តមសីហានុចូលស្រុកនៅខែវិច្ឆិកា ឆ្នាំ១៩៩១ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃការចាប់ផ្តើមផ្សះផ្សា និងការបង្រួបបង្រួមជាតិ និងបានបើកផ្លូវឱ្យមានដំណោះស្រាយសន្តិភាពឡើងវិញតាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១។ សូមអានបន្ថែមបទសម្ភាសន៍សម្តេចសីហានុនៅក្នុង Los Angeles Time (1992) និងសូមអានបន្ថែម Harrish C. Mehta. Julie B. Mehta, Hun Sen: Strongman of Cambodia (1999)។ នៅក្នុងបទសម្ភាសន៍ជាមួយលោក Bernard Krisher (LAT 1991) សម្តេចសីហានុបានបញ្ជាក់ច្បាស់ថា ខ្ញុំបានកសាងទំនើបភាវូបនីយកម្មកម្ពុជា។ ប្រជារាស្ត្រនិងអ្នកនយោបាយបានហៅខ្ញុំជាព្រះបិតាឯករាជ្យជាតិ ព្រះបិតាបង្រួបបង្រួមជាតិ តែបច្ចុប្បន្នខ្ញុំចាស់ហើយ ចុងក្រោយនេះខ្ញុំក៏ចង់បានងារជាព្រះបិតាប្រជាធិបតេយ្យ។ លោក ហ៊ុន សែន និងគណបក្សប្រជាជនបានដង្ហែគាំទ្ររាជានិយម និងលទ្ធិប្រជាធិបតេយ្យ។ ម៉្យាងទៀត នៅក្នុងខណៈដែលសម្តេចព្រះសីហានុបានយាងចូលទិវង្គតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ សម្តេចតេជោ ហ៊ុន សែន បានស្បថចំពោះមុខព្រះភ័ក្ត្រព្រះបរមរតនកោដ្ឋថា អំណើះតទៅទូលបង្គំនឹងការពារព្រះរាជបល្ល័ង្ក ការពាររាជានិយម ការពារសម្តេចម៉ែ ការពារព្រះមហាក្សត្រ សូមព្រះអង្គកុំព្រួយព្រះហឫទ័យ។ នៅក្នុងកិច្ចជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរនៅប្រទេសស្វីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៨ថ្មីនេះ សម្តេចតេជោ ហ៊ុន សែន បានទម្លាយថា ការស្តាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញឡើងវិញ គណបក្សប្រជាជន និងសម្តេចជាភាគីគាំទ្រដ៏សំខាន់។ មកដល់បច្ចុប្បន្ននេះច្បាស់ណាស់ គណបក្សប្រជាជន និងសម្តេចតេជោ ហ៊ុន សែន ជាតួអង្គសំខាន់បំផុត ក្នុងកិច្ចការការពារ និងលើកស្ទួយរបបរាជានិយម។

៦-ការគិតចំនួន៩លើកនេះ រួមទាំងការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមនាឆ្នាំ២០០៤។ ការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមនៅឆ្នាំ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយថាជារដ្ឋធម្មនុញ្ញ និងជាគោលការណ៍គេមិនអាចពិនិត្យធម្មនុញ្ញភាពនៃរដ្ឋធម្មនុញ្ញបានទេ។ ការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមអាចធ្វើបានតែនៅក្នុងលក្ខណៈពិសេសនៃសភាដើមនីតិកាលតែប៉ុណ្ណោះ។ ដោយការធ្វើវិសោធនកម្មនៃរដ្ឋធម្មនុញ្ញនិងការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមចេញពីសភាតែមួយ គ្រាន់តែការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមក្នុងករណីចាំបាច់អាចធ្វើនៅក្នុងដើមនីតិកាលនីមួយៗ។ ដើម្បីងាយស្រួលក្នុងការសិក្សា ខ្ញុំបានបញ្ចូលជាមួយគ្នាតែម្តងដោយគិត៩លើកក្នុងការសិក្សាពីការវិវត្តប្រែប្រួល។

លូតលាស់សម្បូររុងរឿង។

ខ្ញុំសិក្សាឃើញមានគុណតម្លៃឧត្តុង្គឧត្តម ក្នុងការកសាងទំនើបភាវូបនីយកម្មនេះ។ ទី១ រដ្ឋធម្មនុញ្ញបានកំណត់រក្សាបន្តតម្លៃធម្មនុញ្ញប្រពៃណីរបស់ខ្មែរ (traditional values) ដោយបានរៀបចំស្តារ និងបង្កើតឡើងវិញ របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ដែលជារបបរាជានិយមទំនើបជឿនលឿន (kingship adapted in democracy) ដូចការអនុវត្តនៅប្រទេសអង់គ្លេស និងជប៉ុន និងបានកំណត់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ព្រះពុទ្ធសាសនា និងអង្គព្រះមហាក្សត្រ មានតម្លៃជានិមិត្តរូបឯកភាពជាតិ និងនិរន្តរភាពជាតិ។ ទី២ រដ្ឋធម្មនុញ្ញបានបណ្តុះ និងបង្កាត់ឡើងវិញនូវគុណតម្លៃធម្មនុញ្ញទំនើប (modern values) ដោយបានកំណត់ ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីការរៀបចំសណ្តាប់ធ្នាប់ស្ថាប័ននយោបាយថ្មី តាមប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យសភានិយម បែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការដាច់ដោយឡែកពីគ្នា កំណត់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ និងកំណត់សិទ្ធិសេរីភាព និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ[៧]។ សេរីភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋ ដែលអង្គតម្លៃទំនើបទាំង៣នេះ ជាមូលដ្ឋានគ្រឹះនៅក្នុងការកសាងរដ្ឋទំនើបរបស់បស្ចិមប្រទេសដែលបានកំណត់ថាសិទ្ធិសេរីភាព និងប្រជាធិបតេយ្យ ត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌនៃនីតិរដ្ឋ។

## ៣- ដើមកំណើតនៃលទ្ធិប្រជាធិបតេយ្យសេរី

លទ្ធិប្រជាធិបតេយ្យសេរី មានដើមកំណើតចេញពីរដ្ឋបស្ចិមប្រទេស (western modern nations) ដោយផ្តើមចេញពីប្រទេសអង់គ្លេសជារដ្ឋស្ថាបនិកដំបូង និងបានចូលមកប្រទេសអាមេរិក ប្រទេសបារាំង និងបន្តរីករាលដាលនៅជុំវិញពិភពលោក ដែលជាប្រព័ន្ធនយោបាយដឹកនាំដោយរដ្ឋាភិបាលប្រជាធិបតេយ្យ ជ្រើសតាំងតាមការបោះឆ្នោត បម្រើអភិបាលកិច្ចល្អ លើកស្ទួយលំហសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

នៅសតវត្សទី១៧ (ចន្លោះឆ្នាំ១៦២៨ ដល់ឆ្នាំ១៦៨៨) ប្រទេសអង់គ្លេសបានឆ្លងកាត់ការធ្វើបដិវត្តន៍២ដង ដើម្បីរៀបចំសណ្តាប់ធ្នាប់នយោបាយថ្មី ប្រែក្លាយរបបរាជា-ធិបតេយ្យ មកជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរី ដោយបានទទួលស្គាល់និងគោរពសិទ្ធិសេរីភាពពលរដ្ឋស៊ីវិល (Bill of Rights) និង

---

៧-សូមអានអត្ថបទដើមនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានវិវត្តចេញពីស្មារតីប្រាកដនិយមរបស់សម្តេចតា គណបក្សប្រជាជន គណបក្សហ៊្វុនស៊ិនប៉ិច និងដោយផ្អែកលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ រួមផ្សំបន្ថែមពីបទពិសោធខ្លះ នៃរដ្ឋធម្មនុញ្ញសម័យមុនៗ រដ្ឋធម្មនុញ្ញ១៩៤៧ រដ្ឋធម្មនុញ្ញ១៩៧២ រដ្ឋធម្មនុញ្ញ១៩៨១ រដ្ឋធម្មនុញ្ញ១៩៨៩ និងបទពិសោធពីបស្ចិមប្រទេស។

បានកំណត់ការបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ (separation of powers)។ បច្ចុប្បន្ននេះ ព្រះមហាក្សត្រអង់គ្លេស ទ្រង់គ្រងរាជសម្បត្តិ ជាតំណាងនិមិត្តរូបជាតិ និងនិរន្តរភាពជាតិ និងទ្រង់មិនកាន់អំណាចរដ្ឋឡើយ។

នៅក្នុងស្នាដៃសៀវភៅស្ដីពី Two Treaties on Civil Government (1691), លោក ចនឡុក (John Locke) អ្នកប្រាជ្ញអង់គ្លេស ជាបិតាស្ថាបនិកនៃរដ្ឋធម្មនុញ្ញទំនើប (លក្ខន្តិក:សង្គម) ឈរលើមូលដ្ឋានគ្រឹះនៃសិទ្ធិសេរីភាពស៊ីវិល ការបែងចែកអំណាចរដ្ឋ ប្រជាធិបតេយ្យ និងនីតិរដ្ឋ ដែលជាគុណតម្លៃធម្មនុញ្ញទំនើបនៃលទ្ធិប្រជាធិបតេយ្យសេរីនិយម។ ទស្សនទាន លោក John Locke មានឥទ្ធិពលខ្លាំងលើបដិវត្តន៍នៅប្រទេសអាមេរិក និងប្រទេសបារាំង។ ក្រោយបដិវត្តន៍ដើម្បីឯករាជ្យរបស់អាមេរិកពីអង់គ្លេស (១៧៧៦) ប្រទេសអាមេរិកបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញទំនើប បង្កើតរបបសាធារណៈ-រដ្ឋនិយមប្រធានាធិបតី (១៧៨៨) និងលទ្ធិប្រជាធិបតេយ្យសេរីនិយម។ ស្របគ្នានេះ បដិវត្តន៍នៅប្រទេសបារាំង ឆ្នាំ១៧៨៩ បានចេញសេចក្តីប្រកាសស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (Declaration of the Rights of Man and of the Citizen) និងបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៧៩១ ប្រកាសបង្កើតរបបសាធារណរដ្ឋបារាំងដំបូង ប៉ុន្តែក្រោយមកបានកែប្រែវិលចុះវិលឡើង រហូតមកដល់រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៥ (១៩៥៨) បង្កើតបានជាម៉ូដែលថ្មីមួយជាស្ថាពរ សាធារណរដ្ឋបែបបារាំង មានប្រធានាធិបតីផង និងនាយករដ្ឋមន្ត្រីផង។

នៅក្នុងបណ្តាប្រទេសអាស៊ី ប្រទេសជប៉ុនជាប្រទេសទី១ ដែលបានចាប់ផ្តើមរៀបចំធ្វើទំនើបកម្មប្រទេសតាមបែបរដ្ឋបស្ចិមប្រទេស ដោយបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៨៨៩ យកម៉ូដែលតាមរដ្ឋធម្មនុញ្ញអាឡឺម៉ង់ (Prussian Constitution) ដោយរដ្ឋធម្មនុញ្ញអាឡឺម៉ង់កាលនោះ មានភាពស្រដៀងគ្នាជាមួយទម្លាប់វប្បធម៌នយោបាយជប៉ុន ដែលអធិរាជមានអំណាចសកម្មនៅក្នុងនយោបាយ (កាន់អំណាច) មិនដូចប្រទេសអង់គ្លេសដែលរដ្ឋសភាមានអំណាចអធិបតេយ្យ (parliamentary sovereignty) ទាំងផ្លូវច្បាប់ និងផ្លូវនយោបាយ និងព្រះមហាក្សត្រគ្រាន់តែជានិមិត្តរូប ដោយទ្រង់មិនកាន់អំណាច ចំណែកម៉ូដែលប្រទេសអាមេរិកមានភាពសេរីខ្លាំងពេក មិនស៊ីគ្នាជាមួយទម្លាប់សង្គមវប្បធម៌នយោបាយជប៉ុននាសម័យនោះ។ ប៉ុន្តែក្រោយចប់សង្គ្រាមលោកលើកទី២ ប្រទេសជប៉ុនបានអនុមត័រដ្ឋធម្មនុញ្ញថ្មី ក្រោមសម្ពាធអាមេរិកាំង ដោយទទួលយករដ្ឋធម្មនុញ្ញទំនើប តាមម៉ូដែលប្រទេសអង់គ្លេស រាជានិយមប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរី តាមប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យសភានិយម គិតមកដល់

ពេលនេះមានរយៈពេល៧៣ឆ្នាំ និងជារដ្ឋធម្មនុញ្ញដែលពិបាកកែប្រែ[៨] និងមិនធ្លាប់បានធ្វើវិសោធនកម្ម ប៉ុន្តែតម្លៃប្រជាធិបតេយ្យជប៉ុនបានវិវឌ្ឍពេញលេញ និងរឹងមាំជាស្ថាពរ។

## ៤- ការវិវត្តតម្លៃប្រជាធិបតេយ្យកម្ពុជា

កន្លងទៅ មានការជជែកវែកញែកខ្លះៗ ពីដំណើរការវិវត្តតម្លៃប្រជាធិបតេយ្យកម្ពុជា និងមានការវាយតម្លៃខុសៗគ្នាទៅតាមនិន្នាការរបស់បុគ្គលនិងក្រុម។ នេះអាចមកពីការយល់ដឹងរបស់ពួកគាត់ពីតម្លៃប្រជាធិបតេយ្យកម្ពុជាមិនដូចគ្នា។ ម្យ៉ាងវិញទៀត យើងត្រូវដឹងថា ប្រជាធិបតេយ្យមានគោលការណ៍ នីតិវិធី និងគុណតម្លៃមិនដូចគ្នាទេ នៅតាមប្រទេសនីមួយៗ និងបានវិវត្តប្រែប្រួលតាមដំណាក់កាល។ ចំពោះអ្នកសិក្សាស្រាវជ្រាវមកដល់ពេលនេះ ក៏មិនទាន់មានការឯកភាពគ្នាណាមួយក្នុងការកំណត់តម្លៃប្រជាធិបតេយ្យជារួមនៅឡើយ និងតម្លៃប្រជាធិបតេយ្យវិវត្តតាមដំណាក់កាល។ នៅក្នុងដំណាក់កាលដំបូង (classic democracy, សតវត្សទី១៨ និង១៩) តម្លៃប្រជាធិបតេយ្យសំដៅលើដំណើរការរៀបចំពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងការប្រកួតប្រជែងក្នុងការបោះឆ្នោត (កម្រិតប្រសិទ្ធភាពស្ថាប័ន)។ ការរៀបចំគោលការណ៍ នីតិវិធី និងយន្តការស្ថាប័នធានាឱ្យបានរដ្ឋាភិបាលមួយជារបស់ប្រជាជន ដោយប្រជាជន និងដើម្បីប្រជាជន (a government of the people, by the people and for the people) ដោយកំណត់ការបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការស្របគ្នាជាមួយការរៀបចំសណ្តាប់ធ្នាប់ប្រកួតប្រជែងការបោះឆ្នោត ដែលធានាឱ្យអ្នកនយោបាយ និងបេក្ខជនឈរឈ្មោះ អាចសំដែងមតិដោយសេរី មិនមានការភ័យខ្លាច និងគោរពក្រមសីលធម៌នយោបាយថ្លៃថ្នូរ។

ដោយឡែកនៅក្នុងដំណាក់កាលប្រជាធិបតេយ្យទំនើប (modern democracy, សតវត្សទី២០/២១) តម្លៃប្រជាធិបតេយ្យត្រូវបានពង្រីកទូលំទូលាយ ដោយផ្តោតលើកម្រិតលំហសេរីភាពរបស់ពលរដ្ឋស៊ីវិល និងគណបក្សនយោបាយ។ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពេញលេញក្នុងការចូលរួមគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច និងសង្គមតាមការសំដែងមតិដោយសេរីចំពោះបញ្ហានានាដែលបានកើតមានក្នុងសហគមន៍របស់ពួកគាត់ ស្របគ្នាជាមួយកម្រិតសមត្ថភាពនៃស្ថាប័នប្រជាធិបតេយ្យក្នុងការឆ្លើយ

---

៨-រដ្ឋធម្មនុញ្ញជប៉ុនឆ្នាំ១៩៤៧ បានកំណត់នីតិវិធីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញតាមយន្តការអនុម័តសំឡេង២/៣ ពីសភាទាំងពីរ និងបន្ទាប់មកតាមយន្តការធ្វើប្រជាមតិទូទាំងប្រទេស។ កន្លងទៅអ្នកនយោបាយជប៉ុនបានព្យាយាមសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាច្រើនលើកពាក់ព័ន្ធមាត្រា៩ ដែលបានហាមប្រទេសជប៉ុនមិនឱ្យមានកងកម្លាំងយោធា និងអាវុធយុទ្ធភណ្ឌទាំងអស់បម្រើឱ្យវិស័យយោធាដែលកាលនោះអាមេរិកបានធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញដោយបានកំណត់គោលការណ៍នេះឈរលើមូលដ្ឋានដើម្បីសន្តិភាពពិភពលោក។

តបទៅនឹងសេវាតម្រូវការនិងសេវាសំណូមពររបស់ពលរដ្ឋ។ នៅក្នុងដំណើរការនេះ គណបក្សនយោបាយ (political parties) បានងើបឡើងជាតួអង្គស្នូលសំខាន់ក្នុងដំណើរការប្រជាធិបតេយ្យទំនើប។ ប្រព័ន្ធបក្ស និងគណបក្សនយោបាយបានដើរតួនាទីសំខាន់ក្នុងការផ្តល់នូវជម្រើសគំនិតនយោបាយ និងភាពជាអ្នកដឹកនាំនយោបាយសកម្មនៅក្នុងយន្តការរដ្ឋ។

នៅក្នុងឯកសារគោលរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីផែនការយុទ្ធសាស្ត្រកែទម្រង់ច្បាប់និងតុលាការ បានកំណត់តម្លៃប្រជាធិបតេយ្យកម្ពុជាក្នុងដំណាក់កាលដំបូងផ្តោតលើការរៀបចំកសាងសមត្ថភាពស្ថាប័នតំណាងថ្នាក់ជាតិ វិមជ្ឈការអំណាចទៅថ្នាក់ក្រោមជាតិ សេដ្ឋកិច្ចទីផ្សារ និងសេវាសាធារណៈ។ នៅក្នុងស្ថានភាពជាក់ស្តែងប្រជាធិបតេយ្យរបស់កម្ពុជាបានចាប់ដំណើរការ និងវិវត្តនៅក្នុងដំណាក់កាលព្រមគ្នាក្នុងពេលតែមួយ ពីការបង្កើត ការពង្រឹង និងការពង្រីកប្រសិទ្ធភាពស្ថាប័នប្រជាធិបតេយ្យស្របគ្នាជាមួយលំហូរសេរីភាពចម្រុះពណ៌ និងវត្តមាននៃគណបក្សនយោបាយជាច្រើនដោយមានអន្តរជាតិចូលរួមចំណែកជួយក្នុងដំណើរការកំណែទម្រង់នយោបាយ សេដ្ឋកិច្ច និងច្បាប់។ នៅក្នុងបរិបទបែបនេះ ប្រជាធិបតេយ្យកម្ពុជាស្ថិតក្នុងភាពប្រឈម ប្រសិនបើប្រជាពលរដ្ឋ និងអ្នកនយោបាយកម្ពុជា មិនបានយល់ដឹងច្បាស់ពីតម្លៃប្រជាធិបតេយ្យ និងតម្លៃប្រពៃណីជាតិ។ នៅក្នុងសង្គមប្រជាធិបតេយ្យ របបសេរីភាព និងប្រជាធិបតេយ្យត្រូវបានអនុវត្តនៅក្នុងក្របខ័ណ្ឌច្បាប់។ តម្លៃប្រជាធិបតេយ្យអាស្រ័យលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់អាស្រ័យលើសមត្ថភាពស្ថាប័ន ស្របគ្នានឹងកម្រិតនៃការយល់ដឹងរបស់គណបក្សនយោបាយ និងប្រជាពលរដ្ឋ។

ប្រជាធិបតេយ្យកម្ពុជាប្រតិបត្តិតាមរបបរដ្ឋាភិបាលសភានិយម ប្រកាន់យកប្រព័ន្ធបោះឆ្នោតសមាមាត្រតាមខេត្តក្រុង។ ប្រព័ន្ធនេះនៅក្នុងទ្រឹស្តីអាចជួយបង្កលក្ខណៈឱ្យមានវឌ្ឍនភាពចំពោះពហុបក្សដែលជាមូលដ្ឋានគ្រឹះនៃតម្លៃប្រជាធិបតេយ្យសេរី ជាពិសេសក្នុងរបបសភានិយម។ គណបក្សនយោបាយបានដើរតួនាទីសំខាន់ក្នុងដំណើរការប្រជាធិបតេយ្យសភា និងប្រទេសកម្ពុជាបានកំណត់យកប្រជាធិបតេយ្យសេរីពហុបក្ស។

## តារាងលទ្ធផលបោះឆ្នោតតំណាងរាស្ត្រតាមនីតិកាល

| Election Year | Parties in Election | Parties won Seats | The people's voted | Cabinet Gov't |
|---|---|---|---|---|
| 1993 | 23 | FUNCINPEC<br>58<br>CPP<br>51<br>BLDP<br>10<br>MOLINAKA<br>1 | 86.78% of 4.6 M | Coalition Gov't |
| 1998 | 39 | CPP<br>64<br>FUNCINPEC<br>43<br>SRP<br>15 | 90% | Coalition Gov't<br>Opposition Party |
| 2003 | 23 | CPP<br>73<br>FUNCINPEC<br>26<br>SRP<br>24 | 81% | Coalition Gov't<br>Opposition Party |
| 2008 | 11 | CPP<br>90<br>SRP<br>26<br>HRP<br>3<br>FUNCINPEC<br>2<br>NRP<br>2 | 80% | Coalition Gov't<br>Opposition Parties |

| | | | | |
|---|---|---|---|---|
| 2013 | 8 | CPP<br>68<br>CNRP<br>55 | 69.6% | Ruling Party & Opposition Parties |
| 2018 | 20 | CPP<br>125 | 83.02% of 9.88 M | Ruling Party & Opposition parties |

Note: due to the CNRP was dissolved by the Supreme Court in 2017 and so all assembly seats were re-distributed in according to the election law in which CPP (79), FUNCINPEC (41), Cambodian Nationality Party (2) & Khmer Economic Development Party (1).

ប្រជាធិបតេយ្យបនីយកម្មកម្ពុជានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានវិវត្តពេញលេញដោយកំណត់ការបោះឆ្នោតតាមនីតិកាល ក្នុងនោះរដ្ឋសភា (១៩៩៣ ចំនួន៦ដង) ព្រឹទ្ធសភា (១៩៩៩ ចំនួន៣ដង) ក្រុមប្រឹក្សាឃុំ/សង្កាត់ (២០០២ ចំនួន៤ដង) ក្រុមប្រឹក្សាស្រុក/ខណ្ឌ និងក្រុមប្រឹក្សាខេត្ត/រាជធានី (២០០៩ ចំនួន៣ដង) ដោយមានពហុបក្សចូលរួមប្រកួតប្រជែង។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាចំណុចស្នូលនៃការប្រកួតប្រជែងរបស់គណបក្សនយោបាយនានា ដើម្បីឡើងកាន់អំណាចកំពូលរបស់ប្រទេស។

ពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោត មានការតវ៉ាក្នុងការបោះឆ្នោត ការមិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោត ការធ្វើបាតុកម្ម និងធ្វើពហិការមិនព្រមចូលប្រជុំរដ្ឋសភា និងការធ្វើពហិការមិនព្រមចូលរួមបង្កើតរាជរដ្ឋាភិបាលចម្រុះ ជាចលនាចេញពីគណបក្សដែលចាញ់ឆ្នោត នឹងត្រូវបានការរៀបចំកែសម្រួលជាបន្តបន្ទាប់បង្កើតចេញនូវដំណោះស្រាយថ្មីៗតាមច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីធានានូវដំណើរការរដ្ឋ។

ទី១ ការកែសម្រួលប្រព័ន្ធសភាពីទោលមកទ្វេ (បង្កើតព្រឹទ្ធសភា ឆ្នាំ១៩៩៩) មានសារៈសំខាន់ចំពោះតម្លៃប្រពៃណីនិងតម្លៃប្រជាធិបតេយ្យ។ ទី១ ដើម្បីបង្រួបបង្រួមនយោបាយគណបក្សដែលបានមានអរិភាព។ ទី២ ដើម្បីពង្រីកប្រជាធិបតេយ្យសភាដោយប្រព័ន្ធទ្វិសភាមានតម្លៃប្រជាធិបតេយ្យប្រសើរជាងប្រព័ន្ធសភាទោល ពីព្រោះប្រព័ន្ធ

ទ្ធិសភា បានពង្រីកយន្តការចូលរួមរបស់អ្នកនយោបាយបានទូលំទូលាយ និងបានពង្រឹងការពិនិត្យបានគ្រប់ជ្រុងជ្រោយក្នុងដំណើរការធ្វើច្បាប់។ ទី៣ បានស្តារឡើងវិញនូវស្ថាប័នប្រវត្តិសាស្ត្រដែលធ្លាប់មានពីមុន។ ករណីនេះបានផ្តួចផ្តើមចេញពីការសម្របសម្រួលនយោបាយរវាងគណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច ក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ។ បច្ចុប្បន្នរដ្ឋសភា និងព្រឹទ្ធសភា កាន់អំណាចនីតិប្បញ្ញត្តិ។

ទី២ ការអនុម័តច្បាប់ធម្មនុញ្ញបន្ថែមដើម្បីធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ (ឆ្នាំ២០០៤) ផ្តើមចេញពីស្មារតីសម្របសម្រួលនយោបាយរវាងគណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច។ បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ (២០០៣) ដំណើរការរៀបចំរាជរដ្ឋាភិបាលថ្មីតាមនីតិវិធីរដ្ឋធម្មនុញ្ញដែលបានកំណត់មិនអាចអនុវត្តបាន និងបានជាប់គាំងជិត១ឆ្នាំ។ បញ្ហានេះត្រូវបានដោះស្រាយតាមច្បាប់ធម្មនុញ្ញបន្ថែមឆ្នាំ២០០៤ ដោយបានកំណត់នីតិវិធីថ្មីស្តីពីការរៀបចំការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងក្បាលម៉ាស៊ីនរដ្ឋសភាក្នុងពេលជាមួយគ្នា នឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ ច្បាប់ធម្មនុញ្ញបន្ថែមនេះបានពង្រឹងបន្ថែមសណ្តាប់ធ្នាប់នយោបាយប្រជាធិបតេយ្យរវាងអំណាចទាំង២ ឱ្យដើរស្របតាមឆន្ទៈប្រជាពលរដ្ឋតាមលទ្ធផលនៃការបោះឆ្នោតដើម្បីធានានូវនិរន្តរភាពស្ថាប័នជាតិ និងតម្លៃប្រជាធិបតេយ្យដោយផ្ទាល់។ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយថា ច្បាប់ធម្មនុញ្ញបន្ថែមជារដ្ឋធម្មនុញ្ញ។

ទី៣ ការដាក់រាជសម្បត្តិ (២០០៤) ជាករណីពិសេស។ រដ្ឋធម្មនុញ្ញមិនមានចែងចំពោះករណីនេះទេ ប៉ុន្តែវាបានប្រព្រឹត្តទៅតាមទម្លាប់ប្រពៃណី ដោយការអនុម័តច្បាប់បំពេញបន្ថែម។ ព្រះមហាក្សត្របានផ្ញើព្រះរាជសារជូនរដ្ឋសភាពីការសម្រេចដាក់រាជសម្បត្តិចូលនិវត្តន៍ជាស្ថាពរ (ថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤) ដោយមូលហេតុព្រះរាជសុខភាព និងទម្លាប់ប្រពៃណីនៅក្នុងរបបរាជានិយម។ រដ្ឋសភា និងព្រឹទ្ធសភា បានរៀបចំតាក់តែង និងអនុម័តច្បាប់ស្តីពីក្រុមប្រឹក្សារាជសម្បត្តិ និងបានប្រកាសដាក់ឱ្យប្រើភ្លាមដោយប្រមុខរដ្ឋស្តីទីនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤ ដោយបានកំណត់ថា ក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃក្រោយពី ព្រះមហាក្សត្រ ទ្រង់ចូលទិវង្គត ឬចូលនិវត្តន៍ ឬដាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិត្រូវជ្រើសរើសព្រះមហាក្សត្រថ្មី តាមសំឡេងភាគច្រើនដាច់ខាត។ ព្រះមហាក្សត្រដែលទ្រង់បានយាងចូលនិវត្តន៍ ឬដាក់រាជ្យ និងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញ និងមិនអាចរណារំលោភបំពានបានឡើយ។ ការវិវត្តថ្មីនេះជាការអនុវត្តតាមទម្លាប់ប្រពៃណី។

បច្ចុប្បន្នភាព ព្រះមហាក្សត្រកម្ពុជាទ្រង់មិនគ្រាន់តែជានិមិត្តរូបឯកភាពជាតិ

និរន្តរភាពជាតិ តែទ្រង់ក៏បានក្លាយជានិមិត្តរូបប្រជាធិបតេយ្យ។ ទី១ របបរាជានិយមកម្ពុជា ជារបបជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិដែលមានសមាសភាព៩រូបមកពីប្រធាន អនុប្រធានព្រឹទ្ធសភា ប្រធាន អនុប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងសម្តេចព្រះសង្ឃរាជទាំង២គណៈ។ ក្នុងចំណោម៩រូប មាន៧រូបជាថ្នាក់ដឹកនាំនយោបាយកំពូលដែលត្រូវបានជ្រើសតាំងតាមលទ្ធិប្រជាធិបតេយ្យ និងក៏ជាថ្នាក់ដឹកនាំគណបក្សនយោបាយមានអាសនៈក្នុងសភា។ ទី២ ទ្រង់បានបំពេញព្រះរាជកិច្ចជាព្រះប្រមុខរដ្ឋ ឡាយព្រះហស្តលេខាលើព្រះរាជក្រម និងព្រះរាជក្រឹត្យស្របតាមការស្នើសុំ ពីស្ថាប័នប្រជាធិបតេយ្យ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ទី៣ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ រាជវង្សានុវង្សបានស្ងប់ស្ងាត់ពីនយោបាយដែលបានជួយលើកស្ទួយតម្លៃរាជានិយម។ បើសិនជាការវិវត្តចុងក្រោយនេះ ក្លាយជាក្រមប្រតិបត្តិរបស់រាជវង្សានុវង្សជាប់លាប់ នោះជាបាតុភូតអស្ចារ្យមួយដូចគ្នានឹងការប្រតិបត្តិនៅប្រទេសអង់គ្លេស និងជប៉ុនដែលជានិមិត្តរូបជោគជ័យប្រជាធិបតេយ្យ។

ទី៤ ការកែប្រែរូបមន្ត នៃការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលពី២/៣ ដោយបានទម្លាក់មកនៅត្រឹម ៥០% +១ និងកូរ៉ុមប្រជុំសភាពី ៣/៤ មកនៅត្រឹមពី ២/៣ ឬ ៥០% +១ នៃចំនួនសមាជិកសរុប (ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ២០០៦) ជាការវិវត្តមួយថ្មីទៀតនៃប្រសិទ្ធភាពប្រជាធិបតេយ្យកម្ពុជា ជាពិសេសពង្រឹងការប្រកួតប្រជែង និងការទទួលខុសត្រូវនយោបាយគណបក្ស។ ការវិវត្តនេះជាដំណោះស្រាយបាននាំមកនូវប្រសិទ្ធភាពប្រជាធិបតេយ្យសភា ដែលកន្លងទៅមានការពិបាកក្នុងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ និងក៏បានជួយកាត់បន្ថយជំងឺខ្វះកូរ៉ុមប្រជុំរដ្ឋសភាផងដែរ។

ប្រជាធិបតេយ្យសភាកម្ពុជា សមាជិកនៃរដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសតាំងតាមប្រព័ន្ធសមាមាត្រ ខេត្ត ក្រុង ៥ឆ្នាំម្តង។ គណបក្សនយោបាយត្រូវបានចុះឈ្មោះចូលរួមប្រកួតប្រជែង តាមការរៀបចំចាត់ចែងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណបក្សឈ្នះឆ្នោតត្រូវបានរៀបចំរាជរដ្ឋាភិបាល ដែលត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបអមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក និងត្រូវបានតែងតាំងដោយព្រះមហាក្សត្របន្ទាប់ពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយរដ្ឋសភាតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១)។ នាយករដ្ឋមន្ត្រីត្រូវតែជាសមាជិករដ្ឋសភាមកពីគណបក្សឈ្នះឆ្នោត។

ទី៥ ការកែសម្រួលការរៀបចំការបោះឆ្នោតដើម្បីធានាដំណើរការបោះឆ្នោតឱ្យ

កាន់តែមានទំនុកចិត្ត (២០១៤) ជាការបន្តការកែទម្រង់ស៊ីជម្រៅដើម្បីធានាសណ្តាប់ធ្នាប់ក្នុងការបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ បញ្ហាមិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោតដោយគណបក្សចាញ់ឆ្នោតនៅតែមានបន្តក្នុងរូបភាពប្រមូលផ្តុំបាតុកម្ម និងធ្វើពហិការមិនព្រមចូលប្រជុំរដ្ឋសភា និងបានប្រែក្លាយទៅជាអំពើហិង្សា និងបានបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់នយោបាយប្រជាធិបតេយ្យ និងសេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិ។ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានព្រមព្រៀងគ្នា រៀបចំការកែទម្រង់ការបោះឆ្នោតដោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ប្រែក្លាយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅជាស្ថាប័នធម្មនុញ្ញ (២០១៤) វិសោធនកម្មច្បាប់បោះឆ្នោតដោយកែសម្រួលប្រព័ន្ធចុះឈ្មោះការបោះឆ្នោត ពង្រឹងនូវសណ្តាប់ធ្នាប់ជាថ្មី រួមមានចំណុចសំខាន់ៗជាច្រើន ត្រូវបានដោះស្រាយដើម្បីធានានូវសណ្តាប់ធ្នាប់រៀបរយ និងសេចក្តីថ្លៃថ្នូរក្នុងការបោះឆ្នោត និងក្រោយការបោះឆ្នោតឱ្យកាន់តែរឹងមាំ ដែលក្នុងនោះមានដំណោះស្រាយសំខាន់មួយបានកំណត់ថា គណបក្សនយោបាយណាដែលនៅតែបន្តមិនព្រមចូលរួមប្រជុំរដ្ឋសភាតាមការកោះហៅរបស់ព្រះមហាក្សត្រ ឬមិនព្រមចូលស្បថចូលកាន់តំណែងត្រូវចាត់ទុកថាបានបោះបង់ចោលអាសនៈទាំងស្រុង ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបែងចែកអាសនៈជាថ្មីស្របតាមនីតិវិធីច្បាប់ជាធរមាន។ ការកែទម្រង់ការរៀបចំការបោះឆ្នោតនេះជាការវិវត្តមួយថ្មីទៀត ដើម្បីធានានូវការប្រកួតប្រជែងរបស់គណបក្សនយោបាយឱ្យមានភាពស្មោះត្រង់ និងតម្លាភាពចំពោះតម្លៃប្រជាធិបតេយ្យតាមរយៈលទ្ធផលបោះឆ្នោតដែលជាឆន្ទៈពិតរបស់ពលរដ្ឋ។

ទី៦ វិធានការច្បាប់ក្នុងការរំលាយគណបក្សនយោបាយ (២០១៧) ដើម្បីធានានូវការគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីគណបក្សនយោបាយជាដំណាក់កាលវិវត្តថ្មីចុងក្រោយ។ នៅក្នុងសង្គមប្រជាធិបតេយ្យ ការកំណត់វិធានការច្បាប់រំលាយគណបក្សនយោបាយដែលប្រឆាំងនឹងរដ្ឋ ឬប្រឆាំងនឹងប្រជាធិបតេយ្យមានភាពខុសៗគ្នា និងអាស្រ័យតាមវប្បធម៌នយោបាយរបស់ប្រទេសនីមួយៗ។ នៅក្នុងប្រទេសអាឡឺម៉ង់ ប្រទេសបារាំង អ៊ីតាលី អេស្ប៉ាញ និងថៃឡង់បានប្រកាន់យកជម្រើសរំលាយចោលតាមផ្លូវច្បាប់ឱ្យទៅតុលាការកំពូល ឬតុលាការធម្មនុញ្ញដើម្បីរំលាយគណបក្សនយោបាយ និងបានហាមប្រាមអ្នកនយោបាយ មិនឱ្យធ្វើនយោបាយមួយរយៈ ប្រសិនបើតុលាការបានរកឃើញថា សកម្មភាពនយោបាយរបស់គណបក្សនោះ បានរំលោភលើរដ្ឋធម្មនុញ្ញ ច្បាប់ និងបំផ្លាញរបបប្រជាធិបតេយ្យ។ ប៉ុន្តែដោយឡែក ប្រទេសអង់គ្លេស អាមេរិក និងជប៉ុនបានប្រកាន់ជម្រើសមិនរំលាយគណបក្សនយោបាយទេ ដោយបានអនុវត្តត្រឹមតែពិន័យ

ដកហូតការឈរឈ្មោះពីបុគ្គល ឬអនុវត្តទោសព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក្តី រដ្ឋប្រជាធិបតេយ្យនីមួយៗ មានជម្រើសក្នុងការអនុវត្តរបស់គេ។

ទី៧ សមាជិកភាពរាជរដ្ឋាភិបាល (ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ២០១៨) ត្រូវបានកែសម្រួលកាត់បន្ថយមួយថ្នាក់ (រដ្ឋលេខាធិការ) ដោយកំណត់ត្រឹមរដ្ឋមន្ត្រីជាសមាជិក។ ការកែសម្រួលនេះសំដៅពង្រឹងការទទួលខុសត្រូវ របស់ប្រធានស្ថាប័ន (រដ្ឋមន្ត្រី) ពង្រឹងប្រសិទ្ធភាពប្រជាធិបតេយ្យ និងប្រសិទ្ធភាពអភិបាលកិច្ចល្អនៅតាមក្រសួងស្ថាប័នរដ្ឋនានា។ អភិបាលកិច្ចល្អជាគោលនយោបាយស្នូលរបស់រាជរដ្ឋាភិបាល។

ទី៨ សមាជជាតិជាវេទិកាប្រជាធិបតេយ្យមួយកំណត់ដោយរដ្ឋធម្មនុញ្ញ ដែលមិនទាន់ត្រូវបានអនុវត្តនៅឡើយ។ ករណីនេះត្រូវបានជជែកនៅក្នុងចំណោមអ្នកសិក្សានីតិរដ្ឋធម្មនុញ្ញ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងស្ថានភាពជាក់ស្តែង សមាជជាតិមិនមានភាពចាំបាច់នៅឡើយ នៅពេលប្រជាធិបតេយ្យសភាជាពហុបក្ស និងម៉្យាងវេទិកាប្រជាធិបតេយ្យមួយចំនួនត្រូវបានបង្កើតជាបន្តបន្ទាប់ នៅក្នុងអំណាចនីតិប្រតិបត្តិ (ចាប់ពីឆ្នាំ២០១៣)។ រាជរដ្ឋាភិបាលបានបង្កើតវេទិកាប្រជាធិបតេយ្យដោយផ្ទាល់ ជាច្រើនរូបភាព ដើម្បីពង្រឹងពង្រីកបន្ថែមក្រៅពីដំណើរការប្រជាធិបតេយ្យសភាតំណាង (១) វេទិកាសាធារណៈថ្នាក់មូលដ្ឋានឃុំសង្កាត់ ដើម្បីពង្រឹងប្រសិទ្ធភាព ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការដោះស្រាយបញ្ហាថ្នាក់មូលដ្ឋាននៅនឹងកន្លែង (២) វេទិការាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីពង្រឹងប្រសិទ្ធភាព អភិបាលកិច្ចល្អ និងប្រសិទ្ធភាពនៃដំណើរការកែទម្រង់គោលនយោបាយថ្នាក់ជាតិ និង(៣) វេទិកាឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ ដែលមានសមាសភាពគណបក្សក្រៅរដ្ឋសភា និងគណបក្សកាន់អំណាច ដើម្បីពិគ្រោះយោបល់ដោះស្រាយបញ្ហាជាតិទូទៅនានានិង(៤) រដ្ឋាភិបាលឌីជីថលជាពិសេស Facebook Page របស់សម្តេចតេជោនាយករដ្ឋមន្ត្រីជាយន្តការផ្សព្វផ្សាយសកម្មភាព របស់សម្តេចនាយករដ្ឋមន្ត្រី និងជាការទទួលស្តាប់មតិមហាជន។ នេះជាវឌ្ឍនភាពនៃការវិវត្តសិល្បៈប្រជាធិបតេយ្យកម្ពុជាដែលជាយន្តការសំខាន់មួយក្នុងការពង្រីកលំហសេរីភាពនៅក្នុងសង្គម។

ស្របគ្នានឹងវឌ្ឍនភាពនៃដំណើរការប្រជាធិបតេយ្យ ក៏មាននិន្នាការអវិជ្ជមានថ្មីៗដែលបានធ្វើឱ្យមានឥទ្ធិពល និងប៉ះពាល់ដល់តម្លៃប្រជាធិបតេយ្យកម្ពុជាដែលត្រូវពិនិត្យសិក្សាពិចារណាដោយប្រុងប្រយ័ត្ន។ ក្រុមអ្នកនយោបាយមួយចំនួនកំពុងធ្វើនយោបាយក្រៅក្របខ័ណ្ឌច្បាប់នៅក្រៅប្រទេស ធ្វើសកម្មភាពប្រឆាំងដំណើរការប្រជាធិបតេយ្យ និងឃោសនាប្រឆាំងបរិហាររាជរដ្ឋាភិបាលស្របច្បាប់ និងគណបក្សកាន់អំណាច ញុះញង់

បង្កអរិភាព និងអស្ថិរភាពតាមបណ្តាញសង្គម ធ្វើឱ្យប៉ះពាល់ដល់តម្លៃវប្បធម៌ប្រជាធិប-តេយ្យ សេរីភាព និងនីតិរដ្ឋ។

## ៥- កំណត់សម្គាល់ទូទៅ

(១) រដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នជាច្បាប់កំពូលរបស់ប្រទេស បាននាំមកនូវស្ថិរភាព និងការផ្លាស់ប្តូរ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គនីតិរដ្ឋធានាការគោរពរដ្ឋធម្មនុញ្ញ។ ព្រះមហាក្សត្រកម្ពុជាទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យ ព្រះអង្គទ្រង់គ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ ទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត និងជានិមិត្តរូបឯកភាពជាតិ និរន្តរភាពជាតិ និងប្រជាធិបតេយ្យ។ នេះជាការផ្លាស់ប្តូរដ៏សំខាន់។

(២) ប្រជាធិបតេយ្យកម្ពុជាបានបង្កាត់តាមម៉ូដែលបស្ចិមប្រទេស (ប្រជាធិប-តេយ្យសេរីពហុបក្ស) កំណត់យករបបប្រជាធិបតេយ្យសភាដែលត្រូវបានជ្រើសតាំង តាមការបោះឆ្នោតផ្លាស់ប្តូរ៥ឆ្នាំម្តង។ ប្រជាពលរដ្ឋជាម្ចាស់អំណាចទាំងអស់ និងបានប្រើអំណាចតាមការបោះឆ្នោតជ្រើសតាំង និងតាមស្ថាប័នតំណាងរបស់ខ្លួន។

(៣) ប្រជាធិបតេយ្យកម្ពុជាជាប្រជាធិបតេយ្យសេរីពហុបក្ស។ គណបក្សជាតួអង្គប្រតិបត្តិដ៏សំខាន់ក្នុងដំណើរការប្រជាធិបតេយ្យសភា។ គណបក្សជាថ្នាលបណ្តុះទស្សនៈនយោបាយ ថ្នាលបណ្តុះអ្នកនយោបាយវ័យក្មេង ថ្នាលបណ្តុះវប្បធម៌ប្រជាធិប-តេយ្យ វប្បធម៌សន្ទនា និងវប្បធម៌ទទួលខុសត្រូវចំពោះជាតិមាតុភូមិ។ ក្នុងបរិបទនេះប្រជាធិបតេយ្យកម្ពុជាពឹងលើនយោបាយគណបក្ស។ បើនយោបាយគណបក្សមានទស្សនៈប្រាកដនិយមស្របតាមស្មារតីប្រជាធិបតេយ្យ ដើម្បីកសាង ការពារ និងបម្រើផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋ នោះប្រទេសជាតិនឹងមានសុខដុមរមនីយកម្មផ្ទៃកនយោបាយ សេដ្ឋកិច្ច សង្គម កាន់តែរឹងមាំ កាន់តែរីកចម្រើនជឿនលឿន ប្រជាជាតិមានសេចក្តីថ្លៃថ្នូរ និងជារដ្ឋស៊ីវិល័យ។

(៤) សណ្តាប់ធ្នាប់ប្រជាធិបតេយ្យកម្ពុជានៅក្រោមនីតិរដ្ឋ។ ច្បាប់ជាសេចក្តីសំដែងឆន្ទៈជាតិតាមរយៈអំណាចនីតិប្បញ្ញត្តិ។ អំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានលំនឹងស្ថិរភាពនៅគ្រប់នីតិកាល។ សុខដុមរមនីយកម្មប្រជាធិបតេយ្យសភា ជាតម្លៃពិសេសនៃប្រជាធិបតេយ្យកម្ពុជា ដោយអំណាចត្រួតពិនិត្យគ្នារវាងអំណាចទាំង៣ មិនត្រូវបានយកមកអនុវត្តទេ ប៉ុន្តែមានកម្រិតស្វ័យភាពពីគ្នាលើមុខងារ។ គណបក្សក្នុងសភាត្រូវបានផ្លាស់ប្តូរតាមលទ្ធផលនៃការបោះឆ្នោតជាក់ស្តែងទៅតាមនីតិកាលនីមួយៗ។ គណបក្សកាន់អំណាច ជាគណបក្សឈ្នះឆ្នោតមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា

គណបក្សជំទាស់ជាគណបក្សមានអាសនៈតិចជាងនៅក្នុងរដ្ឋសភា ឬនៅក្រៅរដ្ឋសភា មានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសកម្មភាពនយោបាយស្របតាមច្បាប់។ គណបក្សនិយមជ្រុល (Extremist) ដែលបានធ្វើសកម្មភាពប្រឆាំងនឹងរដ្ឋ ឬប្រឆាំងនឹងដំណើរការប្រជាធិបតេយ្យត្រូវបានហាមប្រាមដោយច្បាប់ និងក្លាយជាកម្មវត្ថុរំលាយចោលដោយអំណាចតុលាការដែលជាអំណាចឯករាជ្យ។

(៥) អនាគតប្រជាធិបតេយ្យកម្ពុជាអាស្រ័យលើប្រជាពលរដ្ឋខ្មែរ ដ្បិតលោកជាម្ចាស់វាសនារបស់ប្រទេសជាតិ។ គណបក្សជាតួអង្គប្រតិបត្តិ។ ពហុបក្សជាលំហសេរីភាពដែលធានាដោយច្បាប់ ប៉ុន្តែការបោះឆ្នោតជាការប្រកួតប្រជែងរវាងគណបក្ស និងភាពប្រាកដនិយម នៃកម្មវិធីនយោបាយរបស់គណបក្ស។ គណបក្សមានទស្សនៈនយោបាយប្រាកដនិយម ដោយបានបម្រើ បានដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ និងបាននៅជាប់លាប់ជាមួយពួកគាត់ជាកត្តាកំណត់ភាពឈ្នះ។ ប្រព័ន្ធបោះឆ្នោតកម្ពុជាយកតាមប្រព័ន្ធសមាមាត្រខេត្ត/ក្រុងមានតម្លៃបច្ចេកទេសរឹងមាំណាស់ និងធានាបាននូវការស្រូបយកឆន្ទៈរាស្ត្រចូលក្នុងអាសនៈរដ្ឋសភាមានប្រសិទ្ធភាពខ្ពស់។ សណ្តាប់ធ្នាប់ប្រជាធិបតេយ្យបង្កាត់តាមម៉ូដែលបស្ចិមប្រទេសនេះកំពុងដុះរីកក្នុងថ្នាលវប្បធម៌ប្រពៃណីកម្ពុជា។

## ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ និងត្រូវបានរដ្ឋសភាធ្វើវិសោធនកម្ម ៩លើក)។

កិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញ១៩៤៧, ១៩៧២, ១៩៨១, និង១៩៨៩។

ច្បាប់ស្តីពីគណបក្សនយោបាយ (២០២០) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (២០១៧)។

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ (២០០៤)។

ថាច់ ត្វាន់ ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ ២០១០ (បកប្រែពីច្បាប់ដើមភាសាបារាំង ២០០៩)។

ប៉ាង ខាត់ ប្រវត្តិពុទ្ធសាសនានៅខ្មែរ ១៩៦១។

ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ១៩៧៣។

អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ២០០៥ (បកប្រែពីច្បាប់ដើមភាសាបារាំង ១៩១៤)។

នរោត្តម សីហនុ អនុស្សាវរីយផ្អែមល្ហែម និងជូរចត់ (២០១៧ បកប្រែជាភាសាខ្មែរ ដោយ

ន.រណអង្គ)។

នរោត្តម សីហនុ រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា ភាគ១ (ទសវត្ស ១៩៤០-១៩៥០)។

Hor Peng, Kong Phallack & Jorg Mensel (Eds.), (សៀវភៅ១) Introduction to Cambodian Law (2011), និង (សៀវភៅ ២) Cambodian Constitutional Law (2016).

Hor Peng, Kong Phallack & Soth Sang Bonn (Eds.), Perspectives on Cambodian Constiutional Law (2020).

Hilhelm Hofmeister / Karsten Grabow (Eds.) Political Parties: Functions and Organization in Democratic Societies (KAS 2011).

Yigal Mersel, The Dissolution of Political Parties: The Problem of Internal Democracy (2006, Oxford University Press/New York University School of Law).

Felix Olusanjo Olatuni, Democracy and the Challenge of the Rule of Law in Developing Democratic Society, (in Beytulhikme An International Journal of Philosophy, Volume 3 Issue 2 December 2013).

Tadashi Anno, National Identity and Democracy: Lessons from the Case of Japan (Special Forum, December 2018 ,20).

Csaba Gergely Tamas, The Birth of the Parliamentary Democracy in Japan: An History Approach (international center for Japanese studies, Kyoto, Japan).

Harish C. Mehta, Julie B. Mehta, Strongman: The Extraordinary Life of Hun Sen: From Pagoda Boy to Prime Minister of Cambodia (1999).

Harish C. Mehta, Warrior Prince: Norodom Ranariddh, Son of King Sihanouk of Cambodia (2001).

John Locke, Two Treaties of Civil Government (1691).

Miles Taylor, English Constitution: Walter Bagehot (2001, Oxford University Press).

John Tully, France on the Mekong, a history of the protectorate in Cambodia, -1863 1953.

# ការការពារសិទ្ធិមនុស្ស (តម្លៃទំនើប) និង តម្លៃក្នុងស្រុក (ជាប្រពៃណី)៖ សុខដុមរមនីយកម្មតាមរយៈការបកស្រាយបទប្បញ្ញត្តិច្បាប់

ឯកឧត្តមបណ្ឌិត មាស បូរ៉ា

## ខ្លឹមសារសង្ខេប

បរិបទស្រុកទេសនីមួយៗ ខុសគ្នា ហើយតម្លៃនាំចូល (ទំនើប) មកអនុវត្តក្នុងស្រុក អាចមានភាពមិនរលូន ឬទំនាស់គ្នានឹងតម្លៃក្នុងស្រុក ដោយសារកត្តាផ្សេងៗមួយចំនួនទៀត ដូចជាសមត្ថភាព ឬនិន្នាការគោលគំនិតជាដើម។ ក្រោយពីបានពិនិត្យមើលតម្លៃទាំងពីរ ពីជ្រុងប្រវត្តិសាស្ត្រ និងចរន្តនយោបាយសកល អ្នកនិពន្ធយល់ថា លំហូរនៃតម្លៃទំនើបចូលមក គឺជានិន្នាការជៀសមិនរួច។ អ្វីសំខាន់ គឺថាតម្លៃទំនើបនោះ មានគោលដៅដូចតម្លៃក្នុងស្រុក និងបំពេញបន្ថែមគ្នា។ អាស្រ័យហេតុនេះ ការធ្វើសុខដុមរមនីយកម្មតម្លៃទាំងពីរគឺជាការចាំបាច់ តាមរយៈការបកស្រាយសម្របគ្នា នូវវិធានពាក់ព័ន្ធដែលចែងនូវតម្លៃទាំងពីរនេះ។

## ១- សេចក្តីផ្តើម

ក្រោយសង្គ្រាមស៊ីវិលជាង ៣០ឆ្នាំ កម្ពុជាមានការបោះឆ្នោតជាសកលក្នុងឆ្នាំ ១៩៩៣ ហើយជាលទ្ធផល ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានអនុម័តក្នុងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំដដែល។ ក្នុងនោះ តម្លៃទំនើប និងជាប្រពៃណីត្រូវបានចែងបញ្ចូលផងដែរ។ មកដល់ឆ្នាំ២០២០ នេះ ច្បាប់រដ្ឋធម្មនុញ្ញមានអាយុ ២៧ឆ្នាំ ហើយការអនុវត្តទទួលបានលទ្ធផលវិជ្ជមានមួយចំនួន និងប្រឈមនឹងបញ្ហាមួយចំនួនផងដែរ។ ក្នុងនោះ ទស្សនៈយល់ឃើញខុសគ្នា ជាបញ្ហាកង្វល់ដែលនាំឱ្យមានឧបសគ្គក្នុងការអនុវត្ត ដោយសារតម្លៃទំនើបពិបាកគោរពតាមក្នុងបរិបទនៃស្រុកទេស ហើយតម្លៃជាប្រពៃណី ត្រូវបានប្រកាន់យក។

ដើម្បីចូលរួមបំភ្លឺជួយឱ្យការអនុវត្តគោលការណ៍ចម្បង ក្នុងច្បាប់រដ្ឋធម្មនុញ្ញកាន់តែប្រសើរ អត្ថបទនេះនឹងបង្ហាញថា តម្លៃទាំងពីរសុទ្ធតែបង្កប់នូវបំណងល្អ ដែលត្រូវបកស្រាយឱ្យស្របគ្នា ក្នុងបំណងបញ្ចៀសនូវទំនាស់គ្នា។ អត្ថបទ នឹងរៀបរាប់អ្វីទៅជាតម្លៃទំនើប និងតម្លៃជាប្រពៃណីពាក់ព័ន្ធនឹងការគោរព និងការការពារសិទ្ធិមនុស្ស ព្រមទាំងលទ្ធភាពនៃទំនាស់។ ផ្នែកបន្ទាប់ សង្កត់ធ្ងន់លើទ្រឹស្តីមួយចំនួនសម្រាប់ជាមូលដ្ឋាននៃការពិនិត្យមើលជាក់លាក់នូវទំនាស់ជាក់ស្តែងដើម្បីឱ្យអ្នកអានបានយល់កាន់តែច្បាស់ មុន

នឹងធ្វើការសង្ខេបខ្លឹមសារសំខាន់។

## ២- តម្លៃក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

### ១- តម្លៃទំនើប និងតម្លៃជាប្រពៃណី

សិទ្ធិមនុស្សរីកចម្រើនជាខ្លាំងក្រោយបញ្ចប់សង្គ្រាមលោកលើកទី២ ឆ្នាំ១៩៤៥ និងមានសិទ្ធិជាច្រើនប្រភេទ។ សិទ្ធិមួយចំនួនមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញមុនៗ របស់កម្ពុជា។[១] ទោះបីជាយ៉ាងនេះក្តី សិទ្ធិខ្លះមានការវិវត្តឥតឈប់ឈរ ដែលនាំឱ្យគេសន្និដ្ឋានថា ឯកសារចែងអំពីសិទ្ធិមានភាពរស់រវើក (living instruments)។ ការការពារសិទ្ធិមួយចំនួន ជាតម្លៃទំនើប ក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់កម្ពុជា។ ការការពារសិទ្ធិមនុស្សជាតម្លៃទំនើប ហើយក៏ជាអន្តរជាតិដែរ។

សិទ្ធិមនុស្ស មានសិទ្ធិធម្មតា និងសិទ្ធិចម្បង (fundamental rights) ដែលជាទូទៅត្រូវបានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ដោយសារការយល់ឃើញនូវសិទ្ធិចម្បង ខុសៗគ្នាដូចនេះ វាមិនប្រាកដថា សិទ្ធិដែលមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ជាសិទ្ធិចម្បងទាំងអស់នោះទេ។ សិទ្ធិចម្បង អាចជាសិទ្ធិដាច់ខាត (absolute right) ដូចជាសិទ្ធិរួចផុតពីអំពើទារុណកម្ម (right to freedom from torture)។[២] ក្នុងអត្ថន័យថា សិទ្ធិនេះមិនត្រូវផ្អាកអនុវត្តទេ ទោះបីក្នុងពេលប្រទេសមានគ្រោះអាសន្ន ហើយមិនទទួលយកយុត្តិកម្មណាមួយដើម្បីដោះសាឡើយ សម្រាប់ការប្រព្រឹត្តទារុណកម្ម។[៣]

សិទ្ធិភាគច្រើន ដែលទាមទារការគោរពនិងការពារ ជាតម្លៃទំនើប មានប្រភពពីលោកខាងលិច ដែលគេអះអាងថាមានលក្ខណៈជាសកល (universalism) និងផ្តល់គុណតម្លៃលើបុគ្គល (individualism) ព្រមទាំងអះអាងថា វាជាស្តង់ដារអប្បបរមា ដែលរដ្ឋតូច ឬរដ្ឋធំ ទោះបីប្រកាន់នូវប្រព័ន្ធនយោបាយអ្វី ក៏អាចគោរព និងការពារសិទ្ធិទាំងនោះ

---

១- ជំពូក ២ ស្តីពី សេរីភាព សិទ្ធិ និងករណីយកិច្ចរបស់ខេមរជន រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ឆ្នាំ១៩៤៧។

២- មាត្រា ៤៖ ១.ក្នុងករណីមានភាពអាសន្នសាធារណៈពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ និងដែលត្រូវបានប្រកាសជាផ្លូវការ រដ្ឋភាគីនៃកតិកាសញ្ញានេះ អាចចាត់វិធានការបដិប្បញ្ញត្តិនឹងកាតព្វកិច្ច ដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះកុំឱ្យតែវិធានការទាំងនេះ មានវិស-មិតភាពទៅនឹងកាតព្វកិច្ចដទៃទៀត ដែលច្បាប់អន្តរជាតិតម្រូវ ហើយមិនពាក់ព័ន្ធនឹងការរើសអើង ដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬដើមកំណើតសង្គម។ ២.បទប្បញ្ញត្តិខាងលើនេះមិនអនុញ្ញាតឱ្យមានបដិប្បញ្ញត្តិនឹងមាត្រា៦ មាត្រា៧ មាត្រា៨ (កថាខណ្ឌ១ និង២)មាត្រា១១ មាត្រា១៥ មាត្រា១៦ និង មាត្រា១៨។ UN General Assembly, កតិកាសញ្ញា ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR), 16 December 1966, United Nations, Treaty Series, vol. 999, p. 171, available at: https:www.refworld.orgdocid3ae6b3aa0.html [accessed 3 October 2020]

៣- សូមមើលលេខយោងខាងលើ។

បានដែរ។[៤] តម្លៃទំនើបនេះ អាចប៉ះនឹងតម្លៃនៃតំបន់ (អាស៊ី ឬអាហ្វ្រិក) ដែលគិតថា តំបន់ខ្លួនក៏មានតម្លៃ (Asian Value) ដែលត្រូវការពារ។

តម្លៃតំបន់ ក៏អាចជាន់គ្នានឹងតម្លៃ ឬបរិបទនៃប្រទេសមួយ។ តម្លៃទំនើប ជួនកាល ដូចគ្នានឹងតម្លៃតំបន់ ឬក្នុងស្រុក ដែលអាចត្រូវបានមើលឃើញច្បាស់ក្រឡែត ឬដោយប្រយោល ដូចជាសិទ្ធិរស់រានមានជីវិត (ក្នុងសាសនាព្រះពុទ្ធ បានចែងហាមសម្លាប់មនុស្ស)។ ឧទាហរណ៍ កម្ពុជាយល់ថា ការហាមឃាត់អំពើទារុណកម្ម មានលក្ខណៈដាច់ខាត។ ដូចនេះ តម្លៃទាំងនេះ ត្រូវគ្នានឹងតម្លៃទំនើប។ អ្វីដែលសំខាន់ គឺការអនុវត្តសិទ្ធិដែលពាក់ព័ន្ធនឹងតម្លៃនេះ។

តម្លៃជាប្រពៃណី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានដូចជា ការផ្តល់តម្លៃលើករណីយកិច្ចរបស់ប្រជាពលរដ្ឋ សាសនាជាដើម។ មាត្រាមួយនៃច្បាប់រដ្ឋធម្មនុញ្ញចែងថា៖ *មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ*[៥] ជាឧទាហរណ៍មួយ។ តម្លៃពាក់ព័ន្ធនឹងករណីយកិច្ចនេះ ដូចគ្នានឹងតម្លៃនៃតំបន់ផងដែរ ក៏ប៉ុន្តែមិនអាចត្រូវគ្នាទាំងស្រុងនឹងតម្លៃទំនើប (សកល) ដោយសារ ការបង្គាប់នូវករណីយ-កិច្ចច្រើន នឹងធ្វើឱ្យលំហានៃសិទ្ធិ រួមតូច។[៦] តម្លៃជាប្រពៃណី ពីប្រទេសមួយទៅមួយ ក៏អាចដូចគ្នាផងដែរ។ នោះ ដូចជាការគោរពមនុស្សចាស់។

**២- លទ្ធភាពនៃទំនាស់រវាងតម្លៃទាំងពីរ**

ដូចបានបញ្ជាក់ខាងលើ លទ្ធភាពនៃទំនាស់ ជាទស្សនៈពិតជាមាន។ ក្រុមម្ខាងអាចអះអាងថា ទ្រឹស្តីនៃការបែងចែកអំណាចក្នុងបរិបទកម្ពុជា សំដៅតែលើឯករាជ្យនៃអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដែលនេះផ្ទុយពីអ្វីដែលគេអះអាងថា ក្នុងអត្ថន័យនៃតម្លៃទំនើប តាមទ្រឹស្តីនៃការបែងចែកអំណាច អំណាចទាំងបី ត្រូវតែឯករាជ្យពីគ្នា។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ក៏បានចែងច្បាស់ពីចំណុចនេះដែរ។ ក្រុមម្ខាង បានអះអាងថា ការណ៍ដែលច្បាប់រដ្ឋធម្មនុញ្ញ ចែងថាព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ អាចផ្ទុយនឹងតម្លៃទំនើប នៃសេរីភាពខាងសាសនា ដែលរដ្ឋត្រូវធានា មិនឱ្យមានការរើសអើង។[៧] នៅមានឧទាហរណ៍ច្រើនទៀត ក៏ប៉ុន្តែផ្នែកនេះសូមលើកនូវចំណុចមួយជាចុងក្រោយ

៤- តើអ្វីទៅជាសិទ្ធិមនុស្ស? សិទ្ធិមនុស្ស ជាស្តង់ដារអប្បបរមា អនុវត្តសម្រាប់មនុស្សគ្រប់រូប។ រដ្ឋ និងសង្គមនីមួយៗ កំណត់ដោយសេរី និងអនុវត្តនូវស្តង់ដារដែលជាក់លាក់ និងខ្ពស់ជាងនេះ, https:www.coe.intenwebcompasswhat-are-human-rights-

៥- មាត្រា ៤៧ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

៦- Samuel Moyn, Rights vs. Duties, Boston Review, http:bostonreview.netbooks-ideassamuel-moyn-rights-duties (visited on 1 November 2020).

៧- មាត្រា ១៨, ICCPR, លេខយោងទី២ ខាងលើ។

ដែលពាក់ព័ន្ធនោះ គឺអនុលោមតាមបរិបទនៃស្រុកទេស។ ក្រុមម្ខាង ផ្តល់អាទិភាពលើសិទ្ធិសេដ្ឋកិច្ច[៨] (នាំឱ្យចម្រើនមានបាន) រីឯក្រុមម្ខាង ផ្តល់តម្លៃលើសិទ្ធិនយោបាយ ឬយុត្តិធម៌សង្គម។[៩] *..រដ្ឋយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ...*[១០] អាចត្រូវបានបកស្រាយក្នុងអត្ថន័យនេះ។ ទស្សនៈមូលដ្ឋាននៃការគិតរបៀបនេះ ជះឥទ្ធិពលលើសកម្មភាពផ្សេងៗ ហើយប្រសិនបើ ផលវិបាកជាអ្វីអវិជ្ជមាននោះនឹងបង្កហានិយភ័យដល់សង្គម។

## ៣- ទ្រឹស្តី និងដំណោះស្រាយ

### ១- ទ្រឹស្តី

បេសកកម្មនៃអត្ថបទនេះ គឺដើម្បីជួយបន្ថយនូវភាពតានតឹង ដោយសារទំនាស់ទស្សនៈ តាមរយៈការបំភ្លឺនូវទ្រឹស្តីមួយចំនួន ជាមូលដ្ឋានសម្រាប់ការបកស្រាយវិធានចែងនូវតម្លៃទំនើប និងជាប្រពៃណីឱ្យបានស្របគ្នា។ វាជាវិធីសាស្ត្រហេតុផល ទទួលយកបានកាត់បន្ថយនូវអវិភាព ក្នុងចេតនារួម គឺសុខសន្តិភាព និងការអភិវឌ្ឍយូរអង្វែង។ ទ្រឹស្តីដែលនឹងបង្ហាញ មានពីរពាក់ព័ន្ធនឹងលទ្ធភាពនៃទំនាស់ ក្នុងផ្នែកខាងលើ និងទ្រឹស្តីនៃការបកស្រាយ។

### ក- ការហាមឃាត់ការរើសអើង

ការហាមឃាត់ការរើសអើង (prohibition of non-discrimination) គឺជាគោលការណ៍ចម្បងមួយក្នុងការគោរព និងការពារសិទ្ធិមនុស្ស ដែលឯកសារសិទ្ធិមនុស្សជាច្រើនបានចែង។[១១] ការហាមឃាត់នេះមានភ្ជាប់ជាមួយនឹងការការពារសិទ្ធិទាំងអស់។ ជាក់ស្តែង ការរើសអើង អាចកើតមានក្នុងការផ្តល់សេវា។[១២] មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា បានចែងរួចហើយ មានស្តែងក្នុងមាត្រាដទៃទៀត តាមរយៈពាក្យ *'ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ'*។[១៣] គោលការណ៍នេះ ពាក់ព័ន្ធផងដែរដល់ការការពារស្មើភាពគ្នាដោយច្បាប់ (equal protection before law)។

ជាការពិត គេមិនត្រូវចេះតែនិយាយថា សកម្មភាពអ្វី វិធានអ្វី សុទ្ធតែនាំឱ្យមានការរើសអើងទេ។ តាមយុត្តិសាស្ត្រ ការរើសអើងទាមទារ នូវសមាសភាគចំនួនពីរៈ

---

៨- ដូចជាសិទ្ធិមានជីវភាពរស់នៅសមរម្យ សិទ្ធិទទួលបានការងារធ្វើ។
៩- ដូចជាសិទ្ធិបោះឆ្នោត សិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌។
១០- មាត្រា ៥២ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។
១១- ដូចជាមាត្រា ២ នៃ ICCPR លេខយោងទី២ខាងលើ។
១២- ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ២៦៥។
១៣- ដូចជាមាត្រា ៣៥ និង ៣៦នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣។

ជាការប្រព្រឹត្តខុសគ្នា និងគ្មានហេតុផល (different treatment without justification)។[១៤]

**ខ- ការអនុវត្តមិនស្មើគ្នារវាងសិទ្ធិសេដ្ឋកិច្ច និងនយោបាយ**

បញ្ហានេះ បានកើតមានជាយូរមកហើយ ដោយសារលោកខាងលិចបានយកការពង្រឹងសិទ្ធិនយោបាយ ជាគោលនយោបាយការបរទេស តម្រូវឱ្យរដ្ឋបរទេសគោរព។ នេះនាំឱ្យរដ្ឋបរទេសបដិសេធ ហើយអះអាងថា រដ្ឋនៃលោកខាងលិចមានការអនុវត្តសិទ្ធិស្តង់ដារពីរ (double standard)។ នេះទំនងជារឿងនយោបាយ ច្រើនជាងទ្រឹស្តី និងសង្គម។ ការឯកភាព បានកើតមានឡើង ក្នុងសេចក្តីថ្លែងការណ៍ឆ្នាំ១៩៩៣ ទីក្រុងវៀនណា (Vienna) ដែលចែងថាសិទ្ធិសេដ្ឋកិច្ច (ចម្រើនមានបាន មានការងារធ្វើ) និងសិទ្ធិនយោបាយ ឬសង្គម (សិទ្ធិរស់រានមានជីវិត ឬយុត្តិធម៌) មានទំនាក់ទំនងគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមក (interdependent)។[១៥] ការធានាបានយុត្តិធម៌ ត្រូវការមធ្យោបាយ និងសមត្ថភាព បានមកពីការអភិវឌ្ឍសេដ្ឋកិច្ច។ សិទ្ធិទាំងពីរ ត្រូវធានាឱ្យបានស្មើគ្នា។ ប្រសិនបើមិនដូចនេះទេ ការអភិវឌ្ឍដែលនាំឱ្យមានគម្លាតរវាងអ្នកមាន និងអ្នកក្រ កាន់តែធំ នឹងមិនមានភាពយូរអង្វែងទេ ដោយសារខ្វះយន្តការធានាថា ជនរងគ្រោះមានយុត្តិធម៌ និងបែងចែកផលកម្រៃដោយសមធម៌។ ភាពអយុត្តិធម៌នៅក្នុងចិត្ត ការមិនធានាសិទ្ធិយុត្តិធម៌សង្គម អាចនឹងនាំជនរងគ្រោះកាន់តែមានច្រើន យូរទៅនឹងមានការរង្គោះរង្គើក្នុងសង្គម។

**គ- បកស្រាយវិធានអន្តរជាតិ និងជាតិឱ្យស្របគ្នា**

អ្នកនិពន្ធ សូមកត់សម្គាល់ថា ការការពារសិទ្ធិមនុស្ស ជាវិស័យមួយនៃច្បាប់

---

១៤- ការប្រាស្រ័យសិទ្ធិ និងសេរីភាពស្មើគ្នា មិនមានន័យថា ជាការប្រព្រឹត្តដូចគ្នាបេះបិទនៅក្នុងគ្រប់ស្ថានភាពទេ។ ទាក់ទិនដល់ចំណុចនេះ បទប្បញ្ញត្តិនៃកតិកាសញ្ញា បានចែងយ៉ាងច្បាស់។ ឧទាហរណ៍ មាត្រា៦(៥) ហាមនូវទោសប្រហារជីវិតអនុវត្តលើកុមារអាយុក្រោម ១៨ឆ្នាំ។ កថាខណ្ឌដដែល ហាមឃាត់នូវទោសប្រភេទនេះ អនុវត្តលើស្រ្តីមានផ្ទៃពោះ។ ស្រដៀងគ្នានេះដែរ មាត្រា១០(៣) ទាមទារនូវការបំបែកអ្នកទោសវ័យក្មេងពីអ្នកទោសពេញវ័យ។ បន្ថែមពីលើនេះ មាត្រា២៥ បានធានានូវសិទ្ធិនយោបាយមួយចំនួន ផ្អែកតាមមូលដ្ឋាននៃសញ្ជាតិ (កថាខណ្ឌទី៨), *UN Human Rights Committee (HRC), CCPR General Comment No. 18: Non-discrimination, 10 November 1989, available at: https:www.refworld .orgdocid453883fa8.html [accessed 4 September 2020].*

១៥- សិទ្ធិមនុស្សទាំងអស់មានតម្លៃសកល មិនអាចផ្តាច់ពីគ្នាបាន ពឹងផ្អែក និងមានទំនាក់ទំនងគ្នាទៅវិញទៅមក។ សហគមន៍អន្តរជាតិ ត្រូវប្រព្រឹត្តលើសិទ្ធិលើសកលលោក ដោយត្រឹមត្រូវ និងក្នុងលក្ខណៈដូចគ្នាស្មើគ្នា និងការសង្កត់ធ្ងន់ដូចគ្នា។ ខណៈទទួលស្គាល់នូវសារៈសំខាន់នៃស្ថានភាពជាក់លាក់នៃតំបន់ និងជាតិ ព្រមទាំងសាវតារសាសនា វប្បធម៌ និងប្រវត្តិសាស្រ្ត វាជាករណីយកិច្ចរបស់រដ្ឋក្នុងការលើកកម្ពស់ និងការពារនូវសិទ្ធិ និងសេរីភាពចម្បងទាំងអស់ ដោយគ្មាន គិតអំពីប្រព័ន្ធវប្បធម៌ សេដ្ឋកិច្ច និងនយោបាយ (កថាខណ្ឌទី៥), *UN General Assembly, Vienna Declaration and Programme of Action, 12 July 1993, ACONF.15723, available at: https:www.refworld.org docid3ae6b 39e c.html [accessed 4 September 2020]*

អន្តរជាតិ ដែលច្បាប់ប្រភេទនេះ គ្រប់គ្រងទំនាក់ទំនងរដ្ឋ និងរដ្ឋ ឬរដ្ឋ និងបុគ្គល។[១៦] ច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងអធិបតេយ្យ (state sovereignty) ក្នុងន័យថា ច្បាប់មិនត្រូវអនុវត្ត ឬចងកាតព្វកិច្ចចំពោះរដ្ឋណា ដែលមិនទទួលយក ឬមិនចូលជាភាគីនៃសន្ធិសញ្ញា ដែលក្នុងនោះ មានវិធានចែងពីកាតព្វកិច្ចឱ្យរដ្ឋភាគីគោរពទេ។ ដូចនេះ ប្រសិនបើរដ្ឋចូលជាភាគីដោយប្រយោល អធិបតេយ្យរបស់រដ្ឋត្រូវបានកម្រិត ឬអធិបតេយ្យ ត្រូវបានលះបង់ខ្លះហើយ។ ទ្រឹស្តីនៃអធិបតេយ្យ ពាក់ព័ន្ធផងដែរ ជាមួយនឹងគោលការណ៍ផ្តល់ការព្រមព្រៀង (principle of consent)។[១៧] និយាយជាដដែល និងក្នុងន័យសាមញ្ញប្រសិនបើរដ្ឋមិនចូលជាភាគីទេ កាតព្វកិច្ចចែងក្នុងសន្ធិសញ្ញា មិនចងដល់រដ្ឋនោះទេ។ ការបង្ខំ ឬការស្ទូកប៉ាន់រដ្ឋមួយឱ្យចូលជាភាគី ដែលប៉ះដល់ឆន្ទៈយល់ព្រមពិតប្រាកដ នឹងធ្វើឱ្យសន្ធិសញ្ញានោះគ្មានសុពលភាពសម្រាប់រដ្ឋនោះឡើយ[១៨]។

ជាការពិត មានមូលហេតុជាច្រើន ដែលនាំរដ្ឋចូលជាភាគីសន្ធិសញ្ញាអន្តរជាតិ ដូចជាដើម្បីផលប្រយោជន៍ជាតិជាដើម។ នាពេលចូលជាភាគី រដ្ឋអាចទទួលបានប្រយោជន៍ស្របពេលគ្នានេះ មិនបំពានកាតព្វកិច្ចអន្តរជាតិ ដែលបានចងភ្ជាប់។ សន្ធិសញ្ញាបានចែងឆ្លុះអំពីភាពអាចបត់បែននេះ ដោយបើកសិទ្ធិជូនរដ្ឋ ចុះខរក្សាសិទ្ធិ (reservation)[១៩] មិនអនុវត្តកាតព្វកិច្ចអ្វីមួយ នៅពេលផ្តល់សច្ចាប័ន ឬទទួលយល់ព្រមសន្ធិសញ្ញា ក៏ប៉ុន្តែរដ្ឋនៅតែជាភាគីដដែល[២០]។ នេះដោយសារ យន្តការក្នុងស្រុកមិនអាចជួយអនុវត្តបាន ឬបទប្បញ្ញត្តិនោះ ផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ជាតិ។ ការចុះខរក្សាសិទ្ធិនេះ កុំឱ្យតែផ្ទុយនឹងគោលបំណងនៃសន្ធិសញ្ញា។[២១]

ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងគោរពតាមស្មារតីនៃសន្ធិសញ្ញា សន្ធិ-

---

១៦- មាស បូរ៉ា នីតិអន្តរជាតិសាធារណៈ ឆ្នាំ២០១៣ ទំ. ៨ និង៩។ អាចរកបាននូវ www.measboralaws.com។

១៧- UN General Assembly, *Declaration on Principles of International Law concerning Friendly Relations and Cooperation among States in accordance with the Charter of the United Nations,* 24 October 1970, ARES2625(XXV), available at: https:www.refworld.orgdocid3dda1f104.html [accessed 31 October 2020] ទំ.៤។

១៨- Article 1, Vienna Convention on the Law of Treaties, United Nations, សន្ធិសញ្ញា វៀនណាស្តីពីច្បាប់សន្ធិសញ្ញា (VCLT), United Nations, Treaty Series, vol. 1155, p. 331, available at: https:www.refworld .orgdocid3ae 6b3a10.html [accessed 6 September 2020]

១៩- VCLT, Article 52 លេខយោងខាងលើ។

២០- UN Human Rights Committee (HRC), *CCPR General Comment No. 24: Issues Relating to Reservations Made upon Ratification or Accession to the Covenant or the Optional Protocols thereto, or in Relation to Declarations under Article 41 of the Covenant,* 4 November 1994, CCPRC21Rev.1Add.6, available at: https:www.refworld.orgdocid453883fc11.html [accessed 31 October 2020] កថាខណ្ឌទី១៨។

២១- លេខយោងទី២០ ខាងលើ កថាខណ្ឌទី៦។

សញ្ញាស្តីពីច្បាប់សន្ធិសញ្ញា បានចែងតម្រូវពាក់ព័ន្ធការអនុវត្តសន្ធិសញ្ញា៖ *គ្រប់សន្ធិសញ្ញាដែលចូលជាធរមានចងកាតព្វកិច្ចលើរដ្ឋភាគី និងត្រូវបានអនុវត្តដោយសុទ្ធចិត្ត*[២២]។ *...ភាគីណាមួយមិនអាចលើកយកបទប្បញ្ញត្តិ នៃច្បាប់ជាតិរបស់ខ្លួនមកធ្វើជាយុត្តិកម្ម សម្រាប់ដោះសាការខកខាន មិនបានអនុវត្តសន្ធិសញ្ញា..*។[២៣] ច្បាប់ជាតិ ត្រូវធ្វើឡើងសម្រាប់ជាតិតែមួយ ទោះបីជាយ៉ាងនេះក្តី ចង់មិនចង់ វាពិតជាមានភាពមិនស៊ីចង្វាក់ ដោយសារច្បាប់ធ្វើដោយសមាជិកសភា ជៀសមិនរួចពីកំហុស (សមាជិកសភាក៏ជាមនុស្សលោកដែរ)។ ស្ថានភាពកាន់តែរឹតរវ សម្រាប់ច្បាប់អន្តរជាតិ ដូចជាវិធានក្នុងសន្ធិសញ្ញា ដោយសារវាត្រូវបានរៀបចំឡើងដោយអ្នកតំណាងរដ្ឋ ដែលផលប្រយោជន៍របស់រដ្ឋរៀងៗខ្លួនត្រូវបានរំលេចនៅក្នុងខ្លឹមសារសន្ធិសញ្ញា។ នេះហើយជៀសមិនរួច ពីទំនាស់រវាងច្បាប់ជាតិ និងវិធានច្បាប់អន្តរជាតិ។ ក្រៅពីការចុះខរក្សាសិទ្ធិ និងកែច្បាប់ជាតិឱ្យស្របនឹងសន្ធិសញ្ញា តុលាការគឺជាយន្តការ ដែលអាចជួយបញ្ចៀសទំនាស់រវាងវិធានច្បាប់ទាំងពីរប្រភេទ តាមរយៈការបកស្រាយ។

តុលាការអះអាងថា លើកលែងតែសភាចែងច្បាស់ នូវខដែលផ្ទុយនឹងវិធានច្បាប់អន្តរជាតិ តុលាការនឹងបកស្រាយមិនឱ្យមានទំនាស់រវាងវិធានទាំងពីរ (principle of conformity)។[២៤] តុលាការប្រទេសឥណ្ឌាបានអះអាងថា តុលាការមិនត្រូវផ្អែកលើច្បាប់សភា ធ្វើឱ្យប៉ះដល់សិទ្ធិចម្បងទេ *...ឯកសារអន្តរជាតិទាំងនេះ ទាមទារឱ្យឥណ្ឌា... ហើយតុលាការមានកាតព្វកិច្ចក្នុងការធានាថា ខ្លឹមសារនៃឯកសារទាំងនោះ មិនត្រូវបានបំពាន*[២៥]។ តុលាការអះអាងដូចនេះ ដោយសារថា សភាចូលរួមជាមួយរដ្ឋាភិបាលដើម្បីចូលជាភាគីនៃសន្ធិសញ្ញា។ ក្នុងន័យនេះ សភាមិនមានចេតនា ធ្វើច្បាប់ផ្ទុយនឹងសន្ធិសញ្ញាទេ។ ដូចនេះ តុលាការត្រូវបកស្រាយតាមមូលដ្ឋាននេះ។

ក្នុងករណីខ្លះ វាជាតម្លៃទំនើប និងសកល (រដ្ឋមានដោយប្រយោល) ដែលមានការឯកភាព។ តម្លៃក្នុងស្រុកត្រូវបដិសេធដើម្បីគោរពតម្លៃទំនើប (ករណីហាមឃាត់ទារុណកម្ម)។[២៦] តុលាការសិទ្ធិមនុស្សអឺរ៉ុបបានអះអាងថា ការហាមឃាត់ទារុណកម្ម គឺ

---

២២- មាត្រា ២៦ នៃ VCLT លេខយោងទី១៨ខាងលើ។

២៣- មាត្រា ២៧ នៃ VCLT លេខយោងទី១៨ខាងលើ។

២៤- Dinah Shelton *Ed.,* ច្បាប់អន្តរជាតិ និងប្រព័ន្ធច្បាប់ក្នុងស្រុក៖ ការដាក់បញ្ចូល បំប្លែង និង បញ្ចុះបញ្ចូល (Persuasion), 2011, p.121.

២៥- *Apparel Export Promotion Council v. Chopra,* Supreme Court [1999] INSC 7, 20 January 1999, p.2.

២៦- សាលដីកា ស្តីពីវិធីសាស្ត្រសួរចម្លើយដោយសន្តិសុខ (GSS), តុលាការកំពូលរបស់អ៊ីស្រាអែល ៦ កញ្ញា ១៩៩៩។ *Soering v. The United Kingdom,* 11989161217, Council of Europe: European Court of Human Rights, 7 July 1989, available at: https:www.refworld.orgcases,ECHR,3ae6b6fec.html [accessed 4 September 2020]

ជាតម្លៃចម្បងរបស់សង្គមអឺរ៉ុប។[២៧] ស្រដៀងគ្នានេះដែរ តុលាការកំពូលប្រទេសអ៊ីស្រាអែល ថ្លែងថា ការហាមឃាត់អំពើទារុណកម្ម គឺដាច់ខាត ដែលអាជ្ញាធរស៊ើបអង្កេតមិនអាចបំពាន ដើម្បីទទួលចម្លើយសារភាព ក្រោមលេសថា ការធ្វើទារុណកម្មជាការចាំបាច់នោះទេ។[២៨] នេះតម្រូវឱ្យតុលាការ បកស្រាយយ៉ាងណាកុំឱ្យផ្ទុយ ដោយធ្វើឱ្យស្របនឹងតម្លៃដាច់ខាត នេះ។

**២- ដំណោះស្រាយ**

ក- មាត្រា៥២ នៃច្បាប់រដ្ឋធម្មនុញ្ញបានចែង ...*រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ*...មិនអាចត្រូវបានបកស្រាយ ថា កម្ពុជាផ្តល់អាទិភាពលើសិទ្ធិសេដ្ឋកិច្ចទេ។ ខ្លឹមសារនេះ មិនមែនមានន័យថា រដ្ឋាភិបាល ផ្តោតលើសិទ្ធិសេដ្ឋកិច្ចជាអាទិភាពទេ។ ជាធម្មតា រដ្ឋាភិបាល ក្នុងប្រទេសប្រជាធិបតេយ្យ ដែលមានប្រជាពលរដ្ឋជាម្ចាស់ ត្រូវយកចិត្តទុកដាក់លើជីវភាពរបស់ម្ចាស់ឆ្នោតដូចនេះ ហើយ។ បន្ថែមពីលើនេះ កម្ពុជាដែលជារដ្ឋ បានខិតខំតាមរយៈសកម្មភាព និងក្របខ័ណ្ឌ ច្បាប់ ដើម្បីលើកកម្ពស់ និងធានានូវសិទ្ធិស៊ីវិល និងនយោបាយ ក៏ប៉ុន្តែជាសត្យានុម័ត វា មិនអាចអនុវត្តបានឥតខ្ចោះ ១០០ ភាគរយបាននោះទេ។ នេះជាធម្មតា សម្រាប់រដ្ឋទាំង អស់ ពាក់ព័ន្ធការលើកកម្ពស់ និងគោរពសិទ្ធិមនុស្ស។ លើកលែងតែមានទស្សនៈជាក់ ស្តែង ឬជាលាយលក្ខណ៍អក្សរថា រដ្ឋមានចេតនាលើកកម្ពស់សិទ្ធិសេដ្ឋកិច្ចមុន គេមិនគួរ បកស្រាយមាត្រា៥២ ក្នុងន័យអនុវត្តសិទ្ធិមិនស្មើគ្នាទេ។ ដូចដែលបានអះអាងខាងលើ វាហាក់មានការឯកភាពគ្នាហើយ ថាសិទ្ធិទាំងពីរប្រភេទត្រូវអនុវត្តឱ្យបានស្មើគ្នា។

ការពិតមាត្រានេះ អាចត្រូវបានគេបកស្រាយថា មានភាពរើសអើង ក្នុងការ ផ្តល់សេវា ឬការឧបត្ថម្ភ។ បើមែននោះ សមាសភាគចំនួនពីរ ដែលនាំឱ្យទង្វើណាមួយ រើសអើង ដូចអះអាងខាងលើ ត្រូវតែបង្ហាញ សម្រាប់ការធ្វើការសន្និដ្ឋានដូចនេះ។ អ្នក ស្រាវជ្រាវ ក៏ត្រូវកត់សម្គាល់ថា ជាការពិត ត្រូវតែមានការប្រព្រឹត្តខុសគ្នារវាងប្រជាពលរដ្ឋ និងជនបរទេស។ ក្នុងន័យថា មនុស្សទាំងពីរប្រភេទនេះ មិនមានសិទ្ធិដូចគ្នាទាំងស្រុង នោះទេ។ ច្បាប់ជាតិ ចែងផ្តល់សិទ្ធិបោះឆ្នោតជូនតែប្រជាពលរដ្ឋ[២៩] ហើយសន្ធិសញ្ញា អន្តរជាតិ មិនបានចែងហាម និងចែងកម្រិតសិទ្ធិមួយចំនួនដល់ជនបរទេសផងដែរ។[៣០]

២៧- *Soering v. The United Kingdom,* លេខយោងខាងលើ។

២៨- Matthew G. Amand St., Public Committee against Torture in Israel v. The State of Israel et al: Landmark Human Rights Decision by the Israeli High Court of Justice or Status Quo Maintained, 25N.C. J. Int'l L. & Com. Reg.655 (1999). Available at:http:scholarship.law.unc.edunciljvol25iss37, p. 19.

២៩- មាត្រា ៣៤ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។

៣០- ជាក់ស្តែង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មិនបានចែងអំពីសិទ្ធិលើទ្រព្យសម្បត្តិទេ។

ការប្រើប្រាស់ពាក្យ «ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ» ក៏មានឃើញនៅក្នុងមាត្រាមួយចំនួនផងដែរ ដូចជាមាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ មានការអះអាងថា វាអាចជាការរើសអើង។ ជាការពិត ប្រសិនបើមើលខ្លឹមសារជាក់ស្តែង វាដូចនេះមែន។ ទោះបីជាយ៉ាងនេះក្តី តាមវិធីសាស្រ្តបកស្រាយចែងក្នុងអនុសញ្ញាវៀនណា (VIENNA) គេត្រូវពិនិត្យមើលគោលបំណងនៃច្បាប់ឬសន្ធិសញ្ញាជាមុនសិន។[៣១] គោលបំណងនៃសន្ធិសញ្ញាសិទ្ធិមនុស្ស គឺដើម្បីការពារលើកកម្ពស់ សិទ្ធិមនុស្សគ្រប់ៗរូប។[៣២] តុលាការយុត្តិធម៌អន្តរជាតិ បានពិនិត្យមើលឯកសារកត់ត្រាកិច្ចពិភាក្សា (Drafting History) តែមិនបាននិយាយអំពីបញ្ហានេះទេ ដូចនេះ ការបកស្រាយតាមខ្លឹមសារនិងបំណង មានសុពលភាព។[៣៣]

អ្នកនិពន្ធ បានពិនិត្យឯកសារកំណត់ត្រាពិភាក្សា មាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក៏ប៉ុន្តែ មិនបានឃើញខ្លឹមសារថា មាត្រា៣១ ចែងផ្តល់តែសិទ្ធិជូនប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះទេ។[៣៤]

ខ- ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កម្ពុជា ចែងថា *ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ*។ គេអាចអះអាងថា វាជាការរើសអើងនឹងសាសនាដទៃទៀត។ ខ្លឹមសារនៃមាត្រានេះ មិនមានចរិតរើសអើងទេ ដោយសារថា ប្រជាជនកម្ពុជាភាគច្រើន កាន់សាសនាព្រះពុទ្ធ និងមានប្រវត្តិយូរមកហើយ។ តាំងពីសម័យបុរាណកាល សកម្មភាព ឬភ័ស្តុតាងជាតឹកតាង បានបង្ហាញពីការរួមរស់យ៉ាងសុខសាន្តនៃសាសនាទាំងឡាយក្នុងចំណោមប្រជាពលរដ្ឋខ្មែរទាំងអស់ ហើយជាក់ស្តែងទៅទៀត ក្នុងពេលបច្ចុប្បន្ននេះ អ្នកកាន់សាសនាដទៃ មានសេរីភាព និងអនុវត្តសាសនា ដោយគ្មានការរើសអើងទេ។ វាអាចជាការប្រព្រឹត្តខុសគ្នា ក៏ប៉ុន្តែ ការប្រព្រឹត្តខុសគ្នានេះ សមហេតុសមផល។

តាមការពិនិត្យ និងវិភាគជាក់ស្តែង តម្លៃទាំងពីរ ទំនងមិនមានទំនាស់គ្នាទេ។ អ្វីដែលកើតមាន វាអាចមកពីការលាយឡំរវាងទ្រឹស្តីច្បាប់ និងនយោបាយ ឬការមិនដឹង

---

៣១- VCLT មាត្រា ៣១ លេខយោងទី១៨ ខាងលើ។

៣២- ICCPR មាត្រា ២ លេខយោងទី២ ខាងលើ។

៣៣- មាស បូរ៉ា, ការបកស្រាយច្បាប់, http:www.measboralaws.comdetail721។ ក្នុងករណីនេះ ប្រទេសអាឡឺម៉ង់ ស្នើដល់តុលាការបញ្ជាឱ្យសហរដ្ឋអាមេរិក កុំអាលអនុវត្តប្រហារជីវិតលើជនល្មើស (interim-protection measure)។ សហរដ្ឋអាមេរិកបានអះអាងថា វិធានការនេះមិនចងជាកាតព្វកិច្ចទេ។ តុលាការបានពិនិត្យលក្ខន្តិកៈរបស់តុលាការ ដើម្បីរកឃើញថាតើវិធានការនេះចងជាកាតព្វកិច្ចឬយ៉ាងណា? ខ្លឹមសារនៃមាត្រាពាក់ព័ន្ធមិនបានបង្ហាញយ៉ាងម៉េចទេ។ តុលាការបានពិនិត្យមើល Drafting History ក៏ប៉ុន្តែមិនបានបង្ហាញអ្វីដែរ ហើយតុលាការអះអាងថា Drafting History មិនទាន់ខ្វាស់អ្វីនឹងខ្លឹមសារនៃការបកស្រាយលើអត្ថបទទេ (វិធានការបណ្តោះអាសន្នចងជាកាតព្វកិច្ច)។

៣៤- អគ្គលេខាធិការដ្ឋានរដ្ឋសភា កំណត់ត្រាពិស្តារ សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញ ឆ្នាំ១៩៩៣។

ស៊ីជម្រៅនៃទ្រឹស្តីការគោរព និងលើកកម្ពស់សិទ្ធិមនុស្ស។ នេះធ្វើឱ្យការការពារ និងគោរពសិទ្ធិមនុស្សមានឧបសគ្គ ដែលនាំឱ្យអ្នកប្រកាន់តម្លៃនីមួយៗរិះគន់គ្នាទៅវិញទៅមក។ ជាសត្យានុម័ត គេត្រូវដឹងថា ការអនុវត្តសិទ្ធិមិនទទួលបានភាពឥតខ្ចោះនោះទេ ដូចនេះអ្នករិះគន់ គួរតែពិចារណា និងពិនិត្យមូលដ្ឋានឱ្យច្បាស់លាស់មុននឹងរិះគន់។ រីឯអ្នកអនុវត្តក៏ត្រូវតែខិតខំបង្ហាញថា សិទ្ធិមនុស្សមិននៅលើតែក្រដាស ឬបបូរមាត់ទេ។ ការធ្វើដូចនេះបាន គឺតាមរយៈការផ្តោតលើសិទ្ធិណាមួយ ឱ្យជាក់លាក់ ឱ្យមានការមើលឃើញថាពិតជាមានភាពប្រសើរឡើង។ នោះពិតជាកាត់បន្ថយបានខ្លះ នូវការរិះគន់។

ច្បាប់ប្រទេសកូរ៉េ ធានាសិទ្ធិសម្រាប់មនុស្សគ្រប់គ្នា រាប់ទាំងមនុស្សចាស់ ដោយអនុលោមតាមគោលការណ៍ការពារស្មើគ្នាចំពោះមុខច្បាប់ (equal protection before law) និងគោលការណ៍មិនរើសអើង (principle of non-discrimination)។ នេះបង្ហាញពីតម្លៃទំនើប ស្របនឹងតម្លៃជាប្រពៃណី។ ប្រទេសកូរ៉េ បានដាក់សិទ្ធិរបស់មនុស្សចាស់ ជាអាទិភាពក្នុងការការពារ ដើម្បីជាការតបស្នងរបស់សង្គមកូរ៉េតាំងពីយូរមកហើយដល់ក្រុមមនុស្សចាស់។ វាជាការផ្តល់តម្លៃលើមនុស្សចាស់ជាក់ស្តែង។ ជាក់ស្តែង ចៅក្រមដែលប្រើពាក្យសម្តីមិនគប្បីដល់មនុស្សចាស់ក្នុងពេលសវនាការ ត្រូវបានពិន័យ ដោយសារនេះជាការបំពានសិទ្ធិ (right of elder person to dignity)។[៣៥]

## ៤- សន្និដ្ឋាន

ជាការសន្និដ្ឋាន ខ្ញុំយល់ថា វាមានការពិបាកក្នុងការកំណត់អ្វីជាតម្លៃទំនើប ឬតម្លៃក្នុងស្រុក។ តម្លៃទាំងអស់សុទ្ធតែល្អ ដែលត្រូវប្រើបំពេញបន្ថែមគ្នា និងមិនត្រូវមើលគ្នាក្នុងន័យអវិជ្ជមាន ដោយសារ មូលដ្ឋាននយោបាយ ឬជំហរដាច់ខាត (extremist)។ គេគួរព្យាយាមសម្របសម្រួលតម្លៃទាំងពីរ ក្នុងវិស័យណាមួយ ដែលអាចធ្វើបាន (ករណីការការពារសិទ្ធិមនុស្សចាស់នៅកូរ៉េ) ឱ្យជាក់លាក់ ឃើញលទ្ធផលជាក់ស្តែង នោះគេនឹងអាចបន្សាបបាននូវភាពចាញ់ឈ្នះនូវតម្លៃទាំងពីរ។

ការពិត ទ្រឹស្តីលោកខាងលិច ថាសិទ្ធិមនុស្ស ជាស្តង់ដារអប្បបរមា នោះមិនត្រឹមត្រូវទាំងស្រុងទេ។ ទោះបីជាយ៉ាងនេះក្តី ដើម្បីយុត្តិធម៌ នីតិរដ្ឋ ការការពារសិទ្ធិមនុស្ស (មានចែងរួចហើយក្នុងរដ្ឋធម្មនុញ្ញ) ធានាឱ្យមានការអភិវឌ្ឍសង្គមពេញលេញ និងយូរអង្វែង គេតម្រូវឱ្យមានការសម្របសម្រួលនូវតម្លៃទាំងពីរ តាមរយៈការបកស្រាយតាមមូលដ្ឋានខាងលើ។ ដើម្បីធ្វើដូចនេះបាន សម្រាប់តួនាទីរបស់ស្ថាប័នតុលាការ ឬវិនិច្ឆ័យ

៣៥- Andrew Wolman, គណៈកម្មការសិទ្ធិមនុស្សជាតិ និង វិធានសិទ្ធិមនុស្សអាស៊ី, 3(1) Asian Journal of International Law, 2013, p. 78.

សេចក្តី វាទាមទារនូវការយល់ដឹងទ្រឹស្តីពិតប្រាកដ ដើមកំណើត និងគោលបំណងនៃតម្លៃនីមួយៗ។

## ឯកសារយោង


### ក- ច្បាប់

រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ឆ្នាំ១៩៤៧។

ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩។

### ខ- លិខិតូបករណ៍អន្តរជាតិ

កតិកាសញ្ញា ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR), 16 December 1966, United Nations, Treaty Series, vol. 999, p. 171, available at: https://www.refworld.org/docid/3ae6b3aa0.html [accessed 3 October 2020].

UN Human Rights Committee (HRC), CCPR General Comment No. 18: Non-discrimination, 10 November 1989, available at: https://www.refworld .org/docid/453883fa8.html [accessed 4 September 2020].

UN General Assembly, Vienna Declaration and Programme of Action, 12 July 1993, A/CONF.157/23, available at: https://www.refworld.org /docid/3ae6b 39ec.html [accessed 4 September 2020].

UN General Assembly, Declaration on Principles of International Law concerning Friendly Relations and Cooperation among States in accordance with the Charter of the United Nations, 24 October 1970, A/RES/2625(XXV), available at: https://www.refworld.org/docid/3dda1f104.html [accessed 31 October 2020].

Vienna Convention on the Law of Treaties, United Nations, សន្ធិសញ្ញា វៀនណា ស្តីពីច្បាប់សន្ធិសញ្ញា (VCLT), United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld .org/docid/3ae 6b3a10.html [accessed 6 September 2020]។

## គ- សាលក្រម ឬសេចក្តីសម្រេច

Apparel Export Promotion Council v. Chopra, Supreme Court [1999] INSC 7, 20 January 1999។

សាលដីកា ស្តីពីវិធីសាស្ត្រសួរចម្លើយដោយសន្តិសុខ (GSS), តុលាការកំពូលរបស់អ៊ីស្រាអែល ៦ កញ្ញា ១៩៩៩។

Soering v. The United Kingdom, 1/1989/161/217, Council of Europe: European Court of Human Rights, 7 July 1989, available at: https://www.refworld.org/cases,ECHR,3ae6b6fec.html [accessed 4 September 2020].

## ឃ- សៀវភៅ និងអត្ថបទស្រាវជ្រាវ

មាស បូរ៉ា នីតិអន្តរជាតិសាធារណៈ ឆ្នាំ២០១៣ អាចរកបាននូវ www.measboralaws.com.

Dinah Shelton Ed., ច្បាប់អន្តរជាតិ និងប្រព័ន្ធច្បាប់ក្នុងស្រុក៖ ការដាក់បញ្ចូល បំប្លែង និង បញ្ចុះបញ្ចូល (Persuasion), 2011.

អគ្គលេខាធិការដ្ឋានរដ្ឋសភា កំណត់ត្រាពិស្តារ សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញ ឆ្នាំ១៩៩៣។

Matthew G. Amand St., Public Committee against Torture in Israel v. The State of Israel et al: Landmark Human Rights Decision by the Israeli High Court of Justice or Status Quo Maintained, 25N.C. J. Int'l L. & Com. Reg.655 (1999). Available at:http://scholarship.law.unc.edu/ncilj/vol25/iss3/7.

មាស បូរ៉ា, ការបកស្រាយច្បាប់, http://www.measboralaws.com/detail/721.

Andrew Wolman, គណៈកម្មការសិទ្ធិមនុស្សជាតិ និងវិធានសិទ្ធិមនុស្សអាស៊ី, 3(1) Asian Journal of International Law, 2013.

Samuel Moyn, Rights vs. Duties, Boston Review, http://bostonreview.net/books-ideas/samuel-moyn-rights-duties (visited on 1 November 2020).

# ការអភិវឌ្ឍនៃសិទ្ធិលើដីធ្លីនៅកម្ពុជា

ឯកឧត្តមបណ្ឌិត ហាប់ ផល្ល័១

## សង្ខេបសេចក្តី

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីបង្ហាញពីការវិវត្តនៃសិទ្ធិលើដីធ្លីនៅកម្ពុជាចាប់តាំងពីក្រោយឆ្នាំ១៩៧៩ និងប្រសិទ្ធភាពនៃការគ្រប់គ្រងដីធ្លី។ ការប្រែប្រួលនៃសង្គម និងនយោបាយបានជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើសិទ្ធិដីធ្លី ដែលទាមទារឱ្យមានការកែសម្រួលគោលនយោបាយ និងច្បាប់។ បទសម្ភាសន៍មួយចំនួនពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយដីធ្លី នៅពេលចាប់ផ្តើមក្រុមសាមគ្គីបង្កបង្កើនផលដំបូង ត្រូវបានប្រើប្រាស់ជា វិធីសាស្ត្រនៃការស្រាវជ្រាវយ៉ាងសំខាន់។ ឯកសារគតិយុត្ត និងរបាយការណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានយកមកប្រើប្រាស់ក្នុងការវិភាគជាចម្បង។ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា ការអនុវត្តគោលនយោបាយសាមគ្គីបង្កបង្កើនផលមិនមែនជាយុទ្ធសាស្ត្រសម្រាប់រយៈពេលវែងឡើយ ហើយការផ្តល់កម្មសិទ្ធិឯកជនគឺជាការចាំបាច់។ ការចុះបញ្ជីដីធ្លីឱ្យបានឆាប់រហ័សគប្បីត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីរដ្ឋាភិបាលព្រោះវាជាមធ្យោបាយមួយដើម្បីធានាសុវត្ថិភាពដីធ្លី និងជំរុញឱ្យមានការអភិវឌ្ឍដី។

## សេចក្តីផ្តើម

កម្ពុជាបានឆ្លងកាត់ប្រវត្តិសាស្ត្រដ៏ជូរចត់យ៉ាងខ្លាំង នាកន្លះសតវត្សចុងក្រោយនេះ។ សិទ្ធិលើដីធ្លីត្រូវបានកែលម្អជាលំដាប់ចាប់តាំងពីក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ១៩៧៩មក។ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៨១ បានផ្តល់ត្រឹមតែសិទ្ធិប្រើប្រាស់ និងបន្តមត៌កដីធ្លី តែហាមឃាត់សិទ្ធិទិញ លក់ បញ្ចាំ ឬប្រវាស់។ វិសោធនកម្មរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៩ បានលុបចោលការហាមឃាត់នេះ ប៉ុន្តែបានអនុញ្ញាតឱ្យមានការគ្រប់គ្រងសិទ្ធិ កាន់កាប់ និងប្រើប្រាស់ដោយច្បាប់ដោយឡែក។ ទីបំផុតកម្ពុជាមានរដ្ឋធម្មនុញ្ញថ្មីមួយទៀតនៅឆ្នាំ១៩៩៣ ដែលផ្តល់សិទ្ធិកម្មសិទ្ធិលើដីធ្លីដល់ពលរដ្ឋកម្ពុជា។ តាមរយៈរដ្ឋធម្មនុញ្ញទាំងអស់នេះហើយ ច្បាប់ភូមិបាលត្រូវបានបង្កើតឡើងដើម្បីឱ្យស្របតាមរដ្ឋធម្មនុញ្ញ ដែលចុងក្រោយនេះគឺច្បាប់ភូមិបាលឆ្នាំ២០០១។

---

១- បណ្ឌិត ហាប់ ផល្ល័ បច្ចុប្បន្នជានាយកថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកទទួលបានសញ្ញាបត្របណ្ឌិតច្បាប់ ជំនាញដីធ្លីពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន។

ការស្រាវជ្រាវនេះចាប់ផ្តើមឡើង ដោយបង្ហាញជាដំបូងពីការអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផលចាប់ពីឆ្នាំ១៩៧៩ បន្ទាប់មក ពិភាក្សាពីការផ្តល់កម្មសិទ្ធិឯកជនលើដីធ្លីនៅពេលដែលគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផលទទួលបរាជ័យ។ ការចុះបញ្ជីដីជាចំណុចសំខាន់នៃការពិភាក្សា។

## ១- គោលនយោបាយរដ្ឋាភិបាលចំពោះក្រុមសាមគ្គីបង្កបង្កើនផល

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៩ ប្រជាពលរដ្ឋកម្ពុជាត្រូវបានអនុញ្ញាតឱ្យធ្វើមាតុភូមិនិវត្តន៍ទៅកាន់ស្រុកកំណើត ឬកន្លែងធ្លាប់រស់នៅមុនខែមេសា ឆ្នាំ១៩៧៥។ ប្រជាពលរដ្ឋមួយចំនួនធំ បានបាក់កម្លាំងពលកម្ម ចំណែកពលរដ្ឋជានារីមួយចំនួន បានក្លាយជាស្ត្រីមេម៉ាយ។ កម្មសិទ្ធិឯកជនលើដីធ្លីមិនត្រូវបានអនុញ្ញាត។ ប្រជាពលរដ្ឋកម្ពុជាតម្រូវឱ្យប្រើប្រាស់ដីធ្លីទាំងអស់ក្នុងទម្រង់ជាក្រុមសាមគ្គីបង្កបង្កើនផល។

### ១- ការបន្តកម្មសិទ្ធិសម្ហូភាព

របបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់បទពិសោធដល់ប្រជាពលរដ្ឋកម្ពុជាយ៉ាងជូរចត់ និងឈឺចាប់ពេញមួយជីវិត។ កម្មសិទ្ធិឯកជនដែលមានពីមុនត្រូវបានលុបបំបាត់ ហើយត្រូវបានដាក់ឱ្យក្លាយទៅជាកម្មសិទ្ធិសមូហភាព។ ជាទូទៅប្រជាពលរដ្ឋទាំងអស់ត្រូវបានតម្រូវឱ្យធ្វើការរួមគ្នា និងទទួលទានអាហារក៏រួមគ្នាដែរ ដែលព្រឹត្តិការណ៍ទាំងនេះមិនដែលកើតមានទេនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ នៅពេល របបកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរលំនៅឆ្នាំ១៩៧៩ ប្រជាពលរដ្ឋកម្ពុជាដែលស្ថិតក្នុងរបបថ្មីមួយទៀត គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីឡើយ។ ដីធ្លីទាំងអស់ ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ឬជាកម្មសិទ្ធិសមូហភាព។[២] គួរកត់សម្គាល់ថា នៅពេលនោះ ច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិមិនទាន់ត្រូវបានបង្កើត ដូច្នេះរដ្ឋាភិបាលបានដឹកនាំប្រទេសតាមរយៈគោលនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។

កម្មសិទ្ធិសមូហភាពបានបន្តចាប់ពីឆ្នាំ១៩៧៩ ក្រោមរូបភាពខុសគ្នាមួយចំនួនពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាពលរដ្ឋកម្ពុជា តម្រូវឱ្យធ្វើការរួមគ្នាក្នុងរូបភាពជាក្រុមសាមគ្គីបង្កបង្កើនផល ប៉ុន្តែ ត្រូវបានទទួលចំណែក នៃភោគផលទៅ តាមកម្លាំងពលកម្មនៃសមាជិកគ្រួសារនីមួយៗ។ ភាពខុសគ្នាយ៉ាងច្បាស់ពីកម្មសិទ្ធិសមូហភាព នៅក្នុងរបប

---

២- រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១, មាត្រា១៥។

កម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺនៅសម័យកម្ពុជាប្រជាធិតេយ្យ ធ្វើរួមគ្នា ទទួលទានអាហាររួមគ្នា ចំណែកឯរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ធ្វើរួមគ្នា តែទទួលទានអាហារផ្សេងគ្នា។ ក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានរដ្ឋាភិបាលបង្កើតឡើង ប្រហែលជាក្នុងគោលបំណងជាចម្បងដើម្បីជួយសម្រួលប្រជាពលរដ្ឋដែលខ្វះកម្លាំងពលកម្ម។ ក្រុមសាមគ្គីបង្កបង្កើនផលនោះចែកចេញជា៣ប្រភេទដូចខាងក្រោម៖[៣]

- ក្រុមសាមគ្គីប្រភេទទី១៖

- ដីស្រែ-ចម្ការស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រុមផ្ទាល់
- គោ ក្របី រទេះ និងឧបករណ៍ផលិតកម្ម ប្រើប្រាស់រួមក្នុងក្រុម
- ប្រធានក្រុមចាត់ចែងការបង្កបង្កើនផល និងបែងចែកភោគផលដល់ សមាជិកក្រុម

- ក្រុមសាមគ្គីប្រភេទទី២៖

- ដីស្រែ-ចម្ការស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមផ្ទាល់
- ក្រុមចែកជាពួកតូចៗពី៣ទៅ៥គ្រួសារក្នុងមួយពួក
- ពួកតូចៗចាត់ចែងបង្កបង្កើនផល និងបែងចែកភោគផលដល់សមាជិក ពួក

- ក្រុមសាមគ្គីប្រភេទទី៣

- ក្រុមធ្វើរួមនូវផ្ទៃដីមួយចំនួនតូច
- ផ្ទៃដីមួយចំនួនធំចែកឱ្យគ្រួសារក្រុមបង្កបង្កើន និងទទួលផលជាឯកជន

ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងនៃគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផល គឺអាស្រ័យទៅតាមតំបន់នីមួយៗតែប៉ុណ្ណោះ។ នៅតំបន់ខ្លះ ការចែកដីចម្ការនៅក្នុងភូមិមួយមិនគ្រប់គ្រាន់សម្រាប់ប្រជាជននៅក្នុងភូមិនោះ គេអនុញ្ញាតឱ្យទទួលចំណែកដីចម្ការនៅក្នុងភូមិជាប់គ្នាក៏មាន។[៤] ចំណែកនៅតំបន់ខ្លះទៀត ការអនុវត្តក្រុមសាមគ្គីបង្កបង្កើនផល មិនត្រូវបានធ្វើឡើងទៅតាមគោលនយោបាយ របស់រដ្ឋាភិបាលក៏មាន។ ម្ចាស់ដី នៅមុនឆ្នាំ១៩៧៥ ត្រូវបានទទួលស្គាល់ ហើយប្រជាពលរដ្ឋចំណូលថ្មីមិនត្រូវបានផ្តល់សិទ្ធិឱ្យប្រើប្រាស់ដីទេ ពួកគេគ្រាន់តែដើរស៊ីឈ្នួលធ្វើស្រែចម្ការឱ្យគេដើម្បីទទួលទានតែប៉ុណ្ណោះ។[៥] ដូច្នេះ នៅពេលក្រុមសាមគ្គីបង្កបង្កើនផល ត្រូវបានបញ្ចប់ ម្ចាស់ដីបានកាន់កាប់ដីរបស់ខ្លួនទាំងអស់ដែលធ្វើឱ្យអ្នកចំណូលថ្មី មិនមានដី

---

៣- លឹម វាន់, "របបដីធ្លីនៅកម្ពុជា," (កក្កដា ២០០៦), ៨។

៤- ប្រជាជននៅភូមិគងជ័យមួយចំនួនត្រូវបានប្រគល់ដីចម្ការនៅភូមិគោហៅ ដែលជាភូមិជាប់គ្នា។ ភូមិទាំងពីរនេះស្ថិតនៅក្នុងឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម។

៥- វិទ្យុអាស៊ីសេរី ចេញផ្សាយ ១១ កុម្ភៈ ២០០៧ (ឃុំព្រាល ស្រុកកញ្ជៀច ខេត្តព្រៃវែង មិនបានអនុវត្តឱ្យបានត្រឹមត្រូវតាមគោលនយោបាយ ក្រុមសាមគ្គីបង្កបង្កើនផលទេ ពីព្រោះអាជ្ញាធរអនុញ្ញាត ឱ្យប្រជាពលរដ្ឋទទួលស្គាល់ដីកេរដំណែលរបស់ពួកគេមុនឆ្នាំ១៩៧៥)។

កាន់កាប់ឡើយ។ តំបន់ខ្លះ ការចែកដីត្រូវបានធ្វើឡើងតែចំពោះដីស្រែ ចំណែកដីភូមិមិនត្រូវបានបែងចែកទេ ពោលគឺទុកលទ្ធភាពឱ្យម្ចាស់ដីពីសម័យមុនកាន់កាប់ធម្មតា។[៦] ដូច្នេះបើមានប្រជាជនចំណូលថ្មីខ្លះ ពួកគេមិនទទួលបានដីលំនៅឋានឡើយ។ ចំណែកនៅតំបន់ខ្លះទៀត ដីភូមិត្រូវបានអនុញ្ញាត ទៅឱ្យម្ចាស់ពីសម័យមុនមកកាន់កាប់ រីឯអ្នកចំណូលថ្មីដែលគ្មានដីភូមិពីមុនមក ត្រូវបានអនុញ្ញាតឱ្យកាន់កាប់ដីភូមិ ដែលម្ចាស់បានស្លាប់នៅក្នុងសម័យប៉ុលពត ឬបានរត់ចោលភូមិទៅកាន់ជំរុំ ចំណែកដីស្រែត្រូវបានបែងចែកជាក្រុមសាមគ្គីបង្កបង្កើនផល។[៧]

**២- បទពិសោធពីក្រុមសាមគ្គីបង្កបង្កើនផល**

គោលដៅមួយនៃការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ប្រហែលជាដើម្បីជួយឱ្យប្រជាពលរដ្ឋមានស្បៀងអាហារគ្រប់គ្រាន់តាមរយៈការធ្វើការរួមគ្នា។ ឧបករណ៍ផលិតកម្មកសិកម្មរបស់ប្រជាពលរដ្ឋតាមគ្រួសារនីមួយៗ រួមទាំងកម្លាំងសត្វពាហនៈ ផងនោះត្រូវបានដាក់ឱ្យប្រើរួមគ្នានៅក្នុងក្រុមសាមគ្គីបង្កបង្កើនផល។[៨] នៅពេលប្រមូលផល គេចែកភោគផលទៅតាមកម្លាំងពលកម្មរបស់គ្រួសារនីមួយៗ នៅក្នុងពួក ឬក្រុមសាមគ្គីបង្កបង្កើនផលជាមួយគ្នា។ ដោយឡែកចំពោះក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣ នៅក្នុងភូមិនីមួយៗគេទុកដីមួយចំនួនក្រៅពីដីដែលបានចែកជូនពលរដ្ឋទៅតាមគ្រួសារនីមួយៗ រួចហើយឱ្យប្រជាជនធ្វើស្រែចម្ការរួមគ្នា ដើម្បីជាប្រយោជន៍របស់ភូមិនោះ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានកំណត់ច្បាស់ពីសិទ្ធិប្រើប្រាស់ដីរបស់ក្រុមសាមគ្គីបង្កបង្កើនផល នៅឆ្នាំ១៩៨៥។ រីឯទំហំផ្ទៃដីដែលរដ្ឋប្រគល់ឱ្យក្រុមសាមគ្គីបង្កបង្កើនផលវិញ អាស្រ័យទៅនឹងមធ្យមភាគនៃចំនួនប្រជាជនក្នុងឃុំទាំងមូល។ ដីកសិកម្មដែលក្រុមសាមគ្គីបង្កបង្កើនផលមានសិទ្ធិប្រើប្រាស់រួមមាន៖[៩]

- ដីដែលរដ្ឋអំណាចបដិវត្តន៍បានប្រគល់ឱ្យក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩
- ដីដែលរដ្ឋអំណាចបដិវត្តន៍បានអនុញ្ញាតឱ្យស្តារឡើងវិញ និងគាស់រានបន្ថែម

---

៦- បទសម្ភាសន៍ជាមួយលោក វង់ ឆវី, ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ២៧ មេសា ២០១៧ (ការបែងចែកដីនៅភូមិសាយ៉ាវ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ)។

៧- បទសម្ភាសន៍ជាមួយលោក ទឹង ស៊ន, អតីតសាស្ត្រាចារ្យនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងបច្ចុប្បន្នជាមន្ត្រីវាយតម្លៃនៃគណៈកម្មាធិការធានាគុណភាពអប់រំនៃកម្ពុជា, ២៧ មេសា ២០១៧ (ការបែងចែកដីនៅភូមិថ្មី ឃុំគោកឃ្មុំ (បច្ចុប្បន្ន ឃុំបន្សាយក្រែង) ស្រុកបាត់ដំបង (បច្ចុប្បន្ន ស្រុកថ្មគោល) ខេត្តបាត់ដំបង)។

៨- លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា," (កក្កដា ២០០៦), ៦។

៩-អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម, លេខ៦អនក្រ, ០៦ ឧសភា ១៩៨៥, នៅក្នុង ហាប់ ផល្វី, វាយឡើងវិញ, *កម្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លីនិងនគរូបនីយកម្មឆ្នាំ១៩៨៥-២០១៥*, បោះពុម្ពលើកទី៤ (ភ្នំពេញ៖ ជោគជ័យ, ២០១៨), ២ (តទៅហៅ ថា *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*)។

- ដីដែលរដ្ឋអំណាចបដិវត្តន៍បានប្រគល់ឱ្យប្រើប្រាស់ជាបណ្ដោះអាសន្ន។

គួរបញ្ជាក់ថា ក្រុមសាមគ្គីបង្កបង្កើនផលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ នាពេលអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផលដំបូង។ មិនមានរបាយការណ៍ផ្លូវការណាមួយបង្ហាញពីមូលហេតុនៃការរីកចម្រើនរបស់ក្រុមសាមគ្គីបង្កបង្កើនផលឡើយ។ ហេតុផលមួយចំនួនអាចត្រូវបានលើកឡើង ដើម្បីពន្យល់ពីការរីកចម្រើននេះ។ ប្រជាពលរដ្ឋខ្មែរដែលមានបទពិសោធក្នុងការធ្វើការរួមគ្នារយៈពេលជិត៤ឆ្នាំ ធ្វើឱ្យពួកគេអាចចូលរួមអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលយ៉ាងងាយស្រួល។ ប្រជាជននៅទទួលឥទ្ធិពលភ័យខ្លាចក្នុងការវិលត្រឡប់វិញ នៃរបប ប៉ុល ពត ដូច្នេះ នៅពេលរដ្ឋាភិបាលដាក់គោលនយោបាយអ្វី ពួកគេត្រូវតែធ្វើតាម។ តែទោះបីជាយ៉ាងណាក៏ដោយហេតុផលលេចធ្លោជាងគេមួយនោះគឺថា ការរីកចម្រើននេះអាចបណ្ដាលមកពីប្រជាពលរដ្ឋកម្ពុជាដែលទើបតែត្រូវបានរំដោះពីរបបខ្មែរក្រហម និងរួចផុតពីការកាប់សម្លាប់ដ៏សាហាវយង់ឃ្នង មានក្ដីសប្បាយរីករាយ និងខិតខំធ្វើការដើម្បីបំពេញក្រពះរបស់ពួកគេ ដែលបានស្រេកឃ្លានអស់រយៈពេលជិត៤ឆ្នាំមកហើយ។ លទ្ធភាពនៃការទទួលទានអាហារទៅតាមតម្រូវការនៃគ្រួសារនីមួយៗ បានផ្ដល់ជាកម្លាំងចិត្តដល់សមាជិកនៃក្រុមសាមគ្គីបង្កបង្កើនផលប្រឹងប្រែងបង្កបង្កើនផលអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត។

**៣- ការបរាជ័យនៃក្រុមសាមគ្គីបង្កបង្កើនផល**

មហិច្ឆតាមនុស្សមិនត្រឹមតែមួយចំអែតក្រពះឡើយ។ នៅពេលក្រពះបានឆ្អែតហើយ មនុស្សតែងចង់ ស្អាត ល្អ មានផាសុកភាព និងមានសេចក្ដីថ្លៃថ្នូរ។ អ្នកដែលធ្វើការសកម្ម និងធ្វើការច្រើន តែងចង់បានផលប្រយោជន៍ត្រឡប់វិញច្រើនដែរ។ ការបែងចែកចំណែកទៅតាមកម្លាំងពលកម្មអាចធ្វើឱ្យអ្នកសកម្មមិនសប្បាយចិត្ត ព្រោះគេអាចគិតថាហេតុអ្វីបានជាចំណែករបស់គេមិនត្រូវបានទទួលច្រើនជាង បើគេខំប្រឹងធ្វើការខ្លាំងជាង។ ការណ៍នេះអាចធ្វើឱ្យអ្នកសកម្មទោរទន់ទៅរកភាពអសកម្ម ដែលធ្វើឱ្យកម្លាំងពលកម្មធ្លាក់ចុះ ផលិតផលកសិកម្ម ក៏ធ្លាក់ចុះ ដូច្នេះវាជាហេតុធ្វើឱ្យក្រុមសាមគ្គីបង្កបង្កើនផលកាន់តែខ្សោយកម្លាំង។

ម្យ៉ាងវិញទៀត ការលួចរត់ពន្ធក៏បានរួមចំណែកធ្វើឱ្យកម្លាំងពលកម្មរបស់ក្រុមសាមគ្គីបង្កបង្កើនផលចុះថយមួយចំណែកផងដែរ។ នៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ពីរបីឆ្នាំបន្ទាប់មក ប្រជាជនមួយចំនួនបានចាប់ផ្ដើមនាំគ្នាទៅព្រំដែន ដើម្បីទិញសំពត់មកលក់ នៅក្នុងប្រទេសកម្ពុជាដោយមិនបង់ពន្ធ។ កម្លាំងបុរសបានថយចុះ ដែលជាកត្តាមួយធ្វើឱ្យកម្លាំងពលកម្មក្នុងក្រុមសាមគ្គីបង្កបង្កើនផលចុះខ្សោយ ខ្វះកម្លាំងធ្វើ

ស្រែចម្ការ ហើយគ្រួសារមួយចំនួនក៏បានបោះបង់ស្រែចម្ការចោល។

បទពិសោធនៃការអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផលក្នុងរយៈពេល១ទសវត្សកន្លងមក បានបង្ហាញថា គោលនយោបាយនេះលែងមានប្រសិទ្ធភាពទៀតហើយ។ ក្រុមសាមគ្គីបង្កបង្កើនផលបានរីកចម្រើន ចាប់ពីឆ្នាំ១៩៧៩ដល់១៩៨៣តែប៉ុណ្ណោះ ប៉ុន្តែចាប់ពីឆ្នាំ១៩៨៤មក ក្រុមសាមគ្គីបង្កបង្កើនផលបានថយចុះគួរឱ្យកត់សម្គាល់ ហើយនៅឆ្នាំ១៩៨៧ ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី១ស្ទើរតែបាត់រូបរាងហើយបែរទៅកើនឡើងក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣វិញ។[១០] ការបរាជ័យនៃក្រុមសាមគ្គីបង្កបង្កើនផលនេះ បានធ្វើឱ្យរដ្ឋាភិបាលកម្ពុជាមានការព្រួយបារម្ភយ៉ាងខ្លាំងពីប្រសិទ្ធភាពនៃការប្រើប្រាស់ដីធ្លីនៅទូទាំងប្រទេស។ ការគិតគូរពីគោលនយោបាយដីធ្លីថ្មីបានក្លាយទៅជាអាទិភាព របស់រដ្ឋាភិបាលក្នុងជំហានបន្ទាប់។

## ២- ឯកជនភាវូបនីយកម្មដីធ្លីនៅឆ្នាំ១៩៨៩

ឯកជនភាវូបនីយកម្មដីធ្លីបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៨៩ បន្ទាប់ពីបរាជ័យនៃក្រុមសាមគ្គីបង្កបង្កើនផល ដែលបានអនុវត្តអស់រយៈពេល១០ឆ្នាំកន្លងមក។ ពន្លកនៃកម្មសិទ្ធិឯកជនបានចាប់ផ្តើមជាដំបូងទៅលើកម្មសិទ្ធិផ្ទះ នៅខែមេសា ឆ្នាំ១៩៨៩។[១១] រដ្ឋាភិបាលកម្ពុជា ដែលបានដឹកនាំដោយគណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលក្រោយមកក្លាយជាគណបក្សប្រជាជនកម្ពុជា បានប្រឹងប្រែងដាក់ចេញសេចក្តីសម្រេចចិត្តដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងដីធ្លីឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព។ សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី គឺជាសេចក្តីសម្រេចដែលលេចធ្លោជាងគេក្នុងចំណោមសេចក្តីសម្រេចចំនួន៥[១២] នាខែមេសាឆ្នាំ១៩៨៩របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងដែលត្រូវបានធ្វើឱ្យគេទទួលស្គាល់ថាជាកំណែទម្រង់ដីធ្លីដ៏សំខាន់មួយទាក់ទងនឹងគោលនយោបាយដីធ្លី បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ១៩៧៩។ តាមរយៈសេចក្តីសម្រេចនេះ ទើបរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមផ្តល់កម្មសិទ្ធិ

១០- លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា," (កក្កដា ២០០៦), ៨។

១១- អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះដល់ពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩, នៅក្នុងកម្រងច្បាប់ដីធ្លីឆ្នាំ២០១៨, ទំព័រ ២៤-២៧។

១២- លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា," (កក្កដា ២០០៦), ៩ (សេចក្តីសម្រេចចំនួន៥ដែលចេញ ដោយគណបក្សប្រជាជនបដិវត្តកម្ពុជា នាខែមេសា ឆ្នាំ១៩៨៩ រួមមាន៖ សេចក្តីសម្រេចចិត្តស្តីពី គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី សេចក្តីសម្រេចស្តីពីគោលនយោបាយ ចំពោះកសិករ សេចក្តីសម្រេចិត្តស្តីពីការប្រកបអាជីវកម្ម ផលិតកម្ម តាមរបៀបវេប្រវាស់ដៃ សេចក្តីសម្រេចចិត្ត ស្តីពីគោលនយោបាយចំពោះ ផលិតកម្មអាជីវកម្មរូបភាពជាសិប្បកម្ម-ឧស្សាហកម្មតូចៗ និងសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយ ចំពោះការដឹកជញ្ជូន)។

ឯកជន ដែលគេស្គាល់ជាទូទៅ ថាជាឯកជនភាវូបនីយកម្មដីធ្លី ចាប់ពីខែមិថុនា ឆ្នាំ១៩៨៩ មក។

**១- សញ្ញាណនៃឯកជនភាវូបនីយកម្មដីធ្លី**

គោលដៅចម្បងនៃការផ្តល់កម្មសិទ្ធិឯកជន គឺទំនងជាជំរុញឱ្យមានការអភិវឌ្ឍដីឱ្យអស់ពីលទ្ធភាពរបស់ម្ចាស់ដី។ ប្រសិនបើដីមិនមែនជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ នោះអ្នកកាន់កាប់ដីអាចនឹងរួញរាក្នុងការអភិវឌ្ឍលើដី ព្រោះពួកគេបារម្ភថា ដីនោះអាចត្រូវបានដកហូតដោយរដ្ឋនៅពេលណាក៏បាន ហើយការអភិវឌ្ឍរបស់ខ្លួននឹងត្រូវរលាយអស់។ តាមរយៈការជំរុញឱ្យមានការអភិវឌ្ឍដី រដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ដីជាកម្មសិទ្ធិឯកជន ជូនពលរដ្ឋរបស់ខ្លួនទៅតាមរូបភាព៣ផ្សេងៗគ្នា រួមមានសិទ្ធិកម្មសិទ្ធិ សិទ្ធិភោគៈ និងសិទ្ធិសម្បទាន។[១៣]

**២- ការកម្រិតសិទ្ធិលើដីធ្លី**

គួរកត់សម្គាល់ថា នៅពេលធ្វើឯកជនភាវូបនីយកម្មដីធ្លីដំបូងនៅកម្ពុជា រដ្ឋាភិបាលបានកម្រិតសិទ្ធិទៅលើដីធ្លីដល់ពលរដ្ឋរបស់ខ្លួន។ មិនមានមូលហេតុជាផ្លូវការពីរដ្ឋាភិបាលក្នុងការពន្យល់អំពីការរឹតត្បិតនៃសិទ្ធិទាំងនេះឡើយ។ ទោះបីយ៉ាងណាក៏ដោយពលរដ្ឋកម្ពុជាត្រូវបានផ្តល់សិទ្ធិចំនួន៣ក្នុងការកាន់កាប់ដីធ្លី។ សិទ្ធិទាំងនោះរួមមានសិទ្ធិកម្មសិទ្ធិ សិទ្ធិភោគៈ និងសិទ្ធិសម្បទាន។ សូមមើលរូបខាងក្រោម សម្រាប់សិទ្ធិទាំង៣ដែលប្រជាពលរដ្ឋកម្ពុជាអាចទទួលបានពីរដ្ឋនៅឆ្នាំ១៩៨៩។

រូប១៖ សិទ្ធិលើដីធ្លីដែលពលរដ្ឋកម្ពុជាមាននៅឆ្នាំ១៩៨៩




រូបខាងលើបង្ហាញថាប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិលើដីធ្លីចំនួនតែ៣ប៉ុណ្ណោះ។ គួរកត់សម្គាល់ថា សិទ្ធិកម្មសិទ្ធិត្រូវបានផ្តល់ជូនចំពោះដីលំនៅឋាន សិទ្ធិភោគៈត្រូវផ្តល់ជូនចំពោះដីស្រែចម្ការ រីឯសិទ្ធិសម្បទាន ត្រូវបានផ្តល់ជូនចំពោះដីដែលពលរដ្ឋ មានទំហំលើសពី៥ហិកតាឡើងទៅ។ ចំពោះការកំណត់ទំហំដីកម្មសិទ្ធិ និងដីភោគៈ សូមមើលជំពូកទី២ខាងក្រោម។

---

១៣- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២៨-៣០។

### ៣- ស្ថាប័នទទួលបន្ទុកលើការចុះបញ្ជីដី

ចាប់តាំងពីកម្ពុជាបានផ្តល់ឯកជនភាវូបនីយកម្មដីធ្លី នៅឆ្នាំ១៩៨៩មក ការចុះបញ្ជីដីធ្លីត្រូវបានយកចិត្តទុកដាក់គួរឱ្យកត់សម្គាល់ពីសំណាក់រដ្ឋាភិបាលកម្ពុជា។ កំណែទម្រង់នៃស្ថាប័នទទួលបន្ទុកលើការចុះបញ្ជីដីជាច្រើនលើក ក៏បានឆ្លុះបញ្ចាំងពីសមត្ថភាពរបស់រដ្ឋាភិបាលចំពោះ កិច្ចខិតខំប្រឹងប្រែងនៃការធ្វើកំណែទម្រង់នេះ។ តាមរយៈសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាសដីធ្លី នៅខែមិថុនា ឆ្នាំ១៩៨៩ អាជ្ញាធរមូលដ្ឋាន ដើរតួនាទីសំខាន់ក្នុងការចុះបញ្ជីដី។ អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ស្រុកពោលគឺគណៈកម្មាធិការប្រជាជនស្រុក មានសិទ្ធិឱ្យចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចំពោះដីស្រែចម្ការ រីឯគណៈកម្មាធិការប្រជាជនខេត្ត មានសិទ្ធិចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចំពោះដីលំនៅឋាន។[១៤] ដោយឡែក មានតែក្រសួងកសិកម្មទេ ដែលមានសិទ្ធិចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីសម្បទាន។[១៥]

ការអនុវត្តសិទ្ធិ នៃការចេញប័ណ្ណសម្រាប់អាជ្ញាធរថ្នាក់មូលដ្ឋាន មិនបានផ្តល់បទពិសោធក្នុងការពង្រឹងសមត្ថភាពឡើយក្នុងរយៈពេល៥ឆ្នាំដំបូង។ ដោយមើលឃើញពីកំហុសរបស់អាជ្ញាធរថ្នាក់មូលដ្ឋានក្នុងការចេញប័ណ្ណ នាយកដ្ឋានសុរិយោដីបានសម្រេចដកសិទ្ធិនៃការចេញប័ណ្ណពីគណៈកម្មាធិការប្រជានជនស្រុក និងគណៈកម្មាធិការប្រជាជនខេត្តនៅឆ្នាំ១៩៩៤ ដោយនាយកដ្ឋានសុរិយោដីខ្លួនឯង ជាអ្នកចេញប័ណ្ណសម្គាល់ សិទ្ធិទាំងពីរគឺសិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈ។ ការដកសិទ្ធិនៃការចេញប័ណ្ណនេះ បានបន្ថយការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់មូលដ្ឋាន និងពិសេសទៅទៀត ពួកគេមិនបានរៀនសូត្រពីកំហុសដែលបានប្រព្រឹត្តកន្លងមកឡើយ។ បញ្ហានៅត្រង់ថា តើការដកសិទ្ធិនោះមានគោលបំណងក្នុងការទប់ស្កាត់ និងកាត់បន្ថយបញ្ហា ឬធ្វើឱ្យការចេញប័ណ្ណល្អឥតខ្ចោះដោយគ្មានកំហុសអ្វីទាល់តែសោះ។ ចម្លើយប្រហែលជាមិនអាចទៅរួចឡើយ ក្នុងការសម្រេចគោលបំណងណាមួយខាងលើ។ ការទប់ស្កាត់បញ្ហា និងការកាត់បន្ថយបញ្ហាណាមួយ ទាមទារឱ្យអ្នកមានសមត្ថកិច្ចពាក់ព័ន្ធមានសមត្ថភាព ភាពម្ចាស់ការ ការលះបង់ សេចក្តីអំណត់ និងទេពកោសល្យខ្ពស់។ ម្យ៉ាងទៀត វាទាមទារឱ្យមានការស្រាវជ្រាវច្បាស់លាស់ដើម្បីស្វែងរកឫសគល់នៃបញ្ហា ដើម្បីងាយស្រួលធ្វើការសម្រេចចិត្ត។

ការប៉ុនប៉ងចេញប័ណ្ណឱ្យបានល្អឥតខ្ចោះ តាមរយៈការស្រូបយកអំណាច មកនៅថ្នាក់កណ្តាល មិនបានឆ្លុះបញ្ចាំងអំពីការអនុវត្តដែលមានហេតុផលសមស្របឡើយ។

១៤- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២៨-២៩។

១៥- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ៣០។

នាយករដ្ឋមន្ត្រីទី១ដែលបានសង្កេតឃើញពីការលំបាកស្មុគស្មាញ ក្នុងការដោះស្រាយបញ្ហាដីធ្លី បែរជាយល់ថាមានតែការចូលរួមត្រួតពិនិត្យការចេញប័ណ្ណដោយ ស្ថាប័ននយោបាយទេ ដែលអាចជួយដោះស្រាយបញ្ហានេះបាន។

ដើម្បីចៀសវាងបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ ឬរវាងប្រជារាស្ត្រជាមួយអាជ្ញាធរនោះ ត្រូវអនុវត្តយ៉ាងណាឱ្យរាល់ការស្នើសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្ដីការគណៈរដ្ឋមន្ត្រីតាមរយៈនាយកដ្ឋានសុរិយោដី ដើម្បីពិនិត្យ និងសម្រេចដោយពុំមែនត្រូវបញ្ចប់ត្រឹមនាយកដ្ឋានសុរិយោដីដូចដែលបានអនុវត្តកន្លងមកឡើយ។ ទង្វើបែបនេះ ខ្ញុំយល់ថាយើងអាចដោះស្រាយបន្ថយនូវបញ្ហាបានមួយកម្រិតធំ ឆ្លងកាត់ការពិនិត្យ និងសិក្សាលំអិតពីទីស្ដីការគណៈរដ្ឋមន្ត្រី។[១៦]

គួរឱ្យកត់សម្គាល់ផងដែរ ចាប់ពីឆ្នាំ២០០០មក រដ្ឋាភិបាលបានប្រើរយៈពេល ១០ឆ្នាំ ដើម្បីផ្ដល់សិទ្ធិនៃការចេញប័ណ្ណនេះទៅឱ្យគ្រប់ខេត្តទាំងអស់។ រាជធានីភ្នំពេញ និងខេត្តកណ្ដាលត្រូវផ្ដល់មុនគេបំផុត នៅឆ្នាំ២០០០ ចំណែកខេត្តប៉ៃលិន និងខេត្តមណ្ឌលគិរីត្រូវបានផ្ដល់សិទ្ធិក្រោយគេបំផុតនៅឆ្នាំ២០១០។ ការចំណាយ រយៈពេលយ៉ាងយូរដើម្បីផ្ដល់សិទ្ធិជូនថ្នាក់ខេត្តនេះ ទំនងជាទាក់ទងយ៉ាងជិតស្និទទៅនឹងសមត្ថភាពមន្ត្រីសុរិយោដីថ្នាក់ខេត្ត។ សូមមើលតារាងខាងក្រោម ដើម្បីឱ្យដឹងច្បាស់ពីឆ្នាំទទួលប្រតិភូកម្មហត្ថលេខាក្នុងការចេញប័ណ្ណរបស់ខេត្តនីមួយៗ។

តារាង១៖ កាលបរិច្ឆេទនៃខេត្តដែលត្រូវបានផ្ដល់សិទ្ធិចេញប័ណ្ណ

| លរ | រាជធានី/ខេត្ត | ឆ្នាំទទួលប្រតិភូកម្មហត្ថលេខា | ផ្សេងៗ |
|---|---|---|---|
| 1 | កណ្ដាល | ១៨ កក្កដា ២០០០ | |
| 2 | ភ្នំពេញ | ១៨ កក្កដា ២០០០ | |
| 3 | ព្រះសីហនុ | ១២ សីហា ២០០២ | |
| 4 | កំពត | ១២ សីហា ២០០២ | |
| 5 | កំពង់ធំ | ១២ សីហា ២០០២ | |
| 6 | តាកែវ | ១២ សីហា ២០០២ | |
| 7 | ព្រៃវែង | ២៣ ធ្នូ ២០០៣ | |

១៦- លិខិតរបស់សម្ដេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្ដេចនាយករដ្ឋមន្ត្រីទី២ ស្នើឱ្យការសុំកាន់កាប់ដីធ្លីឆ្លងកាត់ទីស្ដីការគណៈរដ្ឋមន្ត្រី, លេខ ៩១៨ខុទ្ធ/៩៥, ១៦ មិថុនា ១៩៩៥ នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ ២០៨។

| | | | |
|---|---|---|---|
| 8 | កំពង់ចាម | ២៣ ធ្នូ ២០០៣ | |
| 9 | បាត់ដំបង | ២៥ មេសា ២០០៥ | |
| 10 | សៀមរាប | ១៣ តុលា ២០០៥ | |
| 11 | កំពង់ស្ពឺ | ១៣ តុលា ២០០៥ | |
| 12 | ស្វាយរៀង | ១៣ សីហា ២០០៧ | |
| 13 | កែប | ១៣ សីហា ២០០៧ | |
| 14 | ក្រចេះ | ០៥ កញ្ញា ២០០៧ | |
| 15 | ឧត្តរមានជ័យ | ០៥ កញ្ញា ២០០៧ | |
| 16 | បន្ទាយមានជ័យ | ០៥ កញ្ញា ២០០៧ | |
| 17 | ពោធិ៍សាត់ | ០៥ កញ្ញា ២០០៧ | |
| 18 | កំពង់ឆ្នាំង | ០៥ កញ្ញា ២០០៧ | |
| 19 | កោះកុង | ០១ តុលា ២០០៩ | |
| 20 | ព្រះវិហារ | ០១ តុលា ២០០៩ | |
| 21 | ស្ទឹងត្រែង | ០១ តុលា ២០០៩ | |
| 22 | រតនគិរី | ០១ តុលា ២០០៩ | |
| 23 | មណ្ឌលគិរី | ០១ កក្កដា ២០១០ | |
| 24 | ប៉ៃលិន | ០១ កក្កដា ២០១០ | |

គួរកត់សម្គាល់ថា ស្ថាប័នគ្រប់គ្រងដីធ្លីត្រូវបានកែប្រែជាបន្តបន្ទាប់។ នៅឆ្នាំ ១៩៧៩ ក្នុងពេលកម្ពុជា អនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផល នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម ត្រូវបានបង្កើតឡើងនៅក្រោមក្រសួងកសិកម្មដើម្បីគ្រប់គ្រងក្រុមសាមគ្គីបង្កបង្កើនផល។ នៅឆ្នាំ១៩៨៩ នាយកដ្ឋាននេះត្រូវបានផ្ទេរមកជានាយកដ្ឋានសុរិយោដី ដើម្បីជួយក្រសួងកសិកម្ម លើការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនៅទូទាំងប្រទេស។[១៧] នៅឆ្នាំ១៩៩៤ នាយកដ្ឋានសុរិយោដី ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី។ ជាចុងក្រោយ នាយកដ្ឋានសុរិយោដីត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលត្រូវបានបង្កើតនៅឆ្នាំ១៩៩៩។

ការស្វែងយល់អំពីដំណើរវិវត្ត នៃសាខារបស់ស្ថាប័នគ្រប់គ្រងដីនៅថ្នាក់មូលដ្ឋាន មានសារៈសំខាន់ក្នុងការផ្សារភ្ជាប់គ្នារវាងអតីតកាល និងបច្ចុប្បន្នកាល។ ជាផ្លូវការ នៅខែ

១៧- ប្រកាសស្តីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, លេខ១១១ប្រក/ កសក, ៣១ តុលា ១៩៨៩ នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ៤៥-៤៨។

តុលា ឆ្នាំ១៩៨៩ នៅថ្នាក់ខេត្តមានការិយាល័យសុរិយោដីខេត្ត-ក្រុង ហើយនៅថ្នាក់ស្រុក មានការិយាល័យភូមិបាលស្រុក-ខណ្ឌ។[១៨] ចាប់ពីខែកក្កដា ឆ្នាំ១៩៩៩ មក ឈ្មោះរបស់វាត្រូវបានផ្ទេរមកនៅថ្នាក់ខេត្តគឺមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងនៅថ្នាក់ស្រុកគឺការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ។[១៩] ការគួរឱ្យងឿងឆ្ងល់មួយគឺថាហេតុអ្វីបានជានៅពេលបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយបើ ជាខាសារបស់វា នៅថ្នាក់ខេត្ត និងស្រុកបន្ថែមពាក្យនៅពីក្រោយពាក្យពេញរបស់ពាក្យក្រសួងទៀត ដូចជា ភូមិបាលស្រុក និងសុរិយោដីខេត្តទៅវិញ។ នេះប្រហែលជាការរក្សាពាក្យដដែលនេះ ឱ្យត្រូវគ្នានឹងពាក្យដែលមហាជនធ្លាប់ប្រើកន្លងមក។ ប្រជាជនខ្មែរ តែងហៅពាក្យភូមិបាលស្រុក និងសុរិយោដីខេត្ត ដូច្នេះប្រហែលជាហេតុផលនេះហើយ ទើបពាក្យទាំងនេះត្រូវបានប្រើបន្ថែមទៅលើពាក្យរបស់ក្រសួង។ តារាងខាងក្រោមបង្ហាញ ពីការវិវត្តនៃស្ថាប័នទទួលបន្ទុកគ្រប់គ្រងដីធ្លីនៅថ្នាក់មូលដ្ឋាន ចាប់ពីពេលរដ្ឋបានផ្តល់កម្មសិទ្ធិឯកជនលើដីធ្លីនៅឆ្នាំ១៩៨៩ រហូតដល់បច្ចុប្បន្ន។

តារាង២៖ ការវិវត្តឈ្មោះស្ថាប័នទទួលបន្ទុកគ្រប់គ្រងដីធ្លីនៅថ្នាក់មូលដ្ឋាន

| កាលបរិច្ឆេទ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក |
|---|---|---|
| 1989-1999 | ការិយាល័យសុរិយោដីខេត្ត | ការិយាល័យភូមិបាលស្រុក |
| 1999-បច្ចុប្បន្ន | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក |

(ប្រភព៖ ប្រកាសស្តីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, លេខ១១១ ប្រកកសក, ០១ តុលា ១៩៨៩ និងប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទី និងភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ, លេខ៧៦ប្រក, ០២ កញ្ញា ១៩៩៩)

១៨- ប្រកាសស្តីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, លេខ១១១ប្រក/ កសក, ៣១ តុលា ១៩៨៩, មាត្រា៤ នៅក្នុង *ក្រមុងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ៤៧-៤៨។

១៩-អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/ បក, ២០ កក្កដា ១៩៩៩ នៅក្នុង *ក្រមុងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ៣២១។ រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មខែកុម្ភៈ ឆ្នាំ២០០៨។

ការយល់ពីការវិវត្ត នៃរដ្ឋបាលដែនដីនៅកម្ពុជាមានសារៈសំខាន់ក្នុងការពិភាក្សា។ មុនឆ្នាំ២០០៨ រដ្ឋបាលថ្នាក់ ក្រោមជាតិមានខេត្ត ក្រុង និងស្រុក ខណ្ឌ។ ចាប់ពី ឆ្នាំ២០០៨ មក ថ្នាក់ខេត្តក្រុង ត្រូវបានប្តូរមកជាថ្នាក់រាជធានី ខេត្ត រីឯស្រុក ខណ្ឌ ត្រូវបានប្តូរមកជាក្រុង ស្រុក ខណ្ឌ។[២០] ដើម្បីងាយស្រួលក្នុងការហៅឈ្មោះសៀវភៅនេះ ប្រើពាក្យខេត្ត សំដៅទៅលើខេត្ត ក្រុង មុនឆ្នាំ២០០៨ និងរាជធានី ខេត្ត ចាប់ពីឆ្នាំ២០០៨ រីឯពាក្យស្រុក សំដៅទៅលើស្រុក ខណ្ឌ មុនឆ្នាំ២០០៨ និងក្រុង ស្រុក ខណ្ឌ ចាប់ពីឆ្នាំ២០០៨មក។ តារាងខាងក្រោមបង្ហាញ យ៉ាងងាយស្រួលពីការប្រែប្រួលរដ្ឋបាលដែនដីថ្នាក់ក្រោមជាតិ។

តារាង៣៖ ការប្រែប្រួលឈ្មោះនៃរដ្ឋបាលដែនដីថ្នាក់ក្រោមជាតិនៅកម្ពុជា

| ឈ្មោះរដ្ឋបាលដែនដីថ្នាក់ក្រោមជាតិ | | |
|---|---|---|
| ឈ្មោះហៅក្នុងសៀវភៅនេះ | មុន១៥ កុម្ភៈ ២០០៨ | ចាប់ពី១៥ កុម្ភៈ ២០០៨ |
| ថ្នាក់ខេត្ត | ខេត្ត-ក្រុង | រាជធានី-ខេត្ត |
| ថ្នាក់ស្រុក | ស្រុក-ខណ្ឌ | ក្រុង-ស្រុក-ខណ្ឌ |
| ថ្នាក់ឃុំ | ឃុំ-សង្កាត់ | ឃុំ-សង្កាត់ |

## ៣- សិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈនៅឆ្នាំ១៩៨៩-២០០១

ដូចបានរៀបរាប់នៅក្នុងចំណុចទី១ខាងលើ ឯកជនភាវូបនីយកម្មដីធ្លីត្រូវបានធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៨៩ បន្ទាប់ពីបរាជ័យនៃការអនុវត្តគោលនយោបាយក្រុមសាមគ្គីបង្កបង្កើនផល ដែលត្រូវបានអនុវត្តអស់រយៈពេល១០ឆ្នាំកន្លងមក។ ការសម្រេចផ្តល់សិទ្ធិកម្មសិទ្ធិលើដីធ្លីដល់ពលរដ្ឋកម្ពុជាជាដំបូងនេះ គឺក្នុងគោលបំណងជាចម្បងឱ្យពលរដ្ឋប្រឹងប្រែងអភិវឌ្ឍដីរបស់ខ្លួនឱ្យអស់ពីលទ្ធភាព។

នៅពេលណាដែលផលប្រយោជន៍របស់កសិករត្រូវបានធានា នៅពេលនោះទើបកសិករបញ្ចេញអស់កម្លាំងកាយចិត្តរបស់ខ្លួនធ្វើពលកម្ម ផលិតកម្ម ច្នៃប្រឌិត បង្កើននូវទ្រព្យសម្បត្តិ សម្ភារៈដើម្បីលើកស្ទួយជីវភាពខ្លួន និងសេដ្ឋកិច្ចជាតិ។[២១]

២០- រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មខែកុម្ភៈ ឆ្នាំ២០០៨។

២១- សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់គណបក្សប្រជាជនកម្ពុជា ក្នុងមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២, ខែមេសា ឆ្នាំ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ ២០១៨*, ទំព័រ១៨។

### ១- កម្មសិទ្ធិលើដីលំនៅឋាន

ការផ្ដួចផ្ដើមផ្ដល់កម្មសិទ្ធិដីធ្លីដល់ពលរដ្ឋកម្ពុជា គឺការសម្រេចចិត្តតែមួយគត់របស់គណបក្សប្រជាជនបដិវត្តន៍កម្ពុជានៅខែមេសា ឆ្នាំ១៩៨៩។ ការសម្រេចចិត្ត នាពេលនោះបានបែងចែកដីធ្លីជា៤ប្រភេទ រួមមានដីសម្រាប់ សង់លំនៅឋាន ដីស្រែ និងចម្ការ សម្រាប់ផលិតកម្ម-អាជីវកម្ម ដីបម្រុងរុក្ខានិងនេសាទ និងដីបម្រុងរបស់រដ្ឋ។[២២] គួរកត់សម្គាល់ថាគណបក្សប្រជាជនបដិវត្តន៍កម្ពុជាបានសម្រេចផ្ដល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីជា ៣ប្រភេទដែលក្នុងនោះរួមមានសិទ្ធិកម្មសិទ្ធិត្រូវបានផ្ដល់ ជូនចំពោះដីលំនៅឋាន សិទ្ធិភោគៈចំពោះដីស្រែចម្ការ និងសិទ្ធិសម្បទានគឺជាសិទ្ធិទៅលើដីដែលលើសពីសិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈដែលបានផ្ដល់ជូនទាំង២ខាងលើ។ សិទ្ធិទាំងអស់នេះបានតម្រូវឱ្យរដ្ឋចេញច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដើម្បីធានាការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព។[២៣]

ការរៀបចំច្បាប់ដើម្បីគ្រប់គ្រង និងប្រើប្រាស់ដីធ្លីភ្លាមៗ អាចជួបប្រទះបញ្ហាប្រឈមជាច្រើន។ រដ្ឋាភិបាលកម្ពុជា បានសម្រេចចិត្តចេញសេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីជំនួសវិញ ដើម្បីបំពេញតម្រូវការជាបន្ទាន់ជំនួសឱ្យការចេញច្បាប់។ សេចក្ដីណែនាំនេះត្រូវបានធ្វើឡើងស្របគ្នាទៅនឹងសេចក្ដីសម្រេចចិត្តរបស់គណបក្សប្រជាជនបដិវត្តន៍កម្ពុជានៅខែមេសា ឆ្នាំ១៩៨៩។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្ដល់សិទ្ធិកម្មសិទ្ធិ ជាលើកដំបូងប្រកបដោយភាពបត់បែនជាមូលហេតុចម្បងដែលនាំឱ្យមានបញ្ហានៅពេលក្រោយ។ រដ្ឋមិនទទួលស្គាល់សិទ្ធិកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ ប៉ុន្តែបែរជាទទួលស្គាល់សិទ្ធិកាន់កាប់ចាប់ពីខែមករា ឆ្នាំ១៩៧៩។ "រដ្ឋមិនសើរើ និងបែងចែកជាថ្មីលើដីដែលបានកាន់កាប់រួចហើយចាប់ពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មកទល់ថ្ងៃចេញសេចក្ដីណែនាំអនុវត្តនេះ រហូតដល់មានច្បាប់ភូមិបាល។"[២៤] ចម្ងល់មួយកើតឡើង ថាតើមូលហេតុអ្វីបានជារដ្ឋមិនសើរើ និងបែងចែកដីជាថ្មីចាប់ពីខែមិថុនា ឆ្នាំ១៩៨៩មក ពីព្រោះថា ការកាន់កាប់ពីមុននោះ មិនមែនជាកាន់កាប់យកជាកម្មសិទ្ធិទេ។ ពាក្យថា "រហូតដល់មានច្បាប់ភូមិបាល" អាចត្រូវបានគេយល់ថាលុះត្រាតែមានច្បាប់

---

២២- សេចក្ដីសម្រេចចិត្តស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់គណបក្សប្រជាជនកម្ពុជាក្នុងមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២, ខែមេសា ឆ្នាំ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ១៩-២០។

២៣- សេចក្ដីសម្រេចចិត្តស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់គណបក្សប្រជាជនកម្ពុជាក្នុងមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២, ខែមេសា ឆ្នាំ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២១។

២៤- សេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២៨-៣០។

ភូមិបាល ទើបរដ្ឋសើរើ និងបែងចែកជាថ្មី។

ការកម្រិតពីទំហំនៃដីកម្មសិទ្ធិ និងការមិនសើរើបែងចែកជាថ្មីបានបង្កជាឧបសគ្គក្នុងការអនុវត្ត។ សិទ្ធិកម្មសិទ្ធិត្រូវបានផ្តល់ជូនចំពោះតែដីលំនៅឋាន ដែលមានទំហំមិនលើសពី២០០០ម៉ែត្រការ៉េ ប៉ុន្តែគ្រួសារដែលបានកាន់កាប់ដីលំនៅឋានលើសពី២០០០ម៉ែត្រការ៉េ ចំណែកដែលលើសត្រូវបានចាត់ទុកជាដីភោគៈទៅវិញ។[២៥] ហេតុអ្វីបានជារដ្ឋមិនយកចំណែកដីដែលលើសនោះ ចែកជូនពលរដ្ឋផ្សេងដើម្បីសម្រួលដល់ការអនុវត្ត? ម្យ៉ាងទៀត សមត្ថកិច្ចផ្តល់សិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈក៏ផ្សេងគ្នាដែរ។ ការកំណត់បែបនេះ អាចបណ្តាលឱ្យប្រជាជនដែលរស់នៅក្នុងភូមិជាមួយគ្នា ទទួលបានទំហំដីលំនៅឋានមិនដូចគ្នា។

ទោះបីជាយ៉ាងណាក៏ដោយ ទំហំនៃដីលំនៅឋានមិនត្រូវបានកំណត់ដោយ ច្បាប់ភូមិបាលឆ្នាំ១៩៩២។ ការយល់ផ្សេងៗគ្នាជាច្រើនទៀតទាក់ទងនឹងទំហំដី ជាកម្មសិទ្ធិត្រូវបានបន្តទាំងក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ និងប្រជាពលរដ្ឋទូទៅ។ មតិមួយចំនួនអាចយល់ថា ទំហំដីត្រូវបានរក្សាទុកដូចមានចែងក្នុងសេចក្តីណែនាំ អនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឆ្នាំ១៩៨៩ ពោលគឺ២០០០ម៉ែត្រការ៉េ រីឯមតិមួយចំនួនទៀតអាចនឹងលើកឡើងថាទំហំដីលែងចាំបាច់ទៀត ឱ្យតែជាដីលំនៅឋាន ប៉ុន្មានម៉ែត្រការ៉េក៏បាន។ ការយល់ ឃើញផ្សេងៗគ្នាអាចនាំឱ្យការអនុវត្តក៏មានភាពខុសគ្នាផងដែរ។ បើផ្អែកតាមការពិនិត្យផ្អែកច្បាប់ឱ្យបានល្អិតល្អន់ ច្បាប់ភូមិបាលឆ្នាំ១៩៩២បានកំណត់ថា មានតែដីលំនៅឋានទេដែលអាចទទួលបានសិទ្ធិកម្មសិទ្ធិ[២៦] ហើយក៏គ្មានមាត្រាណាមួយក្នុងច្បាប់នេះបានរឹតត្បិតទំហំកម្មសិទ្ធិឡើយ។ ហេតុនេះហើយ ការកំណត់ទំហំសិទ្ធិកម្មសិទ្ធិលើដីលំនៅឋាន ដែលបានចេញដោយសេចក្តីណែនាំឆ្នាំ១៩៨៩ មិនមានឥទ្ធិពលលើច្បាប់ភូមិបាលឡើយ។

**២- សិទ្ធិភោគៈលើដីស្រែចម្ការ**

ឯកជនភាវូបនីយកម្មដីធ្លីនៅឆ្នាំ១៩៨៩ បានធ្វើឱ្យមានការងឿងឆ្ងល់យ៉ាង ខ្លាំងចំពោះការផ្តល់សិទ្ធិទៅលើដីស្រែចម្ការ។ រដ្ឋបានអនុញ្ញាតផ្តល់តែសិទ្ធិភោគៈប៉ុណ្ណោះលើដីស្រែចម្ការ ហើយទំហំដីវិញមិនឱ្យលើសពី ៥ហិកតា។ គ្មានមូលហេតុផ្លូវការណាមួយបង្ហាញពីការសម្រេចចិត្តបែបនេះឡើយ។ ដីភោគៈត្រូវបានរដ្ឋប្រគល់ជាសិទ្ធិផ្តាច់មុខជូនគ្រួសារកសិករកាន់កាប់ប្រើប្រាស់ដោយគ្មានកំណត់រយៈពេលនិងអាចបន្តមត៌ក

---

២៥- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ២៨។

២៦- ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៩ (តទៅហៅថាច្បាប់ភូមិបាលឆ្នាំ ១៩៩២)។

បាន។[២៧] ការអនុញ្ញាតឱ្យផ្ទេរសិទ្ធិភោគៈតាមរយៈការលក់ ដូរ នឹងឱ្យនៅជាបញ្ហាចំពោះការយល់ឃើញរបស់មន្ត្រីអនុវត្ត។ បើតាមឃ្លាខាងលើ ទំនងជាគេអាចបកស្រាយថា សិទ្ធិភោគៈនៅឆ្នាំ១៩៨៩អាចឱ្យភោគីត្រឹមតែប្រើប្រាស់ និងអាស្រ័យផល ព្រមទាំងបន្តមតិកប៉ុណ្ណោះ ពោលគឺមិនអាចផ្ទេរក្រោមរូបភាព លក់ ដូរ និងធ្វើអំណោយបានទេ ទោះបីជារដ្ឋមិនបានហាមឱ្យច្បាស់ក្នុងការផ្ទេរ សិទ្ធិភោគៈក៏ដោយ។

អត្ថន័យនៃដីភោគៈបានបង្កប់នូវគោលបំណង នៃការផ្ដល់សិទ្ធិភោគៈលើដី ស្រែចម្ការគួរឱ្យកត់សម្គាល់។ ដីភោគៈខុសគ្នាជាចម្បងនឹងដីកម្មសិទ្ធិត្រង់ថា "ដីភោគៈអាចថេរក្នុងដំណាក់កាលដែលកំពុងប្រើប្រាស់ ពេលឈប់ប្រើប្រាស់គឺ លែងជាភោគៈ"[២៨] ទៀតហើយ។ ក្នុងន័យនេះ ប្រហែលជារដ្ឋចង់ជំរុញឱ្យគ្រួសារ កសិករប្រើប្រាស់ដីឱ្យអស់ពីលទ្ធភាព ស្របទៅតាមគោលបំណងនៃឯកជនភាវូបនីយកម្មដីធ្លី។ តារាងខាងក្រោមបង្ហាញពីភាពខុសគ្នារវាងដីភោគៈ និងដីកម្មសិទ្ធិ នៅឆ្នាំ១៩៨៩។

តារាង៤៖ ភាពខុសគ្នារវាងដីភោគៈ និងដីកម្មសិទ្ធិនៅឆ្នាំ១៩៨៩

| ភាពខុសគ្នា | ដីភោគៈ | ដីកម្មសិទ្ធិ |
|---|---|---|
| ថេរភាព | ថេរភាពរបស់វា អាស្រ័យលើការប្រើប្រាស់ បើឈប់ប្រើប្រាស់ លែងជាដីភោគៈទៀតហើយ ពោលគឺជាដីរបស់រដ្ឋ។ | ថេរភាពរបស់វាគ្មានកំណត់ ពោលគឺមិនអាស្រ័យ លើការប្រើប្រាស់ ឬធ្វើអាជីវកម្មលើដីនោះទេ។ |
| ទំហំ | មិនលើសពី៥ហិកតា | មិនលើសពី២០០០ម$^{២}$ |

ជាការគួរឱ្យចាប់អារម្មណ៍ មូលដ្ឋាននីមួយៗត្រូវបានតម្រូវឱ្យរក្សាទុកដីស្រែចម្ការជាដីបម្រុងរបស់មូលដ្ឋានខ្លួន។ ឃុំនីមួយៗអាចរក្សាទុកដីស្រែចម្ការបម្រុងរបស់ឃុំចាប់ពី៣ទៅ៦ហិកតា អាស្រ័យតាមលទ្ធភាពជាក់ស្ដែង រីឯភូមិវិញអាចរក្សាទុកដីស្រែចម្ការបម្រុងរបស់ខ្លួនចំនួនពី១ទៅ២ហិកតា។[២៩] បើមូលដ្ឋាននីមួយៗ បានរក្សាទុកដីលើសពីការកំណត់ខាងលើ ដីដែលលើសនោះតម្រូវឱ្យបែងចែកជូនប្រជាពលរដ្ឋវិញ។ ដីបម្រុងនេះហើយ ក្រោយមកអាចនឹងក្លាយទៅជាដីឯកជនរបស់រដ្ឋ។

២៧- សេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២៩។
២៨- សេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ២៩។
២៩- សេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ២៩។

ដូចគ្នានឹងដីលំនៅឋានដែរ ច្បាប់ភូមិបាលឆ្នាំ១៩៩២មិនបានកំណត់ទំហំ នៃដីស្រែចម្ការដែលត្រូវផ្តល់ជាសិទ្ធិភោគៈនោះឡើយ។ បញ្ហានេះអាចបង្កឱ្យមានការយល់ផ្សេងៗគ្នាថាតើដីស្រែចម្ការអាចមានច្រើនបំផុត ត្រឹម៥ហិកតា ដូចសេចក្តីណែនាំឆ្នាំ១៩៨៩ ឬមិនកំណត់ទំហំ។ អ្វីដែលធ្វើឱ្យកាន់តែឆ្ងល់ទៅទៀតនោះ គឺដីសម្បទានមិនត្រូវបានចែងក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ទេ ហើយថាតើដីសម្បទាននេះអាចត្រូវបានប្រែក្លាយជាសិទ្ធិភោគៈដែរឬទេ។ លើសពីនេះទៅទៀត តាមការអនុវត្តជាក់ស្តែង ក្រសួងកសិកម្មមិនបានចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីសម្បទានឡើយ។[៣០] ត្រង់ចំណុចនេះ សិទ្ធិសម្បទាននេះអាចត្រូវបានប្រែក្លាយ ទៅជាសិទ្ធិភោគៈតាមច្បាប់ភូមិបាលឆ្នាំ១៩៩២។

**៣- បញ្ហានៃការទទួលស្គាល់សិទ្ធិភូមិបាល**

សិទ្ធិភូមិបាលត្រូវបានរៀបចំផ្តល់ជូនពលរដ្ឋកម្ពុជា តាមរយៈសេចក្តីសម្រេចចិត្តរបស់គណបក្សប្រជាជនបដិវត្តន៍កម្ពុជានាខែមេសា ឆ្នាំ១៩៨៩ មុននឹងសម្រេចជាផ្លូវការអនុវត្តគោលនយោបាយឯកជនភាវូបនីយកម្មដីធ្លី នៅខែមិថុនា ឆ្នាំ១៩៨៩។ ភាពមិនដាច់ណាត់ នៃការកំណត់ទំហំដីដែលត្រូវផ្តល់ពីដំបូងបានបន្សល់ទុកបញ្ហាស្មុគស្មាញទៅពេលក្រោយ។ រដ្ឋាភិបាលទើបសម្រេចផ្តល់កម្មសិទ្ធិឯកជនលើដីធ្លីដល់ពលរដ្ឋរបស់ខ្លួន ប៉ុន្តែរដ្ឋបែរជាមិនសើរើដីដែលបានកាន់កាប់ពីមុនមកទៅវិញ។ ជាឧទាហរណ៍ នៅក្នុងការទទួលស្គាល់សិទ្ធិកម្មសិទ្ធិ រដ្ឋផ្តល់ជូនតែដីលំនៅឋានទេ ហើយទំហំមិនលើសពី២០០០ម៉ែត្រការ៉េ។ ក្នុងករណីដែលពលរដ្ឋណាបានកាន់កាប់ មុនឆ្នាំ១៩៨៩ លើសពីទំហំនេះ ទំហំដែលលើសនេះនឹងត្រូវផ្តល់ជាសិទ្ធិភោគៈ។ ការលំបាកមួយអាចនឹងកើតឡើងប្រសិនបើគ្រួសារមួយបានកាន់កាប់ដីភូមិមួយកន្លែង ដែលមានទទឹង៣០ម៉ែត្រ និងបណ្តោយ៦៨ម៉ែត្រ នោះទំហំដីសរុបចំនួន២០០៤ម៉ែត្រការ៉េ។ បើតាមគោលការណ៍ណែនាំ រដ្ឋត្រូវផ្តល់កម្មសិទ្ធិលើដីលំនៅឋាន ខាងលើនេះត្រឹមទំហំតែ២០០០ម៉ែត្រការ៉េប៉ុណ្ណោះ ចុះ៤ម៉ែត្រការ៉េទៀតត្រូវផ្តល់ជូនក្នុងទម្រង់បែបណាវិញ?

ដូចគ្នានេះដែរ ការកម្រិតសិទ្ធិភោគៈលើដីកសិកម្មមិនឱ្យលើសពី៥ហិកតា បានផ្តល់ជាបញ្ហាក្នុងការអនុវត្ត។ ឧបមាថា គ្រួសារដែលបានកាន់កាប់ដីលំនៅឋាន ២០០៤ម៉ែត្រការ៉េខាងលើ បានកាន់កាប់ដីស្រែចម្ការ ចំនួន៥,១ហិកតាទៀត នោះគាត់អាចទទួលបានសិទ្ធិភោគៈតែ៥ហិកតាប៉ុណ្ណោះ។ ក្នុងករណីនេះ បញ្ហាដែល កើតឡើងគឺថាដីភោគៈត្រូវបានផ្តល់ឱ្យត្រឹម៥ហិកតាទេ ចុះទំហំដីដែលលើសនោះ ត្រូវបានផ្តល់ជូនយ៉ាងដូចម្តេច? បើពិនិត្យយ៉ាងល្អិតល្អន់ទៅលើសេចក្តីសម្រេចចិត្ត ស្តីពីគោលនយោបាយគ្រប់គ្រង

---

៣០- លឹម វ៉ាន់ (អតីតអគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ), បទសម្ភាសន៍ផ្ទាល់ខ្លួន, ៤ កញ្ញា ២០១៣។

និងប្រើប្រាស់ដីធ្លីរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជានៅឆ្នាំ១៩៨៩ ទំហំដីដែលកំណត់នេះបង្កជាឧបសគ្គដល់ការអនុវត្តផង និងការយល់ពីខ្លឹមសារតាំងពីពេលនោះមក។ តាមរយៈនេះ ទំហំដីដែលលើសត្រូវបានផ្តល់ជូនជាសម្បទានដែលក្នុងនោះក្រសួងកសិកម្ម ជាអ្នកមានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីសម្បទាន។[៣១] អត្ថន័យនៃសម្បទាននៅពេលនោះ សំដៅទៅលើ "សិទ្ធិកាន់កាប់ជាដំណាក់កាលដែលរដ្ឋបើកឱ្យលើផ្ទៃដីធំសម្រាប់ដាំដុះដំណាំសំខាន់ៗបម្រើឱ្យសេដ្ឋកិច្ចជាតិ។"[៣២] បើតាមអត្ថន័យនេះ និងឧទាហរណ៍ខាងលើ ឃើញថាដីដែលលើសពីទំហំ៥ហិកតាចំនួន១០០៤ ម៉ែត្រការ៉េជាដីទំហំតូចទៅវិញ។

ការតម្រូវឱ្យប្រជាពលរដ្ឋដាក់ពាក្យសុំកាន់កាប់ដី ក្នុងអំឡុងពេលមួយច្បាស់លាស់គឺជាវិធានការដ៏មានប្រសិទ្ធភាពមួយរបស់រដ្ឋ។ នៅពេលប្រជាពលរដ្ឋមើលឃើញកាលបរិច្ឆេទកំណត់ឈប់ទទួលពាក្យសុំ ហើយដីធ្លី ដែលអ្នកកាន់កាប់មិនបានស្នើសុំនឹងត្រូវបានចាត់ទុកជាដីដែលគ្មានម្ចាស់នោះ ប្រជាពលរដ្ឋអាចនឹងប្រឹងប្រែង ខ្នះខ្នែងដាក់ពាក្យសុំទាំងអស់គ្នា។

ប្រកាសបើកថ្ងៃទទួលពាក្យសុំកាន់កាប់ដីទូទាំងប្រទេស ចាប់ពីថ្ងៃចេញសេចក្តីណែនាំអនុវត្តនេះដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៨៩។ ផុតកំណត់នេះ រដ្ឋចាត់ទុកថាជាដីទំនេរគ្មានម្ចាស់កាន់កាប់។[៣៣]

បញ្ហាចម្បងមួយទៀតចំពោះការទទួលស្គាល់សិទ្ធិភូមិបាល គឺការចេញប័ណ្ណមិនទាន់ទៅតាមការដាក់ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ជាលទ្ធផលគ្រាន់តែរយៈពេល១ឆ្នាំនៃការអនុវត្ត ការដាក់ពាក្យសុំរបស់ប្រជាពលរដ្ឋ មានចំនួនសរុប ៣ ៧០០ ០០០ ប្លង់ដីដែលស្មើនឹង៧០% នៃការប៉ាន់ស្មានប្លង់ដីសរុប[៣៤] គិតមកដល់ខែកក្កដា ឆ្នាំ១៩៩០។ គួរកត់សម្គាល់ថា ពលរដ្ឋភាគច្រើន បានទទួលតែបង្កាន់ដៃទទួលពាក្យ ដែលមិនបានបញ្ជាក់លក្ខណៈពេញច្បាប់នៃដីទេ ពោលគឺគ្រាន់តែជាភ័ស្តុតាងបន្ទាប់

៣១- សេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, ខែមេសា ឆ្នាំ១៩៨៩ និង សេចក្តីណែនាំអនុវត្តគោលនយោបាយ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ២០ & ៣០។

៣២- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ៣០។

៣៣- សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លី ឆ្នាំ២០១៨*, ទំព័រ៣០។

៣៤- សេចក្តីណែនាំស្តីពីការកែសម្រួលសេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ ដីធ្លី, លេខ០៣សណន ចុះថ្ងៃទី០៣ មិថុនា ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី, លេខ០៣សណន, ៨ ធ្នូ ១៩៨៩, នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ៦៣។

បន្សំមួយបញ្ជាក់ពីប្រវត្តិនៃទំនាក់ទំនងនៃដីតែប៉ុណ្ណោះ។ ជាក់ស្តែង គិតមកដល់ឆ្នាំ១៩៩៥ រដ្ឋបានចែកប័ណ្ណជូនពលរដ្ឋរបស់ខ្លួនតែចំនួន ៤៥៨ ២៧៧ ប័ណ្ណ[៣៥] ដែលជាចំនួនតិចបំផុតបើប្រៀបធៀបនឹងការដាក់ពាក្យសុំ។ ចំនួនប័ណ្ណនេះមាន ការកើនឡើងទៀតរហូតមកដល់បច្ចុប្បន្ន ដែលនឹងពិភាក្សាយ៉ាងលំអិតនៅក្នុងជំពូកទី៣ខាងក្រោម។

ការកាន់កាប់ដីដែលមិនមានប័ណ្ណ គឺជាហានិភ័យមួយសម្រាប់អ្នកកាន់កាប់ដី។ បើបកស្រាយយ៉ាងតឹងរ៉ឹង តាមច្បាប់ភូមិបាលឆ្នាំ១៩៩២ ដីធ្លីទាំងឡាយណា ដែលមិនត្រូវបានចុះបញ្ជីចាប់ពីខែតុលា ឆ្នាំ១៩៩៧ មកដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ គឺត្រូវក្លាយជាដីរដ្ឋ។[៣៦] ក្នុងអំឡុងពេលនេះ បើរដ្ឋអភិវឌ្ឍដីចំដីដែលមិនបានចុះបញ្ជី នោះរដ្ឋមិនចាំបាច់បង់ថ្លៃសំណងទេ ព្រោះដីទាំងនោះត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ប៉ុន្តែការទទួលខុសត្រូវរបស់រដ្ឋត្រូវបានតម្រូវចាប់ពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១។ ភោគៈស្របច្បាប់ដែលមិនបានចុះបញ្ជីត្រូវបានគាំទ្រដោយច្បាប់។[៣៧] ទោះបីជាយ៉ាងនេះក៏ដោយ បញ្ហានៅត្រង់ថា នៅពេលដីនោះប៉ះចំគម្រោងអភិវឌ្ឍ បើអាជ្ញាធរមានសមត្ថកិច្ចយល់ថាដីនោះជាដីរដ្ឋ គឺសំណងមិនត្រូវបានទទួលតាមផ្លូវច្បាប់ទេ។ ចំណុចនេះបានបង្កជាបញ្ហាច្រើន នៅក្នុងការអនុវត្តជាក់ស្តែងមួយចំនួន។

## ៤- សិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈនៅក្រោមច្បាប់ភូមិបាលឆ្នាំ២០០១

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បើកសករាជថ្មីក្នុងកំណែទម្រង់ដីធ្លី គួរឱ្យកត់សម្គាល់។ សិទ្ធិកម្មសិទ្ធិលើដីធ្លី ត្រូវបានផ្តល់ជូនពលរដ្ឋកម្ពុជា និងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ដោយមិនគិតពីប្រភេទដីស្រែចម្ការ ឬដីលំនៅឋានទៀតឡើយ។

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[៣៨]

ការយល់ពីអត្ថន័យច្បាស់លាស់នៃសិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈដែលកំណត់ដោយច្បាប់ភូមិបាលឆ្នាំ២០០១ មានសារៈសំខាន់ក្នុងការពិភាក្សា។ សិទ្ធិទាំងពីរ មានការប្រែប្រួលគួរឱ្យកត់សម្គាល់រវាងច្បាប់ភូមិបាល ឆ្នាំ១៩៩២ និងច្បាប់ភូមិបាលឆ្នាំ២០០១។

៣៥- ច័ន្ទ សុផល និងផ្សេងទៀត, "ការកាន់កាប់ដីធ្លីនៅកម្ពុជា៖ បច្ចុប្បន្នភាពកាលបរិច្ឆេទ" [*Land Tenure in Cambodia: A Date Update*], (ឯកសារពិភាក្សាលេខ១៩, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ខែតុលា ២០០៣), ៣០។
៣៦- ច្បាប់ភូមិបាលឆ្នាំ១៩៩២, មាត្រា១៨(២)។
៣៧- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៤២ (តទៅហៅថា ច្បាប់ភូមិបាលឆ្នាំ២០០១)។
៣៨- រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៤។

ការទទួលស្គាល់កម្មសិទ្ធិពេញលេញ ភាពខុសគ្នានៃការទទួលស្គាល់ប័ណ្ណ ព្រមទាំងការផ្ទេរកម្មសិទ្ធិនឹងត្រូវពិភាក្សានៅក្នុងផ្នែកនេះ។

### ១- ការទទួលស្គាល់កម្មសិទ្ធិពេញលេញ

បន្ទាប់ពីការអនុវត្តឯកជនភាវូបនីយកម្មដីធ្លីអស់រយៈពេល១២ឆ្នាំមក សិទ្ធិកម្មសិទ្ធិពេញលេញទើបតែត្រូវ បានទទួលស្គាល់ដោយច្បាប់ភូមិបាលឆ្នាំ២០០១។ សិទ្ធិកម្មសិទ្ធិឯកជនត្រូវបានផ្ដល់ជូនពលរដ្ឋកម្ពុជា ចំពោះដីគ្រប់ប្រភេទ លើកលែងតែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ តាមរយៈនេះ ទាំងដីលំនៅឋាន និងដីស្រែចម្ការ ត្រូវបានផ្ដល់ជាសិទ្ធិកម្មសិទ្ធិ។ ប៉ុន្តែ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថាការទទួលបានសិទ្ធិកម្មសិទ្ធិពេញលេញ ត្រូវរង់ចាំពេលវេលាមួយ ដែលអាស្រ័យទៅតាមការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។ ក្នុងរយៈពេលដែលមិនអាចកំណត់បាននេះ រដ្ឋអនុញ្ញាតឱ្យសិទ្ធិភោគៈស្របតាមបញ្ញត្តិនៃច្បាប់មុនឆ្នាំ២០០១ អាចត្រូវបានប្រើជា "កម្មវត្ថុនៃការផ្លាស់ប្ដូរ ផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួញ"[៣៩] បាន។

ជាលក្ខណៈបច្ចេកទេស ការទទួលបានប័ណ្ណកម្មសិទ្ធិតម្រូវឱ្យរដ្ឋធ្វើការប្ដេជ្ញាចិត្តខាងនយោបាយយ៉ាងខ្លាំង។ តម្រូវការធនធានមនុស្ស ធនធានរូបវន្ត និងថវិកា គឺជាការចាំបាច់ក្នុងការសម្រេចបាននៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។ នៅពេលដែលគម្រោងចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធមិនទាន់បានចាប់ផ្ដើមនៅតំបន់ណាមួយ ជាទូទៅ នៅតំបន់នោះ ប្រជាពលរដ្ឋមិនមានលទ្ធភាពទទួលបានប័ណ្ណកម្មសិទ្ធិឡើយ។ ក្នុងន័យនេះ ការទទួលស្គាល់សិទ្ធិកម្មសិទ្ធិពេញលេញនៅជាបញ្ហាប្រឈមក្នុងការអនុវត្តជាក់ស្ដែងនៅឡើយ។ ក្នុងករណីមានការអភិវឌ្ឍតំបន់ណាមួយ បើអាជ្ញាធរមានសមត្ថកិច្ចគិតថាដីដែលគ្មានប័ណ្ណនោះជាដីរបស់រដ្ឋ នោះប្រជាជនដែលបានកាន់កាប់ដីនោះនឹងមិនទទួលបានសំណងតាមច្បាប់ទេ ដែលបញ្ហានេះបានក្លាយទៅជាក្ដីព្រួយបារម្ភ សម្រាប់ប្រជាពលរដ្ឋទូទៅ។

ការយល់ដឹងនៅមានកម្រិតពីអត្ថន័យនៃកម្មសិទ្ធិពេញលេញ ក្នុងចំណោមប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានបង្កជាបញ្ហានៅក្នុងសង្គមជាតិខ្មែរ។ ប្រជាពលរដ្ឋតែងតែគិតថា ដីរបស់ពួកគេដែលអត់បានចុះបញ្ជីគឺ ប្រឈមនឹងហានិភ័យណាស់ ប្រសិនបើរដ្ឋត្រូវការដីនោះយកទៅប្រើប្រាស់ ទោះបីក្នុងប្រយោជន៍សាធារណៈក៏ដោយ ពោលគឺពួកគេពិបាកនឹងតស៊ូមតិដើម្បីទទួលបានសំណងតាមច្បាប់។ រីឯ អាជ្ញាធរមូលដ្ឋានវិញក៏មិនអាច ជួយប្រជាពលរដ្ឋរបស់ខ្លួនបានដែរ ដោយសារតែយល់ថាប្រជាពលរដ្ឋមិនមានប័ណ្ណ

---

៣៩- ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៣៩។

ដើម្បីគាំទ្រ ហើយក៏អាច គិតថារដ្ឋផ្តល់សំណង គោលនយោបាយជូនពលរដ្ឋគឺជាការគ្រប់គ្រាន់ហើយ។

តាមច្បាប់ កម្មសិទ្ធិពេញលេញត្រូវមានប័ណ្ណកម្មសិទ្ធិ ដែលត្រូវបានទទួល ជាទូទៅតាមរយៈការចុះបញ្ជី ដីមានលក្ខណៈជាប្រព័ន្ធ។ ច្បាប់ភូមិបាលឆ្នាំ២០០១ គាំទ្រទាំងសិទ្ធិកម្មសិទ្ធិពេញលេញ និងសិទ្ធិភោគៈស្របច្បាប់។ "មានតែភោគៈ ត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ដែលអាចនាំឱ្យបានកម្មសិទ្ធិ។"[៤០] ចំណែកច្បាប់អស្សាមិករណ៍វិញក៏ការពារទាំងសិទ្ធិកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សផ្សេងទៀត ដោយរដ្ឋជាអ្នកផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។[៤១] ប៉ុន្តែ អ្វីដែលគួរតែយល់ដឹងឱ្យកាន់តែច្បាស់នោះគឺថា សិទ្ធិស្របច្បាប់នេះ ទោះបីមិនទាន់បានចុះបញ្ជីក៏ដោយ ក៏ច្បាប់នៅតែគាំទ្រដែរ។

បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិ ត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និងមាត្រា៣១នៃ ច្បាប់[ភូមិបាល]។"[៤២]

បញ្ហានៅត្រង់ថាតើភោគៈស្របច្បាប់គឺជាអ្វី? មិនមានការបកស្រាយច្បាស់លាស់ឡើយនៅក្នុងច្បាប់កម្ពុជា រហូតដល់ពេលនេះ។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចយល់បានថាភោគៈស្របច្បាប់គិតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ គឺជាភោគៈដែលមិនមែនជាការកាន់កាប់ដីសាធារណៈរបស់រដ្ឋ ឬជាដីរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀត។ ដូច្នេះ ពលរដ្ឋកម្ពុជាដែលបានកាន់កាប់ដីដោយស្របច្បាប់ ទោះបីមិនទាន់បានទទួលកម្មសិទ្ធិពេញលេញ ដោយហេតុតែមិនទាន់បានចុះបញ្ជីដីរបស់ខ្លួនក៏ដោយ ក៏នៅតែគាំពារដោយច្បាប់ដដែល។

### ២- ភាពខុសគ្នានៃប្លង់ដី

សៀវភៅនេះប្រើពាក្យប្លង់ដី ឬប័ណ្ណដី សំដៅទៅលើប័ណ្ណកម្មសិទ្ធិ និងប័ណ្ណភោគៈ។ ដើម្បីសិក្សាឱ្យកាន់តែច្បាស់អំពីប្លង់ដី ការយល់ដឹងពីការប្រែប្រួលនៃឈ្មោះរបស់វាគឺជាការចាំបាច់។ នៅពេលកម្ពុជាបានចាប់ផ្តើម ផ្តល់ឯកជនភាវូបនីយកម្មដីធ្លីដំបូងក្នុងឆ្នាំ១៩៨៩ រដ្ឋមានលទ្ធភាពចេញតែប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ ដីធ្លីដែលមានអត្ថន័យជាប័ណ្ណភោគៈ ដើម្បីបញ្ជាក់ទាំងសិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈ។

---

៤០- ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៦(១)។

៤១- ច្បាប់អស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៤ និង១៩(១)។

៤២- ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៤២។

តារាង៥៖ ការវិវត្តនៃឈ្មោះប័ណ្ណដី និងកាលបរិច្ឆេទ

| ឆ្នាំ | ការវិវត្តឈ្មោះនៃប័ណ្ណដី | អត្ថន័យ |
|---|---|---|
| 1989 | --------ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី | ប័ណ្ណភោគៈ |
| 1995 | --------ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ | |
| 2018 | | |
| 2002 – បច្ចុប្បន្ន | វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ | ប័ណ្ណកម្មសិទ្ធិ |

តារាងខាងលើបង្ហាញថា នៅឆ្នាំ១៩៩៥ រដ្ឋាភិបាលបានប្តូរឈ្មោះប័ណ្ណដី ពីប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី មកជាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលតម្លៃរបស់វានៅតែជាប័ណ្ណភោគៈដដែល។ ប័ណ្ណ សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះបន្តចេញតាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ រហូតដល់ពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រេចឱ្យបញ្ឈប់ នៅខែមករា ឆ្នាំ២០១៩។[៤៣] ដោយឡែក នៅពេលមានគម្រោងចុះបញ្ជីដីមានលក្ខណៈ ជាប្រព័ន្ធបានចាប់ផ្តើមក្នុងឆ្នាំ ២០០២មក រដ្ឋាភិបាលក្រោមជំនួយបច្ចេកទេសពី ដៃគូអន្តរជាតិ មានលទ្ធភាពចេញប័ណ្ណកម្មសិទ្ធិ ដែលមានឈ្មោះពេញថា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

គួរកត់សម្គាល់ថា ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានហៅឈ្មោះផ្សេងៗក្នុងចំណោម សាធារណជនខ្មែរជាទូទៅ។ ប័ណ្ណនេះត្រូវបានចេញ ជាក់ស្តែងចាប់ពីឆ្នាំ១៩៩២ ហើយប្រជាពលរដ្ឋតែងហៅ ក្រៅផ្លូវការថាប័ណ្ណស្លាបមាន់ ឬប្លង់រឹង។ មូលហេតុគេហៅប័ណ្ណស្លាបមាន់ព្រោះមកពីប័ណ្ណនេះ មានស្លាបប៉ាកកា នៅត្រង់មាត្រដ្ឋានដែលមើលទៅហាក់ដូចជាស្លាបមាន់។ គេក៏ហៅប័ណ្ណនេះថាប្លង់រឹង ព្រោះវាត្រូវបានគេអ៊ុតប្លាស្ទិករឹងដូចអត្តសញ្ញាណប័ណ្ណ។ ទោះបីជាមានការវិវត្តនៃការប្រើពាក្យផ្សេងទៀត ហើយលក្ខណៈនៃប័ណ្ណបច្ចុប្បន្ន មិនត្រូវបានអ៊ុតរឹងទៀតក៏ដោយ ក៏ប័ណ្ណនេះត្រូវបានគេបន្តហៅថាប្លង់រឹងដដែល។ តាមលក្ខណៈច្បាប់ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី

៤៣- លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្ញើជូនប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត, លេខ២០១៧ជនស/អសដក, ២០ សីហា ២០១៨។

ដែលក្រោយមកដូរជាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ត្រូវបានទទួលបានតាមការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ឬជាប្រព័ន្ធចំពោះតែដីដែលមិនទាន់បំពេញល័ក្ខខ័ណ្ឌទទួលបានកម្មសិទ្ធិ ដោយផ្អែកតាមមាត្រា៣១ នៃច្បាប់ភូមិបាលឆ្នាំ២០០១។ ចំណែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ត្រូវបានទទួលតាមរយៈការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ការចុះបញ្ជីបំពេញបន្ថែម និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ចាប់ពីខែមករា ឆ្នាំ២០១៩មក។ រដ្ឋក៏បានផ្តល់សិទ្ធិឱ្យអភិបាលរាជធានីភ្នំពេញ ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ សម្រាប់សម្គាល់កម្មសិទ្ធិលើផ្ទះនៅភ្នំពេញ ដើម្បីឱ្យស្របតាមការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជានៅខែមេសា ឆ្នាំ១៩៨៩។[៩៤]

សរុបសេចក្តីមក ប័ណ្ណភោគៈគឺសម្រាប់សម្គាល់សិទ្ធិភោគៈស្របច្បាប់ដែលត្រូវបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ប៉ុន្តែនៅមានលក្ខណៈបច្ចេកទេសមិនទាន់គ្រប់គ្រាន់ក្នុងការសម្រេចផ្តល់កម្មសិទ្ធិស្ថាពរ។ រីឯ ប័ណ្ណកម្មសិទ្ធិគឺសម្រាប់សម្គាល់សិទ្ធិកម្មសិទ្ធិដែលត្រូវបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី និងមានលក្ខណៈបច្ចេកទេសគ្រប់គ្រាន់ក្នុងការសម្រេចផ្តល់ជាកម្មសិទ្ធិស្ថាពរ។ ទោះជាយ៉ាងណាក៏ដោយ ប័ណ្ណទាំងពីរនេះត្រូវបានការពារដោយច្បាប់ដូចគ្នា។

**៣- ការផ្ទេរកម្មសិទ្ធិ**

ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ត្រូវបានអនុញ្ញាតប្រកបដោយការចម្រូងចម្រាសផ្នែកច្បាប់ តាំងពីមុនឯកជនភាវូបនីយកម្មដីធ្លី។ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១ មិនបានអនុញ្ញាតឱ្យមានការលក់ដីធ្លីទេ។[៩៥] ប៉ុន្តែការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុបែរជាត្រូវបានអនុញ្ញាតនៅខែតុលា ឆ្នាំ១៩៨៨[៩៦] ក្នុងខណៈពេលដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ នៅជាធរមាននៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ រយៈពេលមិនដល់មួយឆ្នាំផង វិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ ត្រូវបានធ្វើឡើងដោយលុបចោលការហាមឃាត់ការលក់ដូរដីធ្លីចេញ។

ការអនុញ្ញាតឱ្យមានកម្មសិទ្ធិលើលំនៅឋានដល់ពលរដ្ឋកម្ពុជា កើតឡើងមុនពេលឯកជនភាវូបនីយកម្មដីធ្លី ត្រឹមតែ១០ថ្ងៃប៉ុណ្ណោះ។ នៅថ្ងៃ២២ មេសា ១៩៨៩ រដ្ឋបានសម្រេចប្រគល់កម្មសិទ្ធិលើលំនៅឋានតែប៉ុណ្ណោះ ដោយកំណត់ថាដី ដែលសង់លំនៅ

---

៩៤- លឹម វាន់, "ការគ្រប់គ្រងដីធ្លីនៅកម្ពុជា," (២៤ ឧសភា ២០០៧), ៧។
៩៥- រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១, មាត្រា១៧។
៩៦- ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ៣៧ក្រច, ២៨ តុលា ១៩៨៨ (តទៅហៅថាច្បាប់ស្តីពីកិច្ចសន្យាឆ្នាំ១៩៨៨)។

ឋាននោះជាកម្មសិទ្ធិរបស់រដ្ឋ។[៤៧] នៅពេលនេះហើយដែលរដ្ឋបានសម្រេចអនុញ្ញាតឱ្យមានការផ្ទេរកម្មសិទ្ធិតាមរយៈការលក់ផ្ទះ ដោយតម្រូវឱ្យបង់ពន្ធប្រថាប់ត្រា រហូតដល់១០ភាគរយ នៃតម្លៃផ្ទះដែលបានលក់។[៤៨]

ការផ្ទេរកម្មសិទ្ធិតាមរយៈការលក់ទិញដីលំនៅឋាន ត្រូវបានអនុញ្ញាតក្នុងរយៈពេលតែ១០ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីការអនុញ្ញាតឱ្យពលរដ្ឋកម្ពុជាមានសិទ្ធិលក់ផ្ទះ។ ការផ្តល់សិទ្ធិកម្មសិទ្ធិលើដីលំនៅឋានចាប់ពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៨៩ អាចត្រូវបានបកស្រាយថាអនុវត្តតាមច្បាប់ស្តីពីកិច្ចសន្យាឆ្នាំ១៩៨៨ ដែលអនុញ្ញាតឱ្យលក់ ទាំងសិទ្ធិកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតផង ដូចជាសិទ្ធិភោគៈជាដើម។

ការលក់ជាកិច្ចសន្យាមួយដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិ នៃវត្ថុមួយសិទ្ធិណាមួយឱ្យទៅបុគ្គលម្នាក់ទៀត ដែលមានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ថ្លៃវត្ថុ ឬសិទ្ធិនោះមកវិញ។[៤៩]

ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតនេះស្របគ្នាទៅនឹងរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជាដែលបានធ្វើវិសោធនកម្មពី រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១។ ទន្ទឹមនឹងនេះដែរ នៅឆ្នាំ១៩៩១ ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ក៏បានកំណត់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិក្រោមរូបភាពលក់ទិញផ្ទះ និងដីសង់លំនៅឋាន ដែលកំណត់អត្រាពន្ធប្រថាប់ត្រាត្រឹម៦%វិញ។[៥០] បើតាមអត្ថន័យនៃច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ការផ្ទេរសិទ្ធិភោគៈមិនត្រូវបានតម្រូវឱ្យបង់ពន្ធប្រថាប់ត្រាទេ ទោះបីច្បាប់ភូមិបាលឆ្នាំ១៩៩២ បានអនុញ្ញាតឱ្យមានការផ្ទេរសិទ្ធិនៃអចលនវត្ថុ តាមរយៈការលក់ក៏ដោយ។[៥១]

តាមលក្ខណៈបច្ចេកទេសនៃប័ណ្ណមុនឆ្នាំ១៩៩៥ ការបង់ពន្ធប្រថាប់ត្រាទំនងជាមិនអាចធ្វើបានទេ។ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីដែលគេតែងហៅថាជាប្លង់រឹងនោះ មិនអាចត្រូវបានប្រើប្រាស់ក្នុងការកត់ត្រា ការផ្លាស់ប្តូរបានឡើយ ពីព្រោះនៅខាងខ្នងប័ណ្ណមិនមានទុកកន្លែងឱ្យសរសេរ។ ទើបតែចាប់ពីឆ្នាំ១៩៩៥មក ប័ណ្ណនេះត្រូវបានដូរឈ្មោះជាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ហើយនៅខាងខ្នងប័ណ្ណមាន

៤៧- អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩, មាត្រា១ នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ២៥។

៤៨- អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩, មាត្រា៧ នៅក្នុង *កម្រងច្បាប់ដីធ្លីឆ្នាំ២០១៨*, ទំព័រ២៦។

៤៩- ច្បាប់ស្តីពីកិច្ចសន្យាឆ្នាំ១៩៨៨, មាត្រា៣៤។

៥០- ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា, លេខ២១ក្រ, ១៥ កុម្ភៈ ១៩៩១, មាត្រា២។

៥១- ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧៧, "ការលក់អចលនវត្ថុជា កិច្ចសន្យាដែលជនម្នាក់ហៅថាអ្នកលក់ ត្រូវផ្ទេរនូវសិទ្ធិនៃអចលនវត្ថុនោះ ឬកម្មសិទ្ធិណាមួយ ជារបស់ខ្លួនឱ្យទៅជនម្នាក់ទៀត ហៅថាអ្នកទិញដែលជាអ្នកត្រូវចេញថ្លៃជាប្រាក់តាម តម្លៃនៃវត្ថុនោះ ឬសិទ្ធិនោះឱ្យអ្នកលក់។" (តទៅហៅថា ច្បាប់ភូមិបាលឆ្នាំ១៩៩២)។

តារាងដើម្បីទុកឱ្យកត់ត្រាការផ្លាស់ប្តូរ ដែលរួមមានទាំងការផ្ទេរឈ្មោះតាមរយៈការលក់ទិញ ប្រទានកម្ម ឬសន្តតិកម្ម។ ការផ្ទេរឈ្មោះអាចធ្វើទៅបាន លុះត្រាតែមានភស្តុតាងពន្ធប្រថាប់ត្រា។ ដូច្នេះហើយ បានជាពន្ធប្រថាប់ត្រាត្រូវបានគេកត់ត្រាចាប់ពីឆ្នាំ១៩៩៥មក។

**៤- ការចុះបញ្ជីដី**

ការចុះបញ្ជីដីត្រូវបានចាប់ផ្តើមភ្លាម នៅទន្ទឹមនឹងពេលឯកជនភាវូបនីយកម្មដីធ្លីនាឆ្នាំ១៩៨៩។ ការចុះបញ្ជីដីដំបូងត្រូវបានធ្វើឡើងតាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមរយៈតម្រូវឱ្យអ្នកកាន់កាប់ដាក់ពាក្យស្នើសុំ ដោយតំណាងជាមេគ្រួសារ។ បន្តមកទៀត តាមច្បាប់ភូមិបាលឆ្នាំ១៩៩២ ការចុះបញ្ជីដីធ្លីមាន កំណត់អំឡុងពេលទុកឱ្យអ្នកកាន់កាប់ទៅសុំរហូតដល់រយៈពេល៥ឆ្នាំ ពោលគឺចាប់ពីខែតុលា ឆ្នាំ១៩៩២ ដល់ខែតុលា ឆ្នាំ១៩៩៧។ ប៉ុន្តែ ច្បាប់ភូមិបាលឆ្នាំ២០០១បង្កើតឱ្យមានការចុះបញ្ជីមួយប្រភេទទៀត គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលតាមរយៈនេះហើយ ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបានក្លាយទៅជាការចុះបញ្ជីដី ដែលលែងកំណត់ពេលវេលាចុះបញ្ជីទៀតឡើយ។ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធបានចាប់ផ្តើម ជាផ្លូវការនៅឆ្នាំ២០០២ ដោយមានជំនួយពីធនាគារពិភពលោក រដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលហ្វាំងឡង់។ នៅចុងខែមិថុនា ឆ្នាំ២០១២ ក្នុងយុទ្ធនាការរយៈពេល១ឆ្នាំរបស់នាយករដ្ឋមន្ត្រីកម្ពុជា ការចុះបញ្ជីដីដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្តបានបង្កើតឡើង និងបានចុះបញ្ជីក្បាលដីបានជាង ៦សែនប័ណ្ណ។

តារាងខាងក្រោមបង្ហាញពីចំនួនប័ណ្ណដែលបានចែកជូនប្រជាពលរដ្ឋតាមរយៈការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ចាប់ពីឆ្នាំ២០០២ ដល់២០១៩ រួមបញ្ចូលនឹងការចុះបញ្ជីដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្តឆ្នាំ ២០១២ និង២០១៣។ ចំនួនប័ណ្ណសរុបគិតត្រឹមដំណាច់ឆ្នាំ២០១៩ គឺ៤.៥៣៧.១៧៤ប័ណ្ណ។

តារាង៦៖ ចំនួនប័ណ្ណតាមឆ្នាំដែលទទួលបានពីការចុះបញ្ជីដីជាប្រព័ន្ធ និងយុវជន ស្ម័គ្រចិត្ត




(ប្រភព៖ របាយការណ៍ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ឆ្នាំ២០០២ ដល់២០១៩)

ចំណែកការចុះបញ្ជីដីសរុប រួមបញ្ចូលទាំងការចុះបញ្ជីដីជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ គិតត្រឹមឆ្នាំ២០១៩មានចំនួន៥.២៨០.៦៣៧ប័ណ្ណ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាង៧៖ ចំនួនប័ណ្ណដែលបានចែកជូនប្រជាពលរដ្ឋសរុបគិតត្រឹមឆ្នាំ២០១៩




(ប្រភព៖ របាយការណ៍ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឆ្នាំ២០១៩)

នៅពេលដីធ្លីត្រូវបានចុះបញ្ជីរួចរាល់ រដ្ឋងាយស្រួលក្នុងការធ្វើផែនការប្រើប្រាស់ដី និងប្រមូលពន្ធលើដីធ្លី។ កន្លងមក ការបង់ពន្ធអចលនវត្ថុប្រចាំឆ្នាំគឺជាកាតព្វកិច្ចដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ ហើយការរាយការណ៍ពីទំហំដីគឺអាស្រ័យទៅតាមការកំណត់របស់ម្ចាស់អចលនវត្ថុ ក្នុងករណីអចលនវត្ថុនោះមិនទាន់បានចុះបញ្ជី។ ក្នុងករណីដែល

ម្ចាស់អចលនវត្ថុខកខានមិនបានបង់ពន្ធ រដ្ឋនឹងពិន័យនៅពេលមានការផ្ទេរកម្មសិទ្ធិកើតឡើង។ ការរង់ចាំការពិន័យនេះមិនមែនជាមធ្យោបាយល្អទេ។ ក្នុងករណីដែលរដ្ឋមានទិន្នន័យដីចុះបញ្ជីគ្រប់គ្រាន់ រដ្ឋអាចធ្វើការក្រើនរំឭក ប្រសិនបើម្ចាស់អចលនវត្ថុមិនទាន់បានបង់ពន្ធ។

## សេចក្តីសន្និដ្ឋាន

ការផ្តល់កម្មសិទ្ធិឯកជនលើដីធ្លី គឺជាមធ្យោបាយមួយក្នុងការលើកទឹកចិត្តអ្នកកាន់កាប់ដីឱ្យធ្វើការវិនិយោគដីរបស់ខ្លួន។ នៅពេលដីជាកម្មសិទ្ធិផ្តាច់មុខ ម្ចាស់ដីនឹងមិនមានភាពភ័យខ្លាចក្នុងការបាត់បង់ដីតាមរយៈការដកយកវិញដោយរដ្ឋ ហើយមានចិត្តក្នុងការប្រើប្រាស់ដីឱ្យអស់ពីលទ្ធភាព។ ទំនុកចិត្តក្នុងការប្រើប្រាស់ដីជាកម្លាំងដ៏ធំមួយដែលនាំឱ្យមានការវិនិយោគរយៈពេលវែងលើដីរបស់ខ្លួន។

ការចុះបញ្ជីដីបានឆាប់រហ័សនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ដល់សង្គមជាតិ។ សេដ្ឋកិច្ចគ្រួសារអាចត្រូវបានលើកកម្ពស់តាមរយៈការប្រើប្រាស់សិទ្ធិលើដីធ្លី អស់ពីលទ្ធភាពដែលរួមមានដាក់ជាប្រាតិភោគប្រត្យក្សដើម្បីទទួលបានលទ្ធភាពក្នុងពង្រីកមុខរបររបស់ម្ចាស់ដី។ សុវត្ថិភាពក្នុងការជួលដីរយៈពេលវែងក៏ជាឱកាសមួយដែលម្ចាស់ដីនិងម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ទទួលផលប្រយោជន៍ពីដីផងដែរ។ បន្ថែមពីនេះ ទំនាស់ដីធ្លីក៏នឹងត្រូវបានកាត់បន្ថយ នៅពេលដីត្រូវបានកំណត់អត្តសញ្ញាណម្ចាស់ដីច្បាស់លាស់។ អត្ថប្រយោជន៍ដ៏ចម្បងមួយទៀតគឺការទទួលបានពន្ធពីដីតាមរយៈការផ្ទេរកម្មសិទ្ធិ និងពន្ធលើអចលនវត្ថុប្រចាំឆ្នាំ។

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ និងវិសោធនកម្ម។

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១។

ច្បាប់អស្សាមិករណ៍, លេខ នសរកម០២១០០០៣, ២៦ កុម្ភៈ ២០១០។

ច្បាប់ភូមិបាល, លេខ នសរកម០៨០១១៤, ៣០ សីហា ២០០១។

ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២។

ច្បាប់ស្ដីពីការបង្កើតពន្ធប្រថាប់ត្រា, លេខ២១ក្រ, ១៥ កុម្ភៈ ១៩៩១។

ច្បាប់ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ៣៧ក្រច, ២៨ តុលា ១៩៨៨។

អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ បក, ២០ កក្កដា ១៩៩៩។

អនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះដល់ពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩។

អនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម, លេខ៦អនក្រ, ០៦ ឧសភា ១៩៨៥។

ប្រកាសស្ដីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, លេខ១១១ប្រក កសក, ៣១ តុលា ១៩៨៩។

លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្ញើជូនប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត, លេខ២០១៧ ដនសអសដភ, ២០ សីហា ២០១៨។

លិខិតរបស់សម្ដេចនាយករដ្ឋមន្ត្រីទី១ផ្ញើជូនសម្ដេចនាយករដ្ឋមន្ត្រីទី២, លេខ ៩១៨ខុទ្ទ ៩៥, ១៦ មិថុនា ១៩៩៥។

សេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ០៣សណន, ៣ មិថុនា ១៩៨៩។

សេចក្ដីសម្រេចចិត្តស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់គណបក្សប្រជាជនកម្ពុជា ក្នុងមហាសន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២, ខែមេសា ឆ្នាំ១៩៨៩។

## សៀវភៅ និងឯកសារផ្សេងៗ


______. "របបដីធ្លីនៅកម្ពុជា." កក្កដា ២០០៦។

ច័ន្ទ សុផល និងផ្សេងទៀត. "ការកាន់កាប់ដីធ្លីនៅកម្ពុជា៖ បច្ចុប្បន្នភាពកាលបរិច្ឆេទ" [*Land Tenure in Cambodia: A Date Update*]. ឯកសារពិភាក្សាលេខ១៩, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ខែតុលា ២០០៣។

ជា សុផារ៉ា. *របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*, លេខ០០៥ជនសអរបនរបរបា. ភ្នំពេញ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ១០ មករា ២០២០។

លឹម វាន់. "ការគ្រប់គ្រងដីធ្លីនៅកម្ពុជា." ២៤ ឧសភា ២០០៧។

ហាប់ ផល្ទី, វាយឡើងវិញ. *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ ១៩៨៥-២០១៥*, បោះពុម្ពលើកទី៤. ភ្នំពេញ៖ ជោគជ័យ, ២០១៨។

# សន្តានិយមកម្ពុជា

## ឯកឧត្តម ឡេង ប៉េងឡុង

### បុព្វកថា

នៅឆ្នាំ១៩៧០ សង្គ្រាមត្រជាក់ដែលពិភពកុម្មុយនីស្តប្រឈមទល់នឹងពិភពលោកសេរីបានអូសទាញដោយជោគជ័យប្រទេសកម្ពុជាអព្យាក្រឹតនិងមានសន្តិភាពដែលដឹកនាំដោយ ព្រះករុណា ព្រះបាទ នរោត្តម សីហនុ ឱ្យចូលទៅក្នុងសង្គ្រាមក្តៅនៃប្រទេសវៀតណាម។

បន្ទាប់ពីរដ្ឋប្រហារដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ របបសាធារណរដ្ឋមួយដែលនិយមអាមេរិកបានកាន់អំណាចនៅភ្នំពេញ ហើយចាប់ពីពេលនោះមក ប្រទេសដ៏តូចនៅអាស៊ីអាគ្នេយ៍មួយនេះ បានចូលលង់កាន់តែជ្រៅទៅៗទៅក្នុងសង្គ្រាមមួយដែលមានលក្ខណៈ អន្តរជាតិផង ជាសង្គ្រាមក្នុងស្រុកផង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបនិយមអាមេរិករបស់លោកសេនាប្រមុខ លន់ នល់ បានទទួលបរាជ័យខាងយោធាទាំងស្រុង ហើយពួកខ្មែរក្រហមក៏បានចូលមកកាន់អំណាចនៅភ្នំពេញ ហើយចាប់ពីពេលនោះមករបបប្រល័យពូជសាសន៍បានត្រួតត្រាកម្ពុជាអស់រយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។

ស្ថិតក្នុងភាពសាហាវព្រៃផ្សៃដ៏យង់ឃ្នងនៃពួកខ្មែរក្រហម ការតស៊ូបានកើតមានឡើងនៅចុងឆ្នាំ១៩៧៨។ ការតស៊ូយ៉ាងប្តូរផ្តាច់របស់អ្នកស្នេហាជាតិពេលនោះមានជាអាទិ៍ ចលនាដឹកនាំដោយ លោក ជា ស៊ីម លោក ហេង សំរិន និងលោក ហ៊ុន សែន ពុំគ្រប់គ្រាន់ដើម្បីវាយរំលំពួកខ្មែរក្រហមបានទេ។ ទាល់តែមានជំនួយពីសំណាក់បណ្តាអង្គភាពស្ម័គ្រចិត្តនៃកងទ័ពកុម្មុយនីស្តវៀតណាម ទើបវាយឱ្យទ័ពខ្មែរក្រហមបែកបាក់ខ្ចាត់ខ្ចាយ ហើយកងទ័ពនិងរាល់ក្បាលម៉ាស៊ីននៃអង្គភាពខ្មែរក្រហមត្រូវបានវាយបណ្តេញឱ្យចាកចេញពីភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ការរំដោះប្រទេសកម្ពុជាពីរបបបង្ហូរឈាមខ្មែរក្រហម មិនបានធ្វើឱ្យប្រជាជនកម្ពុជារស់នៅក្នុងសន្តិភាពពេញលេញនោះទេ។ កាកសំណល់នៃកងទ័ពព្រៃផ្សៃនេះដែលបានភៀសខ្លួនទៅក្នុងព្រៃស្រោង នៃតំបន់ភ្នំនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ មួយរយៈក្រោយមកអាចបានទទួលជំនួយបរទេស និងចាប់កាន់អាវុធជាថ្មីនៅតាមព្រំដែននោះ។ ម្យ៉ាងវិញទៀត ដោយមានជនភៀសខ្លួនកម្ពុជារាប់ពាន់នាក់បានប្រមូលផ្តុំគ្នានៅក្នុងជំរុំ

ជាច្រើនក្នុងតំបន់ព្រំដែនកម្ពុជាថៃនោះ ចលនានយោបាយឬគណបក្សនយោបាយនៅកម្ពុជា ត្រូវបានបង្កើតឡើង ហើយដែលមិនយូរប៉ុន្មានក៏មានការគាំទ្រពីបរទេស។ សម្រាប់ខ្មែរក្រហមនិងគណបក្សនយោបាយទាំងនេះ អន្តរាគមន៍របស់វៀតណាមគឺជាកត្តាជំរុញដ៏សំខាន់មួយដែលត្រូវបានទទួលការគាំទ្រខ្ពស់ពីសំណាក់ក្រុមប្រឆាំងកុម្មុយនីស្តនៅជុំវិញពិភពលោក។

ដូច្នេះហើយ បានជាមានគណបក្សផ្សេងៗនៃប្រទេសកម្ពុជា បានកើតជាបន្តបន្ទាប់ពីឆ្នាំ១៩៧៩ ដែលប្រមូលផ្តុំខ្មែរក្រហម និងចលនានយោបាយសេរី ដែលភាគច្រើនជាពួកគាំទ្រ សម្តេចព្រះនរោត្តមសីហនុ និងដែលដឹកនាំការតស៊ូប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាលនៃរដ្ឋកម្ពុជា ដែលកំពុងស្ថិតក្នុងការកសាងប្រទេសឡើងវិញ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះហើយ ប្រទេសកម្ពុជាបានឈានចូលដំណាក់កាលថ្មីនៃសង្គ្រាម ដែលនេះជាសង្គ្រាមស៊ីវិលនៅក្នុងប្រទេសមួយ នៃតំបន់អាស៊ីអាគ្នេយ៍ ជាជម្លោះមួយដែលបានអូសបន្លាយរហូតដល់ឆ្នាំ១៩៩៣ ពោលគឺ ៣ឆ្នាំបន្ទាប់ពីការដួលរលំនៃជញ្ជាំងទីក្រុងប៊ែកឡាំង។

នៅក្នុងការប៉ុនប៉ងដើម្បីដោះស្រាយជម្លោះនេះ ការសន្ទនា ការចរចាក្នុងកម្រិតតំបន់ទាំងអស់សុទ្ធតែបញ្ចប់ដោយការបរាជ័យ។ ផ្ទុយទៅវិញ កិច្ចចរចាអន្តរកម្ពុជា ដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៨៧ ទទួលបានជោគជ័យក្នុងការស្វែងរកដំណោះស្រាយ។ នោះគឺជាកិច្ចព្រមព្រៀងសន្តិភាពថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលតួអង្គទាំងអស់នៃជម្លោះទាំងនៅជិតក្តី នៅឆ្ងាយក្តីសុទ្ធតែបានចូលរួមដោយផ្ទាល់ និងបានចុះហត្ថលេខា ដោយមានដាក់នូវល័ក្ខខ័ណ្ឌសន្តិភាព និងជាកំណើតនៃរដ្ឋកម្ពុជាអនាគត ជាពិសេសការស្តារលទ្ធិប្រជាធិបតេយ្យឡើងវិញ និងគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ។

## សេចក្តីផ្តើម

ប្រទេសកម្ពុជាបច្ចុប្បន្ន ជារដ្ឋដែលប្រកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញបែបសភានិយម។ រដ្ឋធម្មនុញ្ញរបស់កម្ពុជាត្រូវបានប្រកាសឱ្យប្រើជាផ្លូវការដោយព្រះមហាក្សត្រ នរោត្តម សីហនុ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ដើម្បីយល់ឱ្យកាន់តែច្បាស់ពីស្ថានភាពនៃរបបប្រជាធិបតេយ្យបែបតំណាងនេះ គួរតែរំលឹកឡើងវិញយ៉ាងខ្លីៗពីល័ក្ខខ័ណ្ឌនានានៃកំណើតរបបមួយដែលបានគ្រប់គ្រងប្រជាជនកម្ពុជាចាប់តាំងពី២៧ឆ្នាំកន្លងមក។ គ្រប់ៗគ្នាបានដឹងហើយថានៅចុងសតវត្សរ៍ទី២០ ជាពិសេស៖

-នៅលើឆាកអន្តរជាតិៈ ការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងនយោបាយឡើងវិញនៃសហភាពសូវៀត ដែលគាំទ្រនិងអនុវត្តដោយលោកហ្គបាឆូវ ហើយដែលផ្អែកលើការបើកទូលាយទំនាក់ទំនងនិងតម្លាភាព បណ្តាលឱ្យមានការដួលរលំជញ្ជាំងទីក្រុងប៉ែកឡាំង និងការបង្រួបបង្រួមប្រទេសអាល្លឺម៉ង់។ សេចក្តីប្រកាសឯករាជ្យជាបន្តបន្ទាប់របស់បណ្តាប្រទេសសមាជិកនៃសហភាពសូវៀតដែលជាលទ្ធផលនាំឱ្យមានការរំលាយសហភាពសូវៀតនៅឆ្នាំ១៩៩១ ហើយទីបំផុតសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ ដែលសរុបមកគឺជ័យជម្នះបានទៅខាងប្រទេសប្រជាធិបតេយ្យ រីឯការបរាជ័យគឺខាងប្រទេសសង្គមនិយម។

-នៅខាងកម្ពុជាវិញ ការវាយប្រហារនៅតាមព្រំដែនជាមួយវៀតណាមខាងត្បូងគឺកើតមានជាញឹកញាប់ ទោះបីជាមុនថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ដែលនៅពេលនោះសេនាប្រមុខ **លន់ នល់** បានធ្វើរដ្ឋប្រហារប្រឆាំងនឹងរបបរាជានិយមរបស់ សម្តេចសីហនុ និងបានប្រកាសប្រកាន់យករបបសាធារណរដ្ឋនៅកម្ពុជាទៅវិញ។ ហើយក្រោយមកទៀតគ្រប់ៗគ្នាក៏បានដឹងហើយថាប្រទេសកម្ពុជា បានឈានដល់សង្គ្រាមពេញលេញមួយក្នុងក្របខ័ណ្ឌនៃការប្រឈមមុខគ្នារវាងប្លុកពីរនៅឥណ្ឌូចិន ហើយដែលទីបំផុតបានបើកលទ្ធភាពឱ្យពួកកុម្មុយនីស្តប្រល័យពូជសាសន៍ នៃរបបខ្មែរក្រហមចូលមកកាន់អំណាចនៅកម្ពុជា។ ការធ្វើអន្តរាគមន៍របស់កងទ័ពស្ម័គ្រចិត្តវៀតណាមដែលបានរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការសម្លាប់រង្គាលរបស់បនប៉ុលពត នៅតែត្រូវបានសហគមន៍អន្តរជាតិចាត់ទុកថាជាការឈ្លានពានមួយ សូម្បីតែចាប់តាំងពីឆ្នាំ១៩៨៩ នៅពេលដែលប្រទេសកម្ពុជាមានរចនាសម្ព័ន្ធនយោបាយ រដ្ឋបាល និងយោធារបស់ខ្លួនជាកម្ពុជា១០០% ក៏ដោយ។ ប៉ុន្តែប្លុកដែលឈ្នះប្លុកកុម្មុយនីស្តនៅដើមទសវត្ស៩០ នៅតែចិញ្ចឹមការស្អប់របស់ខ្លួនចំពោះជនជាតិមួយ ដែលបានឆ្លងកាត់ដោយសង្គ្រាម និងអសន្តិសុខយ៉ាងខ្លាំងដោយការដាក់ទណ្ឌកម្មនយោបាយនឹងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរបន្ថែមលើកម្ពុជា ធ្វើឱ្យកម្ពុជាមានភាពឯកោផ្នែកការទូត និងជួបប្រទះការលំបាកយ៉ាងខ្លាំង។ ម្យ៉ាងទៀតប្រជាជនកម្ពុជាដ៏ក្រីក្ររបស់យើងដែលនៅតែត្រូវប្រយុទ្ធប្រឆាំងនឹងអំពើឃោរឃៅរបស់ពួកនិយម **ប៉ុល ពត** ដែលនៅសេសសល់ ទោះបីដឹងថាពួកវាគឺជាឧក្រិដ្ឋជន និងជាពេជ្ឈឃាដសម្លាប់ប្រជាជនកម្ពុជារាប់លាននាក់ហើយក៏ដោយ។ ជាក់ស្តែងសហគមន៍អន្តរជាតិស្ទើរតែនោះបានបន្តគាំទ្រពួកគេជាផ្លូវការនៅក្នុងអង្គការសហប្រជាជាតិទៀតផង។

ដូច្នេះហើយ ក្រោមល័ក្ខខ័ណ្ឌទាំងឡាយនៃការបញ្ចប់សង្គ្រាមត្រជាក់ បណ្តាប្រទេសនានាលើពិភពលោកនិងប្រទេសនៅអាស៊ីអាគ្នេយ៍ បានយល់ដឹងពីតម្រូវការចាំ

បាច់ក្នុងការស្តារសន្តិភាព និងស្ថិរភាពឡើងវិញដល់កម្ពុជា និងនៅតំបន់អាស៊ីអាគ្នេយ៍ និងបន្ទាប់ពីការចរចាយ៉ាងសកម្មអស់រយៈពេលជាង ៥ឆ្នាំមក ការផ្សះផ្សាមួយត្រូវបានព្រមព្រៀងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលក្នុងនោះខាងផ្នែកនយោបាយរបស់កម្ពុជា គេបានតម្រូវទាមទារឱ្យមានការបង្កើតលទ្ធិប្រជាធិបតេយ្យមួយនៅកម្ពុជា។

## ១- ប្រជាធិបតេយ្យកម្ពុជា - ប្រជាធិបតេយ្យមួយដូចប្រទេសដទៃទៀត

ក- កិច្ចព្រមព្រៀងនេះហៅថា «កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយដ៏ទូលំទូលាយនៃជម្លោះកម្ពុជា» មាន ៣ផ្នែក និងឧបសម្ព័ន្ធចំនួន៥ ដែលជាផ្នែកសំខាន់ នៃកិច្ចព្រមព្រៀង។

យើងចាប់អារម្មណ៍តែលើទិដ្ឋភាពនយោបាយ គឺមាត្រា២៣ នៃកិច្ចព្រមព្រៀងដែលចែងថា៖ គោលការណ៍គ្រឹះ (រដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជា) ត្រូវតែរាប់បញ្ចូលគោលការណ៍សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានក៏ដូចជាលក្ខន្តិកៈនៃអព្យាក្រឹតភាព ហើយគោលការណ៍សំខាន់ៗនឹងត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងនេះ។

ខ- យើងកត់សម្គាល់ឃើញថា គោលការណ៍ប្រជាធិបតេយ្យដែលត្រូវការសម្រាប់ការធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញកម្ពុជាថ្មី គឺជាគុណតម្លៃទំនើបឬអាចនិយាយជាសកល និងបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។ យើងក៏កត់សម្គាល់ផងដែរថា ដោយទទួលយកសេចក្តីតម្រូវនានារបស់អន្តរជាតិ អ្នកធ្វើសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាបានដាក់បញ្ចូលដោយចេតនា ទៅក្នុងច្បាប់មូលដ្ឋាននេះ នូវគុណតម្លៃជាតិដែលពួកគេចាត់ទុកថាមានសារៈសំខាន់ខ្លាំង សម្រាប់ការសម្រេចលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ពួកគេ។

គួរកត់សម្គាល់ថាសូម្បីតែមុនពេលនៃការអនុម័តរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣នេះ ប្រទេសកម្ពុជានៅតែជាសមាជិករបស់អង្គការសហប្រជាជាតិ ដែលខ្លួនមានកាតព្វកិច្ចអនុវត្ត ជាពិសេសនូវវិធាននៃច្បាប់របស់អង្គការសហប្រជាជាតិ ឧទាហរណ៍ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងអនុសញ្ញាផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ។ ហើយយើងគួរកត់សម្គាល់ផងដែរថា ក្នុងសម័យអន្តរកាលពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយស្ថាប័នមួយដោយមានការឯកភាពគ្នារវាងគណបក្សនយោបាយ។ ស្ថាប័ននេះមានឈ្មោះថា «ឧត្តមក្រុមប្រឹក្សាជាតិ»។ ស្ថាប័ននេះដែលជាតំណាងបណ្តោះអាសន្ន បាន

ផ្តល់សច្ចាប័នដល់កតិកាសញ្ញាអង្គការសហប្រជាជាតិទាំងពីរ គឺ «កតិកាសញ្ញាស៊ីវិល និងនយោបាយនិងកតិកាសញ្ញាវប្បធម៌សង្គមនិងសេដ្ឋកិច្ច»។ «កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌»។

ឥឡូវនេះ សូមមើលលក្ខណៈសំខាន់ៗនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។

អត្ថបទនេះរួមមាន បុព្វកថាចំនួន១ ជំពូកចំនួន១៧ ជាមួយមាត្រាចំនួន១៦០ ដោយមានឧបសម្ព័ន្ធចំនួន២ គឺភ្លេងជាតិ និងអត្ថបទសច្ចាប្រណិធាន ដែលអ្នកជាប់ឆ្នោតត្រូវធ្វើសច្ចាប្រណិធាន (ធ្វើការប្រកាសពាក្យសម្បថ)។

-គោលការណ៍ប្រជាធិបតេយ្យនៅកម្ពុជាមានចែងក្នុងមាត្រា១ នៃជំពូកទី១

-ជំពូកទី២ ឧទ្ទិសដល់បុព្វសិទ្ធិរបស់ព្រះមហាក្សត្រ មាន ២៣មាត្រា

-សិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរត្រូវបានសរសេរក្នុងជំពូកទី៣ ដែលមាន ១៩មាត្រា

-របបនយោបាយ ជាពិសេសការបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សការបែងចែកអំណាច នយោបាយការបរទេស និងការពារជាតិ គឺជាប្រធានបទនៃជំពូកទី៤ មាន៥មាត្រា

-គោលនយោបាយសេដ្ឋកិច្ច ប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិជាតិ និងការពារបរិស្ថានមានចែងក្នុងជំពូកទី៥ ដែលមាន ៨មាត្រា

-អប់រំ វប្បធម៌និងសង្គមកិច្ច ត្រូវបានកំណត់ក្នុងជំពូកទី៦ មាន ១០មាត្រា

-ការរៀបចំអំណាចរដ្ឋ តាមរយៈនិយមន័យ នៃស្ថាប័ននិងទំនាក់ទំនងរវាងស្ថាប័នមានចំនួន៨ ជំពូក ដែលក្នុងនោះ មាន១ជំពូកសម្រាប់ស្ថាប័ននីមួយៗ។ ទាំងនេះរួមមាន រដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល តុលាការ ក្រុមប្រឹក្សាធម្មនុញ្ញនិងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ហើយ រដ្ឋធម្មនុញ្ញនេះត្រូវបានបំពេញបន្ថែមដោយ ៤ជំពូកពិសេស ដែលបានកំណត់៖ ១.រដ្ឋបាលដែនដី ២.សមាជជាតិ ៣. ការប្រជុំនៅក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភា ៤. ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ដូច្នេះគោលការណ៍ចាំបាច់ទាំងអស់ នៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ប៉ុន្តែដើម្បីឱ្យកាន់តែច្បាស់ យើងសូមដកស្រង់ករណីជាក់ស្តែងមួយចំនួន៖

១- លក្ខណៈ នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមានចែងក្នុងមាត្រា៥១ ដែលចែងថា " ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី។

អំណាចត្រូវបានបែងចែកជាអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

២- មាត្រា៣៤ ចែងថា៖ «ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត»។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។

ដោយបន្ថែមលើមាត្រានេះ ជំពូកទី ១៥ ផ្តោតទៅលើការបង្កើតស្ថាប័នបោះឆ្នោតមួយដែលមានឈ្មោះថា «គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត» ដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតទាំងអស់នៅក្នុងប្រទេសតាមការកំណត់នៃច្បាប់។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនេះ គោរពច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានិងកំណត់នីតិវិធី និងបែបបទនៃការបោះឆ្នោតឱ្យបានល្អិតល្អន់បំផុត ដើម្បីដោះស្រាយវិវាទការបោះឆ្នោតឱ្យបានកាន់តែលឿនបំផុត។

៣- ខ្លឹមសារនៃជំពូកទី៣ ដែលមាន ២០មាត្រា ធានានូវសេរីភាពបុគ្គលម្នាក់ៗក៏ដូចជាសេរីភាពសមូហភាពរបស់ពួកគេ ដូចប្រទេសប្រជាធិបតេយ្យផ្សេងទៀតនៅលើពិភពលោក។

៤-ជំពូកទី ៦ ទាំងមូលមាន១០ មាត្រា ធានាសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងវិស័យអប់រំ វប្បធម៌ និងសុខភាព។

## ២- ការអនុវត្ត

ក្នុងគ្រាដំបូងការប្រកាសឱ្យប្រើជាផ្លូវការនូវរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បង្កើតជាបញ្ហាប្រឈមមួយ។ ការលំបាកនានាបានកើតឡើងភ្លាមៗបន្ទាប់ពីការបោះឆ្នោតទូទៅក៏ដូចជាក្នុងនីតិកាលទី១ នៃរដ្ឋសភា។

របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនៅកម្ពុជា តាមរយៈសភាដូចដែលយើងឃើញហើយនេះ គឺជារបបសភានិយម តាមបែបឯកសិទ្ធិជាតិ (Moniste)។

ដូចបណ្ដាប្រទេសប្រជាធិបតេយ្យដទៃទៀតដែរ ខណៈដែលប្រព័ន្ធតុលាការស្ថិតនៅក្នុងដៃចៅក្រម ការប្រកួតប្រជែងមានភាពខ្លាំងក្លា រវាងអង្គនីតិប្រតិបត្តិ និងអង្គនីតិប្បញ្ញត្តិ។ លក្ខណៈឯកសិទ្ធិជាតិនៃរបបនយោបាយរបស់យើង ស្ថិតនៅក្នុងតួនាទីជានិមិត្តរូបរបស់ព្រះមហាក្សត្រដែលទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ។ ហើយទោះបីជាព្រះមហាក្សត្រមានបុព្វសិទ្ធិច្រើនក៏ដោយ ក៏ព្រះមហាក្សត្រព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ អ្នកកាន់អំណាចនីតិប្រតិបត្តិពិតប្រាកដ គឺនាយករដ្ឋមន្ត្រី។ នៅពេលបញ្ចប់ការបោះឆ្នោតទូទៅនីមួយៗ អ្នកដឹកនាំគណបក្សឈ្នះឆ្នោតដែលមានសំឡេងច្រើនជាងគេត្រូវបានព្រះមហាក្សត្រចាត់តាំងឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ ក្រោយរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ រាជរដ្ឋាភិបាលត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងដើម្បីដំណើរការ។

យើងកត់សម្គាល់ថា បើនិយាយពីគណនេយ្យភាព នាយករដ្ឋមន្ត្រីត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា ខណៈដែលរដ្ឋមន្ត្រីនានាទទួលខុសត្រូវទាំងចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភា។

ការប្រកួតប្រជែងរវាងអំណាចទាំងពីរ (នីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ) គឺស្ថិតនៅក្នុងអំណាចនៃការរំលាយរដ្ឋសភា និងរដ្ឋាភិបាល។ ទាក់ទងនឹងប្រធានបទនេះ តុល្យភាពមួយបែបត្រូវបានគ្រោងទុកៈ

១- រដ្ឋសភាមានសិទ្ធិអញ្ជើញរាជរដ្ឋាភិបាល (នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី) មកបំភ្លឺអំពីបញ្ហាអ្វីមួយហើយអាចរហូតដល់អនុម័តញត្តិបន្ទោស ដែលអាចទម្លាក់រាជរដ្ឋាភិបាលពីតំណែង ឬអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រីចេញពីតំណែង តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

២- ប៉ុន្តែក្នុងករណីដែលរដ្ឋសភាទម្លាក់រាជរដ្ឋាភិបាលចំនួនពីរដង ក្នុងរយៈពេល

១២ខែ រដ្ឋសភាខ្លួនឯងក៏ត្រូវព្រះមហាក្សត្ររំលាយផងដែរ ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។

ករណីទាំង២ ក្នុងចំណុចទី២ខាងលើនេះ ពុំដែលកកើតក្នុងរយៈពេល ២៧ឆ្នាំមកហើយនេះទេ។ ប៉ុន្តែមានការលំបាកខ្លះៗក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា គឺមកពីបុព្វហេតុជាច្រើនរួមមានៈ

- អាចមកពីអត្តទត្តនិយមគណបក្សនយោបាយនីមួយៗ

- ភាពក្មេងខ្ចី និងកង្វះបទពិសោធ និងប្រពៃណីប្រជាធិបតេយ្យរបស់ប្រជាជនកម្ពុជា។

ប៉ុន្តែដូចនៅក្នុងប្រទេសទាំងអស់ដែលបានប្រើប្រព័ន្ធសភា ការបែងចែកអំណាចរវាងនីតិប្រតិបត្តិនិងនីតិប្បញ្ញត្តិមិនទាន់ទាំងស្រុងទេ។ កិច្ចសហប្រតិបត្តិការ ឬការសម្របសម្រួលអាចធ្វើទៅបាន។ ចំណែកការលំបាកផ្សេងទៀតដែលរបបប្រជាធិបតេយ្យកម្ពុជាជួបប្រទះ គឺជាការលំបាកធម្មតាដូចដែលប្រទេសប្រជាធិបតេយ្យដទៃទៀតក្នុងលោកជួបប្រទះដូចគ្នាដែរ។

## ៣- ក្រុមប្រឹក្សាធម្មនុញ្ញ

ដោយប្រកាសថា កម្ពុជាជាប្រទេសប្រកាន់រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ កម្ពុជាក៏មាននូវរដ្ឋធម្មនុញ្ញមួយ ជាបទដ្ឋានគ្រឹះមូលដ្ឋាន ដែលច្បាប់ទាំងអស់ត្រូវតែគោរពតាមគោលការណ៍នានានៃបទដ្ឋានគ្រឹះនេះ។ ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ក៏ត្រូវកើតមានឡើងដែរ។ ដើម្បីឆ្លើយតបនឹងសំណួរនេះ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ក្នុងជំពូកទី១២ បានចែងអំពីការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានអំណាចសំខាន់ៗដូចជាៈ

- ធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ

- បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

- ពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ឆ្នាំ ហើយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំង ៩រូប ត្រូវបានតែងតាំងតាមរូបមន្ត សមាជិក ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ សមាជិក៣រូបត្រូវជ្រើសតាំងដោយរដ្ឋសភា និង៣រូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការពិនិត្យធម្មនុញ្ញភាព នៃច្បាប់អាចត្រូវបានធ្វើជាមុនឬ

ក្រោយច្បាប់អនុម័ត។ ក្នុងករណីទី១ ជាអាទិកាលនៅពេលដែលច្បាប់មួយត្រូវបាន អនុម័តដោយសភា ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ១/១០ នៃសមាជិករដ្ឋសភានិង ១/៤ នៃសមាជិកព្រឹទ្ធសភាអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យអំពីរដ្ឋធម្មនុញ្ញភាព នៃច្បាប់នោះ មុនពេលប្រកាសឱ្យប្រើ។

ក្នុងករណីទី២ ជាបច្ឆាកាលសមាសភាពដដែលខាងលើនេះបូកនឹងតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យអំពីរដ្ឋធម្មនុញ្ញភាពនៃច្បាប់ដែលបានប្រកាសឱ្យ ប្រើរួចហើយ។

ប្រជារាស្ត្រមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ អំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា។

ក្រៅពីនេះ អត្ថបទគតិយុត្តចំនួន៣ ត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយក្រុមប្រឹក្សា ធម្មនុញ្ញ។ ជាបឋម គឺពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមុន នៃសេចក្ដីព្រាងច្បាប់រដ្ឋ ធម្មនុញ្ញដោយព្រះមហាក្សត្រ។ បន្ទាប់មក ច្បាប់ដែលហៅថាច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា ត្រូវតែអនុម័តយល់ព្រមដោយក្រុមប្រឹក្សាធម្មនុញ្ញ ជាមុនទើបប្រកាសឱ្យប្រើបាន។

ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថាច្បាប់ ឬមាត្រាមួយចំនួន នៃ អត្ថបទគតិយុត្តនេះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធមិនអាចត្រូវបាន អនុវត្តឡើយ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។

នៅក្នុងប្រទេសកម្ពុជាមិនមានការចុះបញ្ជី «ប្លុករដ្ឋធម្មនុញ្ញភាព» ទេ។

## សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ដែលត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ជាប្រទេសប្រជាធិបតេយ្យ។ ចាប់តាំងពី២៧ ឆ្នាំមកនេះ សង្គមកម្ពុជាដែលមិន ធ្លាប់មានប្រពៃណីរឹងមាំនៃរបបបែបនេះ បានសម្របខ្លួនបន្តិចម្ដងៗ ដែលធ្វើឱ្យគណបក្ស នយោបាយមួយចំនួនមានភាពចាស់ទុំផ្នែកបទពិសោធ។

វិបត្តិនយោបាយធំឬតូចនានា បន្ទាប់ពីការបោះឆ្នោតនីមួយៗ មិនមានន័យថា លទ្ធិប្រជាធិបតេយ្យ មានវិសមិតភាពជាមួយនឹងសង្គមខ្មែរទេ ហើយក៏មិនមានន័យថា សង្គមខ្មែរបដិសេធលទ្ធិប្រជាធិបតេយ្យដែរ ពីព្រោះស្ថានការណ៍បែបនេះក៏ជាលក្ខណៈ មួយនៃរបបនយោបាយនេះដែរ។

ដោយបានឆ្លងកាត់ការសាកល្បងប្រជាធិបតេយ្យរយៈពេល២៧ឆ្នាំមកនេះ ប្រជាជនកម្ពុជាបានទទួលផលប្រយោជន៍ជាច្រើនដែលសំខាន់បំផុត គឺការទទួលបានសិទ្ធិជាមូលដ្ឋាន និងសេរីភាព និងសិទ្ធិផ្សេងៗទៀត ដូចជាសិទ្ធិបុគ្គល និងសេរីភាព សិទ្ធិសម្ហភាព ក៏ដូចជាការធានាសិទ្ធិសង្គមរបស់ពួកគេ។ សិទ្ធិនិងសេរីភាពទាំងអស់នេះត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ចំនួនជាង៥០០ ដែលប្រកាសឱ្យប្រើដោយប្រមុខរដ្ឋតាំងពីឆ្នាំ១៩៩៣មក។ ទាំងនេះគឺជាល័ក្ខខ័ណ្ឌដែលអនុញ្ញាតឱ្យមានការអភិវឌ្ឍរីកចម្រើនរបស់ប្រជាជនកម្ពុជាម្នាក់ៗ ហើយយើងក៏អាចនិយាយបានថាសម្រាប់សង្គមកម្ពុជាទាំងមូលដែរ។

ទោះជាយ៉ាងនេះក៏ដោយ ល័ក្ខខ័ណ្ឌទាំងនេះមិនទាន់គ្រប់គ្រាន់ទេ ដោយសារតែកេរដំណែលនៃការបំផ្លិចបំផ្លាញអស់រយៈពេលជាង ២០ឆ្នាំកន្លងមក មានការបំផ្លិចបំផ្លាញសម្ភារៈ និងការបាត់បង់ធនធានមនុស្ស ដែលពិបាកក្នុងការជំនួសវិញនេះ ញ៉ាំងឱ្យមានន័យថាប្រទេសកម្ពុជាកំពុងស្ថិតនៅជាប្រទេសមួយ នៅមានលក្ខណៈយឺតយ៉ាវក្នុងចំណោមបណ្តាប្រទេសនានានៅក្នុងតំបន់។

ក្នុងពេលបច្ចុប្បន្ន នៅពេលដែលពិភពលោកកំពុងវិវត្តយ៉ាងឆាប់រហ័ស ជាពិសេសផ្នែកចំណេះដឹង និងចំណេះធ្វើ ប្រទេសកម្ពុជាមិនអាចគេចផុតពីការកត់សម្គាល់ចំណុចនេះបានឡើយ។

លទ្ធិប្រជាធិបតេយ្យបង្កើតជាល័ក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍប្រទេស និងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យខ្លួនឯងផងដែរ ពីព្រោះប្រសិនបើសង្គមមិនបានទទួលកម្រិតអភិវឌ្ឍមួយសមស្រប ជាឧទាហរណ៍ក្នុងវិស័យអប់រំនិងសេដ្ឋកិច្ចទេ លទ្ធិប្រជាធិបតេយ្យក៏មិនអាចបង្កើតល័ក្ខខ័ណ្ឌអភិវឌ្ឍប្រទេសបានល្អប្រសើរនៅឡើយទេ ដោយហេតុគ្រប់សមិទ្ធផលទាំងអស់មិនអាចទទួលបានដោយសារការចេញក្រឹត្យច្បាប់នោះទេ។ មានតែការប្រឹងប្រែងទេដែលអាចធ្វើឱ្យសុបិនមួយក្លាយជាការពិតបាន។

## *សេចក្ដីសង្ខេបគោលគំនិតសំខាន់ៗមួយចំនួនរបស់*
## ឯកឧត្ដមកិត្ដិនីតិកោសលបណ្ឌិត *អ៊ឹម ឈុនលឹម* ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
## ថ្លែងក្នុងពិធីបិទសន្និសីទអបអរសាទរទិវារំលឹកខួប២៧ឆ្នាំនៃការប្រកាស
## ឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រារព្ធធ្វើនៅ
## ថ្ងៃពុធ ទី២៣ ខែកញ្ញា ឆ្នាំ២០២០

សន្និសីទបានបញ្ចប់ដូចការគ្រោងទុក និងសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ និងគួរឱ្យមានមោទនភាព ដោយបានប្រមូលផ្ដុំនីតិបញ្ញវន្ដខ្មែរ រួមគ្នាពិនិត្យវាយតម្លៃការគោរពអនុវត្តគោលការណ៍គ្រឹះទាំងឡាយនៃរដ្ឋធម្មនុញ្ញរបស់ជាតិ ដើម្បីឧទ្ទិសដល់ទិវាខួប២៧ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញថ្មីនេះ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

សន្និសីទបានឯកភាពគ្នា ធ្វើការវាយតម្លៃខ្ពស់ស្នាដៃរបស់សភាធម្មនុញ្ញ ដែលបានធ្វើការពិចារណា និងពិភាក្សាយ៉ាងជ្រាលជ្រៅ ដើម្បីសម្រេចបានរដ្ឋធម្មនុញ្ញថ្មីមួយប្រកបដោយចក្ខុវិស័យដ៏ភ្លឺស្វាង ដោយបានចែងយ៉ាងច្បាស់នូវគោលការណ៍ធម្មនុញ្ញនិយមទំនើប (ដូចមានចែងក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) ទន្ទឹមនេះ ក៏បានចែងខ្លឹមសារទាំងឡាយទាក់ទងនឹងវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់នៃសង្គមខ្មែរ ដែលជាបុព្វល័ក្ខខ័ណ្ឌនាំមកនូវប្រព័ន្ធគ្រប់គ្រងរដ្ឋមួយដែលអាចសម្រេចបាន និងមានភាពទន់ភ្លន់ផង និងភាពរឹងមាំផង ដែលអាចធានានូវការឯកភាពរបស់ប្រទេសជាតិ។

ប្រធានបទទាំង១១ ដែលវាគ្មិនបានជ្រើសរើសយកមកបកស្រាយ សុទ្ធសឹងឆ្លុះបញ្ចាំងនូវសមិទ្ធផលសម្រេចបាន ស្របតាមស្មារតីដែលសភាធម្មនុញ្ញចង់បាន ដោយបានទទួលនូវការចាប់អារម្មណ៍ខ្ពស់ ចំពោះអ្នកដែលមិននឹកស្មានថា កម្ពុជាអាចសម្រេចបាន ទន្ទឹមនេះក៏ឆ្លុះបញ្ចាំងនូវចំណុចដែលអ្នកសង្កេតការណ៍ពិបាកយល់ ចំពោះឥរិយាបថជាក់ស្ដែងនិយមបែបខ្មែរ និងនៅមានការមន្ទិលសង្ស័យ និងការបារម្ភ។ ចំពោះប្រការនេះ សន្និសីទក៏បានយកចិត្តទុកដាក់ធ្វើស្វ័យវិភាគ និងលើកឡើងនូវគោលគំនិតមួយចំនួន ក្នុងទិសដៅកែលម្អសភាពការណ៍ទន្ទឹមនឹងធ្វើការប្រៀបធៀបនឹងសភាពការណ៍នៅបណ្ដាប្រទេសផ្សេងទៀតដែលកំពុងដើរលើគម្រាយផ្លូវនៃធម្មនុញ្ញនិយមទំនើប ដែលបាន និងកំពុងសម្រេចនូវសមិទ្ធផល និងដោះស្រាយនូវបញ្ហាប្រឈមខុសៗគ្នា ទៅតាមបរិបទនៃប្រទេសនីមួយៗ។